សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ ធ្នូ ឆ្នាំ 2014

# លីអាហូណា




## ការនាំអ្នកដទៃឲ្យត្រឡប់មករកសេចក្ដីជំនឿលើព្រះគ្រីស្ទ ទំព័រ 12

មេរៀនទាំងបួននៅក្នុងព្រៃពិសិដ្ឋ ទំព័រ 24

ការស្គាល់ពីធាតុពិតនៃបុណ្យគ្រីស្ទម៉ាស់ ទំព័រ 36

កម្មវិធីសិក្សាសម្រាប់យុវវ័យ ៖ របៀបដែលអ្នកអាចជួយពួកអ្នកប្រែចិត្តជឿថ្មី ទំព័រ 50



*« ការដឹងគុណផ្លាស់ប្តូរ
អ្វីគ្រប់យ៉ាងដែលកំពុងកើត
ជុំវិញយើង ។ វាលើសពីការ
ខកចិត្ត ការបាក់ទឹកចិត្ត និង
ភាពអស់សង្ឃឹម ។ វានឹង
រីកយ៉ាងស្រស់បំព្រងទាំងនៅក្នុង
ទីវាលទឹកកកនារដូវរងា និងកំដៅ
ដ៏រីករាយនារដូវក្តៅ » ។*

ប្រធាន ឌៀថើរ អែហ្វ អុជដូហ្វ ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ « Grateful in Any Circumstances » *Liahona* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 75 ។

# លីអាហូណា ខែ ធ្នូ ឆ្នាំ 2014



12

## សារលិខិត


4 **សារលិខិតគណៈប្រធានទីមួយ: បំពេញពិភពលោកនេះដោយសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទ**
ដោយ ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ

7 **សារលិខិតបង្រៀនសួរសុខទុក្ខ: បេសកកម្មដ៏ទេវភាពនៃព្រះយេស៊ូវគ្រីស្ទ ៖ ព្រះអម្ចាស់នៃមេត្រីភាព**


## អត្ថបទពិសេស។


12 **ការជួយអ្នកដទៃស្វែងរកសេចក្ដីជំនឿលើព្រះគ្រីស្ទ**
ដោយ អែលឌើរ អិល ថមភើរ
*អ្នកអាចពង្រឹងសេចក្ដីជំនឿរបស់អ្នកនៅពេលនេះ ហើយជួយអ្នកដទៃឲ្យត្រឡប់មករកគ្រឹះដ៏រឹងមាំនៃសេចក្ដីជំនឿលើព្រះអង្គសង្គ្រោះ ។*

18 **អ្នកត្រួសត្រាយផ្លូវនៅគ្រប់ដែនដី: សាសនាចក្រនៅក្នុងប្រទេសស៊ុយអែត—ការរីកចម្រើន ការធ្វើអន្តោប្រវេសន៍ និង ភាពរឹងមាំ**
ដោយ អ៊ីងហ្គ័រ ហុគឡាន់ដ៏
*ថ្វីបើមានឧបសគ្គជាច្រើនក្ដី ក៏ព្រះអម្ចាស់កំពុងពន្លឿនកិច្ចការរបស់ទ្រង់នៅក្នុងប្រទេសស្រស់បំព្រងនេះដែរ ។*

24 **មេរៀននៅក្នុងព្រៃពិសិដ្ឋ**
ដោយអែលឌើរ ម៉ាលីន យេ ជែនសិន
*តាមរយៈការសង្កេតមើលឃើញគំរូនៃការរីកលូតលាស់នៃដើមឈើទាំងឡាយ យើងអាចរៀនពីរបៀបដើម្បីរក្សាខ្លួនយើងឲ្យចាក់ឫស យ៉ាងរឹងមាំនៅក្នុងសេចក្ដីពិតដ៏អស់កល្ប ។*

30 **ការរង់ចាំរយៈពេល 500 ឆ្នាំ ៖ ចាប់តាំងពីម៉ាឡាគីរហូតដល់យ៉ូហាន បាទីស្ទ**
ដោយអេស ខេន ប្រោន និង រីឆាដ នីតហ្សេល ហុលហ្សាពហ្វេល
*តើមានអ្វីបានកើតឡើងក្នុងអំឡុងឆ្នាំរវាងព្រះគម្ពីរសញ្ញាចាស់ និង ព្រះគម្ពីរសញ្ញាថ្មី ?*

36 **ធាតុពិតនៃបុណ្យគ្រីស្ទម៉ាស់**
ដោយ ប៊ីស្សព ហ្គែរី អ៊ី ស្ទីវិនសុន
*ចូរយើងទទួលស្គាល់ថា ព្រះឱរសដែលបានប្រសូតនៅភូមិបេថ្លេហិមគឺជាព្រះប្រោសលោះដ៏ពិតប្រាកដ ។*


## ផ្នែកទាំងឡាយ


8 **អ្វីដែលយើងជឿ: ដង្វាយមួយភាគក្នុងដប់ជួយស្ថាបនានគរព្រះ**

10 **ការពិចារណា: អព្ភូតហេតុនៃបុណ្យគ្រីស្ទម៉ាស់**
ដោយ លីនសី អាលឌើរ

11 **ពួកព្យាការីគម្ពីរសញ្ញាចាស់: ម៉ាឡាគី**

40 **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

80 **លុះត្រាយើងជួបទៀត: ខ្ញុំដឹងថា ទ្រង់មានព្រះជន្មរស់ ។**
ដោយអែលឌើរ មេលវិន ជេ បាឡឺដ
*ព្រះយេស៊ូវគឺជាព្រះអម្ចាស់របស់យើងដែលមានព្រះជន្មរស់ឡើងវិញ ហើយទ្រង់អញ្ជើញយើងទាំងអស់គ្នាឲ្យមករកទ្រង់ ។*


**នៅលើគម្រប**
ខាងមុខ ៖ រចនារូបថតដោយ ម៉ាចាយ រៀ ។ ខាងក្នុងគម្រប
ខាងមុខ ៖ រូបភាពរក្សាសិទ្ធិដោយ Johnér/**offset.com** ។

## មជ្ឈិមវ័យវ័យក្មេង





44 **ចម្លើយចំពោះសំណួរពិបាក។**
ដោយ អ័រ វ៉ាល ចនសុន
*ប្រសិនបើការសង្ស័យចាប់ផ្តើមជ្រាបចូលទៅក្នុងដួងចិត្តរបស់អ្នក សូមចងចាំពីគោលការណ៍ទាំងប្រាំយ៉ាងនេះ ។*




***ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ តើសត្វអាចបង្រៀនយើងពីការគោរពប្រតិបត្តិបានដោយរបៀបណា ?***




## យុវវ័យ


48 **ព្រះអង្គសង្គ្រោះ និង ពិធីសាក្រាម៉ង់**
ដោយ ដេវីឌ អេល បេក
*កាលព្រះអង្គសង្គ្រោះបានចាប់ផ្ដើមពិធីសាក្រាម៉ង់ ទ្រង់បានមានបន្ទូលថា « ចូរធ្វើបុណ្យនេះដើម្បីរំឭកពីខ្ញុំចុះ » ។*

50 **តើការធ្វើជាសមាជិកដ៏ថ្មីស្រឡាងម្នាក់មានអារម្មណ៍បែបណាដែរ ?**
ដោយ យូស្វេ ជេ ភីឌី
*រៀនពីរបៀបដែលអ្នកអាចជួយពួកអ្នកប្រែចិត្តជឿថ្មីឲ្យសម្របខ្លួនទៅនឹងភាពជាសមាជិកនៅក្នុងសាសនាចក្រ ។*

54 **សំណួរ និង ចម្លើយទាំងឡាយ**
*តើខ្ញុំគួរធ្វើអ្វីខ្លះនៅពេលខ្ញុំត្រូវបានគេសើចចំអកនៅឯសាលា ដោយសារធ្វើតាមបទដ្ឋានសាសនាចក្រនោះ ?*

56 **មកពីតំបន់បេសកកម្ម: មិនត្រូវការពួកទេវតាឡើយ**
ដោយ ជេនៀន ជេនសិន នៀលសិន

57 **ប័ណ្ណប្រកាស: រៀបចំកន្លែងមួយ**

58 **តើខ្ញុំនៅទីណា ? របៀបដើម្បីស្វែងរក ហើយអភិវឌ្ឍអំណោយទានខាងវិញ្ញាណ និង ទេពកោសល្យរបស់អ្នក**
ដោយ អែលឌើរ មើរវីន ប៊ី អាណុល
*តើពូរបស់ខ្ញុំអាចធ្វើអ្វីបានខ្លះជាមួយនឹងបំណែកលោហធាតុដ៏ចាស់មួយនេះ ?*

62 **របៀបរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ**
ដោយ អែលឌើរ ដាល្លិន អេច អូក្ស៍
*តើអ្នកនឹងធ្វើដូចម្តេច ប្រសិនបើអ្នកបានដឹងថាអ្នកនឹងជួបព្រះអម្ចាស់នៅថ្ងៃស្អែក ?*

63 **អំណោយបុណ្យគ្រីស្ទម៉ាស់របស់ខ្ញុំ**
ដោយជាស្ទីន រូដ
*ទោះជាខ្ញុំបានជ្រមុជទឹកតាំងពីអាយុប្រាំបីឆ្នាំក្តី ខ្ញុំមិនដែលបានទៅព្រះវិហារឡើយ—រហូតមានអ្វីមួយបានផ្លាស់ប្តូរជីវិតរបស់ខ្ញុំជារៀងរហូត ។*

64 **ត្រៀមខ្លួនជាស្រេចដើរឆ្ពោះទៅមុខ**
ដោយ វីឆាត អិម រ៉ូមនី
*កុមារអាយុ 12 ឆ្នាំ ចំនួនប្រាំពីរនាក់ប្រាប់ពីអារម្មណ៍នៃការឡើងថ្នាក់ពីថ្នាក់កុមារទៅថ្នាក់យុវជន ឬយុវនារី ។*


## កុមារ





67 **សាក្សីពិសេស: តើព្រះយេស៊ូវពិតជាបានសុគត ហើយមានព្រះជន្មឡើងវិញម្តងទៀតមែនទេ ?**
ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន

68 **ការនាំថ្នាក់កុមារមកក្នុងលំនៅដ្ឋាន: យើងចងចាំ ហើយថ្វាយបង្គំដល់ព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ**
ដោយ អេរីន សាន់ឌើរសុន និង ជីន ប៊ីងហាំ

70 **ប៉េនស៊ី**
ដោយអែលឌើរ ប្រេន អេច នៀលសិន
*ប្រសិនបើសេះយើងស្តាប់បង្គាប់ វាអាចមានជីវិតមួយដ៏រីករាយ ។*

71 **ទំព័ររបស់យើង**

72 **មិត្តភាពនៅជុំវិញពិភពលោក: ខ្ញុំឈ្មោះមីនណា មកពីប្រទេសស៊ុយអែត**
ដោយ អេមី ជេន ឡីវិត

74 **បុណ្យគ្រីស្ទម៉ាស់ដំបូង**
ដោយ ជេន វិលកស៍
*សូមចងចាំពីការប្រសូតរបស់ព្រះយេស៊ូវ នៅពេលអ្នកសម្តែងរឿងនេះ ។*

76 **សូមមើលទៅខាងក្នុង !**
ដោយ សូហ្វៀ ស៊ី

77 **រូបភាពបទគម្ពីរក្នុងព្រះគម្ពីរសញ្ញាចាស់: ដាវីឌ និង កូលីយ៉ាត**

78 **សម្រាប់កុមារតូចៗ: បុណ្យគ្រីស្ទម៉ាស់បន្តិចម្តងៗ ជារៀងរាល់ថ្ងៃ**
ដោយ ខេត ស្រ្តុងអឹន

# គំនិតទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ នៅខាងក្រោមជាគំនិតចំនួនពីរ ។*



« **ការចូលរួមក្នុងសាសនាចក្រអាចជារឿងដ៏លំបាក ៖ រឿងព្រេងរបស់ពួកអ្នកប្រែចិត្តជឿ** » ទំព័រ 50 ៖ សូមពិចារណាដើម្បីមានការពិភាក្សាមួយជាមួយគ្រួសារអ្នកអំពីដំណើររឿងនៃការប្រែចិត្តជឿដែលបានចែកចាយដោយសមាជិកនៅក្នុងអត្ថបទនេះ ។ អ្នកក៏អាចអានស្ដីពីបញ្ជីនៃឧបសគ្គទាំង 10 យ៉ាងដែលពួកអ្នកប្រែចិត្តជឿបានជួបប្រទះ (រួមបញ្ចូលទាំងនៅក្នុងអត្ថបទ) ផងដែរ ។ សូមកត់សម្គាល់ជាគ្រួសារពីសមាជិកថ្មីនៅក្នុងវួដ ឬសាខារបស់អ្នក ឬសមាជិកដែលកំពុងចាប់ផ្ដើមត្រឡប់មកសកម្មភាពក្នុងសាសនាចក្រវិញ ។ រួចធ្វើការរួមគ្នាដើម្បីបង្កើតផែនការមួយធ្វើជាមិត្តនឹងសមាជិកទាំងនោះ ហើយជួយពួកគេ កាលពួកគេព្យាយាមស្វែងរកនូវកម្លាំងដើម្បីសម្របខ្លួនទាំងខាងសង្គម និង ខាងវប្បធម៌ ព្រមទាំងដើម្បីរីកចម្រើនខាងវិញ្ញាណផងដែរ ។

« **យើងចងចាំ ហើយថ្វាយបង្គំដល់ព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ** » ទំព័រ 68 និង « **បុណ្យគ្រីស្ទម៉ាស់ដំបូង** » ទំព័រ 74 ៖ អបអរដល់ការប្រសូតរបស់ព្រះអង្គសង្គ្រោះជាមួយនឹងគំនិតមួយសម្រាប់សកម្មភាពផ្ដោតលើបុណ្យគ្រីស្ទម៉ាស់ នៅក្នុងលេខនេះ ។ ឧទាហរណ៍ អ្នកអាចកាត់ប្រអប់នៅទំព័រ 69 ហើយធ្វើការសម្រេចចិត្តជាគ្រួសារពីរបៀបដែលអ្នកនឹងបង្ហាញសេចក្ដីស្រឡាញ់របស់អ្នក ដល់ព្រះអង្គសង្គ្រោះអំឡុងពេលនៃរដូវកាលបុណ្យគ្រីស្ទម៉ាស់នេះ និងពេញមួយឆ្នាំ ។ អ្នកក៏អាចពិចារណាប្រើអត្ថបទរឿងនៅទំព័រ 74 ជាការណែនាំមួយដើម្បីជួយគ្រួសារអ្នកឲ្យសម្ដែងពីការប្រសូតរបស់ព្រះយេស៊ូវផងដែរ ។ សកម្មភាពទាំងពីរនេះអាចជួយកូនចៅអ្នកឲ្យរៀនពីរបៀបផ្ដោតគំនិតរបស់ពួកគេទៅលើព្រះអង្គសង្គ្រោះនៅគ្រាបុណ្យគ្រីស្ទម៉ាស់ ។

## ជាភាសារបស់អ្នក

*លីអាហូណា* និងឯកសារផ្សេងទៀតរបស់សាសនាចក្រមានជាច្រើនភាសានៅ languages.lds.org ។

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**

*លេខទាំងឡាយគឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*


***ការក្បត់សាសនា*** *30*
***ការគោរពប្រតិបត្តិ*** *30, 54, 70*
***ការដឹងគុណ*** *10*
***ការបម្រើ*** *4, 10, 12, 41, 43, 56, 78*
***ការប្រែចិត្តជឿ*** *42, 50, 63*
***ការយាងមកជាលើកទីពីរ*** *62*
***ការសង្ស័យ*** *44*
***ការស្ដារឡើងវិញ*** *24*
***កិច្ចការផ្សព្វផ្សាយសាសនា*** *12, 18, 50, 56, 76*
***គ្រួសារ*** *10, 40, 42*
***ដង្វាយមួយភាគក្នុងដប់*** *8*
***ដំណើររស់ឡើងវិញ*** *67*
***ទីបន្ទាល់*** *44*
***ទុក្ខវេទនា*** *24, 54*
***បុណ្យគ្រីស្ទម៉ាស់*** *4, 10, 36, 40, 42, 43, 57, 63, 74, 76, 78*
***ពិធីសាក្រាម៉ង់*** *48*
***ព្រះគម្ពីរ*** *30*
***ព្រះគម្ពីរសញ្ញាចាស់*** *11, 30*
***ព្រះយេស៊ូវគ្រីស្ទ*** *4, 7, 12, 36, 48, 57, 67, 68, 74, 80*
***ភាពសុខសាន្ត*** *7*
***មិត្តភាព*** *50*
***សេចក្ដីជំនឿ*** *12, 24, 44, 80*
***សេចក្ដីស្រឡាញ់*** *4, 40, 50*
***សេចក្ដីស្លាប់*** *40*
***ស៊ីយ៉ូន*** *18, 72*
***អំណោយទាំងឡាយខាងវិញ្ញាណ*** *58*
***អ្នកត្រួសត្រាយផ្លូវ*** *18*



**ខែ ធ្នូ ឆ្នាំ 2014 វ៉ុល 13 លេខ 6**
**លីអាហូណា 10992 258**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ



**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** បយដ៍ ខេ. ផាកកឺ, អិល. ថម ភែរី, រ័សុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ័សុល បាឡឺដ, រីឆាដ ជី. ស្កត, រ៉ូបឺត ឌី. ហែល, ជែហ្វ្រី អ័រ. ហូឡិន, ដេវីឌ អេ. បែដណា, ឃ្វីនថិន អិល. ឃុក, ឌី ថត. គ្រីស្តូហ្វឺសិន, នែល អិល. អាន់ឌើរសិន

**អ្នកកែសម្រួល ៖** ក្រេក អេ. ខារដុន
**អ្នកប្រឹក្សា ៖** សមើរីន ប៊ី អាណុល, ឡារី អ័រ ឡរ៉ែរិន, ជេមស៍ ប៊ី ម៉ាទីណូ, យ៉ូសែប ដបុលយូ ស៊ីតាទី គ្រីស្តូហ្វែល ហ្គូលឌិន

**នាយកគ្រប់គ្រង ៖** ដេវីឌ ធី. វ៉ះនើរ
**នាយកគាំទ្រគ្រួសារ និង សមាជិក ៖** វីនសេនត៍ អេ. វ៉ាញ
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ. ឡយបិច
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន

**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការអ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** ជ៉អិន ខារ
**ជំនួយការផ្នែកបោះពុម្ព ៖** លីស្សា ស៊ី ឡប៉េស្ស
**និពន្ធ និងកែសម្រួល ៖** ប្រ៊ិតថានី ប៊ីតធី, ដេវីដ ឌិកសុន, ដេវីដ អេ. អែដវ៉ដ, ម៉ាថាយ ឌី. ហ្វលិតតុន, ឡារី ហ្វលឡើរ ហ្គេរី អេច. ហ្គាហ្វ, ឡារិនេ ផតធើរ ហ្គួន, មីនឌី អាន់ ឡេវិត ម៉ៃឃើល អ័រ. ម៉ូរីស, សាលី ចនសុន អូឌេឃឺក, យ៉ូស្វេ ជេ ភឺគី, ជេន ភីនប៊ូវ៉ាហ្វ, រីឆាដ អិម. រ៉មនី, ប៉ុល វ៉ែនដិនបើជ, ម៉ារីស្សា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ. ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ថាត អ័រ. ភីធើរសុន
**រចនាម៉ូត ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី. អាន់ត្រូស, មែនឌី អឹម. ប៊ែនលី, ស៊ី. ឃីមបឹលបុត, ថូម៉ាស ឆាល, ណាត ហ្គីនេស, ខូលីន ហ៊ីងគ្លី, អេរិក ភី. ចនសិន, ស៊ូសាន ឡហ្វ្រីន, ស្កត អិម. ម៉ូយ, ម៉ាក ដបុលយូ. រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ. នីកូល វ៉កឃិនហ្វស

**អ្នកសម្របសម្រួលកម្មសិទ្ធបញ្ញា ៖** ខូលែត នែបឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស័
**ផលិតកម្ម ៖** ខេវិន ស៊ី ប៊េងស៍, ខននី ប៊ូស្រូប ប្រ៊ីជ, ជូលី ប៊ើដេត, ប្រាយអេន ដបុលយូ. ជីគី, ដេនីស គើបៃ, ជិន្នីស ឌឹប៊ី, ជីន្នី ហ្គីននី ជេ. នីលសុន, ហ្គេលី ថេត វ៉ាហ្វើធី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល. ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ក្រេហ្គ ខេ. សែតវីត
**នាយកផ្នែកចែកចាយ ៖** ស្ដេហ្វិន អ័រ គ្រីស្ទិនសិន



ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអ៊ិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ *Liahona,* Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ៊្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងហ្គារី, អាយឡេនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។



© 2014 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។



**For Readers in the United States and Canada:**
December 2014 Vol. 13 No. 6. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 707.4.12.5). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.



ដោយ ប្រធាន
ឌៀថើរ អេហ្វ អុជដូហ្វ
ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ

# បំពេញពិភពលោកនេះដោយ សេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទ

កាលណាយើងគិតពីបុណ្យគ្រីស្ទម៉ាស់ ជារឿយៗយើងគិតពីការផ្ដល់ឲ្យ និង ការទទួលបាននូវអំណោយ ។ អំណោយអាចជាផ្នែកមួយនៃទម្លាប់ដ៏ល្អមួយ ប៉ុន្តែវាក៏អាចជាការឲ្យឃ្លាតចេញពីសេចក្ដីថ្លៃថ្នូរដ៏សាមញ្ញនៃរដូវកាលនេះ ហើយបង្វែរចិត្តយើងឲ្យឃ្លាតចេញពីការអបអរដល់ការប្រសូតរបស់ព្រះអង្គសង្គ្រោះយើងតាមរបៀបដ៏សំខាន់មួយផងដែរ ។

ខ្ញុំដឹងនៅក្នុងបទពិសោធន៍ផ្ទាល់ខ្លួនថា បុណ្យគ្រីស្ទម៉ាស់ដែលគួរឲ្យចងចាំបំផុតអាចជាគ្រាដ៏រាបសាបំផុត ។ អំណោយដែលខ្ញុំមានកាលពីក្មេងបានក្លាយទៅជារបស់ដ៏សាមញ្ញសម្រាប់បទដ្ឋាននាបច្ចុប្បន្ននេះ ។ ពេលខ្លះ ខ្ញុំបានទទួលអាវមួយដែលមានបំណាស់ ឬស្រោមដៃ ឬស្រោមជើងមួយគូ ។ ខ្ញុំនៅចាំពីបុណ្យគ្រីស្ទម៉ាស់ដ៏ពិសេសមួយ កាលបងប្រុសខ្ញុំបានឲ្យកាំបិតឈើដែលគាត់ធ្វើមកឲ្យខ្ញុំ ។

វាពុំចាំបាច់មាននូវអំណោយដែលមានតម្លៃថ្លៃដើម្បីមានបុណ្យគ្រីស្ទម៉ាស់ដ៏មានអត្ថន័យនោះទេ ។ ខ្ញុំបាននឹកឃើញពីដំណើររឿងមួយដែលបានលើកឡើងដោយអែលឌើរ គ្លេន អិល រ៉ាត់ ដែលបម្រើជាសមាជិកក្នុងពួកចិតសិបនាក់ពីឆ្នាំ 1987 ដល់ឆ្នាំ 1992 ។ ជាយូរយារណាស់មកហើយ នៅថ្ងៃមួយពីមុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ កាលលោកកំពុងគ្រប់គ្រងឃ្លាំងរបស់ប៊ីស្សព លោកបានដឹងពីអ្នកដឹកនាំខាងសាសនាម្នាក់ស្ដីពីគ្រួសារក្រីក្រមួយដែលទើបផ្លាស់ទីលំនៅចូលមកទីក្រុងនោះ ។ កាលលោកបានចេញទៅដល់ផ្ទះជួលដ៏តូចរបស់ពួកគេ លោកបានឃើញមានម្ដាយមេម៉ាយម្នាក់ និង កូនបួននាក់អាយុក្រោម 10 ឆ្នាំ ។

គ្រួសារនេះមានសេចក្ដីត្រូវការខ្លាំងណាស់ រហូតដល់ម្ដាយមិនអាចទិញអាហារ ឬអំណោយសម្រាប់កូននាងនៅថ្ងៃបុណ្យគ្រីស្ទម៉ាស់ឆ្នាំនោះបាន—នាងគ្មានលទ្ធភាពសូម្បីតែទិញដើមឈើគ្រីស្ទម៉ាស់មួយដើមផង ។ បងប្រុសរ៉ាត់បាននិយាយជាមួយគ្រួសារ ហើយបានដឹងថា ក្មេងស្រីតូចបីនាក់នោះចូលចិត្តកូនក្រមុំជ័រ ឬរបស់លេងជាតុក្កតារូបសត្វ ។ កាលគាត់បានសួរដល់កូនប្រុសដែលមានអាយុប្រាំមួយឆ្នាំពីអ្វីដែលគាត់ចង់បាន ក្មេងប្រុសតូចដ៏ស្រេកឃ្លាននេះបានតបថា « ខ្ញុំចង់បានបបរម្សៅគ្រាប់ធញ្ញជាតិមួយចាន » ។

បងប្រុសរ៉ាត់បានសន្យានឹងក្មេងប្រុសតូចនោះថានឹងយកបបរម្សៅគ្រាប់ធញ្ញជាតិនោះ ឬប្រហែលជាអ្វីមួយផ្សេងទៀតមកឲ្យគាត់ផងដែរ ។ រួចគាត់បានទៅឃ្លាំងរបស់ប៊ីស្សព ហើយប្រមូលអាហារ និង សម្ភារផ្សេងទៀត ដើម្បីបំពេញដល់សេចក្ដីត្រូវការភ្លាមៗរបស់គ្រួសារនោះ ។

នៅព្រឹកនោះមានពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏សប្បុរសម្នាក់បានឲ្យលោក 50 ដុល្លារ « សម្រាប់ឲ្យទៅមនុស្សដែលខ្វះខាត » ។ ដោយប្រើនូវការបរិច្ចាគនោះ បងប្រុសរ៉ាត់នាំកូនលោកបីនាក់ទៅទិញឥវ៉ាន់សម្រាប់បុណ្យគ្រីស្ទម៉ាស់—កូនគាត់បានរើសយករបស់លេងសម្រាប់ក្មេងក្រខ្សត់ទាំងនោះ ។

បន្ទាប់ពីយកអាហារ សំលៀកបំពាក់ អំណោយដើម គ្រីស្ទម៉ាស់ និង គ្រឿងតុបតែងមួយចំនួនដាក់ក្នុងឡានរួចហើយ គ្រួសាររ៉ាត់បានបើកឡានសំដៅទៅផ្ទះរបស់គ្រួសារនោះ ។ ពួកគេបានជួយម្ដាយ និង កូនរបស់គាត់រៀបចំតំឡើងដើមគ្រីស្ទម៉ាស់ ។ រួចពួកគេបានដាក់អំណោយនៅក្រោមដើមគ្រីស្ទម៉ាសនោះ ហើយបានឲ្យក្មេងប្រុសតូចនោះនូវបបរម្សៅគ្រាប់ធញ្ញជាតិមួយកញ្ចប់ធំ ។

ម្ដាយបានស្រក់ទឹកភ្នែក កូនៗបានរីករាយ ហើយពួកគេទាំងអស់គ្នាបានច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់មួយបទ ។ នៅយប់នោះ កាលគ្រួសាររ៉ាត់បានប្រមូលផ្ដុំគ្នាសម្រាប់អាហារពេលល្ងាច ពួកគេបានថ្លែងអំណរគុណ ដែលពួកគេអាចនាំយកភាពរីករាយមួយចំនួនក្នុងបុណ្យគ្រីស្ទម៉ាស់ទៅឲ្យគ្រួសារមួយទៀត ហើយជួយក្មេងប្រុសតូចម្នាក់ឲ្យទទួលបាននូវបបរម្សៅគ្រាប់ធញ្ញជាតិមួយចាន ។[1]

### ព្រះគ្រីស្ទ និង វិញ្ញាណនៃការផ្ដល់ឲ្យ

សូមគិតពីរបៀបដ៏សាមញ្ញ ហើយថ្លៃថ្នូរដែលព្រះវរបិតាសួគ៌យើងបានជ្រើសដើម្បីផ្ដល់កិត្តិយសដល់ការប្រសូតនៃព្រះរាជបុត្រាទ្រង់ ។



រូបថតស្លាយដោយ ALEXANDRUM79/ISTOCK/THINKSTOCK រូបថតផែនដីដោយ STOCKBYTE រូបថតចានដោយ SEREGAM/ISTOCK/THINKSTOCK រូបថតស្លាបព្រាដោយ LISAISON/ISTOCK/THINKSTOCK រូបថតស្លាបព្រាដោយ OKEA/ISTOCK/THINKSTOCK

នៅយប់ដ៏បរិសុទ្ធនោះ ពួកទេវតាមិនបានលេចមកឯពួកអ្នកមានទេ ប៉ុន្តែដល់ពួកគង្វាលចៀម ។ ព្រះឱរសជាព្រះគ្រីស្ទមិនបានប្រសូតមកក្នុងវិមានទេ ប៉ុន្តែនៅក្នុងស្នូក ។ ទ្រង់មិនត្រូវបានគេរុំនឹងក្រណាត់សូតទេ ប៉ុន្តែនឹងសំពត់ ។

ភាពដ៏សាមញ្ញនៃបុណ្យគ្រីស្ទម៉ាស់ដំបូងនោះបានបង្ហាញពីជីវិតនៃព្រះអង្គសង្គ្រោះ ។ ទោះជាទ្រង់បានបង្កើតផែនដី បានយាងដោយឫទ្ធានុភាព និង សិរីល្អ ហើយបានគង់នៅខាងស្ដាំព្រះហស្តនៃព្រះវរបិតាក៏ដោយ ទ្រង់បានយាងមកផែនដីជាក្មេងម្នាក់ដ៏រាបសា ។ ជីវិតទ្រង់គឺជាគំរូមួយនៃភាពរាបសាដ៏ថ្លៃថ្នូរ ហើយបានយាងដើរក្នុងចំណោមពួកជនក្រីក្រ អ្នកឈឺ អ្នកសោកសៅ និង អ្នកដែលមានបន្ទុកធ្ងន់ ។

ទោះជាទ្រង់ជាស្ដេចមួយអង្គក្ដី ក៏ទ្រង់មិនដែលខ្វល់ខ្វាយពីកិត្តិយស ឬទ្រព្យសម្បត្តិរបស់មនុស្សឡើយ ។ ជីវិតទ្រង់ ព្រះបន្ទូលទ្រង់ និង សកម្មភាពប្រចាំថ្ងៃរបស់ទ្រង់គឺជាគ្រឹះនៃភាពថ្លៃថ្នូរដ៏សាមញ្ញ ហើយអស្ចារ្យ ។

ព្រះយេស៊ូវជាព្រះគ្រីស្ទ ជាអង្គដែលយល់ដឹងយ៉ាងល្អឥតខ្ចោះ ពីរបៀបប្រទានឲ្យបានបង្ហាញគំរូដល់យើងពីរបៀបនៃការផ្ដល់ឲ្យ ។ ចំពោះជនដែលមានដួងចិត្តពោរពេញដោយភាពឯកោ និង ទុក្ខសោក ទ្រង់បាននាំមកនូវសេចក្ដីមេត្តាករុណា និង ការលួងលោម ។ ចំពោះជនដែលមានរូបកាយ និង គំនិតរងទុក្ខដោយជំងឺ និងការឈឺចាប់ ទ្រង់នាំមកនូវសេចក្ដីស្រឡាញ់ និង ការព្យាបាល ។ ចំពោះជនដែលមានព្រលឹងពោរពេញដោយអំពើបាប ទ្រង់បានផ្ដល់សេចក្ដីសង្ឃឹម ការអត់ទោស និង ការប្រោសលោះ ។

ប្រសិនបើព្រះអង្គសង្គ្រោះគង់នៅក្នុងចំណោមយើងសព្វថ្ងៃ យើងនឹងរកឃើញទ្រង់នៅកន្លែងដែលទ្រង់តែងគង់នៅ—ដោយបម្រើដល់អ្នកទន់ខ្សោយ អ្នកសោកសៅ អ្នករាបសា អ្នកមានទុក្ខព្រួយ និងអ្នកខ្សត់ខ្សោយខាងវិញ្ញាណ ។ អំឡុងរដូវកាលបុណ្យគ្រីស្ទម៉ាស់នេះ និងជារៀងរហូតតទៅ សូមឲ្យយើងថ្វាយដល់ទ្រង់តាមរយៈសេចក្ដីស្រឡាញ់ដូចដែលទ្រង់មាន ។ សូមឲ្យយើងចងចាំពីសេចក្ដីថ្លៃថ្នូរដ៏រាបសានៃការប្រសូត អំណោយ និង ជីវិតរបស់ទ្រង់ ។ ហើយសូមឲ្យយើង បំពេញពិភពលោកនេះជាមួយនឹងពន្លឺនៃសេចក្ដីស្រឡាញ់ និង ព្រះចេស្ដានៃការព្យាបាលរបស់ទ្រង់ តាមរយៈទង្វើនៃសេចក្ដីទន់ភ្លន់សប្បុរសធម៌ និងសេចក្ដីមេត្តាករុណាដ៏សាមញ្ញ ។ ■

**កំណត់ចំណាំ**

1. សូមមើល គ្លេន អិល រ៉ាត់ *Pure Religion: The Story of Church Welfare since 1930* (ឆ្នាំ 1995) ទំព័រ 352–53 សូមមើលផងដែរ គ្លេន អិល រ៉ាត់ « A Bowl of Oatmeal » *Church News* ថ្ងៃទី 2 ខែ ធ្នូ ឆ្នាំ 2006 ទំព័រ 16 ។

**ការបង្រៀនចេញពីសារលិខិតនេះ**

ប្រធាន អុជដូហ្វ បង្រៀនថា យើងគួរធ្វើតាមគំរូនៃការផ្ដល់ឲ្យរបស់ព្រះអង្គសង្គ្រោះ ។ សូមពិចារណាសួរដល់សមាជិកដែលអ្នកទៅសួរសុខទុក្ខ ដើម្បីប្ដូរវេនគ្នាប្រាប់ពីអំណោយទានមួយដែលព្រះអង្គសង្គ្រោះបានប្រទានដល់ពួកគេ ហើយពិភាក្សាពីរបៀបដែលពួកគេអាចប្រើអំណោយទាននោះបម្រើដល់អ្នកដទៃ ។ ឧទាហរណ៍ ប្រសិនបើសមាជិកម្នាក់ត្រូវបានប្រទានពរឲ្យនូវការយំពាក់យំប៉ិនផ្នែកតន្ត្រី គាត់អាចទៅច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់ដល់អ្នកជិតខាងមួយចំនួន ។ អ្នកអាចសូមលុតជង្គង់អធិស្ឋានជាមួយនឹងសមាជិកដែលអ្នកទៅសួរសុខទុក្ខ ដោយសុំការបំផុសគំនិតអំពីអំណោយទានណាមួយដើម្បីចែកចាយ ពីរបៀបដើម្បីចែកចាយវា និង មនុស្សដែលត្រូវចែកចាយ ។ តាមដាននូវរាល់ការបំផុសគំនិតដែលអ្នកបានទទួល ។

សម្រាប់យោបល់នានាស្ដីពីការបង្រៀនសារលិខិតនេះសម្រាប់យុវវ័យ និង ក្មេង។ សូមមើលទំព័រទី 6 ។

## យុវវ័យ

### រៀនពីបទពិសោធន៍របស់អ្នកដទៃ

ប្រធាន អុជដូហ្វ លើកឡើងពីបទពិសោធន៍ផ្ទាល់ខ្លួន កាលលោកបង្រៀនថា « បុណ្យគ្រីស្ទម៉ាស់ដែលគួរឲ្យចងចាំបំផុតអាចជាគ្រាដ៏រាបសាបំផុត » ។ យើងអាចរៀនយ៉ាងច្រើនពីជំនាន់មុន មានមនុស្សពេញវ័យជាច្រើនបានរស់នៅឆ្លងកាត់គ្រាសង្គ្រាម ភាពអត់ការងារធ្វើ ជំងឺ ឬការសាកល្បងផ្សេងទៀត ។ សូមសមាជិកចំណាស់ៗនៅក្នុងវួដ ឬសាខារបស់អ្នកប្រាប់អ្នកពីបុណ្យគ្រីស្ទម៉ាស់ដ៏មានអត្ថន័យបំផុតរបស់ពួកគាត់ ។ អ្នកអាចសរសេរពីដំណើររឿងរបស់ពួកគេ ។ សូមព្យាយាមរៀនពីគំរូរបស់ពួកគេដោយផ្ដោតឲ្យបានច្រើននៅបុណ្យគ្រីស្ទម៉ាស់នេះទៅលើការផ្ដល់នូវការបម្រើដ៏ស្មោះ ហើយការចងចាំដល់ព្រះអង្គសង្គ្រោះ ។

## កុមារ

### អំណោយពីព្រះយេស៊ូវគ្រីស្ទ

មានមនុស្សមួយចំនួនប្រើដើមគ្រីស្ទម៉ាស់ដើម្បីអបអរដល់ការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ។ ពេលខ្លះមនុស្សបានដាក់អំណោយសម្រាប់អ្នកដទៃនៅក្រោមដើមឈើនោះ ។ តើអំណោយអ្វីខ្លះដែលព្រះអង្គសង្គ្រោះបានប្រទានដល់អ្នក? សូមអានបទគម្ពីរនីមួយៗដូចមានខាងក្រោមនេះ ហើយផាត់ពណ៌អំណោយនោះ ។ អ្នកអាចថ្វាយអំណោយត្រឡប់ទៅព្រះយេស៊ូវិញតាមរយៈការរកវិធីជួយដល់អ្នកដទៃ ។




រូបភាពនៃអំណោយដោយ ALEKSBOND/ISTOCK/THINKSTOCK

**សារលិខិតបង្រៀនសួរសុខទុក្ខ**

*សូមសិក្សាឯកសារនេះដោយការអធិស្ឋាន ហើយព្យាយាមយល់ដឹងនូវអ្វីដែលត្រូវចែកចាយ ។ តើការយល់ដឹងពីឆាកជីវិត និង បេសកកម្មរបស់ព្រះអង្គសង្គ្រោះ នឹងពង្រឹងសេចក្ដីជំនឿរបស់អ្នកលើទ្រង់ ហើយប្រទានពរដល់អ្នកទាំងឡាយដែលអ្នកមើលថែតាមរយៈការបង្រៀនសួរសុខទុក្ខបានដោយរបៀបណា ? ចំពោះព័ត៌មានបន្ថែម សូមចូលទៅ reliefsociety.lds.org ។*

# បេសកកម្មដ៏ទេវភាពនៃព្រះយេស៊ូវគ្រីស្ទ ៖ ព្រះអម្ចាស់នៃមេត្រីភាព


ព័ត៌មានលម្អិតពីផ្ទាំងគំនូរ *A SAVIOR IS BORN,* ដោយម៉ៃឃើល ម៉ាល់ម

*នេះជាផ្នែកនៃគំរូមួយអំពីសារលិខិតបង្រៀនសួរសុខទុក្ខ ដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃបេសកកម្មរបស់ព្រះអង្គសង្គ្រោះ ។*

អែលឌើរ ឃ្វីនធិន អិល ឃុក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងថា « ព្រះអង្គសង្គ្រោះគឺជាប្រភពនៃសេចក្ដីសុខសាន្តដ៏ពិត » ។ « ដោយសារដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ និងព្រះគុណទ្រង់ ទោះជាស្ថិតក្នុងការសាកល្បងនៃជីវិតក្ដី ការរស់នៅសុចរិតនឹងទទួលបានរង្វាន់នៃក្ដីសុខសាន្តផ្ទាល់ខ្លួន» ។[1] ការយល់ដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអម្ចាស់នៃមេត្រីភាពអាចជួយយើងឲ្យមានសេចក្ដីសុខសាន្តនៅក្នុងចិត្ត ហើយបង្កើនសេចក្ដីជំនឿយើងលើទ្រង់ ។

ព្រះយេស៊ូវគ្រីស្ទមានបន្ទូលថា ៖ « ខ្ញុំប្រាប់សេចក្ដីទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នាបានសេចក្ដីសុខសាន្ត ។ ដោយសារនៅលោកិយនេះ នោះអ្នករាល់គ្នាមានសេចក្ដីវេទនាមែន ប៉ុន្តែត្រូវសង្ឃឹមឡើង ត្បិតខ្ញុំបានឈ្នះលោកិយហើយ » (យ៉ូហាន 16:33) ។ ដោយថ្លែងទីបន្ទាល់ពីសេចក្ដីពិតនោះ លីនដា អេស រីវ៍ស ជាទីប្រឹក្សាទីពីរក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅបានថ្លែងថា ៖ « ព្រះអម្ចាស់មានក្ដីមេត្តាចំពោះខ្ញុំ ហើយបានជួយសម្រាលដល់បន្ទុកខ្ញុំ ។ ទ្រង់បានជួយខ្ញុំមានអារម្មណ៍សុខសាន្តយ៉ាងខ្លាំង » ។[2]

អែលឌើរ រីឆាដ ជី ស្កត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « កន្លែងដ៏ឥតខ្ចោះសម្រាប់ភាពសុខសាន្តគឺស្ថិតនៅក្នុងរង្វង់ជញ្ជាំងនៃគេហដ្ឋានយើងផ្ទាល់ ជាកន្លែងដែលយើងខំអស់ពីសមត្ថភាព ដើម្បីផ្ដោតទៅលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ» ។[3]

***ព្រះគម្ពីរបន្ថែម***

អេសាយ 9:6, លូកា 2:14, យ៉ូហាន 14:27, នីហ្វៃទី 1 13:37, គោលលទ្ធិ និង សេចក្ដីសញ្ញា 59:23

**សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ**

***ដកស្រង់ចេញពីព្រះគម្ពីរ***

អេសាយបានព្យាករពីការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃមេត្រីភាព (សូមមើល អេសាយ 9:6) ។ នៅទ្វីបអាមេរិក សាំយូអែល សាសន៍លេមិនបានប្រាប់ពីសញ្ញាដែលមាននៅឯការប្រសូតរបស់ព្រះគ្រីស្ទប្រាំឆ្នាំក្រោយមក (សូមមើល ហេលេមិន 14:3, 5) ។ កាលថ្ងៃដែលបានព្យាករបានមកដល់ ពួកអ្នកឥតជំនឿបានគម្រាមយកជីវិតពីពួកអ្នកដើរតាមព្រះគ្រីស្ទទាំងអស់ប្រសិនបើសញ្ញាទាំងនេះមិនបានកើតឡើង ។ ព្យាការីនីហ្វៃ « បានអំពាវនាវយ៉ាងខ្លាំងដល់ព្រះពេញមួយថ្ងៃ ហើយមើលចុះសំឡេងនៃព្រះអម្ចាស់បានបន្លឺមកកាន់លោកថា៖ . . . ថ្ងៃស្អែកឡើង យើងនឹងចុះមកឯលោកិយ » (នីហ្វៃទី 3 1:12–13) ។ សញ្ញាទាំងឡាយបានលេចចេញមក ហើយជាមួយនឹងការប្រសូតរបស់ព្រះគ្រីស្ទ « ប្រជាជនចាប់ផ្ដើមមានសន្តិភាពជាថ្មីនៅលើដែនដី » (ខទី 23) ។

នៅឯភូមិបេថ្លេហិម ម៉ារា « ប្រសូតបានបុត្រាមួយជាចម្បងមក រួចរុំនឹងសំពត់ផ្ដេកក្នុងស្នូក » (លូកា 2:7) ។

***សូមពិចារណាចំណុចនេះ***

តើព្រះអង្គសង្គ្រោះនាំយកនូវសេចក្ដីសុខសាន្តមកក្នុងជីវិតអ្នកតាមរបៀបណា ?

**កំណត់ចំណាំ**

1. ឃ្វីនធិន អិល ឃុក « Personal Peace: The Reward of Righteousness, » *Liahona,* ខែ ឧសភា ឆ្នាំ 2013 ទំព័រ 35 ។
2. លីនដា អេស រីវ៍ស « Claim the Blessings of Your Covenants, » *Liahona,* ខែ វិច្ឆិកា ឆ្នាំ 2013 ទំព័រ 120 ។
3. រីឆាដ ជី ស្កត « For Peace at Home, » *Liahona,* ខែ ឧសភា ឆ្នាំ 2013 ទំព័រ 29 ។

# ដង្វាយមួយភាគក្នុងដប់ជួយស្ថាបនានគរព្រះ

យើងជឿលើការថ្វាយមួយភាគក្នុងដប់នៃប្រាក់ចំណូលរបស់យើងដល់ព្រះអម្ចាស់ ដើម្បីជួយស្ថាបនានគរទ្រង់ ។ ច្បាប់ដង្វាយមួយភាគក្នុងដប់តម្រូវឲ្យយើងលះបង់សម្ភាររបស់យើងមួយចំនួន ដើម្បីរីករាយនឹងពរជ័យខាងវិញ្ញាណកាន់តែច្រើន ។

គោលការណ៍នៃដង្វាយមួយភាគក្នុងដប់បានអនុវត្តចាប់តាំងពីដំណឹងល្អត្រូវបានបង្រៀនជាលើកដំបូងនៅលើផែនដីមកម្ល៉េះ ។ ឧទាហរណ៍ អ័ប្រាហាំបានបង់ដង្វាយមួយភាគក្នុងដប់ដល់សង្ឃជាន់ខ្ពស់មិលគីស្សាដែក (សូមមើល លោកុប្បត្តិ 14:18–20) ។ ព្រះអម្ចាស់បានបង្គាប់ម៉ូសេឲ្យបង្រៀនដល់ប្រជាជន អំពីដង្វាយមួយភាគក្នុងដប់ (សូមមើល លេវីវិន័យ 27:30–34) ។ ក្រោយមកទៀត កាលព្រះអង្គសង្គ្រោះបានយាងទៅជួបនឹងសាសន៍នីហ្វៃ ទ្រង់បានប្រទានដល់ពួកគេនូវច្បាប់ដង្វាយមួយភាគក្នុងដប់ (សូមមើល នីហ្វៃទី 3 24) ។ ហើយនៅក្នុងជំនាន់យើង ទ្រង់បានស្ដារឡើងវិញនូវបទបញ្ញត្តិនេះតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ (សូមមើល គ. និង ស. 119) ។

ដើម្បីបំពេញបទបញ្ញត្តិនេះ យើងថ្វាយមួយភាគក្នុងដប់នៃប្រាក់ចំណូលយើងដល់ព្រះអម្ចាស់ តាមរយៈអ្នកដឹកនាំបព្វជិតភាពក្នុងមូលដ្ឋាន ។ មូលនិធិនេះត្រូវបានបញ្ជូនទៅទីស្នាក់ការកណ្ដាលរបស់សាសនាចក្រ ជាកន្លែងដែលក្រុមប្រឹក្សាមួយ ដែលរួមមានគណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និងគណៈប៊ីស្សពជាអធិបតីកំណត់ពីរបៀបដែលមូលនិធិដ៏ពិសិដ្ឋនេះនឹងត្រូវបានប្រើប្រាស់ (សូមមើល គ. និង ស. 120) ។

ដង្វាយមួយភាគក្នុងដប់អនុញ្ញាតឲ្យសាសនាចក្រសាងសង់ ហើយថែរក្សាព្រះវិហារបរិសុទ្ធ និង សាលាប្រជុំ ជួយដល់ថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថាន ផ្ដល់សម្ភារសម្រាប់សមាជិកសាសនាចក្រ និងជួយគាំទ្រដល់កិច្ចការអ្នកផ្សព្វផ្សាយសាសនា ព្រះវិហារបរិសុទ្ធ និង ពង្សប្រវត្តិ ។

យើងជឿលើការបង់ដង្វាយមួយភាគក្នុងដប់ដោយចិត្តស្មោះ « ត្បិតព្រះទ្រង់ស្រឡាញ់ដល់អ្នកណាដែលថ្វាយដោយអំណរ » (កូរិនថូសទី 2 9:7) ។ ការបង់ដង្វាយមួយភាគក្នុងដប់គឺជាវិធីមួយដែលយើងអាចជួយស្ថាបនានគរព្រះនៅលើផែនដី ហើយបង្ហាញអំណរគុណដល់ព្រះវរបិតាសួគ៌ចំពោះការប្រទានពរដល់យើងនូវអ្វីៗទាំងអស់ ដែលយើងមាន ។ ប៉ុន្តែការបង់ដង្វាយមួយភាគក្នុងដប់នាំពរជ័យកាន់តែច្រើនមកក្នុងជីវិតយើង ។ ដូចដែលម៉ាឡាគីបានបង្រៀនថា ៖ « ចូរនាំយកដង្វាយមួយភាគក្នុងដប់ទាំងអស់ មកដាក់ក្នុងឃ្លាំងចុះ ដើម្បីឲ្យមានស្បៀងអាហារនៅក្នុងដំណាក់នៃអញ ហើយល្បងលអញឥឡូវនេះ បើអញមិនបើកទ្វារស្ថានសួគ៌ដើម្បីចាក់ព្រះពរមកលើឯង ដែលនឹងគ្មានកន្លែងល្មមទុកបានទេ នេះហើយជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ » (ម៉ាឡាគី 3:10) ។ ពរជ័យខាងវិញ្ញាណ និង ខាងសាច់ឈាមអាចកើតមានដល់ជនគ្រប់រូបដែលបង់ដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់ ទោះជាចំនួនទឹកប្រាក់នោះតិចតួចក្ដី ។ ■

*សម្រាប់ព័ត៌មានបន្ថែមទៀត សូមមើលលោកុប្បត្តិ 28:20–22, ម៉ាឡាគី 3:8–11 និង ជំពូកទី 12 នៅក្នុង* Teachings of Presidents of the Church: Lorenzo Snow *(ឆ្នាំ 2012) ។*

## ពរជ័យនៃការបង់ដង្វាយមួយភាគក្នុងដប់



« ដង្វាយមួយភាគក្នុងដប់អភិវឌ្ឍ ហើយសាកល្បងសេចក្ដីជំនឿរបស់យើង ។ តាមរយៈការលះបង់ថ្វាយព្រះអម្ចាស់ នូវអ្វីដែលយើងអាចគិតថាយើងត្រូវការ ឬចង់បានសម្រាប់ខ្លួនឯង យើងរៀនពឹងផ្អែកទៅលើទ្រង់ ។ សេចក្ដីជំនឿរបស់យើងទៅលើទ្រង់ធ្វើឲ្យការរក្សាសេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធ និងការទទួលពរជ័យដ៏អស់កល្បក្នុងព្រះវិហារបរិសុទ្ធអាចកើតឡើងបាន ។ . . .

« ដង្វាយមួយភាគក្នុងដប់ក៏បង្រៀនយើងដើម្បីគ្រប់គ្រងបំណងប្រាថ្នាយើង និង មហិច្ឆតារបស់យើងសម្រាប់របស់ក្នុងលោកិយនេះផងដែរ ។ ការបង់ដង្វាយមួយភាគក្នុងដប់លើកទឹកចិត្តយើងឲ្យស្មោះត្រង់ នៅក្នុងទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ ។ យើងរៀនទុកចិត្តថា អ្វីដែលយើងត្រូវបានប្រទានឲ្យ តាមរយៈពរជ័យរបស់ព្រះអម្ចាស់ និង កិច្ចខិតខំដោយឧស្សាហ៍ព្យាយាមរបស់យើងផ្ទាល់ គឺគ្រប់គ្រាន់សម្រាប់សេចក្ដីត្រូវការរបស់យើង ។ . . .

« ព្រះអម្ចាស់សន្យានូវពរជ័យយ៉ាងច្រើនបរិបូរណ៍ចំពោះជនទាំងឡាយណាដែលរស់នៅដោយស្មោះត្រង់ ហើយទៀងត្រង់នឹងច្បាប់ដង្វាយមួយភាគក្នុងដប់ ។ ពរជ័យទាំងនេះមួយចំនួនគឺជាពរជ័យខាងសាច់ឈាម ដូចជាដង្វាយមួយភាគក្នុងដប់ជារឿងខាងសាច់ឈាមដែរ ។ ប៉ុន្តែដូចជាពិធីបរិសុទ្ធខាងសាច់ឈាមខាងក្រៅនៃពិធីបុណ្យជ្រមុជទឹក និង ពិធីសាក្រាម៉ង់ដែរ បទបញ្ញត្តិដើម្បីបង់ដង្វាយមួយភាគក្នុងដប់ តម្រូវឲ្យមានការលះបង់ខាងសាច់ឈាម ដែលនៅទីបំផុតវានឹងដឹកនាំទៅរកពរជ័យដ៏ធំធេងខាងវិញ្ញាណ » ។

**អែលឌើរ រ៉ូប៊ើត ឌី ហែល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Tithing: A Test of Faith with Eternal Blessings, »** ***Liahona,*** **ខែវិច្ឆិកា ឆ្នាំ 2002 ទំព័រ 27 ។**



ដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងទៀត
ត្រូវបានថ្វាយដល់ព្រះអម្ចាស់តាមរយៈសមាជិក
ម្នាក់នៃគណៈប៊ីស្សព ឬគណៈប្រធានសាខារបស់
អ្នក ។



ដង្វាយមួយភាគក្នុងដប់បង់ថ្លៃ
សម្រាប់ថ្លៃសាងសង់ និងការ
ថែរក្សាព្រះវិហារបរិសុទ្ធ និង
សាលាប្រជុំ ។



ដង្វាយមួយភាគក្នុងដប់បង់ថ្លៃ
សម្រាប់ការបកប្រែ និង ការ
បោះពុម្ពព្រះគម្ពីរ និង សម្ភារ
មេរៀន ។



មូលនិធិដង្វាយមួយភាគក្នុងដប់ត្រូវបានបញ្ជូនពី
វួដ និង សាខាទៅកាន់ទីស្នាក់ការកណ្ដាលរបស់
សាសនាចក្រ ជាកន្លែងដែលក្រុមប្រឹក្សាមួយ
ដែលរួមមានគណៈប្រធានទីមួយ បានសម្រេច
ចិត្តពីរបៀបដែលមូលនិធិដ៏ពិសិដ្ឋទាំងនេះ
នឹងត្រូវបានប្រើប្រាស់ ។



ដង្វាយមួយភាគក្នុងដប់ជួយ
បង់ថ្លៃសម្រាប់ការអប់រំរបស់
សមាជិក ដែលជាយុវវ័យក្នុង
សាលារៀនរបស់សាសនាចក្រ
ថ្នាក់សិក្ខាសាលា និង
ថ្នាក់វិទ្យាស្ថាននៃសាសនា ។

រចនារូបភាពដោយ ដេវីដ ហាប៊ិន

# អព្ភូតហេតុនៃបុណ្យគ្រីស្ទម៉ាស់

ដោយ លីនសេ អាល់ឌើរ

*បេះដូងគាត់នៅតែលោត ។ ប៉ុន្តែមិនដូចពីមុនពេលមានជំងឺគាំងបេះដូងឡើយ ។ ប៉ុន្តែវានៅតែលោត ។*



គំនូរដោយ ជូឌី ស្ទ៊ែល

ចិត្តខ្ញុំមានភាពកក់ក្ដៅនាយប់នេះ ។ ពិតណាស់វាបានខ្ទេចខ្ទាំ ហើយមានរបួសស្នាម ។ ប៉ុន្តែវាទទួលបាននូវភាពកក់ក្ដៅយ៉ាងអស្ចារ្យ ។ ខ្ញុំមានអារម្មណ៍នូវការដឹងគុណជាខ្លាំង—ជាការដឹងគុណយ៉ាងជ្រាលជ្រៅដែលវាហាក់ដូចជាមានចន្លោះថ្មីមួយត្រូវបានបើកចំហរនៅក្នុងព្រលឹងរបស់ខ្ញុំ ដើម្បីទុករឿងនេះ វាជាការដឹងគុណយ៉ាងខ្លាំងរហូតធ្វើឲ្យខ្ញុំមិនអាចហាមឃាត់ទឹកភ្នែកបាន ។ ស្វាមីខ្ញុំនៅតែដកដង្ហើម ។ ខ្ញុំអាចឮគាត់ដកដង្ហើមវែងៗ ហើយស្ងៀមស្ងាត់ ។

ទើបតែប៉ុន្មានម៉ោងមុននេះ ខ្ញុំរត់សំដៅទៅរកគ្រែរបស់គាត់ក្នុងមន្ទីរពេទ្យ ដោយមិនខ្វល់ពីការធាក់ថ្នមៗនៃទារកតូចរបស់យើងក្នុងផ្ទៃ ដែលនឹងកើតមកក្នុងពេលឆាប់ៗ ហើយស្វែងរកកន្លែងមួយដែលខ្ញុំអាចផ្ដេកក្បាលខ្ញុំនៅលើដើមទ្រូងគាត់ ដែលមានសុទ្ធតែខ្សែដែលតភ្ជាប់ទៅនឹងឧបករណ៍ព្យាបាល ។ ការដេកស្ដាប់ចង្វាក់បេះដូងរបស់គាត់គឺជាបទពិសោធន៍មួយដែលបានឆេះ ឆួលនៅក្នុងចិត្តខ្ញុំជារៀងរហូត ។

បេះដូងគាត់នៅតែលោត ។ ប៉ុន្តែមិនដូចពីមុនពេលមានជំងឺគាំងបេះដូងឡើយ ។ ប៉ុន្តែវានៅលោត ។

ភ្លើងបុណ្យគ្រីស្ទម៉ាស់ដ៏ស្រទន់ដែលបានព្យួរនៅជ្រុងម្ខាងទៀតនៃបន្ទប់បានធ្វើឲ្យខ្ញុំមានអារម្មណ៍កក់ក្ដៅនាយប់នេះ ។ ពន្លឺព្រាងៗរបស់ពួកគេបង្កើតនូវបរិយាកាសដ៏កក់ក្ដៅមួយ ប៉ុន្តែភាពកក់ក្ដៅដ៏ពិតកើតចេញពីការដឹងថា មានមិត្តពិតជាច្រើនបានសុខចិត្តលះបង់ល្ងាចមុនថ្ងៃបុណ្យគ្រីស្ទម៉ាស់របស់ពួកគេមកតុបតែងឲ្យយើង នៅពេលប្រាយអ៊ិនផ្លាស់មកពីបន្ទប់សង្គ្រោះបន្ទាន់ ។ ដើមឈើបុណ្យគ្រីស្ទម៉ាស់កម្ពស់មួយម៉ែត្របានដាក់តាំងនៅត្រង់មាត់បង្អួចជាសញ្ញានៃសេចក្ដីស្រឡាញ់របស់ពួកគេ ។

តើខ្ញុំអាចអរគុណដល់មិត្តយើងតាមរបៀបណាបាន ? តើពួកគេបានដឹងទេថាខ្ញុំត្រូវការពួកគេ ហើយមានអំណរគុណចំពោះពួកគេប៉ុណ្ណាទេ ? កាលដែលគំនិតខ្ញុំផ្ដោតតែទៅលើស្វាមីខ្ញុំ នោះពួកគេបានមើលថែដល់កូនៗខ្ញុំ បោសសម្អាតផ្ទះខ្ញុំ ទិញម្ហូបដាក់បំពេញទូរទឹកកកខ្ញុំ បោកខោអាវឲ្យខ្ញុំ រុំអំណោយបុណ្យគ្រីស្ទម៉ាស់ឲ្យយើង ហើយផ្ដល់សេចក្ដីស្រឡាញ់ដល់ខ្ញុំតាមរយៈការឱប អាហារពេលល្ងាច ប័ណ្ណអំណោយ ប្រាក់ តាមទូរសព្ទ ផ្ញើសារ ផ្ញើអ៊ីម៉ែល ផ្លែឈើឈ្មោះស៊ិណ្ណាមិនមួយថង់ និងគ្រឿងតុបតែងមួយវ៉ាលីពេញ ។ ពួកគេបានយំជាមួយនឹងខ្ញុំ ហើយបានអធិស្ឋាន និងតមអាហារ ។ ហើយដោយការធ្វើទង្វើទាំងអស់នេះ ពួកគេបានផ្ដល់ឲ្យខ្ញុំនូវអំណោយដ៏មានតម្លៃបំផុតដែលពួកគេអាចធ្វើបានគឺ ៖ ពេលវេលារបស់ពួកគេ ។ ខ្ញុំស្រឡាញ់ពួកគេទាំងអស់គ្នាខ្លាំងណាស់!

ខ្ញុំគិតថា ខ្ញុំនឹងដេកយ៉ាងលង់លក់នាយប់នេះ ដោយសារខ្ញុំពោរពេញទៅដោយការដឹងគុណយ៉ាងពេញលេញចំពោះពួកគេទាំងអស់គ្នា ។

ប៉ុន្តែខ្ញុំមានការដឹងគុណជាខ្លាំងចំពោះព្រះអម្ចាស់សម្រាប់ជីវិតរបស់ស្វាមីខ្ញុំ—សម្រាប់ការដកដង្ហើមវែងៗរបស់គាត់ សម្រាប់បេះដូងគាត់ដែលសប់ឈាម សម្រាប់រូបកាយដ៏មានជីវិត និង ព្រលឹងរបស់គាត់ ។ ជីវិតរបស់គាត់គឺជាអព្ភូតហេតុនៃបុណ្យគ្រីស្ទម៉ាស់របស់ខ្ញុំ ។ ■

*អ្នកនិពន្ធរស់នៅ រដ្ឋ ខារ៉ូឡាញណាខាងជើង ស.រ.អា. ។*

# ម៉ាឡាគី

*« [ព្រះយេស៊ូវ] បានបញ្ជាឲ្យពួកគេសរសេរទុកនូវព្រះបន្ទូលទាំងឡាយដែលព្រះវរបិតាទ្រង់បានប្រទានឲ្យម៉ាឡាគី » (នីហ្វៃទី 3 24:1) ។*

ឈ្មោះខ្ញុំមានន័យថា « ទូតយើង » ហេតុដូច្នេះហើយខ្ញុំបានផ្ញើ « ព្រះបន្ទូលយ៉ាងធ្ងន់នៃព្រះអម្ចាស់ដល់អ៊ីស្រាអែល » ។[1] នៅក្នុងជំនាន់ខ្ញុំ ប្រមាណជា 450 ឆ្នាំពីមុនការប្រសូតរបស់ព្រះគ្រីស្ទ[2] មានពួកសាសន៍យូដាជាច្រើនបានបាក់ទឹកចិត្ត ហើយបានឈប់រស់នៅដោយសុចរិត ។[3] ព្រះអម្ចាស់បានស្ដីបន្ទោសដល់ពួកគេតាមរយៈការបង្រៀនរបស់ខ្ញុំ ។

ពួកសង្ឃសាសន៍យូដាមកពីពូជអម្បូរលេវីជាធម្មតាត្រូវបានតែងតាំងដើម្បីផ្ដល់ពិធីបរិសុទ្ធនានា ប៉ុន្តែសាសន៍លេវីបានប្រព្រឹត្តអំពើពុករលួយនៅក្នុងជំនាន់ខ្ញុំ ។ ពួកគេខ្វះការដឹងគុណ មិនគោរពដល់ព្រះ ហើយថ្វាយនំប៉័ងខូច និងការបូជាសត្វដែលមិនបរិសុទ្ធ ។[4] ពួកគេបានបំពានលើសេចក្ដីសញ្ញានៃបព្វជិតភាពដែលព្រះបានធ្វើជាមួយនឹងលេវី ។

ប្រជាជននោះ—មិនត្រឹមតែពួកសង្ឃប៉ុណ្ណោះទេ—ក៏បានប្រព្រឹត្តអំពើពុករលួយផងដែរ ។ ពួកគេបានរៀបការក្រៅសេចក្ដីសញ្ញា លែងលះប្រពន្ធតាំងពីក្មេង ហើយមិនព្រមបង់ដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងទៀតរបស់ពួកគេទេ ។[5]

ប៉ុន្តែទោះជាព្រះអម្ចាស់បានមានបន្ទូលទាស់នឹងទង្វើដ៏ទុច្ចរិតទាំងនេះក្ដី ក៏ទ្រង់នៅតែមានព្រះទ័យអត់ឱនទោសផងដែរ ដោយសារទ្រង់ស្រឡាញ់រាស្ត្ររបស់ទ្រង់ ៖ « ចូរវិលមកឯយើងវិញចុះ នោះយើងនឹងត្រឡប់មកឯឯងវិញដែរ » ។[6] វិធីមួយដើម្បីត្រឡប់ទៅរកព្រះអម្ចាស់វិញគឺការនាំយក « ដង្វាយមួយភាគក្នុងដប់ទាំងអស់មកដាក់ក្នុងឃ្លាំង » ។[7]

ប្រជាជននោះបានត្អូញត្អែរថា « ការដែលខំគោរពតាមព្រះនោះឥតអំពើទេ៖ . . . ពួកអ្នកដែលប្រព្រឹត្តការអាក្រក់បានតាំងឡើង [យ៉ាងច្រើន] »[8] ប៉ុន្តែខ្ញុំបានបង្រៀនថា ឈ្មោះជនដែល « កោតខ្លាចដល់ព្រះអម្ចាស់ . . . និងពួកអ្នកដែលនឹកដល់ព្រះនាមទ្រង់» ត្រូវបានសរសេរនៅក្នុង « សៀវភៅរំឭក » ។[9]

ខ្ញុំក៏បានព្យាករផងដែរថា នៅការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ មនុស្សទុច្ចរិត « នឹងដូចជាជញ្ជ្រាំង » ប៉ុន្តែជនដែលកោតខ្លាចដល់ព្រះនាមទ្រង់ « ព្រះអាទិត្យនៃសេចក្ដីសុចរិតនឹងរះឡើង មានទាំងអំណាចប្រោសឲ្យជានៅក្នុងចំអែងស្លាប »។[10]

ខ្ញុំបានព្យាករថា ពីមុនការយាងមកជាលើកទីពីរ ព្យាការីអេលីយ៉ានឹងមកដើម្បីស្ដារឡើងវិញនូវកូនសោនៃបព្វជិតភាពដែលនឹង « បង្វែរចិត្តពួកឪពុកមកឯកូន និងចិត្តកូនមកឯឪពុកវិញ » ។[11]

តាមរយៈការបង្រៀនរបស់ខ្ញុំ យើងឃើញថាព្រះអម្ចាស់ចងចាំរាស្ត្ររបស់ទ្រង់ ហើយរក្សាការសន្យាចំពោះកូនចៅដ៏ស្មោះត្រង់របស់ទ្រង់ ។ ទ្រង់សព្វព្រះទ័យឲ្យយើងមានសេចក្ដីជំនឿលើការសន្យាទាំងនេះ ហើយត្រឡប់មករកទ្រង់វិញតាមរយៈការប្រែចិត្ត ។[12] ■



រូបថតជញ្ជាំងដោយ PAVLO VAKRUSHEV/ISTOCK/THINKSTOCK រូបថតកាលបរិច្ឆេទដោយ AKSPHOTO/ISTOCK/THINKSTOCK

**កំណត់ចំណាំ**

1. ម៉ាឡាគី 1:1 ។
2. សូមមើល Bible Dictionary « Malachi » ទំព័រ 728 ។
3. សូមមើល *ព្រះគម្ពីរសញ្ញាចាស់សៀវភៅការណែនាំការសិក្សាសម្រាប់សិស្សសិក្ខាសាលា* (ឆ្នាំ 2002) ទំព័រ 226 ។
4. សូមមើល ម៉ាឡាគី 1: 2, 6–14, សូមមើលផងដែរ *Old Testament Instructor's Guide, Religion* 301–2 (ឆ្នាំ 1994) ទំព័រ 109–110 ។
5. សូមមើល ម៉ាឡាគី 2:11, 14–16, 3:8 ។
6. ម៉ាឡាគី 3:7 ។
7. ម៉ាឡាគី 3:10, សូមមើលផងដែរ LeGrand Richards « The Second Coming of Christ, » *Ensign*, ខែ ឧសភា ឆ្នាំ 1978 ទំព័រ 75 ។
8. ម៉ាឡាគី 3:14–15 ។
9. ម៉ាឡាគី 3:16 ។
10. ម៉ាឡាគី 4:1–2 ។
11. ម៉ាឡាគី 4:6, សូមមើលផងដែរ គោលលទ្ធិ និង សេចក្ដីសញ្ញា 110 ។
12. សូមមើល *Old Testament Teacher Resource Manual* (ឆ្នាំ 2003) ទំព័រ 215 ។



**ដោយអែលឌើរ អិល ថម ភែរី**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# ការជួយអ្នកដទៃស្វែងរក សេចក្ដីជំនឿលើព្រះគ្រីស្ទ

*ខ្ញុំសុំណូមពរអ្នកឲ្យជួយដល់កូនចៅរបស់ព្រះឲ្យត្រឡប់មករកសេចក្ដីជំនឿជាពួកគ្រីស្ទានរបស់ពួកគេវិញ និងមករកគ្រឹះសាសនាដ៏រឹងមាំដែលសំខាន់បំផុតសម្រាប់សេចក្ដីសុខសាន្តនៃគំនិត និង សុភមង្គលពិត ។*

ដោយភាពសោកសៅនឹងភាពទន់ខ្សោយនៃព្រះវិហារគ្រីស្ទាននៅទ្វីបអឺរ៉ុប អូស្ត្រាលី និង សហរដ្ឋអាមេរិក ព្រះសង្ឃប៉ូប បេណេឌីក បានពោលថា « គ្មានភស្ដុតាងចំពោះការត្រូវការព្រះទៀតឡើយ សូម្បីតែព្រះគ្រីស្ទផងដែរ » ។ លោកបានបន្ថែមទៀតថា « ព្រះវិហារពីដើម មើលទៅដូចជាវាកំពុងតែជិតផុតរលត់ទៅហើយ » ។[1]

យើងបានងាកចេញពីការថ្វាយបង្គំតាមទំនៀមទំលាប់ ។ មានមនុស្សជាច្រើនបានពោលថា ពួកគេជាមនុស្សមានសេចក្ដីជំនឿរឹងមាំ ជាជាងអ្នកកាន់សាសនាទៅទៀត ។ ប្រសិនបើមានការបង្រៀនមួយស្របតាមរចនាបទជីវិតពួកគេ នោះពួកគេនឹងទទួលវា ហើយវានឹងក្លាយទៅជាផ្នែកមួយនៃសេចក្ដីជំនឿពួកគេ ។ បើសិនជាមិនដូច្នោះ ពួកគេបង្កើតសេចក្ដីជំនឿដោយខ្លួនឯង ។ សេចក្ដីជំនឿ និងជីវភាពខាងវិញ្ញាណ ឥឡូវនេះត្រូវបានគិតថា ជាផលិតផលប្រើប្រាស់ប្រចាំថ្ងៃ ។ ទ្រព្យសម្បត្តិរបស់លោកិយត្រូវបានយកមកជំនួសព្រះវិញ ។

ក្នុងនាមជាពួកបរិសុទ្ធថ្ងៃចុងក្រោយ សំឡេងរបស់យើងត្រូវតែបន្លឺឡើងក្នុងការតតាំងនឹងនិន្នាការដ៏គ្រោះថ្នាក់ទាំងនេះដែលបានរៀបចំឡើងដើម្បីបំផ្លាញសេចក្ដីជំនឿរបស់មនុស្ស ។ ព្រះគម្ពីរមរមនព្រមានយើងម្ដងហើយម្ដងទៀតអំពីការយករឿងមិនចិតថេរមកជំនួសនឹងទំនុកចិត្តរបស់យើងទៅលើព្រះ ។ មានការពិពណ៌នាអំពីគ្រាមួយដែលប្រជាជននីហ្វៃជាច្រើនបានងាកចេញពីសេចក្ដីជំនឿរបស់ពួកគេ លោកមរមនបានថ្លែងថា ៖ « ពួកគេបានទៅជាឆ្មើងឆ្មៃទៅវិញ ដោយលើកខ្លួនឡើងក្នុងចិត្តរបស់គេដោយព្រោះទ្រព្យដ៏ច្រើនលើសលប់របស់គេ ហេតុដូច្នេះហើយ ពួកគេបានទៅជាអ្នកមាននៅចំពោះភ្នែករបស់គេផ្ទាល់ ហើយពុំស្ដាប់បង្គាប់តាមពាក្យពេចន៍របស់ពួកព្យាការី ដើម្បីដើរដោយត្រង់នៅចំពោះព្រះឡើយ » (អាលម៉ា 45:24) ។

**_រឿងពិតដ៏ល្អបំផុតដែលបានកត់ត្រាទុកនៅក្នុងប្រវត្តិសាស្ត្រ គឺជាដំណើររឿងនៃការប្រសូត និង បេសកកម្មរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទនៅលើផែនដី ។_**

កាលអ្នកមើលឃើញពីភាពទន់ខ្សោយនៃសេចក្ដីជំនឿរបស់ពួកគ្រីស្ទាន នៅក្នុងសង្គម សេចក្ដីជំនឿរបស់អ្នកផ្ទាល់ត្រូវតែមានភាពរឹងមាំ ហើយច្បាស់លាស់ ។ ហេលេមិនបានប្រកាសថា៖ « ចូរចងចាំចុះ ចូរចងចាំចុះថា គឺនៅលើសិលានៃព្រះដ៏ប្រោសលោះនៃយើង គឺព្រះគ្រីស្ទជាព្រះរាជបុត្រានៃព្រះ ដែលកូនត្រូវ

*THE HEALING BALM,* ដោយ ដើរ៉ង លីនក្វី





***ហេតុដូច្នេះ ពលិកម្មត្រូវបានបង្កើតឡើងនៅលើផែនដីជាពិធីបរិសុទ្ធដំណើងល្អមួយ ដើម្បីត្រូវបានអនុវត្តនិងធ្វើឡើងដោយសិទ្ធិអំណាចនៃបព្វជិតភាពជាគំរូយ៉ាងអំពីការពលិកម្មនៃកូនមនុស្សដែលនឹងប្រទានជីវិតរបស់ទ្រង់សម្រាប់អំពើបាបនៃពិភពលោក ។***

សង់គ្រឹះរបស់កូន ដើម្បីកាលណាអារក្សបញ្ចេញខ្យល់ដ៏ខ្លាំងក្លារបស់វាមក មែនហើយ ព្រួញរបស់វានៅក្នុងខ្យល់គួច មែនហើយ កាលណាព្រិល និងខ្យល់ព្យុះកំណាចទាំងអស់របស់វាបោកបក់មកលើកូន នោះវានឹងគ្មានអំណាចមកលើកូនឡើយ ដើម្បីទាញកូនចុះទៅក្នុងជង្ហុក នៃសេចក្ដីវេទនា និងទុក្ខលំបាកដ៏មិនចេះចប់មិនចេះហើយ ពីព្រោះមកពីសិលាដែលកូនបានសង់នៅលើនោះ ដែលជាគ្រឹះដ៏ខ្ជាប់ខ្ជួនមួយជាគ្រឹះមួយ បើសិនណាមនុស្សសង់នៅលើនោះ នោះពួកគេមិនអាចរលំបានឡើយ » (ហេលេមិន 5:12) ។ នីហ្វៃបានរំឭកយើងថា ៖

« យើងនិយាយអំពីព្រះគ្រីស្ទ យើងអររីករាយក្នុងព្រះគ្រីស្ទ យើងផ្សាយអំពីព្រះគ្រីស្ទ យើងព្យាករអំពីព្រះគ្រីស្ទ ហើយយើងសរសេរស្របតាមពាក្យព្យាករណ៍ទាំងឡាយរបស់យើង ដើម្បីឲ្យកូនចៅយើងអាចដឹងថា តើត្រូវស្វែងរកប្រភពណាមួយ ដើម្បីឲ្យបានផ្ដាច់បាបរបស់ពួកគេ និង ជីវិតដែលនៅក្នុងព្រះគ្រីស្ទ ។ . . .

«. . . ព្រោះផ្លូវត្រឹមត្រូវ គឺជឿដល់ព្រះគ្រីស្ទ » (នីហ្វៃទី 2 25:26–28)។

តើយើងមានគ្រឹះដើម្បីគាំទ្រនូវការអះអាងដូច្នេះទេ ?

## និមិត្តសញ្ញានៃការលះបង់របស់ព្រះគ្រីស្ទ

រឿងពិតដ៏ល្អបំផុតដែលបានកត់ត្រាទុក នៅក្នុងប្រវត្តិសាស្ត្រគឺជាដំណើររឿងនៃការប្រសូត និង បេសកកម្មរបស់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទនៅលើផែនដី ។ បេសកកម្មរបស់ទ្រង់ត្រូវបានព្យាករតាំងពីជំនាន់ឪពុកម្ដាយទីមួយរបស់យើងមកម្ល៉េះ ។ ក្នុងព្រះគម្ពីរម៉ូសេ យើងអានថា ៖

« ហើយអ័ដាម និងនាងអេវ៉ា ជាប្រពន្ធគាត់បានអំពាវនាវដល់ព្រះនាមនៃព្រះអម្ចាស់ ហើយពួកគេបានឮសម្លេងនៃព្រះអម្ចាស់ចេញពីផ្លូវឆ្ពោះទៅសួនច្បារអេដែនមានបន្ទូលមកពួកគេ ហើយពួកគេមើលមិនឃើញទ្រង់សោះ ត្បិតពួកគេត្រូវបានបិទចេញពីវត្តមានរបស់ទ្រង់ ។

« ហើយទ្រង់បានប្រទានដល់ពួកគេនូវព្រះបញ្ញត្តិទាំងឡាយថា ពួកគេគប្បីថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់ពួកគេ ហើយគប្បីយកកូនសត្វច្បងនៃហ្វូងចៀមរបស់គេមកថ្វាយជាយញ្ញបូជាទាំងឡាយរបស់ព្រះអម្ចាស់ ។ ហើយអ័ដាមបានគោរពតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ ។

« ហើយជាច្រើនថ្ងៃកន្លងមក នោះមានទេវតាមួយពីព្រះអម្ចាស់បានលេចមកឲ្យអ័ដាមឃើញដោយសួរថា ៖ ហេតុអ្វីបានជាអ្នកថ្វាយយញ្ញបូជាទាំងឡាយដល់ព្រះអម្ចាស់ ? ហើយអ័ដាមបានទូលតបទៅលោកថា៖ ខ្ញុំមិនដឹងទេ លើកលែងតែព្រះអម្ចាស់ទ្រង់បញ្ជាខ្ញុំប៉ុណ្ណោះ ។

« ហើយខណៈនោះទេវតាប្រាប់ថា៖ ការណ៍នេះគឺជានិមិត្តរូបអំពីការបូជានៃព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា ដែលពោរពេញទៅដោយព្រះគុណ និងសេចក្ដីពិត ។

« ហេតុដូច្នោះហើយ អ្នកនឹងត្រូវធ្វើអ្វីៗទាំងអស់ ដែលអ្នកធ្វើដោយនូវព្រះនាមនៃព្រះរាជបុត្រា ហើយអ្នកត្រូវប្រែចិត្ត ហើយអំពាវនាវដល់ព្រះដោយនូវព្រះនាមនៃព្រះរាជបុត្រាជារៀងដរាបរហូតតទៅ » (ម៉ូសេ 5:4–8) ។

ហេតុដូច្នេះ ពលិកម្មត្រូវបានបង្កើតឡើងនៅលើផែនដី ជាពិធីបរិសុទ្ធដំណឹងល្អមួយ ដើម្បីអនុវត្ត និងធ្វើឡើងដោយសិទ្ធិអំណាចនៃបព្វជិតភាពជាតួយ៉ាងអំពីការពលិកម្មនៃកូនមនុស្សដែលនឹងប្រទានជីវិតរបស់ទ្រង់ សម្រាប់អំពើបាបនៃពិភពលោក ។

ទម្រង់នៃពិធីបរិសុទ្ធនេះត្រូវបានរៀបចំឡើង ដើម្បីបង្កើតជាចំណុចជាក់លាក់នៃការពលិកម្មរបស់ព្រះអម្ចាស់ នៅពេលទ្រង់នឹងយាងមកនៅក្នុងកាលដ៏ខ្ពង់ខ្ពស់បំផុត ។ ឧទាហរណ៍ ដង្វាយថ្វាយនៃបុណ្យរំលងក្រោយមកទៀតបានចែងលក្ខខណ្ឌថា ចៀមឈ្មោលមួយនៃឆ្នាំដំបូងដែលគ្មានប្រឡាក់ ឬស្នាមជាំ ត្រូវបានជ្រើសជាដង្វាយថ្វាយ ។ លោហិតត្រូវបានបង្ហូរចុះ ហើយការមើលថែកុំឲ្យមានការបាក់ឆ្អឹងណាមួយទាំងអស់—ជានិមិត្តរូបនៃការសុគតរបស់ព្រះអង្គសង្គ្រោះ ។

វាគឺជារឿងអស្ចារ្យណាស់ដែលការថ្វាយយញ្ញបូជា បានបន្តមានគ្រប់សម័យកាល ចាប់តាំងពីអ័ដាមរហូតដល់ជំនាន់របស់ព្រះអង្គសង្គ្រោះ ។ ទោះជាកូនចៅអ៊ីស្រាអែលបានឆ្លងកាត់នូវគ្រានៃការក្បត់សាសនាជាច្រើនលើកច្រើនគ្រាក្ដី ក៏សេចក្ដីសង្ឃឹមថាព្រះរាជបុត្រាបង្កើតតែមួយនឹងយាងមកធ្វើឲ្យធួននឹងអំពើបាបរបស់មនុស្សលោក ហើយថាព្រះលោហិតដែលធ្វើឲ្យធួនរបស់ទ្រង់នឹងធ្វើឲ្យអមតភាពកើតឡើង ដោយបានដក់ជាប់នៅក្នុងដួងចិត្តរបស់មនុស្សជាច្រើនដែរ ។

ជាទូទៅការថ្វាយយញ្ញបូជានេះបានឈប់អនុវត្ត បន្ទាប់ពីមានដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។ ពិធីសាក្រាម៉ង់ត្រូវបានបង្កើតឡើង ដើម្បីរំឭកដល់អ្នកដើរតាមទ្រង់ថា ទ្រង់បានយាងមកលើផែនដី ហើយបានធ្វើការបម្រើលើផែនដី ។ យើងអាននៅក្នុងលូកាថា ៖

« រួចទ្រង់ក៏យកនំបុ័ងមកអរព្រះគុណ ហើយកាច់ប្រទានទៅគេដោយបន្ទូលថា នេះហើយជារូបកាយខ្ញុំដែលបានប្រទានមកសម្រាប់អ្នករាល់គ្នា ចូរធ្វើបុណ្យនេះដើម្បីរំឭកពីខ្ញុំចុះ ។

« នោះទ្រង់បានយកពែងមកធ្វើបែបដូច្នោះដែរ ដោយបន្ទូលថា ពែងនេះជាសញ្ញាថ្មីដែលតាំងដោយនូវឈាមខ្ញុំ គឺជាឈាមដែលត្រូវច្រួចចេញសម្រាប់អ្នករាល់គ្នា » (លូកា 22:19–20) ។

ជាថ្មីម្ដងទៀត ខ្ញុំមានភាពអស្ចារ្យណាស់ដែលការរំឭកនេះ ថ្វីបើនៅក្នុងគ្រាដ៏ងងឹតនៃការក្បត់សាសនាក្ដី វាត្រូវបានអនុវត្តតាមទម្រង់ និងវិធីជាច្រើនប្រភេទនៅគ្រប់ជំនាន់រហូតមកដល់ការស្ដារឡើងវិញនៃដំណឹងល្អ នៅពេលអំណាចបព្វជិតភាពត្រូវបានមានស្ដារជាថ្មីនៅលើផែនដី ដើម្បីធ្វើពិធីបរិសុទ្ធដ៏សង្គ្រោះនេះ ។

នៅគ្រប់គ្រានៃប្រវត្តិសាស្ត្រដែលបានកត់ត្រា យើងរកឃើញនូវការរំឭកយ៉ាងខ្ជាប់ខ្ជួនអំពីបេសកកម្មរបស់ព្រះអង្គសង្គ្រោះរបស់យើង ។ ទ្រង់បានយាងមកលើផែនដី ក្នុងនាមជាមនុស្សម្នាក់ដែលមានសញ្ជាតិពីរ—មួយមកពីព្រះហើយមួយទៀតមកពីមនុស្ស ។ ការណ៍នេះផ្ដល់លទ្ធភាពដល់ទ្រង់ ដើម្បីធ្វើនូវការលះបង់ដ៏ខ្ពង់ខ្ពស់បំផុតរបស់ទ្រង់សម្រាប់យើងរាល់គ្នាតាមរយៈដង្វាយធួនរបស់ទ្រង់ ។ តើមានភស្តុតាងដ៏រឹងមាំណាមួយដែលថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃពិភពលោក ជាជាងការសិក្សា និង ការរស់នៅតាមគោលលទ្ធិដ៏សង្គ្រោះរបស់ទ្រង់ ដែលទ្រង់បានបើកសម្ដែងនៅគ្រប់គ្រាកាន់កាប់ត្រួតត្រានៃពិភពលោកនេះដែរឬទេ ? ទ្រង់បានប្រទានដំណឹងល្អរបស់ទ្រង់ដើម្បីដឹកនាំ និងណែនាំផ្លូវយើង អំឡុងពេលនៃការស្នាក់អាស្រ័យរបស់យើងលើផែនដីនេះ ។

## ដំណឹងល្អគឺជាដំណោះស្រាយ

ប្រធានដេវីឌ អូ ម៉ាក់ឃេ (1873–1970) បានថ្លែងថា ៖

« ការទទួលខុសត្រូវក្នុងការបង្ហាញដល់ពិភពលោកថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនឹងដោះស្រាយបញ្ហា គឺមានចំពោះជនដែលមានដំណឹងល្អនេះ ។ . . . ខ្ញុំជឿផងដែរថារាល់ *បញ្ហារបស់លោកិយអាចនឹងត្រូវដោះស្រាយបាន តាមរយៈការគោរពប្រតិបត្តិចំពោះគោលការណ៍នៃដំណឹងល្អរបស់ព្រះយេស៊ូវ គ្រីស្ទ* ។

« ដំណោះស្រាយចំពោះបញ្ហាដ៏ធំនៃលោកិយ គឺមាននៅទីនេះ ក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។ ការឧបត្ថម្ភដ៏គ្រប់គ្រាន់ត្រូវបានធ្វើឡើង មិនគ្រាន់តែសម្រាប់សេចក្ដីត្រូវការរបស់បុគ្គលម្នាក់ៗប៉ុណ្ណោះនោះទេ ប៉ុន្តែក៏សម្រាប់ជាតិសាសន៍ និងក្រុមនៃជាតិសាសន៍ទាំងឡាយផងដែរ ។ . . . ខ្ញុំចង់សារភាពថា យើងហាក់ដូចជាអួតក្អេងក្អាងចំពោះ ខ្លួនយើងនូវប្រាជ្ញាដ៏ខ្ពង់ខ្ពស់ ប៉ុន្តែនោះពុំមែនជាការណ៍ពិតទេ ។ វាគ្រាន់តែជាការប្រើប្រាស់ផែនការរបស់ព្រះដើម្បីដោះស្រាយបញ្ហានៃពិភពលោកប៉ុណ្ណោះ ។ អ្នកដែលកាន់បព្វជិតភាពមានការទទួលខុសត្រូវកាន់តែធំមហិមាជាងនៅសព្វថ្ងៃនេះ ក្នុងពេលនេះដែលអ្នករស់នៅក្នុងគ្រាឆ្នៃប្រឌិតជឿនលឿនខ្ពស់ ក្នុង

*ADAM AND EVE OFFERING SACRIFICES,* ដោយរ៉ិច ឡូរ៉េន

ប្រវត្តិសាស្ត្រពិភពលោកនេះជាង ដែលសាសនាចក្រធ្លាប់មានពីមុនមក ។ ខ្ញុំសូមនិយាយម្ដងទៀត ។ ប្រសិនបើយើងប្រកាសថាកាន់តាមសេចក្ដីពិត នោះវាគឺជាកាតព្វកិច្ចរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយគ្រប់រូបដើម្បីអនុវត្តតាម នឹងថានៅពេលមនុស្សរបស់លោកិយចូលមក តាមការដង្ហោយហៅឲ្យមក ដើម្បីភ្លក់ផ្លែឈើនៃដើមឈើជីវិត នោះពួកគេនឹងឃើញថាវាមានរស់ជាតិល្អ ហើយឆ្ងាញ់ » ។[2]

សារលិខិតដ៏មហិមាដែលយើងយកទៅចែករំលែកនឹងពិភពលោក គឺជាដំណឹងល្អរបស់ព្រះអម្ចាស់ និង ព្រះអង្គសង្គ្រោះនៃយើងដែលត្រូវបាន ស្ដារជាថ្មីឡើងវិញមកលើផែនដី ។ សាសនាចក្ររបស់ទ្រង់មាននៅលើផែនដី សារជាថ្មីទៀត ព្រមជាមួយនឹងអំណាច និង សិរីល្អនៃបព្វជិតភាពដ៏បរិសុទ្ធ ។

ចំពោះអស់អ្នកដែលត្រូវបានតែងតាំង គឺត្រូវបានផ្ដល់អំណាចដើម្បីធ្វើ កិច្ចការជំនួសទ្រង់ ក្នុងនាមជាភ្នាក់ងាររបស់ទ្រង់ ដើម្បីនាំគោលលទ្ធិ ពិធីបរិសុទ្ធ គោលការណ៍ និងអំណាច ដើម្បីចងទុកនៅលើផែនដី ក៏ដូចជា នៅលើស្ថានសួគ៌ដែរ ។ នេះគឺជាសាសនាចក្ររបស់ព្រះអង្គសង្គ្រោះ ។ ហើយទ្រង់ដឹកនាំកិច្ចការនៃសាសនាចក្ររបស់ទ្រង់ តាមរយៈពួកព្យាការីដ៏ ជម្រើសរបស់ទ្រង់ ។ ពួកព្យាការីបង្រៀនដំណឹងល្អដល់អ្នកដទៃ ហើយថ្លែង ទីបន្ទាល់អំពីព្រះយេស៊ូវថាជាព្រះអង្គសង្គ្រោះ និង ព្រះប្រោសលោះរបស់យើង ។ យុគសម័យនេះ គឺជាគ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ ដែលត្រូវ បាននិយាយដោយពួកព្យាការីចាប់តាំងពីដំបូងមក ។ វាគឺជាពេលនៃការ បំពេញនៅរាល់អ្វី ដែលបានលើកឡើងដោយពួកព្យាការីរបស់ព្រះអម្ចាស់ ហើយ បានកត់ត្រានៅក្នុងព្រះគម្ពីរបរិសុទ្ធ ។ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួក បរិសុទ្ធថ្ងៃចុងក្រោយពុំមែនជាព្រះវិហារមួយថ្មីនោះទេ ប៉ុន្តែជាសាសនាចក្រ ដែលបានស្ដារឡើងវិញដល់ពិភពលោកនៅជំនាន់នេះ ។

អ្នករាល់គ្នាជាជំនាន់ដែលព្រះអម្ចាស់បានរក្សាទុកសម្រាប់ថ្ងៃនេះ ។ អ្នកបាន ងើបចេញមកពីទឹក នៃ ពិធីបុណ្យជ្រមុជទឹកជាមួយនឹងសេចក្ដីសញ្ញា និងការ សន្យាមួយចំពោះព្រះអម្ចាស់របស់អ្នក ដើម្បីធ្វើជាតំណាងរបស់ទ្រង់ ក្នុងការជួយ ដល់មនុស្សឲ្យបោះបង់ផ្លូវខាងលោកិយរបស់ពួកគេ ហើយត្រឡប់មករកពរជ័យ ទាំងឡាយដែលបានសន្យាសម្រាប់យើង បើសិនជាយើងនឹងធ្វើតាមទ្រង់ ហើយរស់នៅតាមដំណឹងល្អរបស់ទ្រង់ ។ អ្នកអាចជួយដល់កូនចៅរបស់ ព្រះវរបិតាសួគ៌ឲ្យត្រឡប់មករកសេចក្ដីជំនឿជាពួកគ្រីស្ទានរបស់គេវិញ ហើយអភិវឌ្ឍសេចក្ដីជំនឿទៅលើទ្រង់ និងត្រឡប់ទៅផ្លូវរបស់ទ្រង់វិញ ។

## អ្វីដែលយើងអាចធ្វើ

អ្នកអាចសួរថា «តើខ្ញុំអាចធ្វើអ្វីខ្លះ ? » កាលពីប៉ុន្មានខែកន្លងទៅ ប្រធាន ស្ដេករបស់យើងបាននិយាយ នៅក្នុងការប្រជុំសាក្រាម៉ង់ដោយផ្ដល់ជាយោបល់ នូវរឿងបួនយ៉ាងដែលយើងអាចធ្វើ ដើម្បីនាំអ្នកដទៃឲ្យត្រឡប់មករកសេចក្ដីជំនឿ ជាពួកគ្រីស្ទានរបស់ពួកគេវិញ ៖

*1. អធិស្ឋានរាល់ថ្ងៃ ។*

ប្រធាន ថូម៉ាស អេស ម៉នសុន បានថ្លែងថា ៖ « អស់អ្នកទាំងឡាយណាដែល ស្ដាប់ឮពាក្យខ្ញុំ ដែលកំពុងតែពុះពារនឹងឧបសគ្គ និងបញ្ហាលំបាកទោះតូចឬ ធំក្ដី ការអធិស្ឋានគឺជាអ្នកផ្ដល់នូវកម្លាំងខាងវិញ្ញាណ ។ . . .ការអធិស្ឋានគឺ ជាមធ្យោបាយដែលយើងនិយាយទៅកាន់ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ របស់យើងដែលស្រឡាញ់យើង ។ សូមទូលប្រាប់ ទ្រង់នៅក្នុងការអធិស្ឋាន ហើយស្ដាប់ចម្លើយ ។ អព្ភូតហេតុជាច្រើន កើតមានតាមរយៈការអធិស្ឋាន ។ . . . សូមចងចាំដើម្បីអធិស្ឋានជាញឹកញាប់ » ។[3]

សូមធ្វើការអធិស្ឋាន ជារៀងរាល់ថ្ងៃ រួចហើយជួយអ្នកដទៃឲ្យត្រឡប់មករក សេចក្ដីជំនឿរបស់ពួកគេជាពួកគ្រីស្ទាន តាមរយៈការលើកទឹកចិត្តឲ្យពួកគេលត់ ជង្គង់ចុះហើយអធិស្ឋានដល់ព្រះ ។

*2. សូមសិក្សាព្រះគម្ពីរជាប្រចាំថ្ងៃ ។*

តើមានទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទណា ខ្លាំងក្លាជាងទីបន្ទាល់ទាំងឡាយ ដែលយើងរកឃើញមាននៅក្នុងព្រះគម្ពីរមរមនឬទេ ? ក្នុងចំណោមជំពូកចំនួន 239 មានជំពូកចំនួន 233 បានប្រាប់អំពីព្រះអង្គសង្គ្រោះ ។[4] តើវាមិនអស្ចារ្យទេឬអី ?

ធ្វើយ៉ាងណា សិក្សាព្រះគម្ពីរផ្ទាល់ខ្លួនជារៀងរាល់ថ្ងៃ ។ រួចហើយជួយអ្នកដទៃ ឲ្យត្រឡប់មករកសេចក្ដីជំនឿជាពួកគ្រីស្ទានរបស់គេ តាមរយៈការលើកទឹកចិត្ត ឲ្យពួកគេសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃ ។

*3. ចូរបន្តមានភាពសក្តិសមជានិច្ច ដើម្បីចូលរួមក្នុងព្រះវិហារបរិសុទ្ធ ។*

អ្នករាល់គ្នាខ្លះបានទៅព្រះវិហារបរិសុទ្ធរួចហើយ ហើយអ្នករាល់ខ្លះទៀត មិនទាន់បានទៅនៅឡើយ។ វាជាការចាំបាច់ណាស់ ដើម្បីយល់នូវលក្ខណៈ សម្បត្តិដែលតម្រូវឲ្យមានដើម្បីទទួលបានប័ណ្ណចូលព្រះវិហារបរិសុទ្ធ ។ យើងបានយល់យ៉ាងច្បាស់អំពីដំណើរការ ដែលយើងទៅជួបនឹងចៅក្រម នៃអ៊ីស្រាអែលរបស់យើង ហើយបញ្ជាក់ប្រាប់ពួកគេអំពីភាពស័ក្ដិសមរបស់យើង ក្នុងការកាន់ប័ណ្ណចូលព្រះវិហារបរិសុទ្ធដែលមានសុពលភាព រួចហើយរស់នៅ តាមបទដ្ឋានទាំងឡាយដែលតម្រូវឲ្យមានសម្រាប់ការកាន់ប័ណ្ណនោះ ។

រស់នៅតាមរបៀបណាមួយ ដែលនឹងបង្ហាញនូវគំរូសុចរិតរបស់អ្នក អំពីរបៀបដើម្បីរស់នៅដោយភាពស័ក្ដិសម ក្នុងការទទួលបានពរជ័យនៃព្រះវិហារ បរិសុទ្ធ ។

*4. ផ្ដល់ការបម្រើរាល់ថ្ងៃ ។*

សូមចងចាំនូវពាក្យរបស់ស្ដេចបេនយ៉ាមីន៖ «ហើយមើលចុះ យើងសុំប្រាប់អ្នក នូវការណ៍ទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នាអាចមានប្រាជ្ញា ដើម្បីឲ្យអ្នករាល់គ្នាអាច បានដឹងថា កាលណាអ្នករាល់គ្នានៅក្នុងការបម្រើដល់មនុស្សទូទៅ នោះអ្នករាល់ គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ » (ម៉ូសាយ 2:17) ។ ព្រះអម្ចាស់ពិត ជាឆ្លើយតបការអធិស្ឋានរបស់យើង តាមរយៈការបម្រើដែលយើង ផ្ដល់ដល់អ្នកដទៃ ។

ធ្វើជាគំរូនៃការបម្រើដូចជាព្រះគ្រីស្ទ ហើយជួយអ្នកដទៃឲ្យត្រឡប់មករកសេចក្ដី ជំនឿជាពួកគ្រីស្ទានរបស់ពួកគេវិញ តាមរយៈការលើកទឹកចិត្តពួកគេឲ្យបម្រើដល់ អ្នកដទៃ ។

## ក្រោកឈរឡើងចំពោះអាកប្បកិរិយាថ្មីនៃការប្ដេជ្ញាចិត្ត

ខ្ញុំដឹងថា ព្រះមានព្រះជន្មរស់នៅ ។ ខ្ញុំដឹងថា យើងទាំងអស់គ្នា គឺជាកូនចៅរបស់ទ្រង់ ហើយទ្រង់ស្រឡាញ់យើង ។ ខ្ញុំដឹងថា ទ្រង់បាន

រូបភាព KING BENJAMIN'S ADDRESS ដោយ ហ្គេរី ខាប់



បញ្ជូនព្រះរាជបុត្រាទ្រង់មកកាន់ពិភពលោកនេះ ដើម្បីធ្វើពលិកម្មដ៏ធួនសម្រាប់មនុស្សលោក ។ ខ្ញុំដឹងថាជនដែលឱបក្រសោបដំណឹងល្អរបស់ទ្រង់ ហើយធ្វើតាមទ្រង់ នឹងរីករាយនូវជីវិតដ៏នៅអស់កល្បជានិច្ច ជាអំណោយទានដ៏ធំជាងគេបំផុតរបស់ព្រះ ។ ខ្ញុំដឹងថាព្រះអង្គសង្គ្រោះបានដឹកនាំការស្ដារឡើងវិញនៃដំណឹងល្អនៅលើផែនដី តាមរយៈកិច្ចការបម្រើរបស់ព្យាការីយ៉ូសែប ស្ម៊ីធ ។ ខ្ញុំដឹងថាសេចក្ដីអំណរ និងសុភមង្គលយូរអង្វែងដែលយើងនឹងរកឃើញនៅក្នុងបទពិសោធន៍នៃជីវិតរមែងស្លាប់នេះ នឹងកើតមានតែតាមរយៈការធ្វើតាមព្រះអង្គសង្គ្រោះគោរពតាមច្បាប់របស់ទ្រង់ និងរក្សាបទបញ្ញត្តិរបស់ទ្រង់ប៉ុណ្ណោះ ។

ខ្ញុំសូមអញ្ជើញឲ្យអ្នកក្រោកឡើងឆ្ពោះទៅរកអាកប្បកិរិយានៃការតាំងចិត្តថ្មីមួយ ។ ខ្ញុំអញ្ជើញអ្នកឲ្យជួយដល់កូនចៅរបស់ព្រះឲ្យត្រឡប់មករកសេចក្ដីជំនឿជាពួកគ្រីស្ទានរបស់ពួកគេវិញ និងមករកគ្រឹះសាសនាដ៏រឹងមាំដែលសំខាន់បំផុតសម្រាប់សេចក្ដីសុខសាន្តនៃគំនិត និងសុភមង្គលពិតនៅក្នុងគ្រានៃការសាកល្បងនៃជីវិតរមែងស្លាប់នេះ ។

សូមឲ្យព្រះអម្ចាស់ប្រទានពរដល់អ្នក នូវភាពក្លាហានភាពអង់អាច និងបំណងប្រាថ្នាដើម្បីស្ដារសេចក្ដីជំនឿឡើងវិញតាមរយៈដំណឹងល្អរបស់ព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់យើង ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៅឯការប្រជុំពិសេសសម្រាប់ប្រពន្ធ័អប់រំសាសនាចក្រ « We Were the Greatest Generation » ដែលធ្វើឡើងនៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់នៅថ្ងៃទី 6 ខែ មិនា ឆ្នាំ 2011 ។ សម្រាប់សុន្ទរកថាទាំងស្រុង សូមចូលទៅ cesdevotionals.lds.org ។*

**កំណត់ចំណាំ**

1. ប៉ូប ប៊ែណេឌីកទីដប់ប្រាំមួយ នៅក្នុង Noelle Knox « Religion Takes a Back Seat in Western Europe, » *USA Today,* ថ្ងៃទី 10 ខែ សីហា ឆ្នាំ 2005, usatoday.com/news/world/2005-08-10-europe-religion-cover_x.htm ។
2. ដេវីឌ អូ ម៉ាក់ឃេ *Gospel Ideals,* (ឆ្នាំ 1953) ទំព័រ 5 ការគូសបញ្ជាក់នៅក្នុងច្បាប់ដើម ។
3. ថូម៉ាស អេស ម៉នសុន « Be Your Best Self, » *Liahona,* ខែ ឧសភា ឆ្នាំ 2009 ទំព័រ 68, 69 ។
4. សូមមើល រ៉ូប៊ឺត ជេ ម៉ាថាយ នៅក្នុង *The Book of Mormon: The Keystone Scripture,* រៀបរៀងដោយ ផល អ័រ ឈីសមិន និង អ្នកដទៃទៀត (ឆ្នាំ 1988) ទំព័រ 33 ។

***តើមានទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទណាខ្លាំងក្លាជាងទីបន្ទាល់ទាំងឡាយដែលយើងរកឃើញមាននៅក្នុងព្រះគម្ពីរមរមនឬទេ ? ក្នុងចំណោមជំពូកចំនួន 239 មាន 233 ជំពូកបានប្រាប់អំពីព្រះអង្គសង្គ្រោះ ។***








# សាសនាចក្រ នៅក្នុង ប្រទេសស៊ុយអែត

## ការរីកចម្រើន ការធ្វើ អន្តោរប្រវេសន៍ និង ភាពរឹងមាំ

*សាសនាចក្រនៅក្នុងប្រទេសស៊ុយអែតបានទ្រាំទ្រនឹងការធ្វើ អន្តោប្រវេសន៍របស់សមាជិកដ៏ស្មោះត្រង់ជាច្រើន របាយការណ៍រិះគន់ ពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយ និង កំណើននៃមជ្ឈដ្ឋានលោកិយ ប៉ុន្តែ ព្រះអម្ចាស់កំពុងពន្លឿនកិច្ចការរបស់ទ្រង់នៅក្នុងដែនដីដ៏ជម្រើសនេះ ។*

**ដោយ អឹងហ្គឺរ ហុគឡាន់ដ៏**

ក្នុងឆ្នាំ 1849 ប្រធាន ព្រិកហាំ យ៉ង់បានហៅពួកបុរសមួយចំនួនតូច ធ្វើដំណើរទៅកាន់ផ្នែកផ្សេងៗគ្នានៃពិភពលោកដើម្បីផ្សាយដំណឹងល្អ ។ មានអតីតអ្នកនេសាទសាសន៍ស៊ុយអែតម្នាក់ ឈ្មោះ ចន ហ្វ័រស្គ្រិន ដែលបានចូលរួមនឹងសាសនាចក្រនៅរដ្ឋម៉ាស្សាឈូសេត ស.រ.អា. ហើយបានធ្វើដំណើរទៅជ្រលងភ្នំសលត៍ លេក បានសូមឲ្យប្រធានយ៉ង់ឲ្យបញ្ជូនគាត់ទៅប្រទេសស៊ុយអែតធ្វើជាអ្នកផ្សព្វផ្សាយសាសនា ។ គាត់ត្រូវបានហៅឲ្យបម្រើ ហើយបានទៅដល់ប្រទេសស៊ុយអែតនៅខែ មិថុនា ឆ្នាំ 1850 ។

ដំបូង អែលឌើរ ហ្វ័រស្គ្រិន បានទៅលេងនឹងប្អូនៗរបស់គាត់នៅទីក្រុង ជេវលើ ។ ប្អូនប្រុសគាត់ឈ្មោះ ភីធើរ បានឈឺ ហើយពួកវេជ្ជបណ្ឌិតបាននិយាយថា ពួកគេមិនអាចជួយគាត់បានទេ ។ អែលឌើរ ហ្វ័រស្គ្រិន បានពន្យល់ពីគោលបំណងនៃបេសកកម្មរបស់គាត់ទៅដល់ប្អូនៗគាត់ រួចបានលាបប្រេង ហើយប្រសិទ្ធពរដល់ភីធើរ ដែលត្រូវបានធ្វើឲ្យមានសុខភាពពេញលេញឡើងវិញ ។ នៅថ្ងៃទី 19 ខែ កក្កដា ឆ្នាំ 1850 អែលឌើរ ហ្វ័រស្គ្រិន បានជ្រមុជទឹកឲ្យប្អូនប្រុសគាត់ ដែលបានក្លាយជាអ្នកប្រែចិត្តជឿដំបូងគេនៅប្រទេសស៊ុយអែត ។

ប្អូនស្រីរបស់អែលឌើរហ្វ័រស្គ្រិនម្នាក់ ឈ្មោះ អេរីកា មានបទពិសោធន៍មួយដែលគួរឲ្យចាប់អារម្មណ៍ដែលបានរៀបចំនាង និង ភីធើរទទួលដំណឹងល្អ ។ ប៉ុន្មានខែពីមុនបងប្រុសនាងបានមកដល់ នាងបានទៅព្រះវិហារតាមទម្លាប់របស់នាង ។ នៅពេលកំពុងច្រៀងទំនុកតម្កើង នាងបានឃើញមនុស្សម្នាក់ឈរនៅពីមុខនាង ហើយពោលថា « នៅថ្ងៃទីប្រាំ ខែ កក្កដា នឹងមានបុរសម្នាក់មករកអ្នកជាមួយនឹងព្រះគម្ពីរបីក្បាល ហើយអស់អ្នកដែលជឿលើរឿងដែលបានសរសេរនៅក្នុងព្រះគម្ពីរទាំងនោះនឹងត្រូវបានសង្គ្រោះ » ។ កាលបងប្រុសនាងបានមកដល់ដោយមានព្រះគម្ពីរប៊ីប ព្រះគម្ពីរមរមន និង ព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា នាងបានជឿលើទីបន្ទាល់គាត់ដោយគ្មានការសង្ស័យ ។[1]

ជាអកុសល អែលឌើរ ហ្វ័រស្គ្រិនត្រូវតែចាកចេញពីប្រទេសនេះ បីខែក្រោយមក ។ តែពីរបីឆ្នាំប៉ុណ្ណោះ មានពួកអ្នកផ្សព្វផ្សាយសាសនាផ្សេងទៀតត្រូវបានបញ្ជូនទៅប្រទេសស៊ុយអែត ។ ពួកគេបានរកឃើញមនុស្សនៅស្កូណាប៉ែកក្នុងខេត្តស្កេន ដែលដែលព្រមទទួលយកដំណឹងល្អ ។ មានមនុស្សជាច្រើនបានប្រែចិត្តជឿរហូតដល់សាខាដំបូងត្រូវបានរៀបចំឡើងនៅទីនោះក្នុងឆ្នាំ 1853 ដោយមានសមាជិកចំនួន 36 នាក់ ។ ថ្នាក់ដឹកនាំដំបូងនៅស្កេនគឺ ខាល ខាបសិន ត្រូវបានហៅជាប្រធានសាខានៅទីក្រុង ឡេនដ៍ ។ មានសមាជិកប្រមាណជា 100 នាក់បានចូលរួមសន្និសីទដំបូងរបស់សាសនាចក្រនៅកសិដ្ឋានរបស់ខាល ដែលបានធ្វើឡើងនៅពេលយប់ ដើម្បីជៀសវាងពីការបៀតបៀន ។[2]

រូបថតដោយ ម៉ៃខល ឃេលហ៊ីមើរ លើកលែងតែមានកំណត់សម្គាល់ ។ ផ្នែកខាងលើ ៖ រូបថតដោយ PINKBADGER/ISTOCK/THINKSTOCK ។ ផ្នែកខាងក្រោម ៖ រូបថតលោកអេលឌើរ ចាប ប៊ែរស៊ីន ... ផ្នែកខាងក្រោម ៖ រូបថតដោយ ADISA/ISTOCK/THINKSTOCK ។



*សមាជិកនៅវ៉ាស្ទើរ៉ាសបានជួបជុំគ្នាក្នុងផ្ទះនេះនៅឆ្នាំ 1950 ។*

រហូតដល់គាត់បានទទួលមរណភាពក្នុងវ័យ 91 ឆ្នាំ ។ ជាច្រើនអាទិត្យ គាត់បានទៅសាលាប្រជុំ បើកភ្លើង ហើយរង់ចាំសមាជិកផ្សេងៗទៀតមក ។ ជារឿយៗ គ្មាននរណាមកទេ ។ នៅម៉ោង 11:00 ព្រឹក គាត់បានប្រាប់ខ្លួនឯងថា « ព្រះមិនគួររង់ចាំនោះទេ » ។ គាត់បានច្រៀងចម្រៀងមួយបទ អធិស្ឋាន ឡើងថ្លែងសុន្ទរកថាខ្លីមួយ រួចបញ្ចប់ជាមួយចម្រៀង និង ការអធិស្ឋាន ។

កាលគាត់មានឱកាសធ្វើដំណើរទៅស្តុកខុលតាមរថភ្លើង នោះ បងស្រី ម៉ាន់ធើរ បានដើរចែកកូនសៀវភៅអំពីសាសនាចក្រ ។ មរតកនៃសេចក្ដីជំនឿរបស់គាត់បានបន្ត ៖ កូនចៅរបស់គាត់មួយចំនួនបានត្រឡប់មកប្រទេសស៊ុយអែតវិញជាពួកអ្នកផ្សាយសាសនា ។[3]

ពួកអ្នកផ្សាយសាសនាក៏បានទៅតំបន់ ស្មេដដេបាគិន ក្នុងខេត្ត ដាឡាណា ផងដែរ ។ ក្នុងចំណោមគ្រួសារផ្សេងទៀត គ្រួសារជេនសុន បាន ក្លាយជាសមាជិកសាសនាចក្រក្នុងឆ្នាំ 1886 ។ កូនចៅនៃគ្រួសារនោះគឺ រីដ ចនសុន ជាអ្នកផ្សាយសាសនាម្នាក់ដែលបានមកដល់ប្រទេសស៊ុយអែត ក្រោយពីសង្គ្រាមលោកលើកទីពីរ ។ គាត់បានត្រឡប់មកជាច្រើនដង

កាលប្បវត្តិ

*1850 ៖ អ្នកផ្សាយសាសនាដំបូងឈ្មោះ ចន ហ្វ៉ស្រ្គិន មកដល់ប្រទេសស៊ុយអែត។ ពួកអ្នកប្រែចិត្តដំបូងឈ្មោះភីធើរ ► និង អេរីកា ហ្វ៉ស្រ្គិន បានជ្រមុជទឹក*



*1853 ៖ សាខាដំបូង សាខាស្គូណាប៉ែក បានបង្កើតឡើងដោយមានសមាជិក 36 នាក់*

*1854 ៖ សាខាស្តុកខុលបានបង្កើតឡើង*




*◄ 1878 ៖ ព្រះគម្ពីរមរមនបានបកប្រែ ហើយបោះពុម្ពជាភាសាស៊ុយអែត*

*► 1904 ៖ បានដាក់ឈ្មោះតាមអាសយដ្ឋានផ្លូវ ស្វាតេនស៍ង៉ាតាន់ 3 អគារសាសនាចក្រដំបូង បានទិញនៅប្រទេសស៊ុយអែត (បានបង្ហាញនៅទីនេះក្នុងឆ្នាំ 1946)*

## ស្ត្រីនៃសេចក្ដីជំនឿ

ស្ត្រីដែលបានទទួលដំណឹងល្អបានក្លាយជាគ្រឹះនៃភាពរឹងមាំនៅប្រទេសស៊ុយអែត ។ ឧទាហរណ៍មួយគឺប្រ៊ីតា អ៊ុលស្តុតធើរ កើសុន ជាមនុស្សទីមួយដែលទទួលយកដំណឹងល្អនៅតំបន់ វីងហ្គាយើរ ។ ក្នុងឆ្នាំ 1877 ដើម្បីជួយផ្គត់ផ្គង់ដល់គ្រួសារនាង នាងបានធ្វើដំណើរទៅស្តុកខុលដើម្បីលក់គ្រឿងតម្បាញរបស់នាង ។ នៅទីនោះនាងបានជួបនឹងពួកអ្នកផ្សាយសាសនា ហើយបានដឹងថាពួកគេកំពុងបង្រៀនពីសេចក្ដីពិត ហើយបានជ្រមុជទឹកនៅអាយុ 50 ឆ្នាំ ។

នៅទីបំផុត ការប្រែចិត្តជឿរបស់នាង និង ពលិកម្មដ៏ក្លាហាន ដើម្បីលើកកម្ពស់ដល់កិច្ចការរបស់ព្រះអម្ចាស់បានដឹកនាំទៅរកបុណ្យជ្រមុជទឹកកាន់តែច្រើន ហើយសាខាមួយត្រូវបានស្ថាបនាឡើងនៅតំបន់វីងហ្គាយើរ ។ កូនចៅរបស់គាត់នៅតែសកម្មក្នុងសាសនាចក្រ ។ ចៅលួតរបស់បងស្រីកើសុន ឈ្មោះ ឡេឡា គ្រីលបិន បានថ្លែងថា « វាគឺជាការអស្ចារ្យណាស់ដោយមើលឃើញនូវអ្វីដែលបានកើតឡើងនៅក្នុងជំនាន់កូន និង ចៅៗរបស់យើង ។ ឥឡូវនេះ ក្រុមគ្រួសាររបស់យើងមានពួកអ្នកកាន់បព្វជិតភាព និងអ្នកផ្សាយសាសនាមួយចំនួន » ។

ស្ត្រីជាអ្នកត្រួសត្រាយផ្លូវម្នាក់ទៀតគឺ ឡូវីស្សា ម៉ាន់ធើរ រស់នៅក្នុងទីក្រុងអ៊ុបសាឡា ។ គាត់បានក្លាយជាសមាជិកក្នុងឆ្នាំ 1886 ហើយបានស្មោះត្រង់បន្ទាប់ពីបេសកកម្ម—ជាប្រធានបេសកកម្ម អ្នកតំណាងភូមិភាគ និងប្រធានព្រះវិហារបរិសុទ្ធ ។ គ្រួសារជេនសុនក៏បានបង្កើតកវិយាររបស់ព្យាការីផងដែរ គឺសិស្ទើរ ហ្វ្រេនសេស ម៉ុនសុន ។

## ការយកឈ្នះលើការបៀតបៀន

អស់រយៈពេលជាច្រើនទសវត្ស ការបៀតបៀនដល់សមាជិកសាសនាចក្រមានភាពធ្ងន់ធ្ងរ ។ ពួកអ្នកផ្សាយសាសនាជាច្រើនត្រូវបានចាប់ឃុំ រួមមានមីកែល ចនសុន ជាជនជាតិស៊ុយអែត ។ គាត់ត្រូវបានឃាត់ខ្លួននៅឆ្នាំ 1852 ហើយត្រូវបាននាំទៅម៉ាលម៉ូ ចម្ងាយ 770 គ.ម. ទាំងជាប់ច្រវាក់ ជាកន្លែងដែលគាត់ត្រូវបានដាក់នៅក្នុងគុកដ៏ធំ ទុកឲ្យស្រេកឃ្លាន ហើយរងទុក្ខលំបាក ។ មានសង្ឃម្នាក់បានមកជួបគាត់ ហើយរកឃើញថា អែលឌើរចនសុន គឺជាបុរសម្នាក់មានប្រាជ្ញាឈ្លាសវៃដោយមានការអប់រំមួយចំនួន ។ សង្ឃនោះបានប្រកាសថាគាត់ព្រមជួយ ហើយថែមទាំងបានសន្យាឲ្យគាត់រៀនបន្ថែមទៀតផងដែរ—ដោយដាក់លក្ខខណ្ឌថា គាត់ត្រូវចូលរួមនឹងសាសនាលូធើរិន ហើយបដិសេធ « សាសនាមរមន » ។ អែលឌើរ ចនសុន មិនបានបដិសេធសេចក្ដីជំនឿរបស់គាត់ទេ ដូច្នេះគាត់ត្រូវបានគេនិរទេស ។[4]

អ្នកផ្សព្វផ្សាយសាសនាដ៏ស្មោះត្រង់ម្នាក់ទៀតគឺ ខាល អេ ខាលឃ្វីស្ត៍

រូបថតនៃសាលាប្រជុំសាខាវ៉ាស្ទើរ៉ាស និង ពួកអ្នកផ្សាយសាសនា ទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ; រូបថតរបស់ភីធើរ ហ្វ៉ស្រ្គិន ទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការពីស៊ូហ្សិន អ៊ីស្ទិន ប្លាក

កើតនៅក្បែររ៉ាណើរស្បើក ក្នុងឆ្នាំ 1857 ។ ក្នុងវ័យ 17 ឆ្នាំគាត់មានបំណងយ៉ាងខ្លាំងដើម្បីផ្សាយដំណឹងល្អ ហើយត្រូវបានហៅឲ្យចែកចាយអត្ថបទប្រកាសរបស់សាសនាចក្រនៅជុំវិញ ចុនកុភីង ។ គាត់ក្រីក្រ ដូច្នេះសមាជិកក្នុងសាខាគាត់ រួមមានស្ត្រីមេម៉ាយប្រាំពីរនាក់ និង កូនៗពួកគេ បានទិញអាវធំ និង ស្បែកជើងឲ្យគាត់ ។ កាលរដូវរងារបានមកដល់ ខាល គ្មានអាវរងារទេ ប៉ុន្តែគាត់ត្រូវបានសមាជិកមួយចំនួនអនុញ្ញាតឲ្យខ្ចីពីរទៅបីម៉ោងជារៀងរាល់ថ្ងៃ នៅពេលពួកគេមិនត្រូវការវា ។[5]

ក្រោយមក ខាល បានធ្វើអន្តោប្រវេសន៍ទៅរដ្ឋយូថាហ៍ ហើយរៀបការនឹង ហ៊ុលដា អុស្ទើរគ្រិន ជាជនអន្តោប្រវេសន៍ជនជនស៊ុយអែតម្នាក់ ។ គាត់បានត្រឡប់ទៅប្រទេសស៊ុយអែតវិញជាច្រើនដង នៅក្នុងបេសកកម្ម របស់គាត់ រួមទាំងជាប្រធានបេសកកម្មនៃបេសកកម្មស្កេនឌីណាវៀនផងដែរ ។ ភាគច្រើននៃបេសកកម្មចុងក្រោយរបស់គាត់ត្រូវបានចំណាយពេលទៅលើការកែតម្រូវរបាយការណ៍ក្លែងបន្លំ ដែលបានចេញផ្សាយអំពីសាសនាចក្រដោយបព្វជិត ភី អ៊ី អាស្លេវ ជាគ្រូគង្វាលម្នាក់ដែលបានរស់នៅក្នុងទីក្រុងសលត៍ លេក ហើយត្រូវបានជួលឲ្យផ្សព្វផ្សាយបញ្ចូលមនោគមប្រឆាំងនឹងពួកមរមននៅក្នុងប្រទេសស៊ុយអែត ។ ឧទាហរណ៍ដូចជា ក្នុងឆ្នាំ 1912 អាស្លេវ បានសរសេរអត្ថបទមួយនៅក្នុងសារព័ត៌មាន *Svenska Dagbladet* ដោយបានប្រកាសថាបងប្រុស ខាលឃ្វីស្ត៍ គឺជាបុរសដែលមានប្រពន្ធច្រើន ។[6] កិច្ចខិតខំរបស់ខាលរួមមានទាំងការជួបជាមួយនឹងស្ដេច ហ្គុស្តាហ្វ ទីប្រាំ និងការឆ្លើយបដិសេធទៅនឹងការប្រកាសរបស់អាស្លេវនៅក្នុងការប្រជុំជាសាធារណៈ ។[7]

ដើម្បីជួយតតាំងនឹងការឃោសនារបស់អាស្លេវ មានសមាជិកក្នុងមូលដ្ឋានម្នាក់ឈ្មោះ អ៊ីណា ចូហាន់សុន បានផ្ដល់ការទ្បើងនិយាយការពារសាសនាចក្រ ។ គាត់បានផ្ដើមកិច្ចដំណើរការតាមនិតិវិធីច្បាប់ ដោយសារអាស្លេវ ក៏បានថ្លែងផងដែរថា ការិយាល័យបេសកកម្មរបស់សាសនាចក្រ « គឺជាជំនួញទាសករពួកស្បែក-ស » ជាពាក្យបណ្ដឹងបង្ខូចឈ្មោះមួយ ។[8] បងប្រុសចូហាន់សុនបានក្លាយជាអ្នកដឹកនាំដ៏សំខាន់ ហើយដ៏មានប្រសិទ្ធភាពម្នាក់សម្រាប់សាសនាចក្រនៅប្រទេសស៊ុយអែតរួមទាំងជាប្រធានសាខានៅស្តុកខុលទៀតផង ។[9]

ថ្វីបើមានការបៀតបៀននៅក្នុងសម័យនេះក្តី ក៏មានមនុស្សជាច្រើនបានប្រែចិត្តជឿដល់ដំណឹងល្អដែរ ។ ឆ្នាំដ៏ជោគជ័យបំផុតរហូតមកដល់ពេលនេះគឺឆ្នាំ 1862 ពេលដែលមានមនុស្ស 640 នាក់បានទទួលបុណ្យជ្រមុជទឹក ហើយត្រូវបានបញ្ជាក់ ។ ប៉ុន្តែមិនយូរប៉ុន្មាន ពួកអ្នកប្រែចិត្តជឿភាគច្រើនបានធ្វើដំណើរទៅរដ្ឋយូថាហ៍ ។ នៅពេលនោះ ថ្នាក់ដឹកនាំបានលើកទឹកចិត្តឲ្យមានការធ្វើអន្តោប្រវេសន៍នេះ ដើម្បីពង្រឹងសាសនាចក្រនៅទីនោះ ។ លទ្ធផលនៃការធ្វើអន្តោប្រវេសន៍នោះគឺអាចមើលឃើញនៅសព្វថ្ងៃនេះ ៖ ប្រហែលជាពាក់កណ្ដាលនៃប្រជាជនក្នុងរដ្ឋយូថាហ៍មានដូនតាមកពីស្កេនឌីណាវៀន ។

ប៉ុន្តែក្នុងឆ្នាំ 1910 ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានទៅទស្សនកិច្ចនៅស្តុកខុល ហើយបានលើកទឹកចិត្តសមាជិកឲ្យរស់នៅ ហើយស្ថាបនាសាសនាចក្រនៅប្រទេសស៊ុយអែត ។

**សាសនាចក្រក្រោយពីសង្គ្រាមលោកលើកទីពីរ**

កាលសង្គ្រាមលោកលើកទីពីរបានផ្ទុះឡើង ពួកអ្នកផ្សាយសាសនាជនជាតិអាមេរិកទាំងអស់ត្រូវតែត្រឡប់មកផ្ទះវិញ ។ បន្ទាប់មក បុរសអ្នកស្រុកសាសន៍ស៊ុយអែតត្រូវបានសូមឲ្យបម្រើជាអ្នកផ្សាយសាសនា ។ ស៊ី ហ្វ្រីតស្ស៍ ចូហាន់សុន ដែលបានចូលក្នុងសាសនាចក្រនៅឆ្នាំ 1931 ត្រូវបានហៅឲ្យធ្វើជាប្រធានបេសកកម្មថ្មី ។ មួយឆ្នាំមុននឹងសង្គ្រាមនោះ គាត់បានលក់ហាងអាហាររបស់គាត់ ហើយក្លាយជាអ្នកផ្សាយសាសនាជាមួយនឹងភរិយាគាត់ ព្រមទាំងកូនបីនាក់ ។ នៅពេលសង្គ្រាមបានបញ្ចប់ទៅ ប្រធាន ចូហាន់សុន និង ពួកអ្នកផ្សាយសាសនាប្រាំពីរនាក់មកពីប្រទេសស៊ុយអែតត្រូវបានហៅ ឲ្យបើកកិច្ចការផ្សព្វផ្សាយសាសនាឡើងវិញនៅប្រទេសហ្វាំងឡង់ ដែលបានបិទដោយសារសង្គ្រាម ។

នៅពេលអ្នកផ្សាយសាសនាអាមេរិកបានត្រឡប់មកប្រទេសស៊ុយអែត ក្នុងឆ្នាំ 1946 ពួកគេបានបើកថ្នាក់ភាសាអង់គ្លេសជាផ្នែកមួយនៃកិច្ចការផ្សព្វផ្សាយសាសនារបស់ពួកគេ ហើយសិស្សរបស់ពួកគេជាច្រើនបានក្លាយជាសមាជិកសាសនាចក្រ ។ ប៉ុន្តែការរីកចម្រើននោះមិនបានយូរទេ ដោយសារមានសមាជិកស៊ុយអែតជាច្រើនបានធ្វើអន្តោប្រវេសន៍ទៅរដ្ឋយូថាហ៍ ។ ដោយភ័យខ្លាចចំពោះមារសត្រូវពីមុនរបស់ពួកគេ ហើយដោយទទួលការលើកទឹកចិត្តពីប្រធានបេសកកម្ម និងឱកាសដើម្បីទទួលបានពិធីបរិសុទ្ធទាំងឡាយនៅក្នុងព្រះវិហារបរិសុទ្ធ បានជំរុញឲ្យសមាជិកសកម្មចំនួន 250 នាក់ ចាកចេញពីប្រទេសស៊ុយអែតនៅចន្លោះឆ្នាំ 1948 និង 1950 ។

ក្នុងចំណោមសមាជិកទាំងនោះមានគ្រួសារមួយគឺអូស្ការ និង អាល់ប៊ើរទីណា អាន់ឌើរសិន ដែលបានក្លាយជាសមាជិកសាសនាចក្រក្នុងឆ្នាំ 1915 ។



*► 1905 ៖ បេសកកម្មស៊ុយអែតបានរៀបចំឡើង*



*1914 ៖ សមាជិកសាភាស៊ុយអែតបានបោះឆ្នោតប្រឆាំងសំណើមួយដើម្បីបណ្ដេញ « ភ្នាក់ងារមរមន » ចេញពីប្រទេស ។*

*1926 ៖ សាសនាចក្រទទួលការអនុញ្ញាតស្របច្បាប់ដើម្បីធ្វើការបញ្ចុះសពដល់សមាជិកខ្លួន*

*1952 ៖ ច្បាប់ថ្មីសម្រាប់ធានាសេរីភាពព្រះវិហារទាំងអស់ដែលមិនមែនជារបស់រដ្ឋ ។ សាសានចក្រទទួលការអនុញ្ញាតស្របច្បាប់ដើម្បីរៀបការឲ្យសមាជិកខ្លួន ។*







ក្រោយពីសង្គ្រាមលោកលើកទីពីរ អូស្ការ អាល់ប៊ើរទីណា និង កូនប្រាំពីរនាក់របស់ពួកគេដែលបានរៀបការនឹងសមាជិកសាសនាចក្រ បានសម្រេចចិត្តដ៏ពិបាកដើម្បីលក់ទ្រព្យសម្បត្តិរបស់ពួកគេ ហើយ « ធ្វើដំណើរទៅទីក្រុងស៊ីយ៉ូន » ។ ពីឆ្នាំ 1949 រហូតដល់ 1950 មានសមាជិកគ្រួសារអាន់ឌើរសិនចំនួន 29 នាក់ បានចាកចេញពីប្រទេសស៊ុយអែត ។ អូស្ការ និង អាល់ប៊ើរតា បានចាកចោលផ្ទះសម្បែង កូនបីនាក់ និង ចៅបួននាក់របស់ខ្លួន ហើយមិនបានឃើញពួកគេម្ដងទៀតឡើយ ។ ពួកគេបានទៅដល់ទីក្រុងវាលខ្សាច់មួយ ដែលមានមនុស្សនិយាយភាសាដែលពួកគេមិនយល់ ។ ប៉ុន្តែចំពោះសមាជិកដ៏ស្មោះត្រង់ទាំងនេះ ការបាននៅក្បែរព្រះវិហារបរិសុទ្ធគឺជារឿងសំខាន់ជាងអ្វីៗផ្សេងទៀត ។

ចាប់តាំងពីពេលនោះមក សមាជិកគ្រួសារអាន់ឌើរសិនបានបម្រើជាអ្នកផ្សាយសាសនា និង ជាថ្នាក់ដឹកនាំសាសនាចក្រនៅជុំវិញពិភពលោក រួមទាំងជាប្រធានតំបន់នៅប្រទេសអាហ្វ្រិក និង ជាប្រធានព្រះវិហារបរិសុទ្ធនៅប្រទេសស៊ុយអែតផងដែរ ។

ប៉ុន្តែសមាជិកសាសនាចក្រដទៃទៀតបានសម្រេចចិត្តរស់ នៅក្នុងប្រទេសស៊ុយអែត ហើយបានក្លាយជាថ្នាក់ដឹកនាំ ។ ដូចជា បូ វេនណើរឡុន ជាឪពុកវ័យក្មេងម្នាក់ដែលបានជ្រមុជទឹកក្នុងឆ្នាំ 1949 ។ គាត់បានក្លាយជាអ្នកដឹកនាំដ៏សំខាន់មួយរូបរបស់សាសនាចក្រក្នុងប្រទេសស៊ុយអែត ដោយបម្រើជាប្រធានបេសកកម្ម អ្នកតំណាងភូមិភាគ និង ប្រធានព្រះវិហារបរិសុទ្ធ ។

**ពរជ័យនៃព្រះវិហារបរិសុទ្ធក្នុងប្រទេសស៊ុយអែត**

ការធ្វើអន្តោប្រវេសន៍ត្រូវបានបញ្ឈប់នៅពេលមានព្រះវិហារបរិសុទ្ធត្រូវបានឧទ្ទិសឆ្លងនៅប្រទេសស្វ៊ីសក្នុងឆ្នាំ 1955 ។ អស់រយៈពេល 30 ឆ្នាំដែលសមាជិកស៊ុយអែតបានធ្វើដំណើររយៈពេលជាច្រើនថ្ងៃទៅកាន់ទីនោះតាមរថភ្លើង តាមរថយន្តក្រុង តាមរថយន្ត និងតាមយន្តហោះទៀតផង— ពេលខ្លះពីរទៅបីដងក្នុងមួយឆ្នាំ ។

សមាជិកទាំងនោះមានសេចក្ដីអំណរយ៉ាងខ្លាំង នៅពេលព្រះវិហារបរិសុទ្ធត្រូវបានសាងសង់នៅស្តុកខុល ហើយបានឧទ្ទិសឆ្លងក្នុងឆ្នាំ 1985 ។ ប៊ើរិត វេនណើរហូម ជាសមាជិកម្នាក់ក្នុងវួដវ៉ាស្ទើរហានីង បានពិពណ៌នាពីការឧទ្ទិសឆ្លងនោះថា ជា « បទពិសោធន៍មួយដែលទន្ទឹងរង់ចាំមកជាយូរ ហើយអស្ចារ្យ ។ អ្វីដែលខ្ញុំចងចាំបំផុតនោះ គឺពេលយើងទាំងអស់គ្រវីកូនកន្សែងដៃពណ៌-សរបស់យើង ហើយស្រែកឡើងថា ‹ ហូសាណា ! ›»

ជម្រើសនៃទីតាំងព្រះវិហារបរិសុទ្ធបង្ហាញពីព្រះហស្តរបស់ព្រះអម្ចាស់នៅក្នុងដំណើរការនេះ ។ បន្ទាប់ពីមានការពិភាក្សាជាច្រើនជាមួយនឹងសាលាក្រុងមួយចំនួននៅក្នុងតំបន់ស្តុកខុល ទីតាំងសមរម្យពីរត្រូវបានរកឃើញ ។

**សាសនាចក្រក្នុងប្រទេសស៊ុយអែត**
បេសកកម្ម ៖ 1
ស្តេក ៖ 4
មណ្ឌល ៖ 1
វួដ ៖ 24
សាខា ៖ 16
សមាជិក ៖ 9,463 នាក់

*1953 ៖ សមាជិកដំបូងជាស្វាមីនិងភរិយា ប៊េងត៍-អាន ម៉ាន់ហាំម៉ា និង ឃើរស្ទីន ស្តុគ បានរៀបការឲ្យដោយប្រធានបេសកកម្ម ឃ្លែរេនស៍ អេហ្វ ចនសុន*



*◄ 1955 ៖ សមាជិកស៊ុយអែតក្រុមដំបូងបានធ្វើដំណើរទៅព្រះវិហារបរិសុទ្ធនៅប៊ឺន ប្រទេសស្វ៊ីស*

*1965 ៖ សាលាប្រជុំដំបូងបានសង់ដោយសាសនាចក្រត្រូវបានឧទ្ទិសឆ្លងក្នុងហ្គូបបាន់ជេន ស្តុកខុល*









*ក្រុមចម្រៀងរោងឧបោសថម៉រមនបានសម្តែងនៅក្នុងមហោស្រពតន្ត្រីស្តុកខុល ក្នុងឆ្នាំ 1982 ។*

គណៈកម្មាការរបស់ថ្នាក់ដឹកនាំសាសនាចក្រក្នុងមូលដ្ឋានបានផ្ដល់ជាយោបល់អំពីទីតាំងមួយ ប៉ុន្តែប្រធានសាសនាចក្របានសម្រេចថាទីតាំងមួយទៀតគឺប្រសើរជាង ។ ការសម្រេចចិត្តនេះបានបង្ហាញពីការទទួលបានការបំផុសគំនិត ដោយសារទីតាំងមួយទៀតក្រោយមកបានបង្ហាញថាមិនសក្តិសមសម្រាប់ព្រះវិហារបរិសុទ្ធ ។

ទោះជាសាសនាចក្រមានការពិបាកដើម្បីទទួលបានការចាប់អារម្មណ៍ជាវិជ្ជមាននៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់ស៊ុយអែតក្ដី គ្រាមួយវាបានកើតឡើងក្នុងឆ្នាំ 1984 កាលបងប្អូនប្រុសវ័យក្មេងក្នុងគ្រួសារ ហ៊ែរ ឈ្នះការប្រកួតចម្រៀងដ៏ធំបំផុតនៅក្នុងទ្វីបអឺរ៉ុប ។ ការបង្ហាញខ្លួនរបស់ពួកគេតាមទូរទស្សន៍ និងតាមសារព័ត៌មានបានផ្ដល់នូវការផ្សព្វផ្សាយវិជ្ជមានដល់សាសនាចក្រ ហើយមានយុវវ័យជាច្រើនបានចូលរួមនឹងសមាជិកនៅពេលនោះ ។

នៅចុងទសវត្សរ៍ឆ្នាំ 1980 មានសមាជិកម្នាក់ទៀតដែលបាន ទទួលការអធិប្បាយល្អនោះគឺជាឯកអគ្គរដ្ឋទូតអាមេរិកប្រចាំប្រទេសស៊ុយអែតវ័យ 35 ឆ្នាំ ឈ្មោះ គ្រេហ្គ័រី ញ៉ូវែល ដែលជារឿយៗបានឃើញនៅក្នុងខ្ញុំបានបង្ហាញទស្សនៈរបស់ខ្ញុំថា ព្រះអម្ចាស់កំពុងប្រមូលអ៊ីស្រាអែលដោយធ្វើឲ្យពួកគេបែកខ្ញែកចេញពីដែនដីកំណើតរបស់ខ្លួន ។ មានការពន្លឿនដ៏ពិតមួយនៃកិច្ចការនៅជុំវិញយើង ក្នុងដែនដីដ៏ជម្រើសនេះ » ។

សាសនាចក្រក៏រីកចម្រើនក្នុងចំណោមសមាជិកផងដែរ ។ សន្និសីទពហុស្តេកបានទាក់ទាញយុវវ័យជាច្រើនពីប្រទេសជិតខាង ហើយចូលរួមចំណែកដល់ការបង្កើតក្រុមគ្រួសារថ្មី ។ ប្រាក់បុរេប្រទានសម្រាប់កូន និង ការបង់ថ្លៃឈប់សម្រាកសម្រាប់ឪពុកម្ដាយថ្មី ប្រកបដោយសេចក្ដីសប្បុរសពីរដ្ឋាភិបាល បានធ្វើឲ្យស្វាមីភរិយាអាចមានក្រុមគ្រួសារធំល្មមបាន ។

សព្វថ្ងៃនេះ សមាជិកវ័យក្មេងសកម្មភាគច្រើនបានបម្រើបេសកកម្មនៅជុំវិញពិភពលោក ។ មានអ្នកផ្សាយសាសនាដែលបានត្រឡប់មកវិញម្នាក់ឈ្មោះ ដេវីឌ ហាលខេន ជាអ្នកផ្សាយសាសនាដំបូងនៅយេកាទើរីនប៊ឺគ ប្រទេសរុស្ស៊ី សព្វថ្ងៃនេះមានគ្រួសារមួយដ៏ល្អ ដោយមានកូនប្រាំមួយនាក់ ។ គាត់ប្រាប់ពីរបៀបដែលដំណឹងល្អជួយដល់គ្រួសារគាត់ថា ៖ « មានសំឡេងច្រើនណាស់ដែលអាចនាំកូនចៅយើងឲ្យវង្វេង ។ ដំណឹងល្អជួយ

1975 ៖ *ស្តេកដំបូងបានរៀបចំឡើងក្នុងស្តុកខុល ដោយនៅពេលនោះជាអែលឌើរ ថូម៉ាស អេស ម៉នសុន*




◄ 1985 ៖ *ព្រះវិហារបរិសុទ្ធស្តុកខុលបានឧទ្ទិសឆ្លងដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី*

1991 ៖ *សមាជិកដំបូងពីប្រទេសរុស្ស៊ីបានមកព្រះវិហារបរិសុទ្ធស្តុកខុល។ រុស្ស៊ី និង រដ្ឋបាល់ទិកគឺស្ថិតនៅក្នុងមណ្ឌលនៃព្រះវិហារបរិសុទ្ធនេះ*



◄ 1995 ៖ *ស្តេក ខាល ទីដប់ប្រាំមួយ ហ្គាស់ស្តាហ្វ និង ម្ចាស់ក្សត្រី ស៊ីល្វីយ៉ា ត្រូវបានប្រធានថូម៉ាស អេស ម៉នសុន នាំដើរទស្សនកិច្ចបរិវេណព្រះវិហារបរិសុទ្ធស្តុកខុល*

ព្រឹត្តិការណ៍សាធារណៈជាច្រើន ។ គាត់ និងភរិយាបានត្រឡប់មកប្រទេសស៊ុយអែតវិញក្នុងឆ្នាំ 2011 ដើម្បីគ្រប់គ្រងបេសកកម្មស្តុកខុលស៊ុយអែតរហូតដល់ខែ កក្កដា ឆ្នាំ 2014 ។

ប្រធានញូវែលបានគ្រប់គ្រងចំនួនអ្នកផ្សាយសាសនាដែលកើនឡើងពី 84 នាក់ ទៅ 205 នាក់ ។ ដោយព្រោះតែផ្ទះជួលពិបាកនឹងរក ហើយមានតម្លៃថ្លៃនៅក្នុងប្រទេសស៊ុយអែត គាត់បានពិពណ៌នាថា វាជា « អព្ភូតហេតុមួយដែលបេសកកម្មអាចរកផ្ទះជួលចំនួន 56 កន្លែងបន្ថែមទៀតសម្រាប់ពួកអ្នកផ្សាយសាសនាមកដល់ថ្មី » ។

## ការរីកចម្រើនដ៏ពិត

នៅគ្រាក្រោយពីសង្គ្រាម ប្រទេសស៊ុយអែតបានក្លាយជាប្រទេសមួយដ៏ខ្លាំង ។ ប៉ុន្តែមានជនអន្តោប្រវេសន៍ជាច្រើនដែលកំពុងស្វែងរកព្រះ ។ សព្វថ្ងៃនេះ ក្នុងចំណោមជនជាតិស៊ុយអែតប្រាំមួយនាក់ មានម្នាក់មិនបានកើតក្នុង ប្រទេសស៊ុយអែតទេ ។ ភាគច្រើននៃចំនួនប្រជាជនដែលចូលរួមសាសនាចក្រក្នុងប្រទេសស៊ុយអែតគឺជាជនអន្តោប្រវេសន៍ ។ ប្រធានញ៉ូវែលបានរៀបរាប់ពីពួកអ្នកប្រែចិត្តជឿថ្មីៗមួយចំនួនថា ៖ « បងប្អូនប្រុសស្រីមកពីប្រទេសចំនួន 28 ផ្សេងគ្នាបានប្រែចិត្តជឿដល់សាសនាចក្រក្នុងប្រទេសស៊ុយអែត ។ យើងឲ្យពង្រឹងពួកគេ ហើយទទួលបានទំនុកចិត្តរបស់ពួកគេ » ។

ថ្វីបើមានមជ្ឈដ្ឋានលោកិយ និង ការអូសទាញដ៏អាក្រក់មួយចំនួនក្ដី ក៏មានសមាជិកស្មោះត្រង់ និង ថ្នាក់ដឹកនាំសាសនាចក្រដ៏រឹងមាំជាច្រើនរស់នៅក្នុងប្រទេសស៊ុយអែតផងដែរ ។ សមាជិកមានអំណរគុណចំពោះជំនួយដែលការបង្រៀន និង សកម្មភាពសាសនាចក្របានផ្ដល់ដល់ក្រុមគ្រួសារ និង បុគ្គលម្នាក់ៗ ហើយវាគឺជាការប៉ងប្រាថ្នាដ៏ធំរបស់ពួកគេថា នឹងមានមនុស្សជាច្រើនព្រមទទួលយកសារលិខិតដ៏អំណរនៃព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនទ្រង់ ។ ■

*អ្នកនិពន្ធរស់នៅប្រទេសស៊ុយអែត*

**កំណត់ចំណាំ**

1. សូមមើល *Box Elder Lore of the Nineteenth Century,* (ឆ្នាំ 1951) ទំព័រ 58 ។
2. សូមមើល អាន់ឌ្រូ ជេនសិន *History of the Scandinavian Mission,* (ឆ្នាំ 1979) ទំព័រ 81 ។
3. សូមមើល Inger Höglund and Caj-Aage Johansson, *Steg i tro* (ឆ្នាំ 2000) ទំព័រ 122 ។
4. សូមមើល ជេនសិន *History of the Scandinavian Mission* ទំព័រ 53 ។
5. សូមមើល Myrtle McDonald, *No Regrets: The Life of Carl A. Carlquist,* (ឆ្នាំ 1985) ទំព័រ 19–21 ។
6. សូមមើល McDonald, *No Regrets,* ទំព័រ 219 ។
7. សូមមើល អាន់ឌ្រូ ជេនសិន *History of the Scandinavian Mission,* ទំព័រ 331 ។
8. សូមមើល McDonald, *No Regrets,* ទំព័រ 239 ។
9. សូមមើល McDonald, *No Regrets,* ទំព័រ 219 ។

ខាងស្ដាំ ៖ រូបថតប្រើដោយមានការអនុញ្ញាតពី *CHURCH NEWS*



**អែលឌើរ**
**ម៉ាលីន ជេ ជែនសិន**
បានបម្រើជាសមាជិកនៃ
ពួកចិតសិបនាក់ពីឆ្នាំ 1989
ដល់ឆ្នាំ 2012

## មេរៀននៅក្នុង

# ព្រៃពិសិដ្ឋ





ក្នុងឆ្នាំ 1993 បួនឆ្នាំបន្ទាប់ពីការហៅរបស់ខ្ញុំក្នុងពួកចិតសិប គ្រួសារខ្ញុំ និង ខ្ញុំត្រូវបានស្នើសុំឲ្យបម្រើក្នុងបេសកកម្ម នូវយ៉ក រ៉ូឆេស្ទ័រ ។ បេសកកម្មនោះរួមមានទីក្រុង ប៉ាលម៉ៃរ៉ា (កន្លែងដែលភាគច្រើន យ៉ូសែប ស្ម៊ីធ និងគ្រួសារលោកបានរស់នៅក្នុងទសវត្ស 1820) និង ហ្វាយ៉េត្ត (កន្លែងដែលសាសនាចក្រត្រូវបានស្ថាបនាក្នុងខែ មេសា ឆ្នាំ 1830) ។

វាជាស្រុកដ៏វិចិត្រ ដែលពេញដោយទីជម្រាល ទីទួលដែលមានព្រៃដុះពាសពេញ ទន្លេ និងអូរដែលមានទឹកថ្លាឆ្វង់ ហើយប្រជាជនស្រស់ស្អាត និងរួសរាយ ។ វាក៏ជាកន្លែងមួយដែលពិសិដ្ឋ ដោយព្រោះអ្វីដែលបានកើតឡើងនៅទីនោះផងដែរ ។

ក្នុងព្រៃមួយដែលមានដើមប៊ីច ដើម អូក ដើមម៉េផល និងដើមឈើផ្សេងទៀតខ្ពស់ៗ ប្រហែល ជិតកន្លះគីឡូម៉ែត្រ ខាងលិចផ្ទះរបស់គ្រួសារ យ៉ូសែប និង លូស៊ី ម៉ាក ស្ម៊ីធ ជិតប៉ាលម៉ៃរ៉ា នោះយ៉ូសែប ស្ម៊ីធ ដែលមានអាយុ 14 ឆ្នាំ បានឃើញព្រះជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទនៅក្នុងការនិមិត្ត ។ ការបើកសម្តែងដ៏ទេវភាពនេះ ដែលជាការឆ្លើយតបទៅនឹងការអធិស្ឋានរបស់យ៉ូសែប ស្ម៊ីធ ដើម្បីដឹងការពិត ទាក់ទងនឹងសាសនា បានចាប់ផ្តើមការស្តារឡើងវិញនៃដំណឹងល្អ ក្នុងសម័យកាន់កាប់ត្រួតត្រាចុងក្រោយនេះ ។ វាក៏បានធ្វើឲ្យព្រៃនោះក្លាយជាកន្លែងដ៏គួរឲ្យគោរព ក្នុងប្រវត្តិសាស្ត្រសាសនាចក្រផងដែរ—ជាកន្លែងមួយដែលយើងឲ្យឈ្មោះថាព្រៃពិសិដ្ឋ ។

គ្រួសារខ្ញុំ និងខ្ញុំបានជាប់ចិត្តស្រឡាញ់ព្រៃនោះ ហើយទទួលអារម្មណ៍នៃភាពពិសិដ្ឋរបស់វា ។ យើងបានទៅទីនោះជាញឹកញាប់ ។ រៀងរាល់ខែ ពេលដែលមានពួកអ្នកផ្សព្វផ្សាយថ្មីមកដល់ និងនៅពេលដែលពួកអ្នកផ្សព្វផ្សាយដែលចប់ត្រូវចាកចេញ យើងបាននាំពួកគេទៅទីនោះ ។

កាលដែលខ្ញុំបានដើរកាត់ព្រៃពិសិដ្ឋ ដោយគារវភាពឬអង្គុយដោយសញ្ជឹងគិតនៅលើកៅអីដែលគេដាក់នៅទីនោះ ជាញឹកញាប់ ខ្ញុំសញ្ជឹងគិតពីការប្រៀបធៀបក្នុងព្រះគម្ពីរទាក់ទងនឹងដើមឈើ គ្រាប់ពូជ ផ្លែ ឫសឈើ និងព្រៃប្រឹក្សា ។ អ្នកសង្កេតពីធម្មជាតិដ៏យកចិត្តទុកដាក់ម្នាក់ អាចរៀននូវមេរៀនដ៏ចាំបាច់មួយចំនួនពីប្រព័ន្ធបរិស្ថាននៅទីនោះ ។ ខ្ញុំសូមចែកចាយដោយសង្ខេប នូវមេរៀនចំនួនបួននៃមេរៀនទាំងឡាយនោះ ។[1]

រូបថតដោយ ជែលស៍ ជែ



ខ្ញុំសូមលើកទឹកចិត្ត
អ្នកឲ្យឈរជានិច្ច
នៅក្នុងគំនិតអ្នក និង
ក្នុងដួងចិត្តអ្នក ក្នុង
ព្រៃដ៏ពិសិដ្ឋនេះ ហើយ
រស់នៅដោយស្មោះត្រង់
ចំពោះសេចក្ដី
ពិតដែលព្រះបាន
ផ្ដើមបើកសម្ដែង
នៅទីនោះ ។

**1. ដើមឈើតែងតែដុះឡើងឆ្ពោះទៅរកពន្លឺ ។**

ក្នុងព្រៃពិសិដ្ឋ ដើមឈើដែលដុះលើជាយព្រៃពីដើមមក ព្រមទាំងដើមទាំងឡាយដែលដុះនៅក្នុងបរិវេណព្រៃជាជួរខ្វែងខ្វាត់គ្របបាំងដុះឆ្ពោះតម្រង់ទៅលើ ដើម្បីស្រូបយកពន្លឺថ្ងៃល្អបំផុតនៃព្រះអាទិត្យ ។ ដើម និងមែកដ៏កោងរបស់ពួកវា ដុះខុសពីដើមជិតៗនោះ ដែលដុះស្ទើរតែត្រង់ឥតខ្ចោះតែម្ដង ។ ដើមឈើស្ទើរតែ ទាំងអស់ គឺជាសេរីៈដែលមានជីវិត ដែលត្រូវការពន្លឺថ្ងៃ ដើម្បីអាចមានជីវិតនិងលូតលាស់ឡើង ។ ដើមឈើទាំងនោះនឹងខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីស្រូបពន្លឺថ្ងៃឲ្យបានច្រើនតាមដែលអាចធ្វើបាន ដើម្បីជម្រុញឲ្យមានរស្មីសំយោគ—ដែលជាដំណើរការនៃការផ្លាស់ប្ដូរទៅជាថាមពលពន្លឺ ទៅជាថាមពលគីមី ។

ពន្លឺ គឺជាកត្តាប្រតិកម្មគីមីកាន់តែសំខាន់ ក្នុងពិភពវិញ្ញាណជាជាងបរិស្ថានធម្មជាតិ ។ វាអញ្ចឹងមែន ព្រោះតែពន្លឺនោះចាំបាច់ដល់ការលូតលាស់ខាងវិញ្ញាណ និងការយល់ដឹងពីសក្ដានុពលដ៏ពេញលេញរបស់យើងក្នុងនាមជាបុត្រា និងបុត្រីនៃព្រះ ។

ភាពងងឹតគឺផ្ទុយពីពន្លឺ ហើយតំណាងឲ្យឋាមពលក្នុងលោកិយ ដែលព្យាយាមបង្វែរយើងពីព្រះ និងបង្អាក់ផែនការដ៏ទេវភាពរបស់ទ្រង់ សម្រាប់ជីវិតយើង ។ ជាធម្មតា គឺបន្ទាប់ពីភាពងងឹត ឬនៅក្នុងទីងងឹតដែលកងកម្លាំងអារក្ស ប្រើឥទ្ធិពលដ៏ខ្លាំងបំផុតរបស់វា ។ ការបំពានលើច្បាប់ព្រហ្មចារីភាព ទង្វើនៃការលួច ការបំពានពាក្យសម្បថនៃប្រាជ្ញាវាងវៃ និងឥរិយាបថផ្សេងៗទៀត ដែលត្រូវបានហាមឃាត់ដោយព្រះបិតាសួគ៌យើង គឺជានិច្ចកាលត្រូវបានធ្វើឡើងនៅក្រោមការគ្របបាំងនៃភាពងងឹត ។ សូម្បីពេលយើងជ្រើសរើសធ្វើខុសក្នុងពេលថ្ងៃក្ដី យើងមិនអាចទប់មិនឲ្យមានអារម្មណ៍នៃភាពងងឹតបានទេ ។

ជាការល្អ ព្រះវិញ្ញាណនៃព្រះគ្រីស្ទ « ប្រទានពន្លឺដល់មនុស្សគ្រប់រូបណាដែលមកក្នុងលោកិយ ហើយព្រះវិញ្ញាណបំភ្លឺគ្រប់មនុស្សពាសពេញលោកិយដែលប្រុងស្ដាប់តាមសម្លេងនៃព្រះវិញ្ញាណ ។

« ហើយមនុស្សគ្រប់រូបណា ដែលប្រុងស្ដាប់តាមសម្លេងនៃព្រះវិញ្ញាណ នោះមករកព្រះ គឺព្រះវរបិតា » (គ. និង ស. 84:46–47) ។

បទគម្ពីរនេះពិពណ៌នាយ៉ាងល្អពីការឈោងដៃរបស់មនុស្សឆ្ពោះទៅលើ ជាសភាវគតិខាងវិញ្ញាណដែលព្រះប្រទាន ដែលយើងទាំងអស់គ្នាមាន—បើយើងមិនរារាំងវា—ហើយក្នុងការធ្វើដូច្នោះ គឺដើម្បីឆ្ពោះទៅឯពន្លឺគឺឆ្ពោះទៅព្រះ និងព្រះរាជបុត្រាទ្រង់ និងក្លាយកាន់តែដូចពួកទ្រង់ដែរ ។ ព្រះយេស៊ូវគ្រីស្ទបានមានព្រះបន្ទូលថា « ខ្ញុំជាពន្លឺលោកីយ អ្នកណាដែលតាមខ្ញុំ នោះមិនដែលដើរក្នុងសេចក្ដីងងឹតឡើយគឺនឹងមានពន្លឺនៃជីវិតវិញ» (យ៉ូហាន 8:12) ។

ខ្ញុំសូមអង្វរអ្នកឲ្យអ្នកជៀសវាងពីសេចក្ដីងងឹតនៃអំពីបាបនៅក្នុងគ្រប់ទម្រង់ដ៏អាក្រក់របស់វា ហើយសូមបំពេញជីវិតអ្នកនូវព្រះវិញ្ញាណ សេចក្ដីពិត និងពន្លឺនៃព្រះអង្គសង្គ្រោះ គឺព្រះយេស៊ូវគ្រីស្ទ ។ អ្នកធ្វើបែបនេះបានដោយការស្វែងរកបានមិត្តដែលថ្លៃថ្នូរ តន្ត្រី និងសិល្បៈដែលបំផុសគំនិត ចំណេះដឹងចេញពីសៀវភៅដែលល្អបំផុត (ជាពិសេសព្រះគម្ពីរ) ពេលវេលាអធិស្ឋានដោយស្មោះត្រង់ ពេលស្ងប់ស្ងាត់ក្នុងធម្មជាតិ សកម្មភាព និងការសន្ទនាល្អៗ និងជីវិតដែលផ្ដោតលើព្រះគ្រីស្ទ និងការបង្រៀនរបស់ទ្រង់ពីក្ដីស្រឡាញ់ និងការបម្រើ ។

**2. ដើមឈើត្រូវការភាពផ្ទុយ ដើម្បីបំពេញតាមសក្ដានុពលនៃការបង្កបង្កើតរបស់វា ។**

មានទស្សនៈជាច្រើនប្រភេទ អំពីការគ្រប់គ្រងថែទាំព្រៃឈើ ដែលត្រូវបានយកមកអនុវត្ត អស់ជាច្រើនឆ្នាំ ក្នុងការថែរក្សាព្រៃពិសិដ្ឋ ។ មានម្ដងនោះ គេបានជ្រើសរើសតំបន់សាកពិសោធន៍មួយ ហើយប្រើប្រាស់ការអនុវត្តមួយដែលត្រូវគេស្គាល់ថា*រំដោះភាពក្រិន* ។ ពួកអ្នកថែរក្សាព្រៃបានរកឃើញអ្វី ដែលពួកគេមានអារម្មណ៍ថា ជាកូនឈើង ដ៏មានសក្ដានុភាពដែលអាចក្លាយជាដើមឈើដ៏ធំបំផុត និងមានសុខភាពល្អបំផុត នៅក្នុងតំបន់សាកពិសោធន៍នោះ បន្ទាប់មក



ពួកគេបានកាត់ចោល និងតម្រឹមមែកនៃដើមណាដែលមិនសូវដុះធំល្អ និងដើមតូចៗដែលខំប្រឹងដុះប្រកួតប្រជែងក្រោមដើមធំៗ ។ តាមការសន្មត់នោះគឺថា ដោយការកាត់ចេញនូវដើមឈើណាដែលកំពុងតែប្រកួតដណ្ដើមយកជាតិទឹក និងពន្លឺថ្ងៃ ជីវជាតិដីនៃដី ដើម្បីឲ្យដើមជម្រើសទាំងនោះអាចត្រូវបាន*រំដោះ* ឲ្យដុះ និងលូតលាស់ក្នុងរបៀបដ៏អស្ចារ្យ ។

វាជាក់ស្ដែងណាស់ថា ជាច្រើនឆ្នាំកន្លងទៅ អ្វីដែលកំពុងតែកើតឡើងដែលមានដំណើរការផ្ទុយពីអ្វីដែលគេបានសន្មត់ ។ ពេលដែលពុំមានការប្រជែងពីដើមផ្សេងៗ នោះដើមដែលគេជ្រើសរើសទាំងនោះបានក្លាយទៅជាមិនខំលូតលាស់ទៅវិញ ។ ជាជាងការលូតទៅលើឆ្ពោះទៅកាន់ពន្លឺ ពួកវាពន្យឺតការដុះត្រង់របស់វាវិញ ដោយវាមានដុះមែកនៅទាបៗជាច្រើន ដែលនៅទីបំផុត វានឹងគ្មានប្រយោជន៍ទេ នៅពេលដែលស្លឹកធំៗដុះគ្របជិត ហើយពេលដើមឈើនោះកាន់តែតឿ ។ គ្មានដើមណាមួយនៅក្នុងតំបន់សាកពិសោធន៍នោះ អាចប្រៀបធៀបជាមួយនឹងដើមទាំងឡាយ ដែលគេទុកឲ្យដុះតាមធម្មជាតិនោះទេ ទាំងទំហំ ឬភាពរឹងមាំក៏ដោយ ។



*ដើមឈើនៅក្នុងព្រៃពិសិដ្ឋទាំងនេះបង្ហាញថា ការផ្ទុយអាចជាប្រយោជន៍ដល់យើង ហើយថានៅក្នុងពេលដ៏លំបាកក្រៃលែងរបស់យើង នោះជាញឹកញាប់មានអ្វីជាច្រើនដែលយើងអាចរីកចម្រើន ។*

គោលលទ្ធិសំខាន់មួយនៃព្រះគម្ពីរមរមន គឺថា ត្រូវតែមាន « ការផ្ទុយគ្រប់ការណ៍ទាំងអស់ » (នីហ្វៃទី 2 2:11) ។ ពិភពលោកមួយដែលមានការផ្ទុយ ផ្ដល់នូវជម្រើសរវាងល្អ និងអាក្រក់ ដើម្បីឲ្យសិទ្ធិជ្រើសរើសអាចអនុវត្តឡើងបាន ។ វាសំខាន់ស្មើគ្នា គឺគោលការណ៍ដែលថា ត្រូវតែមានការផ្ទុយ ដើម្បីមានការលូតលាស់ខាងវិញ្ញាណ ។ ការយល់ដឹង និងការឱបក្រសោបយកគោលការណ៍នេះ គឺជាគន្លឹះមួយក្នុងការទទួល យក ហើយមានភាពរីករាយជាទូទៅក្នុងជីវិត ។ វាក៏ចាំបាច់បាច់ផងដែរ ចំពោះការទទួលបទពិសោធន៍ដែលត្រូវការ ដល់ការរីកចម្រើន និងការអភិវឌ្ឍន៍ផ្ទាល់ខ្លួន ។

មិនយូរ មិនឆាប់ យើងទាំងអស់គ្នានឹងជួបប្រទះការផ្ទុយ និងទុក្ខលំបាក ។ ការផ្ទុយ និងទុក្ខលំបាកខ្លះកើតឡើងជាលទ្ធផលនៃការរស់នៅទីនេះក្នុងជីវិតរមែងស្លាប់ នៅក្នុងពិភពដ៏ធ្លាក់ចុះនេះ ។ វាអាចជាប់ទាក់ទងនិងកម្លាំងនានានៃធម្មជាតិ ជំងឺផ្សេងៗ ការល្បួង ភាពឯកោ ឬភាពមិនល្អឥតខ្ចោះខាងរូបកាយ ឬខាងផ្លូវចិត្ត ។ ជួនកាល ការផ្ទុយ និងទុក្ខលំបាក កើតឡើងដោយព្រោះជម្រើសដែលនាំទៅផ្លូវខុសរបស់យើងផ្ទាល់ ។ យើងទាំងអស់គ្នាគួរមានអំណរគុណយ៉ាងខ្លាំងចំពោះព្រះអង្គសង្គ្រោះយើង ដែលដង្វាយធួនរបស់ទ្រង់ ផ្ដល់ជារបៀបមួយដើម្បីយើងអាចជួសជុលនូវអ្វីដែលខូចបង់វិញបាន ។

ខ្ញុំទទួលនូវអារម្មណ៍នៃការធូរស្បើយដ៏ខ្លាំងពីពាក្យសម្ដីរបស់ព្រះអម្ចាស់ដល់យ៉ូសែប ស្ម៊ីធនៅក្នុងគុកលីបើទី ក្នុងគ្រាដែលបន្ទុករបស់យ៉ូសែបស្ទើរតែទ្រាំទ្រលែងបាននោះ ៖ « បុត្រយើងអើយ ចូរអ្នកដឹងថា គ្រប់ការណ៍ទាំងនេះ នឹងផ្ដល់ការពិសោធន៍ដល់អ្នក ហើយនឹងទៅជាការល្អដល់អ្នកទៅវិញ » (គ. និង ស. 122:7) ។

ដើមឈើមួយចំនួននៅក្នុងព្រៃពិសិដ្ឋ បង្ហាញថា ការផ្ទុយអាចផ្ដល់ជាប្រយោជន៍ដល់យើង ហើយថានៅក្នុងពេលដ៏លំបាកក្រៃលែងរបស់យើង នោះជាញឹកញាប់មានអ្វីជាច្រើនដែលយើងអាចបានកើនឡើង ។ ដើមឈើទាំងនេះត្រូវតែបានធូរស្បើយពីទម្រង់ផ្សេងៗនៃការផ្ទុយ ឬទុក្ខលំបាកជាច្រើនប្រភេទ—រន្ទះបាញ់ សន្ទុះខ្យល់យ៉ាងខ្លាំង ឬព្រឹលទឹកកក ដែលកកលើដើមយ៉ាងធ្ងន់ ការបៀតបៀន និងការបំពានពីមនុស្សដែលមិនចេះរិះគិត និងជួនកាល សូម្បីតែជាការរុករានពីដើមឈើដែលនៅជិត ។ ចេញពីស្ថានភាពមិនអនុគ្រោះទាំងនេះ ក៏មាននូវដើមឈើដែលរឹងមាំបំផុត និងមើលឃើញទៅថាគួរឲ្យចាប់អារម្មណ៍បំផុត នៅក្នុងព្រៃនោះ ។

**3. ដើមឈើដុះល្អបំផុតនៅក្នុងព្រៃមិនមែនក្នុងកន្លែងដាច់ពីគេនោះទេ ។**

ក្នុងធម្មជាតិ វាចម្លែកណាស់ ដែលឃើញដើមឈើមួយដុះតែឯងនោះ ។ ជានិច្ចកាល ពួកវាដុះផ្ដុំគ្នាក្នុងព្រៃតូចៗ ហើយយូរៗទៅព្រៃតូចៗអាចក្លាយជាព្រៃធំៗ ។ ទោះយ៉ាងណា ក្ដី ព្រៃពិសិដ្ឋគឺពុំគ្រាន់តែជាក្រុមដើមឈើទាំងឡាយប៉ុណ្ណោះនោះទេ ។ វាជាប្រព័ន្ធអេកូដ៏ស្មុគស្មាញមួយ ដែលរួមមានអំបូររុក្ខជាតិ និងសត្វជាច្រើនយ៉ាង ។



មានភាពពាក់ព័ន្ធតភ្ជាប់គ្នាទៅវិញទៅមកមួយដែលអាចសង្កេតមើលឃើញនឹងភ្នែក ក្នុងចំណោមពពួកផ្កាព្រៃ គុម្ពព្រៃ រុក្ខជាតិ ដើមឈើ ផ្សិត ស្លែ សត្វស្លាប សត្វកកេរ ទន្សាយ ក្ដាន់ និងផលបង្កើតផ្សេងៗទៀតខុសៗគ្នាដែលនៅទីនោះ ។ អំបូរទាំងនេះធ្វើអន្តរកម្ម និងពឹងផ្អែកលើគ្នាទៅវិញទៅមក ដើម្បីមានអាហារ ជម្រក និងបរិយាកាសសង្គម និងសីសង្វាក់គ្នាមួយ ដែលអំបូរទាំងអស់អាចទទួលបទពិសោធន៍នៃវដ្ដជីវិតរបស់ពួកវា ។

ផែនការរបស់ព្រះសម្រាប់ជីវិតយើង គឺគិតគូរពីភាពទាក់ទងគ្នាទៅវិញទៅមកស្រដៀងគ្នាមួយ និងពីសង្គមរបស់យើង ។ យើងត្រូវធ្វើឲ្យសេចក្ដីសង្គ្រោះរបស់យើងកើតឡើងរួមជាមួយគ្នា មិនមែនដាច់ដោយឡែកនោះទេ ។ សាសនាចក្រកសាងសាលាជំនុំ មិនមែនអាស្រមឥសីទេ ។

តាំងពីដើមដំបូងនៃការស្ដារឡើងវិញ ព្រះបញ្ញត្តិសម្រាប់យើងរាល់គ្នា គឺឲ្យយើង ប្រមូលផ្ដុំគ្នាក្នុងសហគមន៍នានា ដែលយើងអាចរៀនរស់នៅក្នុងភាពសុខដុម និងគាំទ្រគ្នាទៅវិញទៅមក ដោយការគោរពដល់សេចក្ដីសញ្ញាបុណ្យជ្រមុជទឹករបស់យើង (សូមមើល ម៉ូសាយ 18:8–10) ។ ក្នុងនាមជាបុត្រនៃព្រះ យើងមិនអាចរីកចម្រើនដោយឯកឯងបានឡើយ ប្រៀបដូចជាដើមឈើដែលដុះតែឯងដែរ ។ ដើមឈើដែលមានសុខភាពល្អត្រូវការប្រព័ន្ធបរិស្ថានជុំវិញមួយ មនុស្សដែលមានសុខភាពល្អក៏ត្រូវការគ្នាទៅវិញទៅមកដែរ ។







អរគុណណាស់ ដែលក្នុងខ្លួនយើងទាំងអស់គ្នាមាននូវបំណងចង់រស់នៅក្នុងសង្គម ភាពជាដៃគូ មិត្តដែលស្មោះត្រង់ ។ ដោយជាសមាជិកក្នុងគ្រួសារដ៏អស់កល្បនៃព្រះ យើងទាំងអស់គ្នាមានបំណងប៉ងចង់បាននូវសេចក្ដីសោមនស្ស និងសុវត្ថិភាពដែលទំនាក់ទំនងដ៏ជិតស្និទ្ធ និងយូរអង្វែងអាចផ្ដល់ឲ្យនោះ ។ ថ្វីបើបណ្ដាញសង្គមពិតជាផ្ដល់នូវទម្រង់មួយនៃសង្គមភាព ក៏បណ្ដាញទាំងនោះមិនអាចយកមកដាក់ជំនួសឲ្យមានការទាក់ទងដ៏ស្មោះត្រង់ដោយឥតលាក់លាម និងដោយផ្ទាល់នោះបានទេ ដែលត្រូវតែធ្វើឡើងដើម្បីបង្កើតទំនាក់ទំនងដ៏ពិតប្រាកដ និងយូរអង្វែងមួយនោះ ។

ប្រាកដណាស់ មន្ទីរពិសោធន៍ដំបូងបំផុត និងល្អបំផុតដើម្បីរៀនចុះសម្រុងនឹងគ្នា គឺផ្ទះនោះឯង ។ នៅផ្ទះយើងរៀនមេរៀននៃការបម្រើ ភាពមិនអាត្មានិយម ការអភ័យទោស និងការអត់ធ្មត់ ដែលចាំបាច់ដល់ការបង្កើតទំនាក់ទំនងដ៏យូរអង្វែងជាមួយអ្នកដទៃទៀត ។

ជាការល្អ អង្គការដ៏បំផុសគំនិតរបស់សាសនាចក្រនេះ ក៏បានផ្ដល់នូវបរិយាកាសដែលយើងអាចអភិវឌ្ឍខាងផ្នែកសង្គមផងដែរ ។ ក្នុងការហៅបម្រើ ការប្រជុំ ថ្នាក់រៀនក្វ៉ុម ក្រុមប្រឹក្សា សកម្មភាព និងឱកាសផ្សេងៗសម្រាប់ការប្រាស្រ័យទាក់ទងក្នុងសាសនាចក្រ យើងអភិវឌ្ឍលក្ខណៈសម្បត្តិ និងជំនាញខាងសង្គម ដែលជួយរៀបចំយើងសម្រាប់របៀបរៀបរយក្នុងសង្គមដែលនឹងមាននៅស្ថានសួគ៌ ។

និយាយពីរបៀបរៀបរយដែលខ្ពស់ជាងនេះ ព្រះអម្ចាស់បានមានបន្ទូលតាមរយៈយ៉ូសែប ស៊្មីធ ថា ៖ « ហើយទំនាក់ទំនងដែលមាននៅក្នុងចំណោមពួកយើងនៅទីនេះយ៉ាងណា នោះក៏នឹងមានក្នុងចំណោមយើងនៅទីនោះយ៉ាងនោះដែរ គ្រាន់តែរួបរួមដោយសិរីល្អដ៏នៅអស់កល្បជានិច្ច គឺជាសិរីល្អដែលយើងពុំមានការពិសោធន៍នៅពេលឥឡូវនេះប៉ុណ្ណោះ » (គ. និង ស. 130:2) ។

**4. ដើមឈើទាញយកភាពរឹងមាំពីជីជាតិដែលបង្កើតដោយដើមឈើពីតំណមុនៗ ។**

ក្នុងគ្រាមួយនោះ នៅពេលដែលពួកអ្នកដែលទទួលភារកិច្ច នៃការថែទាំព្រៃពិសិដ្ឋ បានសម្រេចថា ព្រៃនោះគួរមានគេកាត់តម្រឹមនិងមើលថែទាំយ៉ាងស្រស់ស្អាត ។ នៅពេលនោះគម្រោងធ្វើការបម្រើត្រូវបានរៀបចំឡើងដើម្បីសម្អាតដើមឈើដួលរលំ និងមែកឈើដែលបាក់ព្រមទាំងដើមឈើតូចៗដែលដុះពីក្រោមដើមឈើធំៗ និងកំណាត់ឈើ ហើយនិងស្លឹកងាប់ៗផងដែរ ។ មិនយូរប៉ុន្មានតាមការអនុវត្តនេះ ភាពរឹងមាំនៃព្រៃឈើនោះចាប់ផ្ដើមចុះអន់ថយទៅ ។ ដើមឈើលូតលាស់យឺត មានដើមថ្មីថ្មោងតែបន្ដិចបន្តួចលិចពន្លកឡើង អំបូរផ្កា និងរុក្ខជាតិព្រៃខ្លះចាប់ផ្ដើមបាត់បង់ និងចំនួននៃសត្វព្រៃ និងសត្វស្លាបបានថយចុះតិចទៅៗ ។

ក្រោយមកទៀត ដោយបានទទួលអនុសាសន៍ថា ត្រូវទុកឲ្យព្រៃនេះដុះតាមធម្មជាតិចុះ ដើម និងមែកដែលរលំធ្លាក់ចុះត្រូវបានទុកឲ្យរលួយ និងផ្ដល់ជីជាតិដល់ដី ។ ស្លឹកត្រូវទុកឲ្យនៅកន្លែងដែលវាធ្លាក់មក ។ អ្នកទស្សនាត្រូវបានសុំឲ្យដើរនៅលើផ្លូវដែលមានគំនូស ដើម្បីកាត់បន្ថយការរំខានដល់ព្រៃឈើ និងការធ្វើឲ្យដីនៅក្នុងព្រៃហាប់ណែនពេក ។ ក្នុងរយៈពេលតែពីរបីឆ្នាំប៉ុណ្ណោះ ព្រៃបានចាប់ផ្ដើមដុះឡើងវិញដោយខ្លួនវាក្នុងរបៀបមួយដ៏អស្ចារ្យ ។ សព្វថ្ងៃនេះ វាលូតលាស់ជិតដូចស្ថានភាពដ៏ល្អដូចដើមដោយមានរុក្ខជាតិសម្បូរបែប និងសត្វព្រៃជាច្រើន ។

*អ្នកសង្កេតពីធម្មជាតិដ៏យកចិត្តទុកដាក់ម្នាក់អាចរៀននូវមេរៀនដ៏មានតម្លៃមួយចំនួន ពីប្រព័ន្ធបរិស្ថានដែលមាននៅក្នុងព្រៃពិសិដ្ឋនោះ ។*

មេរៀនដែលត្រូវរៀនពីបទពិសោធន៍ក្នុងការគ្រប់គ្រងព្រៃឈើនេះ គឺពេញចិត្តខ្ញុំណាស់ ។ ប្រាំពីរឆ្នាំហើយ ដែលខ្ញុំមានឯកសិទ្ធបម្រើជាអ្នកប្រវិត្តសាស្ត្រ និងអ្នកកត់ត្រារបស់សាសនាចក្រ ។ ហេតុអ្វីបានជាការរក្សាបញ្ជី និងការប្រមូលផ្ដុំ ការរក្សាទុក និងការចែករំលែកប្រវត្តិ ជាការសំខាន់ម្ល៉េះ ក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ? ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីចេះគិតគូរ ហើយទទួលបានកម្លាំងពីជំនាន់មុន ? (សូមមើល គ. និង ស. 21:1, 69:3, 8) ។

ខ្ញុំសូមណែនាំថា វាមិនអាចទៅរួចទេ ដើម្បីរស់នៅឲ្យបានពេញលេញក្នុងពេលបច្ចុប្បន្ននេះ—ព្រមទាំងគ្រោងគោលដៅអនាគតរបស់យើង—បើគ្មានគ្រឹះពីអតីតកាលទេនោះ ។ ការយល់ដឹងនូវទំនាក់ទំនងពីអតីតកាលទៅនឹងបច្ចុប្បន្ន និងនៅពេលអនាគតជួយយើងឲ្យកាន់តែមាន

អំណរគុណចំពោះអត្ថន័យនៃសេចក្ដីពិតរបស់ព្រះអម្ចាស់ ដែលបានបើកសម្ដែងដល់យ៉ូសែប ស៊្មីធ ថា ៖ « សេចក្ដីពិតគឺជាការចេះដឹង អំពីការណ៍ទាំងឡាយដែលមាននៅពេលនេះ និងការណ៍ទាំងឡាយដែលមានមកហើយ ហើយនិងការណ៍ទាំងឡាយដែលនឹងមានខាងមុខ » (គ. និង ស. 93:24) ។

ការចេះដឹងដែលយើងមាន ពីអតីតកាល ដោយសារតែបញ្ជីទាំងឡាយដែលបានរក្សាទុក និងពីអនាគតយើង ដោយសារតែព្រះគម្ពីរ និងការបង្រៀនរបស់ព្យាការីនៅរស់ ផ្ដល់ដល់យើងនូវបរិបទ ដែលជួយយើងប្រើប្រាស់សិទ្ធិជ្រើសរើសរបស់យើង ដោយឈ្លាសវៃ ពេលយើងមានជីវិត ។



វាគឺជាកត្តាសំខាន់ដែលយើងត្រូវតែយល់ដឹងនូវប្រវត្តិសាស្ត្ររបស់សាសនាចក្រយើង ជាពិសេសជាមួយនឹងដំណើររឿងសំខាន់ៗរបស់សាសនាចក្រ ។ ដំណើររឿងទាំងនេះ ដូចជា—ទស្សនៈនិមិត្តដំបូងរបស់យ៉ូសែប ស៊្មីធ ការលេចចេញមកនៃព្រះគម្ពីរមរមន ទស្សនកិច្ចនៃទេវតាយ៉ូហាន បាទីស្ទ ពេត្រុស យ៉ាកុប យ៉ូហាន អេលីយ៉ា អេលីយ៉ាស និង អ្នកផ្សេងទៀត—រួមមាននូវសេចក្ដីពិតដែលជាគ្រឹះនៃការស្ដារឡើងវិញ ។

ជាការគួរឲ្យសោកស្ដាយ នៅក្នុងជំនាន់បច្ចេកវិជ្ជា ជាទីដែលមានព័ត៌មានផ្សព្វផ្សាយដ៏ច្រើនសន្ធឹកសន្ធាប់នេះ—មានព័ត៌មានខ្លះបាននិះគន់ចាប់កំហុសនូវព្រឹត្តិការណ៍និងមនុស្សសំខាន់ៗមួយចំនួនក្នុងប្រវត្តិសាសនាចក្រ—ដែលបានធ្វើឲ្យពួកបរិសុទ្ធមួយចំនួនបែរទៅជាមានមន្ទិលសង្ស័យចំពោះជំនឿរបស់ពួកគេ ហើយចាប់ផ្ដើមងឿងឆ្ងល់ចំពោះជំនឿដែលមានជាយូរហើយនោះ ។ ចំពោះបុគ្គលទាំងឡាយដែលមានការសង្ស័យបែបនោះ ខ្ញុំសូមសំដែងនូវក្ដីស្រឡាញ់ និងការយល់ចិត្ត និងការអះអាងរបស់ខ្ញុំថា បើពួកគេតោងជាប់នឹងគោលការណ៍ទាំងឡាយនៃដំណឹងល្អ ហើយព្យាយាមសិក្សាពីប្រវត្តិសាសនាចក្រប្រកបដោយការអធិស្ឋាន—គឺសិក្សាឲ្យបានគ្រប់គ្រាន់ ដើម្បីទទួលបានការយល់ដឹងដ៏ជ្រាលជ្រៅបន្ថែមទៀតជាជាងការចេះដឹងតែមួយផ្នែក ឬមិនពេញលេញ—នោះព្រះវិញ្ញាណបរិសុទ្ធនឹងបញ្ជាក់ពីជំនឿរបស់គេ ក្នុងព្រឹត្តិការណ៍សំខាន់ៗនៃប្រវត្តិសាសនាចក្រ ដោយបន្ទូលដ៏សុខសាន្តចូលក្នុងគំនិតពួកគេ ។ ក្នុងរបៀបនេះ ពួកគេអាចមានភាពនឹងនរ ក្នុងការប្រាកដប្រជារបស់ពួកគេ ទាក់ទងនឹងប្រវត្តិសាស្ត្រនៃសាសនាចក្រដែលបានស្ដារឡើងវិញ ។

**សេចក្ដីបញ្ចប់**

ពេលយើងកំពុងបម្រើបេសកកម្មជិត ប៉ាល់ម៉ៃរ៉ា ជួនកាល ខ្ញុំធ្លាប់ទៅក្នុងព្រៃពិសិដ្ឋម្នាក់ឯង ហើយឈរដោយគារវភាពនៅជិត « ដើមឈើសាក្សី » ដែលខ្ញុំចូលចិត្តជាងគេ—ជាដើមឈើមួយក្នុងចំណោមដើមឈើបីដើមនៅគ្រានៃការនិមិត្តដំបូងដែលកំពុងលូតលាស់នៅក្នុងព្រៃនោះ ។ ខ្ញុំធ្លាប់ប៉ងស្រមៃថា បើដើមនោះអាចនិយាយបាន នោះវានឹងប្រាប់ខ្ញុំ ពីអ្វីដែលវាបានឃើញ នៅថ្ងៃមួយ នានិទាឃរដូវ ក្នុងឆ្នាំ 1820 នោះ ។ តែខ្ញុំពិតជាមិនត្រូវការដើមនោះប្រាប់ខ្ញុំទេ—ខ្ញុំបានដឹងរួចទៅហើយ ។

ដោយគុណប្រយោជន៍នៃបទពិសោធន៍ខាងវិញ្ញាណ និងអារម្មណ៍ដែលបានចាប់ផ្ដើមក្នុងយុវវ័យរបស់ខ្ញុំ និងបន្តដល់វេលានេះ នោះខ្ញុំបានដឹង ដោយមិនបាច់ពឹងផ្អែកលើទីបន្ទាល់របស់អ្នកផ្សេងទេ ថាព្រះជាព្រះវរបិតាយើង មានព្រះជន្មរស់ ។ ខ្ញុំក៏ដឹងផងដែរថា ព្រះរាជបុត្រាទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ និងអង្គប្រោសលោះនៃមនុស្សលោកទាំងអស់ ។ ខ្ញុំដឹងថា តួអង្គដ៏មានសិរីរុងរឿងទាំងពីរអង្គនេះ បានយាងមកជួបយ៉ូសែប ស៊្មីធ ។

សេចក្ដីពិតដ៏រុងរឿងទាំងនេះ មានដំណើររឿងផ្ដើមរបស់វានៅក្នុងព្រៃពិសិដ្ឋ ។ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យឈរជានិច្ច ក្នុងព្រៃដ៏ពិសិដ្ឋនេះនៅក្នុងគំនិតអ្នក និងក្នុងដួងចិត្តអ្នក ហើយរស់នៅដោយស្មោះត្រង់ចំពោះសេចក្ដីពិតដែលព្រះបានផ្ដើមបើកសម្ដែងនៅទីនោះ ។ ■

*ដកស្រង់ចេញពីសុន្ទរកថាក្នុងការប្រជុំធម្មនិដ្ឋាន ស៊ី.អ៊ី.អេស. « ឈរនៅក្នុងព្រៃពិសិដ្ឋ » ធ្វើឡើងនៅផ្ទះកាលីហ្វូញ៉ា ស.រ.អា. ថ្ងៃទី 6 ខែ ឧសភា ឆ្នាំ 2012 ។ សម្រាប់សុន្ទរកថាទាំងស្រុង សូមចូលទៅ cesdevotionals.lds.org ។*

**កំណត់ចំណាំ**

1. ខ្ញុំមានអំណរគុណចំពោះ រ៉ូប៊ីត ផារ៉ុត ជាបុគ្គលិកថែករក្សាព្រៃឈើ និង ធម្មជាតិរបស់សាសនាចក្រដែលរស់នៅក្នុងប៉ាម៉ៃរ៉ា ដែលបានធ្វើឲ្យខ្ញុំទទួលបាននូវចំណេះដឹងមួយចំនួនស្ដីពីព្រៃពិសិដ្ឋដែលខ្ញុំបានចែកចាយ ។

700 មុន.គ.ស. | 600 មុន.គ.ស. | 500

ការក្បត់សាសនានៅស្រុកយូដា

ពួកបាប៊ីឡូន ឆ្នាំ 597 មុនគ.ស.

អាណាចក្រពើស៊ី ឆ្នាំ 539

# ការរង្វេងរយៈពេល 500 ឆ្នាំ ៖ ចាប់តាំងពីម៉ាឡាគីរហូតដល់យ៉ូហាន បាទីស្ទ

*រយៈពេល 500 ឆ្នាំរវាងព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មីអាចបង្រៀនយើងពីស្ថានភាពនៅក្នុងប្រទេសប៉ាឡេស្ទីនសម័យបុរាណ ពីមុនការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ហើយជួយយើងឲ្យធ្វើការតាំងចិត្តរបស់យើងឡើងវិញដើម្បីធ្វើតាមព្រះអង្គសង្គ្រោះ ។*




**ដោយអេស ខេន ប្រោន**

អតីតសាស្ត្រាចារ្យផ្នែកព្រះគម្ពីរបុរាណ

**និង រីឆាដ នីតហ្សេល ហុលហ្សាពហ្វេល**

សាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រសាសនាចក្រ និង គោលលទ្ធិនៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់


នៅពេលព្យាការី ម៉ាឡាគី បានទទួលមរណភាពប្រមាណជាឆ្នាំ 450 មុន គ.ស. គ្មានសំឡេងព្យាការីដ៏ស្មោះត្រង់ណាមួយត្រូវបានគេឮទៀតឡើយអំឡុងពេលប្រមាណជា 500 ឆ្នាំ ។ យើងស្គាល់គ្រានេះថាជាគ្រាអន្តរសញ្ញា—ជាចន្លោះនៃគ្រា កាន់កាប់ត្រួតត្រារវាងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មី ។ ដោយគ្មានព្យាការី ប្រជាជននៅក្នុងដែនដីនេះបានចាប់ផ្ដើមបំបែកខ្លួនទៅជាបក្សពួក និងក្រុមជាច្រើន ហើយក្រុមនីមួយៗបានប្រកាសអះអាងពីសិទ្ធិដើម្បីបកប្រែព្រះគម្ពីរ ហើយដឹកនាំប្រជាជន ។ ការយល់ដឹងដ៏ពិតប្រាកដអំពីព្រះយេហូវ៉ាត្រូវបានធ្លាក់ចុះអន់ថយនៅក្នុងចំណោមក្រុមទាំងនេះ ។ ក្រោយមកភាពច្របូកច្របល់ដ៏យូរអង្វែងបានកើតឡើង ហើយវាត្រូវបានបញ្ចប់នៅពេលព្រះបានបញ្ជូនព្យាការីថ្មីមួយរូបគឺ យ៉ូហាន បាទីស្ទ ដើម្បីចាប់ផ្ដើមគ្រាកាន់កាប់ត្រួតត្រាថ្មីមួយ ។ ប៉ុន្តែទោះជាមានយ៉ូហាន




បាទីស្ទ និង ព្រះអង្គសង្គ្រោះបង្រៀនដល់ប្រជាជននេះក្ដី ក៏មានមនុស្សជាច្រើនមិនអាចបោះបង់ចោលនូវទំនៀមទម្លាប់ និង ជំនឿដែលបានបង្កើតឡើង ហើយមានការរីកចម្រើននៅអំឡុងគ្រាអន្តរសញ្ញា ។ ដូចដែលយើងយល់ដឹងពីរយៈពេល 500 ឆ្នាំនេះ និងភាពច្របូកច្របល់ដែលកើតមានក្នុងអំឡុងពេលនោះ យើងអាចយល់ដឹងកាន់តែច្រើនអំពីការបម្រើរបស់ព្រះអង្គសង្គ្រោះ ហើយបន្តការតាំងចិត្តជាថ្មីរបស់យើងដើម្បីដើរតាមទ្រង់ ។

**និរទេស និង សេរីភាព ៖ តម្លៃនៃការមិនគោរពប្រតិបត្តិ**

ពួកព្យាការីដូចជា អេសាយ និង យេរេមាបានព្រមានដល់ប្រជាជនក្នុងយេរូសាឡឹមថា ប្រសិនបើពួកគេបន្តបំពានសេចក្ដីសញ្ញារបស់ពួកគេជាមួយនឹងព្រះអម្ចាស់ ទីក្រុងនេះ និង ព្រះវិហារបរិសុទ្ធរបស់ពួកគេនឹងត្រូវបានបំផ្លាញចោល ។ ព្យាករណ៍នេះបានបង្ហាញថាពិត នៅពេលបាប៊ីឡូនដំបូងឡើយបានគ្រប់គ្រងដោយសាសន៍យូដាប្រមាណជាឆ្នាំ 600 គ.ស. ដោយបំផ្លាញភូមិទីក្រុង និងជីវិតខាងសាសនារបស់វា ។

នៅទីបំផុតយេរូសាឡឹមបានធ្លាក់ចុះ ក្នុងឆ្នាំ 587 មុន.គ.ស. ហើយសាសន៍យូដាដែលគេនិរទេសត្រូវបានបង្ខំ ឲ្យចាកចេញពីដែនដីកំណើតរបស់ខ្លួនដែលត្រូវបានបំផ្លិចបំផ្លាញចោលអស់ (សូមមើល ទំនុកដំកើង 137:1) ។ មានមនុស្សមួយចំនួនបានបន្តរស់នៅក្នុងយេរូសាឡឹម និងតំបន់ជុំវិញនោះ—រួមមានសាសន៍សាម៉ារីដែលនៅទីបំផុតបាន

ព្យាការីអេសាយ និង យេរេមាបានព្រមានដល់ប្រជាជនយូដាថា ពួកគេនឹងត្រូវគ្រប់គ្រងដោយសាសន៍ដទៃ ។ ការព្យាកររបស់ពួកលោកបានកើតឡើង នៅពេលភូមិភាគនោះត្រូវបានគ្រប់គ្រងដោយស្ដេចជាច្រើនអង្គមកពីប្រទេសផ្សេងៗគ្នា ៖ ស្ដេចនេប៊ូក្នេសានៃបាប៊ីឡូន ស៊ីរ៉ូដ៏អស្ចារ្យនៃពើស៊ី ស្ដេចដារីយុសនៃពើស៊ី និង អាឡិចសាន់ឌើរដ៏អស្ចារ្យនៃក្រិក ។ កាលអាឡិចសាន់ឌើរបានសោយទីវង្គត់ទៅ ដែនដីរបស់ទ្រង់ត្រូវបានបែងចែកជាច្រើនក្រុមដោយពួកមេទ័ពរបស់ទ្រង់ ។ តូឡេមីទី 1 បានគ្រប់គ្រងប្រទេសប៉ាឡេស្ទីន ។



រៀបការនឹងអ្នកដែលមិនមែនជាសាសន៍អ៊ីស្រាអែល (សូមមើល យេរេមា 40:7, 11–12) ។ ក្រោយមកនិរទេសជនទាំងនោះបានចាប់ផ្ដើមត្រឡប់មកប្រទេសប៉ាឡេស្ទីនវិញ ហើយបានសង់ផ្ទះ និងសាសនារបស់ខ្លួនឡើងវិញ (សូមមើល អែសរ៉ា 3) ។ នៅទីបំផុត ព្រះវិហារបរិសុទ្ធនៅយេរូសាឡឹមត្រូវបានសង់ឡើងវិញត្រឹមឆ្នាំ 515 មុន.គ.ស. ជាថ្មីម្ដងទៀត ព្រះវិហារបរិសុទ្ធនេះបានក្លាយជាគ្រឹះដ៏សំខាន់នៃការថ្វាយបង្គំរបស់ពួកយូដា ។

ដោយសារសាសន៍យូដាបានបដិសេធការជួយរបស់សាសន៍សាម៉ារីដើម្បីសង់ព្រះវិហារបរិសុទ្ធឡើងវិញ សាសន៍សាម៉ារីបានសង់ព្រះវិហារបរិសុទ្ធមួយទៀតនៅចុងសតវត្សទីបួននៅលើភ្នំគេរិស៊ីមប្រមាណជា 64 គ.ម. ភាគខាងជើងនៃទីក្រុងយេរូសាឡឹម ។ ដូច្នេះ ការថ្វាយបង្គំ និង ជំនឿលើព្រះយេហូវ៉ាត្រូវបានបំបែកចេញពីគ្នា រវាងព្រះវិហារបរិសុទ្ធថ្មីនៅភ្នំគេរិស៊ីម និង ព្រះវិហារបរិសុទ្ធយេរូសាឡឹម ដោយសារពួកគេបានធ្វើជាសេចក្ដីប្រកាសអះអាងពីការមានភាពពេញលេញនៃអ្នកដឹកនាំបព្វជិតភាព (សូមមើល យ៉ូហាន 4:20) ។

ប៉ុន្តែបដិវត្តស៍នេះមិននៅបានយូរឡើយ ។ បន្ទាប់ពីម៉ាឡាគី ដូចដែលព្យាការីអេម៉ុសបានព្យាករ ព្រះអម្ចាស់បានចាត់ « អំណត់មកក្នុងស្រុកមិនមែនជាអំណត់ដែលអត់អាហារ ឬដែលស្រេកទឹកទេ គឺជាអំណត់ខាងឯការឮព្រះបន្ទូលនៃព្រះយេហូវ៉ាវិញ » (អេម៉ុស 8:11) ។ ការផ្លាស់ប្ដូរដ៏សំខាន់នេះបានបង្កើតនូវផលវិបាកដ៏ធំ កាលប្រជាជនចង់យល់ដឹង ហើយរស់នៅតាមក្រិត្យវិន័យ

BALAGE BALOUGH/ARTRESOURCE/NY; WAVEBREAKMEDIA LTD./THINKSTOCK; PHOTOS.COM/THINKSTOCK; DORLING KINDERSLEY/THINKSTOCK; GIANNIA DAGLI ORTI/THE ART ARCHIVE AT ART RESOURCE, NY; OLMARMAR/SHUTTERSTOCK.COM; BPK, BERLIN/MUENZKABINETT, STAATLICHE MUSEEN, BERLIN/REINHARD SACZEWSKI/ART RESOURCE, NY

200 មុន.គ.ស. | 150 មុន.គ.ស. | 100

សេឡឺស៊ីដ ឆ្នាំ 198 មុន គ.ស.

ការបះបោរឆ្នាំ 164 មុន គ.ស.

ឯករាជ្យរបស់ប្រជាជាតិយូដា ឆ្នាំ 142 មុន គ.ស.

ដោយគ្មានការបង្រៀន និង ការបកប្រែដ៏ត្រឹមត្រូវរបស់ព្យាការី ។

**ស្ថានភាពនៃការក្បត់សាសនា**

ជាលទ្ធផលនៃការក្បត់សាសនានេះ ប្រជាជនបានបំបែកខ្លួនទៅជាច្រើនក្រុមដោយមានរបៀបវារៈខាងនយោបាយ ខាងសាសនា និង ខាងសង្គមផ្សេងៗគ្នា ។ ពួកគេក៏មានជំនឿ និង ទំនៀមទម្លាប់អំពីព្រះមែស៊ីខុសគ្នាដែរ ។ ក្រុមសាសនាទាំងនោះបានព្យាយាមរស់នៅតាមច្បាប់របស់ម៉ូសេតាមរបៀបដែលពួកគេយល់ពីច្បាប់នោះ ហើយក្រុមនីមួយៗបានបកប្រែព្រះគម្ពីរដោយមានទស្សនៈផ្សេងៗពីគ្នាហេតុធ្វើឲ្យសង្គមរបស់សាសន៍យូដាបែកខ្ញែកគ្នាកាន់តែច្រើនឡើង ។ ជាលទ្ធផលការយល់ដឹងដ៏ពិតស្ដីពីព្រះអង្គសង្គ្រោះបានច្របូកច្របល់ទាំងស្រុង ។

កាលដែលសំឡេងរបស់ពួកព្យាការីបានស្ងប់ស្ងាត់ទៅ ពួកសង្ឃទាំងនោះ និង អ្នកធ្វើការនៅក្នុងព្រះវិហារបរិសុទ្ធរបស់ពួកគេដែលជាសាសន៍លេវី បានក្លាយជាមន្ត្រីដ៏សំខាន់បំផុតនៅក្នុងចំណោមពួកយូដា ហើយបានប្រកាសដោយខ្លួនឯងពីសិទ្ធិអំណាចដើម្បីបកប្រែព្រះគម្ពីរ ។ ប៉ុន្តែ តំណែងនៃសង្ឃជាន់ខ្ពស់នោះបានក្លាយទៅជាពុករលួយ ដោយសារវាត្រូវបានគេទិញដូរនៅអំឡុងគ្រានោះ ។

ពួកយូដាជាច្រើនបានមានអារម្មណ៍ថាពួកសង្ឃ និង ពួកលេវីមិនបានបំពេញទំនួលខុសត្រូវរបស់ពួកគេ ដើម្បីបង្រៀនពីច្បាប់ឲ្យបានត្រឹមត្រូវនោះទេ (សូមមើល ចោទិយកថា 33:10) ដូច្នេះធ្វើឲ្យក្រុមថ្មីមួយដែលខិតខំដើម្បីបង្រៀនពីច្បាប់នេះត្រូវបានបង្កើតឡើង ។ ដោយមាននាមតំណែងជាពួកអាចារ្យ ពួកគេបាន



ប្រទេសប៉ាឡេស្ទីនបានស្ថិតក្រោមការគ្រប់គ្រងរបស់ស្ដេចសេឡឺស៊ីដ ក្នុងចំណោមស្ដេចទាំងនោះមានស្ដេចមួយអង្គឈ្មោះ អាន់ទីអូខាស់ទី 4 អេពីហ្វាណេស ។ អាន់ទីអូខាស់បានបង្កើតវប្បធម៌របស់ក្រិកនៅក្នុងសង្គមយូដាដោយបង្ខំ ពេលខ្លះដោយការសម្លាប់ពួកយូដាជាច្រើននាក់ ដោយហាមឃាត់ការគោរពខាងសាសនាយូដា និង បំផ្លាញព្រះវិហារបរិសុទ្ធ ។ យូដាស ម៉ាកាប៊ីស ជាអ្នកដឹកនាំយូដាប្រឆាំងនឹងក្រិក បានដឹកនាំការបះបោរមួយ ហើយឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធឡើងវិញ ។ ប្រជាជនបានប្រារព្ធបុណ្យហានុកាដំបូង ។

តាំងខ្លួនគេឡើង តាមគំរូរបស់អែសរ៉ា ជាអ្នកដែលបានជួយប្រជាជននេះឲ្យមានអារម្មណ៍ចង់រៀន ហើយគោរពតាមច្បាប់ (សូមមើល អែសរ៉ា 7:25, នេហេមា 8:1–8) ។

អាឡិចសាន់ឌើរដ៏អស្ចារ្យបានគ្រប់គ្រងសាសនានេះក្នុងឆ្នាំ 332 មុន គ.ស. ។ កាលគាត់បានទទួលមរណភាពទៅ នគររបស់គាត់ត្រូវបានបំបែកជាច្រើនក្រុមដោយពួកមេទ័ពរបស់គាត់ ។ នៅពេលនោះ ប្រទេសប៉ាឡេស្ទីនស្ថិតនៅក្រោមអាណាចក្រសេឡឺស៊ីដដែលនិយាយភាសាក្រិក ។ ក្នុងឆ្នាំ 167 មុន គ.ស. អ្នកដឹកនាំរបស់សេឡឺស៊ីដបំពានលើសេចក្ដីជំនឿរបស់ពួកយូដា ដោយហាមប្រាមមិនឲ្យមានការកាត់ស្បែក ហើយប្រមាថដល់ព្រះវិហារបរិសុទ្ធដោយការថ្វាយសត្វជ្រូកជាដង្វាយនៅលើអសនៈ ។ ពួកយូដាជាច្រើនបានក្រោកតស៊ូ ដែលដឹកនាំដោយគ្រួសារមួយដែលគេហៅថា ម៉ាកាប៊ីស ឬហាស់ម៉ូនាន ។ ការបះបោរនោះ—ដែលបានហៅថា សង្គ្រាមម៉ាកាប៊ីន—នៅទីបំផុត បាននាំយកសេរីភាពមកឲ្យពួកយូដា ហើយបានបង្កើតជាប្រជាជាតិយូដាមួយជាលើកដំបូងចាប់តាំងពីការធ្លាក់ចុះរបស់យេរូសាឡឹម ។ នៅគ្រានោះដែរ មានក្រុមសាសនាមួយក្រុមទៀត ត្រូវបានបង្កើតឡើងដែលមានឈ្មោះថា ហាស៊ីឌាន មានន័យថា « គុណធម៌ » ។ ពួកគេបានបង្ហាញការលះបង់របស់ពួកគេចំពោះព្រះតាមរយៈការរស់នៅតាមគ្រប់ច្បាប់របស់ម៉ូសេនៅក្នុងរបៀបដែលពួកគេយល់ ។

ក្រុមសាសនាផ្សេងទៀតក៏បានកើតឡើងនៅក្នុងគ្រាអន្តរសញ្ញានោះដែរ ក្រុមនីមួយៗបានប្រកាសពីសិទ្ធិដើម្បីបកប្រែព្រះគម្ពីរ ។ ពួកផារ៉ាស៊ីគឺជាក្រុមសាសនាឯករាជ្យមួយដែលបានបង្កើតឡើងក្រោយពីសង្គ្រាមម៉ាកាប៊ីនមិនយូរ



មុន.គ.ស. 50 មុន.គ.ស. 1 មុន.គ.ស.



រ៉ូម ឆ្នាំ 63 មុន គ.ស.

ប៉ុន្មាន ។ ពួកគេបានក្លាយជាមនុស្សមានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងសង្គមពួកយូដា ដោយមានការផ្ដោតអារម្មណ៍ដ៏តូចមួយទៅលើច្បាប់អាហារ និងលើភាពបរិសុទ្ធខាងសាសនា និងកត្តានានាដែលត្រូវបានចាក់ឫសជាចម្បងដោយស្ថិតនៅលើតែទំនៀមទម្លាប់បបួរមាត់របស់ពួកគេ ប៉ុន្តែមិនមែនទៅលើព្រះគម្ពីរឡើយ ។ នៅក្នុងផ្ទះរបស់ពួកគេ ពួកគេព្យាយាមរៀបចំអាកប្បកិរិយាដូចជាពួកគេរស់នៅក្នុងព្រះវិហារបរិសុទ្ធ ។

រីឯពួកសាឌូស៊ីដែលគ្មាននូវការស្គាល់ពីប្រភពដើមរបស់ពួកគេ បានបដិសេធនៅរាល់ទំនៀមទម្លាប់ផ្ទាល់មាត់ ហើយប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់តាមគម្ពីរទាំងប្រាំរបស់ម៉ូសេ ដោយបដិសេធចោលនូវការសរសេរនានារបស់ពួកព្យាការីផ្សេងទៀត ។ ភាគច្រើនក្រុមនេះមានសុទ្ធតែពួកអ្នកមានមុខមាត់នៅក្នុងសង្គមយេរូសាឡិម ។ លុះដល់គ្រាព្រះយេស៊ូវប្រសូត ពួកគេបានពង្រីកអំណាចរបស់ខ្លួនតាមរយៈការអះអាងដើម្បីគ្រប់គ្រងព្រះវិហារបរិសុទ្ធយេរូសាឡិម ។

ក្នុងចំណោមក្រុមសាសនាទាំងនេះ ក្រុមនីមួយៗបានរក្សាទំនៀមទម្លាប់ និង គោលលទ្ធិដែលពួកគេជឿថាវាចាំបាច់ចំពោះជីវិតនៃភក្ដីភាព ។ ប៉ុន្តែដោយសារពួកគេខ្វះនូវការដឹកនាំពីព្យាការីពិត ពួកគេបានធ្វើការបកប្រែនានាដោយខ្លួនឯង ។

**ការទន្ទឹងរង់ចាំគ្រាកាន់កាប់ត្រួតត្រាថ្មីមួយ**

ថ្វីបើមានការបញ្ចុះបញ្ចូលតាមសាសនារបស់ខ្លួនគេក្ដី ក៏មានបុរស និង ស្ត្រីសុចរិតនៅតែទន្ទឹងរង់ចាំដល់ការយាងមករបស់ព្រះមែស៊ីនៅអំឡុងគ្រាអន្តរសក្ខីភាពនោះដែរ ។ ពួកគេបានច្រៀងទំនុកដំកើង ហើយប្រជាជនទូទៅបានអធិស្ឋាន បានជជែកគ្នា ហើយបានសុបិន

បន្ទាប់ពីបានឯករាជ្យក្នុងរយៈពេលមួយដ៏ខ្លី យេរូសាឡិមបានធ្លាក់នៅក្រោមការគ្រប់គ្រងរបស់រ៉ូម កាលប៉ុមពេដ៏អស្ចារ្យវាយលុកមកលើទីក្រុងនេះ ។ ពួករ៉ូមបានថ្វាយតំណែងជូនស្ដេចហេរ៉ូឌដ៏អស្ចារ្យ ជាពូជពង្សរបស់អេសៅ ធ្វើជាស្ដេចដែលពឹងផ្អែកលើអំណាចរបស់រ៉ូមឲ្យគ្រប់គ្រងស្រុកយូដា ។ ទ្រង់បានសង់យេរូសាឡិមឡើងវិញ ហើយបានពង្រីកបរិវេណព្រះវិហារបរិសុទ្ធ ។ សេសារ អូគូស្ទ បានបញ្ចប់ការគ្រប់គ្រងរបស់ពួកសាធារណរដ្ឋនៅក្នុងរ៉ូម ហើយបានក្លាយជាស្ដេចរ៉ូមទីពីរបន្ទាប់ពីជូលីអុស សេសារ ។



ពីការយាងមកដល់របស់ទ្រង់—ជាពូជហ្លួងដាវីឌជាអង្គដែលត្រូវបានកំណត់ឲ្យមកសង្គ្រោះដល់រាស្ត្រទ្រង់ ។

ក្រុមមួយដែលបានរង់ចាំព្រះមែស៊ីគឺក្រុមអេសេណេស ដែលបានបង្កើតឡើងនៅក្នុងគ្រាវិបត្តិម៉ាកាប៊ីន ។ ពួកអេសេណេសបានជឿថាពួកសង្ឃក្នុងព្រះវិហារបរិសុទ្ធនៅយេរូសាឡិមមានភាពពុករលួយ ហើយព្រះវិហារបរិសុទ្ធត្រូវការកែទម្រង់ឡើងវិញ ។ នៅក្នុងទស្សនៈពួកគេ ការយាងមករបស់ព្រះមែស៊ីជិតមកដល់ហើយ ។ ពួកគេបានជឿថា ទ្រង់នឹងចូលរួមនឹងពួកគេ ដើម្បីផ្ដួលរំលំពួករ៉ូម ដែលជាអ្នកគ្រប់គ្រងលើពួកប៉ាឡេស្ទីនប្រមាណជា 60 ឆ្នាំពីមុនការប្រសូតរបស់ព្រះយេស៊ូវ ។

ដូចគ្នានឹងការធ្វើកំណែទម្រង់ដែលនាំទៅរកការស្ដារឡើងវិញដែរ គ្រាអន្តរសញ្ញាក៏ស្ដែងឲ្យឃើញពីព្រឹត្តិការណ៍ដែលបានរៀបចំពិភពលោកសម្រាប់ការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ។ នៅគ្រានេះមានការផលិតនៃអត្ថបទជាច្រើនខាងសាសនា រួមមានការបកប្រែនៃព្រះគម្ពីរប៊ីបភាសាហេព្រើរជាភាសាក្រិក និងការចាប់ផ្ដើមនៃការបង្កើតនូវក្រាំងមូល និង អត្ថបទអនាមិកដ៏អស្ចារ្យបំផុត ។ ក្នុងពេលនេះគំនិតស្ដីពីពួកទេវតា ការរស់ឡើងវិញ និង ទស្សនៈស្ដីពីស្ថានសួគ៌ និង ស្ថាននរកបានប្រឌិតឡើងយ៉ាងច្រើន ។

ប៉ុន្តែដោយគ្មានព្យាការីដឹកនាំពួកគេ ពួកយូដាបានជជែកពិភាក្សាគ្នាពីអត្ថន័យរបស់ព្រះគម្ពីរនិងថាតើព្រះមែស៊ីជានរណា ។ កាលមនុស្សភាគច្រើនបានរង់ចាំព្រះមែស៊ីដែលជាពូជពង្សរបស់ដាវីឌ (ជាអង្គដែលជាប់ខ្សែស្រឡាយនឹងស្ដេចដាវីឌ) មានមនុស្សផ្សេងទៀតបានគាំទ្រដល់ព្រះ

ខាងឆ្វេង ៖ រូបចម្លាក់ bpk, BERLIN/ALTES MUSEEN OF STAATLICHE/INGRID GESKE/ART RESOURCE, NY; PHOTOGRAPH OF MENORAH BY PUMBA1/ISTOCK/THINKSTOCK
ខាងស្ដាំ ៖ ALINARI/ART RESOURCE, NY PUMBA1/ISTOCK/THINKSTOCK TIMOTHY L. TAGGART © IRI

**4 មុន.គ.ស.**

**ហេរូឌដ៏អស្ចារ្យ**

**សេសារ អូគូស្ទ**

**ប៉ុនទាស ពីឡាត់**

ម៉ែស៊ីដែលជាពូជពង្សរបស់អើរ៉ុន—ជាសង្ឃម៉ែស៊ី ។ មានមនុស្សផ្សេងទៀតនៅតែ គិតថាព្រះម៉ែស៊ី នឹងមិនយាងមកឡើយ ។

មានការរំពឹងទុកជាច្រើនបានកើតមាននៅក្នុងក្រុមផ្សេងៗគ្នាអំឡុងគ្រាអន្តរសញ្ញានោះរហូតធ្វើឲ្យក្រុមទាំងនោះមិនដឹងពីរបៀបដើម្បីស្គាល់ពីព្រះម៉ែស៊ីពិត កាលទ្រង់បានយាងមកកាន់ពួកគេ ។ គ្មានក្រុមណាមួយ—ទាំងពួកអាចារ្យ ពួកផារ៉ាស៊ី ពួកអេសេណេស ឬពួកសាឌូស៊ី—បានទទួលស្គាល់យ៉ូហាន បាទីស្ទជាព្យាការី ឬព្រះយេស៊ូវ គ្រីស្ទជាព្រះម៉ែស៊ីឡើយ ។ មានសមាជិកមួយចំនួនក្នុងក្រុមនេះបានក្លាយជាសត្រូវដ៏សំខាន់របស់យ៉ូហាន និង ព្រះយេស៊ូវកាលទ្រង់បម្រើនៅលើផែនដី (សូម មើល ម៉ាថាយ 21:23–46) ។

ការជជែកពិភាក្សា និង ការប្រកែកគ្នាក្នុងចំណោមក្រុមផ្សេងៗគ្នា អំពីព្រះម៉ែស៊ីចេះតែកើតជាបន្តបន្ទាប់ ។ ព្យាការីដំបូងនៃគ្រាកាន់កាប់ត្រួតត្រាថ្មី យ៉ូហាន បាទីស្ទ បានប្រកាសពីការយាងមករបស់ព្រះម៉ែស៊ីដ៏ពិត ហើយបានបញ្ជាក់ពីប្រភេទនៃសេចក្ដីសង្គ្រោះដែលទ្រង់នឹងប្រទានឲ្យ ។ យ៉ូហានបានថ្លែងបញ្ជាក់ពីព្រះយេស៊ូវគ្រីស្ទថា « នុះន៏ កូនចៀមនៃព្រះដែលដោះបាបមនុស្សលោក » (យ៉ូហាន 1:29) ។ ពួកយូដាជាច្រើនបានទទួលស្គាល់យ៉ូហានកាលគាត់បានរៀបចំប្រជាជនសម្រាប់យាងមករបស់ព្រះគ្រីស្ទ ។

កាលព្រះយេស៊ូវគ្រីស្ទចាប់ផ្ដើមការបម្រើរបស់ទ្រង់ ទ្រង់បានបង្រៀនដល់ប្រជាជននេះ « ដូចជាមានអំណាចមិនមែនដូចពួកអាចារ្យរបស់គេទេ » (ម៉ាថាយ 7:29) ។ ទ្រង់មានការពិភាក្សាជាច្រើននឹងពួកអ្នកដឹកនាំសាសនា ដោយបញ្ជាក់ពីគោលលទ្ធិនៃអាពាហ៍ពិពាហ៍ ការរស់ឡើងវិញ



**ក្នុងការគ្រប់គ្រងរបស់សេសារ អូគូស្ទ និង ហេរូឌដ៏អស្ចារ្យ ព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទបានប្រសូតនៅភូមិបេថ្លេហិម ។ ទ្រង់បានប្រសូតជាស្ដេចនៃអស់ទាំងស្ដេច និង ជាព្រះអម្ចាស់នៃអស់ទាំងព្រះអម្ចាស់ (សូមមើល អេសាយ 44:6) ។**

ក្រុមព្រះ និងតួនាទីទ្រង់ជាព្រះអង្គសង្គ្រោះ ។ ដោយសារមានពួកអ្នកដឹកនាំសាសនាជាច្រើនបានបដិសេធទ្រង់ (សូមមើល ម៉ាថាយ 26:4) ព្រះយេស៊ូវមានបន្ទូលប្រាប់ពួកគេថា ៖ « អ្នករាល់គ្នាមិនស្គាល់ខ្ញុំ ឬព្រះវរបិតាខ្ញុំទេ៖ បើសិនជាអ្នករាល់គ្នាបានស្គាល់ខ្ញុំ នោះនឹងស្គាល់ដល់ព្រះវរបិតាខ្ញុំដែរ » ។ ទ្រង់បានបន្ថែមទៀតថា « បើព្រះជាព្រះវរបិតារបស់អ្នករាល់គ្នាមែន នោះអ្នកនឹងបានស្រឡាញ់ខ្ញុំ » (យ៉ូហាន 8:19, 42) ។

ដោយសារពួកគេបានគិតថាព្រះម៉ែស៊ីខុសគ្នាពីព្រះយេស៊ូវ នោះពួកគេបានបដិសេធទ្រង់ ។ ជាភ័ព្វសំណាងណាស់ដែលយើងរស់នៅក្នុងសម័យមួយដែលសេចក្ដីពិតនៃដំណឹងល្អត្រូវបានស្ថាបនានៅលើការបង្រៀនដែលជាគ្រឹះរបស់ពួកព្យាការី និងពួកសាវក (សូមមើលអេភេសូរ 2:20) ។ យើងពុំចាំបាច់ត្រូវជ្រើសរើសនៅក្នុងចំណោមឥទ្ធិពលផ្ទុយគ្នាខាងវិញ្ញាណដែលកើតឡើង ដោយសារតែគ្មានការដឹកនាំពីពួកព្យាការី និង ពួកសាវកឡើយ ។ កាលយើងធ្វើតាមពួកព្យាការី និង ពួកសាវកថ្ងៃចុងក្រោយ យើងនឹងយល់ដឹងពីគោលលទ្ធិពិតនៃព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ដូចដែលបានបើកសម្ដែងដល់ព្យាការី យ៉ូសែប ស្ម៊ីធ ថា ៖

« ត្បិត [ខ្ញុំ] បានឃើញទ្រង់គង់នៅខាងស្ដាំព្រះហស្តនៃព្រះ ហើយ [ខ្ញុំ] បានឮសំឡេងដែលថ្លែងទីបន្ទាល់ថា ទ្រង់គឺជាបុត្រាបង្កើតតែមួយនៃព្រះវរបិតា—

« ថាដោយសារព្រះអង្គ និងតាមរយៈព្រះអង្គ ហើយពីព្រោះព្រះអង្គ នោះពិភពលោកទាំងឡាយមានឡើង ហើយបានបង្កើតមក ហើយបណ្ដាជននៅទីនោះគឺជាបុត្រាបុត្រីបង្កើតចំពោះព្រះ » (គ. និង ស. 76:23–24) ។ ■



# ក្រាំងរមូរនៅសមុទ្រស្លាប់

## ជាឧបករណ៍ជួយយើងឲ្យយល់ពីព្រះគម្ពីរប៊ីបសម័យទំនើប

**ដោយ ដូណាល់ ដបុលយូ ផារី**

សាស្ត្រចារ្យផ្នែកព្រះគម្ពីរប៊ីបហេព្រើរនៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់

នៅដើមឆ្នាំ 1947 មានពួកគង្វាលបីនាក់ដែលជាកុលសម្ព័ន្ធតាអាមីរបេឌូអិនបានដើរស្វែងរកសត្វមួយក្បាលដែលបាត់ ។ មានពួកគេម្នាក់បានចោលថ្មមួយដុំចូលទៅក្នុងរូងមួយ ហើយឮសូរសំឡេងដូចជាក្អមបែក ។ កាលពួកគេបានចូលទៅក្នុងរូងនោះ ពួកគេបានឃើញមានក្អមធំៗមួយចំនួន ហើយខ្លះមានក្រាំងរមូរដាក់នៅក្នុងនោះ ។* ច្រើនឆ្នាំក្រោយមក ពួកបេឌូអិន និង បុរាណវិទូបានរកឃើញក្រាំងរមូរជាច្រើននៅក្នុងរូងចំនួន 11 កន្លែងនៅឆ្នេរទិសពាយព្យនៃសមុទ្រស្លាប់នោះ។

មានពួកអ្នកប្រាជ្ញជាច្រើនជឿថា ក្រាំងរមូរនៅសមុទ្រស្លាប់គឺជាការរកឃើញផ្នែកវត្ថុបុរាណដ៏ធំជាងគេបំផុតក្នុងសតវត្សរ៍ទី 20 ។ ក្រាំងរមូរទាំងនោះបានផ្ដល់ជាបណ្ណាល័យបុរាណមួយដែលមានចំនួនច្រើនជាង 900 អត្ថបទ ភាគច្រើនត្រូវបានសរសេរជាភាសាហេព្រើរដើមនៃព្រះគម្ពីរសញ្ញាចាស់ ។ មានក្រាំងរមូរប្រមាណជា 225 រមូរដែលមាននូវច្បាប់ចម្លងដ៏ចំណាស់បំផុតនៃព្រះគម្ពីរសញ្ញាចាស់ (លើកលែងតែគម្ពីរនាងអេសធើរ) ដែលចាស់ជាងច្បាប់ចម្លងដែលបានប្រើនៅក្នុងគ្រានៃប្រវត្តិសាស្ត្ររបស់ទ្វីបអឺរ៉ុបដល់ទៅ 1,00 ឆ្នាំ ។ ក្រាំងរមូរទាំងនោះភាគច្រើនមានកាលបរិច្ឆេទចន្លោះឆ្នាំ 150 មុន គ.ស. និង គ.ស. 68 ទោះជាយ៉ាងណាមានអត្ថបទមួយចំនួនមានកាលបរិច្ឆេទរហូតដល់ទសវត្សរ៍ទីបី មុន គ.ស. ។

បន្ថែមពីលើអត្ថបទព្រះគម្ពីរប៊ីបពីបុរាណ ក្រាំងរមូរនៅសមុទ្រស្លាប់ក៏មាននូវក្រាំងរមូររបស់ព្រះវិហារបរិសុទ្ធ (ការរៀបរាប់ពីព្រះវិហារបរិសុទ្ធមួយត្រូវបានសង់នៅយេរូសាឡឹម និង សង្គមនៃសេចក្ដីសញ្ញាដ៏ល្អបំផុត) ក្រាំងរមូរនៅពេលសង្គ្រាម (រៀបរាប់ពីថ្ងៃបញ្ចប់វិបត្តិ) និងអត្ថបទស្រដៀងគ្នានឹងព្រះគម្ពីរប៊ីប (ដូចជាគម្ពីរអេណុក ណូអេ មិលគីស្សាដែក និង គម្ពីរយ៉ាកុប យូដា និងលេវី) ។ នៅក្នុងព្រះគម្ពីរប៊ីបបានរៀបរាប់តិចតួចណាស់ពីអេណុក ប៉ុន្តែក្នុងក្រាំងរមូរទាំងនោះ អេណុកគឺជាតួអង្គដ៏សំខាន់ម្នាក់—ជាព្យាការីដ៏អស្ចារ្យដោយមាននូវអំណោយទានដ៏ពិសេសជាច្រើន ។

ក្រាំងរមូរទាំងភាគច្រើនត្រូវបានពុករហែកខ្ទេចខ្ទីដោយអាយុកាល និងអាកាសធាតុ ប៉ុន្តែពួកអ្នកប្រាជ្ញអាចរៀននូវព័ត៌មានជាច្រើនអំពីរបៀបដែលពួកអាចារ្យបានធ្វើកិច្ចការរបស់ពួកគេ ។ កិច្ចការដ៏ប្រុងប្រយ័ត្ន ហើយផ្ចិតផ្ចង់បំផុតរបស់ពួកអាចារ្យចង្អុលបង្ហាញពីកម្រិតដ៏ខ្ពស់មួយនៃជំនាញ និងសមត្ថភាព កាលពួកគេចម្លង ហើយប្រគល់អត្ថបទដ៏ពិសិទ្ធទាំងឡាយពីជំនាន់មួយទៅជំនាន់មួយទៀត ។ ពួកយើងដែលស្រឡាញ់ ហើយមានអំណរគុណចំពោះព្រះគម្ពីរបរិសុទ្ធបានជំពាក់គុណយ៉ាងធំចំពោះពួកអាចារ្យទាំងនេះសម្រាប់កិច្ចការដ៏ផ្ចិតផ្ចង់របស់ពួកគេ ។

នៅពេលយើងគិតពិចារណាពីវិធីសាស្ត្រនៃការកត់ចម្លងអត្ថបទនានាដោយដៃកាលពីបុរាណ យើងបានដឹងថាព្រះគម្ពីរប៊ីបបានឆ្លងកាត់នូវដំណើរការដ៏អស្ចារ្យមួយ ដើម្បីបានគង់វង្សរហូតមកដល់សតវត្សរ៍នេះ ។ ក្រាំងរមូរនៅសមុទ្រស្លាប់បានឈរជាសាក្សីថា ព្រះគម្ពីរសញ្ញាចាស់បានប្រគល់តៗគ្នាជាច្រើនសតវត្សរ៍ជាមួយនឹងកម្រិតនៃភាពត្រឹមត្រូវមួយដែលគួរឲ្យគោរព ។ ដោយហេតុផលនេះ យើងត្រូវតែមានអំណរគុណចំពោះពួកព្យាការី ពួកអាចារ្យ និងអ្នកចម្លងដោយដៃ និងមនុស្សគ្រប់គ្នាដែលមានទំនួលខុសត្រូវក្នុងការកត់ចម្លងព្រះគម្ពីរប៊ីប ហើយប្រគល់បន្តពីមួយជំនាន់ទៅមួយជំនាន់ទៀត ។ ■

** ដំណើររឿងស្ដីពីរបៀបដែលក្រាំងរមូរទាំងឡាយត្រូវបានគេរកឃើញ ដោយសារពួកគង្វាលបានពឹងផ្អែកទៅលើការចងចាំរបស់ពួកគេ ហើយប្រាប់ពីដំណើររឿងនោះឡើងវិញនៅច្រើនឆ្នាំក្រោយមក ។*

រូបថតពីឆ្វេង IGDRZH/ISTOCK/THINKSTOCK; រូបថតទី 4 ដោយ RICHO-FAN/ISTOCK/THINKSTOCK





**ដោយ ប៊ីស្សព**
**ហ្គែរី អ៊ី ស្ទីវិនសុន**
ប៊ីស្សពជាអធិបតី

# ធាតុពិត
# នៃបុណ្យគ្រីស្ទម៉ាស់

*បើគ្មានការប្រសូត និង ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះនោះទេ យើងនឹងគ្មានព្រះអង្គសម្របសម្រួល ព្រះអង្គគាំទ្រជាមួយនឹងព្រះវរបិតា និងគ្មានអង្គកណ្ដាល ដែលអាចធ្វើឲ្យយើងអាចត្រឡប់ទៅវត្តមាននៃព្រះវរបិតាសួគ៌ជាទីស្រឡាញ់ របស់យើង ហើយរស់នៅរួមគ្នាជាក្រុមគ្រួសារដ៏អស់កល្បបានឡើយ ។*

កាលឪពុកខ្ញុំនៅពីក្មេង គាត់បានរស់នៅក្នុងក្រុងតូចមួយនៅកណ្ដាលរដ្ឋយូថាហ៍ក្បែរបឹងយូថាហ៍ ។ នៅជំនាន់ពីមុនពួកអ្នកត្រួសត្រាយផ្លូវ ជនជាតិអាមេរិកដើមបានធ្វើការបបាញ់សត្វ និងការស្ទូចត្រីនៅតំបន់នេះ ។ មានកន្លែងជាក់លាក់ជាច្រើននៅជុំវិញបឹងនេះ បានក្លាយទៅជាល្បីល្បាញចំពោះ អស់អ្នកដែលចង់ស្វែងរកក្បាលព្រួញពីបុរាណ ។

នៅក្នុងសកម្មភាពសម្រាប់ឪពុកនិងកូនប្រុស កាលឪពុកខ្ញុំមានអាយុប្រាំឆ្នាំ រ៉ូដរបស់គាត់បានទៅបឹងយូថាហ៍ដើម្បីស្វែងរកក្បាលព្រួញពីបុរាណ ។ បន្ទាប់ពីក្រុមនេះបានចំណាយពេលពេញមួយថ្ងៃ ដើររកក្បាលព្រួញ លោកតាខ្ញុំបានសួរដល់ឪពុកខ្ញុំថាតើគាត់មានបានរកឃើញក្បាលព្រួញដែរឬទេ ។

ឪពុកខ្ញុំតបថា « ទេ កូនមិនបានរកឃើញសោះសូម្បីតែមួយ » ។ រួចគាត់បានលូកដៃចូលក្នុងហោប៉ៅគាត់ ហើយពោលថា « តែកូនបានរកឃើញដុំថ្មដ៏ស្រស់ស្អាតនេះដែលមានរាងដូចជាដើមឈើគ្រីស្ទម៉ាស់ » ។

តាមពិតទៅឪពុកខ្ញុំបានរកឃើញក្បាលព្រួញមួយ ប៉ុន្តែគាត់មិនបានស្គាល់វានោះទេ ។ គាត់បានកាន់វានៅក្នុងដៃ ប៉ុន្តែគាត់មិនបានស្គាល់ទេ ។

**ការស្គាល់ព្រះដ៏ប្រោសលោះ**

សព្វថ្ងៃនេះសម្រាប់មនុស្សជាច្រើន ទស្សនៈរបស់ខ្លួនស្ដីពីអ្វីដែលពិត ហើយសំខាន់បំផុត—ព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃពិភពលោក—ត្រូវបានធ្វើឲ្យស្រពិចស្រពិលដោយរឿងទាំងឡាយដែលមិនពិត ។

ថ្មីៗនេះ ខ្ញុំបានឃើញកម្មវិធីទូរទស្សន៍មួយស្ដីពីព្រះយេស៊ូវគ្រីស្ទ ដែលបានចោទសួរថាតើទ្រង់ពិតជាបានប្រសូតមកពីស្ត្រីព្រហ្មចារីឈ្មោះម៉ារាមែនឬ ។ សូម្បីតែពួកសាស្ត្រាចារ្យមកពីស្ថាប័នអប់រំដ៏ល្បីៗជាច្រើនក៏នៅមានការងឿងឆ្ងល់ពីបញ្ហានេះដែរ ។

ប្រធានអ៊ែសរ៉ា ថាហ្វ បែនសឹន (1899–1994) បានថ្លែងទៅកាន់ពួកអ្នកមានការសង្ស័យបែបនេះថា ៖ « ជនដែលហៅខ្លួនថាជាពួកអ្នកប្រាជ្ញានោះបានខិតខំធ្វើឲ្យយើងជឿថា ការប្រសូតដ៏ទេវភាពរបស់ព្រះគ្រីស្ទ ដែលបានប្រកាសនៅក្នុងព្រះគម្ពីរសញ្ញាថ្មីពុំមែនជារឿងដ៏ទេវភាព ហើយថាម៉ារាពុំមែនជាស្ត្រីព្រហ្មចារីនៅគ្រានៃការចាប់បដិសន្ធិរបស់ព្រះយេស៊ូវនោះទេ ។ ពួកគេចង់ឲ្យយើងជឿថា យ៉ូសែបដែលជាឪពុកចិញ្ចឹមរបស់ព្រះយេស៊ូវ គឺជាឪពុកបង្កើតរបស់ទ្រង់ ហេតុដូច្នេះហើយព្រះយេស៊ូវគឺជាមនុស្សលោកទាំងអត្តចរិក និង បុគ្គលិកលក្ខណៈ ។ ពួកគេបង្ហាញសេចក្ដីសប្បុរសនៅក្នុងការកោតសរសើររបស់ពួកគេចំពោះទ្រង់ កាលពួកគេថ្លែងថា ទ្រង់គឺជាទស្សនវិទូខាងសីលធម៌ដ៏អស្ចារ្យមួយរូប ឬព្រមទាំងអស្ចារ្យជាងគេបំផុតទៀតផង ។ ប៉ុន្តែគោលបំណងដ៏សំខាន់នៃកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេគឺដើម្បីបដិសេធនូវភាពជាព្រះរាជបុត្រាដ៏ទេវភាពរបស់ព្រះយេស៊ូវ ដោយព្រោះថាគោលលទ្ធិនេះ ជាគ្រឹះនៃការអះអាងនានាឯទៀតនៃពិភពសាសនាគ្រីស្ទទាំងអស់ » ។[1]

ខ្ញុំធ្លាប់ជិះស្គីនៅលើទឹកកកសប្បនិម្មិត ហើយធ្លាប់តុបតែងដើមគ្រីស្ទម៉ាស់ជ័រជាមួយនឹងដុំទឹកកកក្លែងក្លាយ ។ ពេលខ្លះវាពិបាកណាស់ដើម្បី



យល់ស្គាល់នូវអ្វីដែលពិតប្រាកដ ជាពិសេសនៅក្នុងជំនាន់នៃជីវិតនិម្មិតនេះ ។ ដូច្នេះតើយើងស្គាល់អ្វីដែលពិតជាក់ស្តែងតាមរបៀបណាបាន ? តើយើងទទួលបានទីបន្ទាល់មួយ អំពីភាពពិតជាក់ស្តែងរបស់ព្រះយេស៊ូវគ្រីស្ទតាមរបៀបណា ?

យើងទទួលបានទីបន្ទាល់មួយស្តីពីអ្វីដែលពិតកាលណាយើងអានព្រះបន្ទូលនៃព្រះនៅក្នុងព្រះគម្ពីរ—ទាំងសម័យបុរាណ និង សម័យទំនើប ។ យើងរៀនពីភាពពិតជាក់ស្តែងរបស់ព្រះអង្គសង្គ្រោះកាលណាយើងស្តាប់ ហើយអានទីបន្ទាល់របស់ពួកព្យាការី និង ពួកសាវកដែលរស់នៅសព្វថ្ងៃ ។ យើងរកឃើញការពិត កាលណាយើងអធិស្ឋាន « ដោយចិត្តស្មោះស គឺដោយស្មោះអស់ពីចិត្ត ដោយមានសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ » (មរ៉ូណៃ 10:4) ។ យើងរកឃើញ « ផ្លូវត្រឹមត្រូវ » កាលណាយើង « ជឿដល់ព្រះគ្រីស្ទ ហើយមិនបដិសេធទ្រង់ » ហើយកាលណាយើង « ក្រាបចំពោះទ្រង់ ហើយថ្វាយបង្គំឲ្យអស់ពីសមត្ថភាព អស់ពីគំនិត អស់ពីកម្លាំង [របស់យើង] ហើយអស់ពីព្រលឹងទាំងមូល [របស់យើង] » (នីហ្វៃទី 2 25:29) ។

## ការព្យាករអំពីការប្រសូតរបស់ព្រះគ្រីស្ទ

ព្រះគម្ពីរបានចែងដូចៗគ្នាពីការព្យាករនោះស្តីពីការប្រសូតរបស់ព្រះគ្រីស្ទ—ជាបុណ្យគ្រីស្ទម៉ាស់ដំបូង ។ យើងអាចនឹងភ្លេចនូវគ្រាដែលយើងអានការព្យាករទាំងនេះក្នុងបទគម្ពីរថាវាពិតជា*ការព្យាករ* ។ វាផ្តល់នូវព័ត៌មានលម្អិតជាច្រើន អំពីអ្វីដែលនឹងកើតឡើង ប៉ុន្តែមិនទាន់បានកើតឡើងនៅឡើយ ។

ការព្យាករ ៖ លោកអេសាយបានព្យាករអំពីកំណើតរបស់ព្រះគ្រីស្ទថា ៖ « ដ្បិតមានបុត្រមួយកើតដល់យើង ព្រះទ្រង់ប្រទានបុត្រាមួយមកយើង ហើយឯការគ្រប់គ្រងនឹងនៅលើស្មារបស់បុត្រនោះ ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ ព្រះដ៏មានព្រះចេស្តា ព្រះវរបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព » (អេសាយ 9:6) ។

ប្រាំមួយរយឆ្នាំពីមុនព្រះអង្គសង្គ្រោះបានប្រសូត នីហ្វៃបានរៀបរាប់ពីការនិមិត្តមួយដែលលោកបានឃើញ អំពីព្រះមាតារបស់ព្រះរាជបុត្រានៃព្រះថា ៖

« ខ្ញុំបានឃើញ . . . ហើយនៅភូមិណាសារ៉ែត ខ្ញុំបានឃើញនាងព្រហ្មចារីម្នាក់ ហើយនាងស្រស់ល្អ ហើយសដ៏លើសលប់ ។ . . .

« ហើយទេវតាមានបន្ទូលមកខ្ញុំថា ៖ មើលចុះ នាងព្រហ្មចារីយ៍ដែលអ្នកឃើញនោះគឺជាមាតារបស់ព្រះរាជបុត្រានៃព្រះ ។ . . .

« ហើយខ្ញុំក៏មើលហើយបានឃើញនាងព្រហ្មចារីម្តងទៀតនាងកំពុងតែបីព្រះឱរសក្នុងដៃរបស់នាង ។

« ហើយទេវតាមានបន្ទូលមកខ្ញុំថា ៖ មើលន៏កូនចៀមនៃព្រះ » (នីហ្វៃទី 1 11:13, 18, 20–21) ។

មួយរយម្ភៃបួនឆ្នាំពីមុនការប្រសូតរបស់ព្រះអង្គសង្គ្រោះ ស្តេចប៊េនយ៉ាមីនបានមានបន្ទូលថា ៖

« មើលចុះ ថ្ងៃនោះនឹងមកដល់ គឺមិនយូរប៉ុន្មានទេ គឺដោយព្រះចេស្តា នោះព្រះអម្ចាស់ដ៏មានគ្រប់ព្រះចេស្តា . . . នឹងយាងចុះមកពីស្ថានសួគ៌មករស់នៅក្នុងចំណោមកូនចៅមនុស្ស ហើយនឹងគង់នៅក្នុងរោងឧបោសថឥដ្ឋ ហើយនឹងយាងទៅក្នុងចំណោមមនុស្ស ដោយសម្តែងអព្ភូតហេតុផ្សេងៗ ។ . . .

« ហើយទ្រង់នឹងត្រូវបានហៅថា ព្រះយេស៊ូវគ្រីស្ទ ព្រះរាជបុត្រានៃព្រះ ព្រះវរបិតានៃស្ថានសួគ៌ និងផែនដី ព្រះដែលបង្កើតវត្ថុសព្វសារពើចាប់តាំងពីដំបូងមក ហើយមាតារបស់ព្រះអង្គនឹងត្រូវបានហៅថា ម៉ារា » (ម៉ូសាយ 3:5, 8) ។

ប៉ែតសិបបីឆ្នាំពីមុនការប្រសូតរបស់ព្រះគ្រីស្ទ អាលម៉ាបានថ្លែងថា « ហើយមើលចុះ [ព្រះរាជបុត្រានៃព្រះ] នឹងប្រសូតមកពីនាងម៉ារានៅក្នុងយេរូសាឡិម ដែលជាដែនដីរបស់ពួកអយ្យកោដើមរបស់យើង នាងជាស្ត្រីព្រហ្មចារីគឺជាប្រដាប់ដ៏ជំរើស » (អាលម៉ា 7:10) ។

ហើយរយៈពេលតែប្រាំមួយឆ្នាំពីមុនបុណ្យគ្រីស្ទម៉ាស់ដំបូងប៉ុណ្ណោះ សាំយ៉ូអែលសាសន៍លេមិនបានប្រកាសថា៖

### ការស្វែងរកព្រះអង្គសង្គ្រោះ



« ពេលខ្លះរឿងដ៏មានតម្លៃ ហើយសំខាន់បំផុតនោះគឺស្ថិតនៅចំពោះមុខយើង ឲ្យយើងឃើញយ៉ាងច្បាស់ ប៉ុន្តែយើងមិនអាចឬមើលវាមិនឃើញឡើយ . . .។

« ខ្ញុំសូមសន្យាថា ប្រសិនបើយើងពង្រឹងជីវិតរបស់យើងបន្តិច ហើយស្វែងរកព្រះគ្រីស្ទដ៏បរិសុទ្ធ ហើយទន់ភ្លន់ដោយអស់ពីចិត្តយើងនៅក្នុងភាពស្មោះត្រង់ ហើយរាបសារ នោះយើងនឹងឃើញទ្រង់—នៅថ្ងៃបុណ្យគ្រីស្ទម៉ាស់ និងពេញមួយឆ្នាំ » ។

**ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ជាទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ «How to See the Christ in Christmas, » *New Era,* ខែ ធ្នូ ឆ្នាំ 2013 ទំព័រ 48 ។**

« ហើយមើលចុះ នេះខ្ញុំនឹងឲ្យទីសំគាល់មួយដល់អ្នករាល់គ្នាគឺនៅពេលទ្រង់នឹងយាងមក ត្បិតមើលចុះ គឺនឹងមានពន្លឺដ៏មហិមានៅលើមេឃដរាបដល់ក្នុងពេលយប់មុនទ្រង់នឹងយាងមកគឺពុំមានភាពងងឹតឡើយ ។ . . .

« ហើយមើលចុះ នឹងមានផ្កាយថ្មីមួយរះឡើងគឺជាផ្កាយមួយដែលអ្នករាល់គ្នាពុំដែលបានឃើញសោះ » (ហេលេមិន 14:3, 5) ។

ប្រជាជនយូដាបានទន្ទឹងរង់ចាំយ៉ាងអន្ទះសារចំពោះព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ ។ ពួកគេបានដឹងថាព្រះមែស៊ីនឹងយាងមក ហើយពួកគេរំពឹងទុកថាទ្រង់នឹងយាងមកក្នុងសិរីល្អ ជួយសម្រាលបន្ទុកពួកគេ ស្តាបនានគរលើផែនដី ហើយគ្រងរាជធ្វើជាស្តេចរបស់ពួកគេ ។

តើនរណាបានដឹងមុនគេពីការប្រសូតរបស់



ព្រះមែស៊ី ? តើវាគួរជាក្រុមប្រឹក្សារបស់ពួកយូដា ឬក្រុមផ្សេងទៀតដែលមានអំណាច និងឥទ្ធិពលមែនទេ ?

ព្រះគម្ពីរប៊ីបប្រាប់យើងថា គឺជាពួកគង្វាលដ៏ទន់ទាបដែលដេកនៅទីវាលទៅវិញទេ ដែលទេវតាបានប្រកាសប្រាប់ពី « ដំណឹងល្អនៃសេចក្ដីអំណរយ៉ាងអស្ចារ្យ » (លូកា 2:10) និងពួកហោរាមកពីទីឆ្ងាយដែលបានឃើញ « ផ្កាយរបស់ទ្រង់ពីទិសខាងកើតមក ហើយ[មក] ថ្វាយបង្គំទ្រង់ » (លូកា 2:10) ។ ពួកអ្នកមានអំណាច និង ឥទ្ធិពល ដែលទស្សនៈរបស់ខ្លួនត្រូវបានធ្វើឲ្យស្រពិចស្រពិលដោយសារតែទស្សនវិជ្ជាខាងលោកិយ មិនស្ថិតនៅជាមួយនឹងព្រះអង្គសង្គ្រោះកាលទ្រង់បានប្រសូតមក ឬក្នុងគ្រានៃការបម្រើរបស់ទ្រង់ឡើយ ។ ពួកគេបានឃើញរឿងពិតនៅចំពោះមុខ ប៉ុន្តែពួកគេបែរជាមិនស្គាល់ ឬមិនទទួលយកទៅវិញ ។

## ការប្រែក្លាយកាន់តែដូចជាព្រះគ្រីស្ទ

ប្រធានបែនសឹនបានថ្លែងថា រឿងដ៏អស្ចារ្យបំផុតមួយអំពីគ្រាបុណ្យគ្រីស្ទម៉ាស់គឺថា វាបង្កើនការយល់ដឹងរបស់យើងពីរឿងនៃព្រះ ៖

« វាធ្វើឲ្យយើងសញ្ជឹងគិតពីទំនាក់ទំនងរបស់យើងជាមួយនឹងព្រះវរបិតា និងពីកម្រិតនៃការលះបង់ដែលយើងមានចំពោះព្រះ ។

« វាបំផុសគំនិតយើងឲ្យកាន់តែចេះអត់ឱន ហើយចែករំលែក គិតគូរពីអ្នកដទៃឲ្យបានច្រើន មានសេចក្ដីសប្បុរស និង សេចក្ដីស្មោះត្រង់កាន់តែច្រើន ពោរពេញដោយសេចក្ដីសង្ឃឹម ចេះជួយទុក្ខធុរៈ និងមានសេចក្ដីស្រឡាញ់ឲ្យបានច្រើន—ដែលជាលក្ខណៈដូចជាព្រះគ្រីស្ទទាំងអស់ ។ ពិតណាស់វិញ្ញាណនៃបុណ្យគ្រីស្ទម៉ាស់បានប៉ះដល់ដួងចិត្តរបស់មនុស្សជុំវិញពិភពលោក ។ . . . ពីព្រោះយ៉ាងហោចណាស់ ពេលខ្លះវាជួយបង្កើនការយកចិត្តទុកដាក់ និង ការលះបង់របស់យើងចំពោះព្រះអម្ចាស់ និង ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ » ។[2]

កាលរដូវកាលនេះបានបំផុសគំនិតយើងឲ្យមានចិត្តសប្បុរសច្រើនជាងមុន នៅបុណ្យគ្រីស្ទម៉ាស់នេះ ចូរឲ្យយើងធ្វើនូវអ្វីមួយដែលបង្ហាញឲ្យឃើញពីអារម្មណ៍របស់យើង ដោយស្ដែងប្រាប់ថាយើងយល់ដឹងថាព្រះឱរស ដែលបានប្រសូតនៅបេថ្លេហិមគឺជាព្រះដ៏ប្រោសលោះដ៏ពិត ។ ប្រធានហាវើដ ដបុលយូ ហ៊ីនធើរ (1907–95) បានផ្ដល់នូវដំបូន្មានសម្រាប់ការអនុវត្តជាក់ស្ដែងដែលជួយយើងឲ្យធ្វើកិច្ចការនោះ ៖

« បុណ្យគ្រីស្ទម៉ាស់នេះ បានស្ដារឡើងវិញនូវទំនាក់ទំនងល្អមួយ ។ សូមស្វែងរកមិត្តម្នាក់ដែលយើងមិនបានគិតដល់ ។ ឈប់សង្ស័យ ហើយជំនួសវិញដោយការទុកចិត្ត ។ សូមសរសេរសំបុត្រមួយច្បាប់ ។ សូមឆ្លើយដោយទន់ភ្លន់ ។ សូមលើកទឹកចិត្តយុវវ័យ ។ សូមបង្ហាញនូវភាពស្មោះត្រង់របស់អ្នកទាំងពាក្យសម្ដី និង ទង្វើ ។ សូមរក្សាសន្យា ។ សូមបំភ្លេចចោលគំនុំគុំគួន ។ សូមអភ័យដល់មារសត្រូវ ។ សុំទោស ។ ព្យាយាមយល់ចិត្ត ។ សញ្ជឹងគិតអំពីតម្រូវការ ទៅលើអ្នកដទៃរបស់អ្នក ។ គិតពីអ្នកដទៃជាមុនសិន ។ ចូរមានចិត្តល្អ ។ ចូរទន់ភ្លន់ ។ សើចឲ្យច្រើនជាងមុន ។ បង្ហាញអំណរគុណរបស់អ្នក ។ ស្វាគមន៍ដល់ជនចម្លែក ។ ធ្វើឲ្យដួងចិត្តកុមារម្នាក់បានរីករាយ ។ រីករាយនឹងភាពស្រស់ស្អាត និងភាពអស្ចារ្យនៃផែនដី ។ បង្ហាញសេចក្ដីស្រឡាញ់របស់អ្នក រួចបន្លឺវាឡើងម្ដងទៀត » ។[3]

បើគ្មានព្រះគ្រីស្ទ នោះគ្មានបុណ្យគ្រីស្ទម៉ាស់ឡើយ ។ បើគ្មានព្រះគ្រីស្ទ នោះគ្មានភាពពេញលេញនៃសេចក្ដីអំណរឡើយ ។ បើគ្មានការប្រសូត និងដង្វាយធួនរបស់ព្រះអង្គសង្គ្រោះនោះទេ យើងនឹងគ្មានព្រះអង្គសម្របសម្រួល ព្រះអង្គគាំទ្រជាមួយនឹងព្រះវរបិតា និងគ្មានអង្គកណ្ដាល ដែលអាចធ្វើឲ្យយើងអាចត្រឡប់ទៅវត្តមាននៃព្រះវរបិតាសួគ៌ជាទីស្រឡាញ់របស់យើង ហើយរស់នៅរួមគ្នាជាក្រុមគ្រួសារដ៏អស់កល្បបានឡើយ ។

ខ្ញុំសូមថ្លែងសេចក្ដីអបអរជាមួយនឹងអ្នកនូវការពិតដ៏មានអត្ថន័យ ហើយភាពពិតជាក់ស្ដែងយ៉ាងអស្ចារ្យនៃការប្រសូត និង បេសកកម្មរបស់ព្រះរាជបុត្រានៃព្រះ ហើយខ្ញុំសូមថ្លែងទីបន្ទាល់របស់ខ្ញុំថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះ និងជាព្រះដ៏ប្រោសលោះរបស់យើង—ជាព្រះមែស៊ីដែលបានសន្យា ។ ■

**កំណត់ចំណាំ**

1. *The Teachings of Ezra Taft Benson,* (ឆ្នាំ 1988) ទំព័រ 128 ។
2. អែសរ៉ា ថាហ្វ បែនសឹន នៅក្នុង ឡារី ស៊ី ផតភើរ « Remembering Christmas Past: Presidents of the Church Celebrate the Birth of the Son of Man and Remember His Servant Joseph Smith, » *BYU Studies,* វ៉ុល 40 លេ.រ. 3 (ឆ្នាំ 2001) ទំព័រ 108 ។
3. ហាវើដ ដបុលយូ ហ៊ីនធើរ « The Gifts of Christmas, » *Ensign*, ខែ ធ្នូ ឆ្នាំ 2002 ទំព័រ 18–19 ។

# ភួយសំឡីបុណ្យគ្រីស្ទម៉ាស់របស់ម្ដាយខ្ញុំ

បទពិសោធន៍ដ៏លំបាកបំផុតមួយនៅក្នុងជីវិតខ្ញុំបានកើតឡើង ក្រោយពីកូនស្រីរបស់យើងអាយុ 10 ដប់ឆ្នាំ ដែលមានជំងឺមហារីកខួរក្បាលបានទទួលមរណភាពមិនយូរប៉ុន្មាន ។ ពាក្យមួយឃ្លាដែលថា « ពេលអ្នកស្លាប់ទៅអ្នកមិនអាចយកអ្វីទៅជាមួយបានទេ » បានសបញ្ជាក់យ៉ាងច្បាស់ កាលយើងក្រឡេកមើលជុំវិញបន្ទប់របស់នាងនៅរសៀលថ្ងៃសៅរ៍មួយ ។

ឃ្លៃរីស្សាបានចែកឋានទៅហើយ ប៉ុន្តែបន្ទប់របស់នាងបានបន្សល់ទុកនូវសម្ភារៈមួយចំនួន ដែលរំឭកកាលនាងនៅមានជីវិត ។ ឥឡូវនេះយើងពិបាកសម្រេចចិត្តថានឹងត្រូវធ្វើយ៉ាងណា ជាមួយនឹងសម្ភារផ្ទាល់ខ្លួនរបស់នាង ។ ខ្ញុំដឹងថា ការយករបស់តែមួយចេញពុំមែនជារឿងងាយស្រួលនោះទេ ជាពិសេសចំពោះភរិយារបស់ខ្ញុំ ។

ដោយមានការបន្ទាន់ជាច្រើនជាមួយនឹងរឿងមន្ទីរពេទ្យ ការព្យាបាលដោយសារធាតុគីមី និង វិទ្យុសកម្ម បានធ្វើឲ្យយើងមានពេលតិចតួចណាស់ដើម្បីសម្អាត ហើយរៀបចំ ។

អនុស្សាវរីយ៍ជាច្រើនត្រូវបាននឹកឃើញកាលយើងបានរៀបចំសម្ភារដែលនាងបានរៀបនៅលើក្បាលដំណេក ឬធ្នើរសៀវភៅរបស់នាងទុក ។ សម្ភារទាំងអស់នោះមានអត្ថន័យជាប់នឹងដួងចិត្ត—មានតាំងពីភួយ សៀវភៅឬខ្សែ-ករូបសត្វ សៀវភៅរៀន និង បាល់ឱបដែលនាងស្រឡាញ់ ។ ភរិយារបស់ខ្ញុំបានយំកាលយើងបានសួរគាត់ថាតើយើងត្រូវធ្វើយ៉ាងម៉េចជាមួយនឹងសម្ភារទាំងនេះ ។

យើងបានប្រមូលសៀវភៅជាច្រើនរបស់ឃ្លៃរីស្សា ហើយយកវាទៅឲ្យសាលាបឋមសិក្សារបស់នាងទុកឲ្យកុមារដទៃទៀតប្រើប្រាស់ ។ យើងបានឲ្យទូរសំលៀកបំពាក់នាងទៅអ្នកជិតខាង ។ សំលៀកបំពាក់នាងមួយចំនួនត្រូវបានឲ្យទៅបងប្អូនជីដូនមួយនាង ។ ការផ្ដោតចិត្តទៅលើអ្នកដទៃ បានជួយធ្វើឲ្យស្ថានភាពដ៏លំបាកនៃការចែករំលែកសម្ភាររបស់នាងមានភាពងាយស្រួលជាងបន្តិច ។

ប៉ុន្មានសប្ដាហ៍ក្រោយមក កាលបុណ្យគ្រីស្ទម៉ាស់ខិតជិតមកដល់ កូនស្រីជំទង់ខ្ញុំពីរនាក់បានសុំម្ដាយពួកគេថា តើពួកគេអាចប្រើសំលៀកបំពាក់មួយចំនួនរបស់ឃ្លៃរីស្សាធ្វើជាអំណោយពិសេសមួយសម្រាប់បុណ្យគ្រីស្ទម៉ាស់បានដែរឬទេ ។ ពួកគេជ្រើសយក

រចនាដោយ ប្រេដលី អេច ខ្លាក



ខ្ញុំនៅចាំជានិច្ចពីអារម្មណ៍ដែលភរិយាខ្ញុំមាន កាលគាត់បានបើកអំណោយនោះ ហើយបានឃើញនូវអ្វីដែលកូនស្រីគាត់បានធ្វើសម្រាប់គាត់ ។

សំលៀកបំពាក់នីមួយៗដែលមានអនុស្សាវរីយ៍យ៉ាងសំខាន់សម្រាប់គ្រួសារ ហើយកាត់វាជារាងបួនជ្រុងដោយប្រុងប្រយ័ត្នដើម្បីបង្ហាញពីគ្រាដ៏មានតម្លៃបំផុតនៅក្នុងជីវិតនាង ។

ពីរបីថ្ងៃ មុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ពួកគេ និង ថ្នាក់ដឹកនាំយុវនារីរបស់ពួកគេ ដែលបានជួយពួកគេផ្ដើមគំនិតបែបនេះ បានបង្ហាញខ្ញុំនូវភួយសំឡីមួយដែលពួកគេកំពុងធ្វើ ។ ខ្ញុំបានមើលទៅក្រណាត់បួនជ្រុងនោះម្ដងមួយៗដែលវាបានបង្ហាញពីព្រឹត្តិការណ៍មួយនៅក្នុងជីវិតរបស់ឃ្លេរីស្សាដោយក្ដីភ្ញាក់ផ្អើល ៖ វាមានក្រណាត់បួនជ្រុងមួយបំណែកនៃឯកសណ្ឋានកីឡាបាល់ទាត់របស់នាង នៃអាវយឺតដែលយើងបានទិញឲ្យកាលធ្វើដំណើរកម្សាន្តជាគ្រួសារ នៃខោអាវដេកយប់ដែលនាងពាក់កាលស្នាក់នៅមន្ទីរពេទ្យ ។ បំណែកនីមួយៗមានតម្លៃ ហើយស្រស់ស្អាតខ្លាំងណាស់ វាបានរំឭកខ្ញុំពីពេលវេលាដែលយើងមានជាមួយនឹងនាង ។ ខ្ញុំបានប្រាប់ដល់កូនស្រីខ្ញុំទាំងពីរនាក់ថា វាល្អក្រៃលែង ។ ខ្ញុំបានដឹងថាម្ដាយរបស់ពួកគេនឹងស្រឡាញ់ភួយ សំឡីនេះ ។

នៅព្រឹកបុណ្យគ្រីស្ទម៉ាស់នោះខ្ញុំបានឃើញអំណោយមួយដែលបានផ្ដល់ឲ្យចេញពីដួងចិត្ត ។ ខ្ញុំនៅចាំជានិច្ចពីអារម្មណ៍ដែលភរិយាខ្ញុំមាន កាលគាត់បានបើកអំណោយនោះ ហើយបានឃើញនូវអ្វីដែលកូនស្រីគាត់បានធ្វើសម្រាប់គាត់ ។ ចាប់ពីពេលនោះមក ជារៀងរាល់យប់ គាត់បានយកភួយ សំឡីអំណោយគ្រីស្ទម៉ាស់របស់គាត់មកដណ្ដប់ ដើម្បីរំឭកពីអនុស្សាវរីយ៍ ហើយស្រមៃពីគ្រាដែលគ្រួសារនឹងរួមរស់ជាមួយគ្នាម្ដងទៀត—យើងសូមអរគុណដល់ដង្វាយធួន និង ការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ ■

ជេដ ផាកកឺ រដ្ឋយូថាហ៍ ស.រ.អ.

# ទ្រង់ត្រូវការការបម្រើរបស់ខ្ញុំនៅពេលនេះ

ខ្ញុំអង្គុយនៅឯម៉ាស៊ីនដេរ ហើយដេរសំពត់ទ្បែន ។ ខ្ញុំកំពុងដេរភួយសំឡីសម្រាប់ទារកទើបនឹងកើតដែលមានពណ៌ស្រស់ៗរៀបចម្រុះតាមគំរូតុបតែងនៅផ្នែកខាងលើ សមស្របនឹងពណ៌នៅផ្នែកខាងក្រោយ ។

សមាគមសង្គ្រោះក្នុងវួដយើងបានរៀបចំសម្ភារសម្រាប់ទារកថ្មី ដើម្បីផ្ដល់ទៅឲ្យតំបន់ក្រីក្រ និង តំបន់ដែលមានគ្រោះមហន្តរាយ ។ ខ្ញុំជាជាងដេរម្នាក់ដែលមិនសូវស្ទាត់ជំនាញ ប៉ុន្តែខ្ញុំបានតាំងចិត្តចូលរួមក្នុងកិច្ចការនេះ ។ ខ្ញុំរីករាយនឹងការរើសក្រណាត់សម្រាប់គម្រោងនេះ ហើយកាត់វាជាបួនជ្រុងឲ្យប៉ុនទំហំភួយ ។

ខ្ញុំបានដាក់ផ្នែកម្ខាងៗស្របត្រឹមត្រូវនឹងគ្នា ដេរជុំវិញ ហើយទុកមួយផ្នែកទំនេរដើម្បីត្រឡប់ភួយនោះម្ខាងទៀត ។ រួចខ្ញុំដេរតាមជាយៗ កាត់ត្រង់ជ្រុងៗរបស់វា ត្រឡប់ភួយទៅម្ខាងទៀតដើម្បីឲ្យផ្នែកដែលមានពណ៌ស្រស់ៗនៅខាងក្រៅ ហើយដេរផ្នែកដែលទុកចំហចោលនោះ ។

ខ្ញុំបានដេរតាមជាយខាងលើដើម្បីឲ្យមានថ្នេរមាំ ។ ខ្ញុំបានបញ្ចូលបន្ទះក្រណាត់នោះទៅក្នុងម៉ាស៊ីនដេរថ្មមៗ ហើយបានចាប់ផ្ដើមដេរវា ។ កាលខ្ញុំប្រញាប់ប្រញាល់បញ្ចប់កិច្ចការដើម្បីខ្ញុំអាចធ្វើកិច្ចការផ្ទះ នោះខ្ញុំគិតឃើញនូវគំនិតមួយថា ៖ « ចុះបើខ្ញុំដេរភួយនេះសម្រាប់ព្រះឱរសយេស៊ូវវិញនោះ ? »

ដោយមានគំនិតនោះដក់ជាប់ក្នុងចិត្ត ខ្ញុំបានចាប់ផ្ដើមដេរថ្នេរនោះដោយប្រុងប្រយ័ត្ន ។ ប៉ុន្តែទោះជាមានការប្រុងប្រយ័ត្នក្ដី ក៏ថ្នេរនោះនៅតែវៀច ។

បន្ទាប់មកទៀតខ្ញុំបានដេរក្រណាត់បួនជ្រុងប្រវែង 25 ស.ម. នៅចំកណ្ដាលដើម្បីភ្ជាប់ផ្នែកខាងមុខ ទៅផ្នែកខាងក្រោយ ។ ខ្ញុំយកក្រដាសរឹងមួយមកធ្វើគំរូ ដាក់វានៅកណ្ដាលភួយនោះ ហើយបានគូសថ្នមៗនៅជុំវិញវា ។ ខ្ញុំដាក់ក្រណាត់នោះចូលម៉ាស៊ីនដេរ ហើយបានដេរវាដោយប្រុងប្រយ័ត្ន ។

ពេលខ្ញុំធ្វើចប់ ខ្ញុំបានកាត់ថ្នេរ ហើយយកភួយដែលធ្វើហើយនោះមកមើល ។ វាមិនចេញរាងបួនជ្រុងទេ—វាមានរាងស្រដៀងនឹងចតុកោណព្នាយកែង និង ចតុកោណព្នាយស្របទៅវិញ ។

ខ្ញុំបានដាក់ភួយនោះទុកមួយអន្លើរ យកក្រណាត់ថ្មីមក ហើយចាប់ផ្ដើមម្ដងទៀត—ដោយផ្ចិតផ្ចង់ជាងមុនដើម្បីឲ្យអំណោយនេះមានតម្លៃសក្ដិសមសម្រាប់ថ្វាយដល់ព្រះអាទិទេព ។ ប៉ុន្តែទោះជាមានការខិតខំបន្ថែមទៀតយ៉ាងណា ក៏លទ្ធផលចេញមកបានប្រសើរជាងមុនតែបន្តិចប៉ុណ្ណោះ ។ ភួយនីមួយៗដែលខ្ញុំដេរគឺមានរាងមិនស្អាតឥតខ្ចោះនោះទេ ។

ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនអាចយកភួយទាំងនេះទៅ ដាក់នៅកន្លែងប្រមូលភួយបានទេ គឺមិនមែននៅឆ្នាំនេះដែរ ។ ខ្ញុំនឹងខំហាត់ ហើយប្រហែលនៅថ្ងៃមួយខ្ញុំអាចចូលរួមបាន ។

រួចគំនិតមួយទៀតបានផុតឡើងក្នុងគំនិតខ្ញុំថា ៖ « ប្រសិនបើឯងចាំដល់ចេះដេរស្ទាត់ នោះព្រះឱរសព្រះគ្រីស្ទនឹងគង់នៅប្រទេសអេហ្ស៊ីបទៅហើយ » ។

ខ្ញុំបានយល់ពីបញ្ហានេះ ។ ឱកាសសម្រាប់ការបម្រើនឹងកន្លងហួសទៅ ។ ព្រះអង្គសង្គ្រោះទទួលដង្វាយរបស់យើង កាលណាយើងខិតខំឲ្យអស់ពីលទ្ធភាព ទោះជាវាមិនល្អឥតខ្ចោះក្ដី ។ ខ្ញុំដឹងថា ទារកទើបនឹងកើត ដោយបានរុំនៅក្នុងភួយទន់ ហើយស្អាត នឹងគេងយ៉ាងលុងលក់ ដោយសារជ្រុងរបស់វាមិនមែនរាងបួនជ្រុង ។

កាលខ្ញុំគិតថាតើការខិតខំរបស់ខ្ញុំជួយដល់សេចក្ដីត្រូវការនៅជុំវិញពិភពលោកដែរឬអត់ នោះខ្ញុំបាននឹកឃើញពីការប្រឹក្សារបស់ព្រះគ្រីស្ទថា ៖ « ដែលអ្នករាល់គ្នាបានធ្វើការទាំងនេះដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថាបានធ្វើដល់យើងដែរ » (ម៉ាថាយ 25:40) ។

ដូច្នេះខ្ញុំបានបន្តដេរភួយទាំងនោះ ដោយខំធ្វើឲ្យវាមានភាពស្អាតល្អតាមដែលខ្ញុំអាចធ្វើបាន ។ ខ្ញុំដឹងថាមាននូវសេចក្ដីត្រូវការមួយនៅពេលឥឡូវនេះ មិនមែនពេលណាមួយនាអនាគត កាលខ្ញុំអាចដេរវាឲ្យយ៉ាងល្អនោះឡើយ ។ ■

ជីន ហោឌេនព្រេួន ម៉ូលទ្រី រដ្ឋវ៉ាស៊ីងតោន ស.រ.អ.



# អំណោយបុណ្យគ្រីស្ទម៉ាស់ដ៏ល្អបំផុត

វាជាល្ងាចមុនបុណ្យគ្រីស្ទម៉ាស់ ហើយគ្រួសារយើងបានជួបជុំគ្នាដើម្បីអបអរសាទរដូចរៀងរាល់ឆ្នាំ ។ ទ្រនិចនាឡិការៀបនឹងចង្អុលដល់ម៉ោងដប់ពីរពាក់កណ្ដាលយប់ទៅហើយ កាលលោកប៉ាស្រែកហៅយើងមកជួបជុំគ្នាដោយពោលថា គាត់មានអ្វីមួយចង់បង្ហាញដល់យើង ។

ដោយមានការរៀបចំ និង ភាពរីករាយដែលមានមកជាមួយនឹងល្ងាចថ្ងៃបុណ្យគ្រីស្ទម៉ាស់ ពួកបងប្អូនស្រីខ្ញុំ ម្ដាយខ្ញុំ និង ខ្ញុំ មិនបានសង្កេតមើលនូវអ្វីដែលលោកប៉ាបានរៀបចំសម្រាប់ឱកាសនេះនោះឡើយ ។ កាលយើងបានមកជួបជុំគ្នាភ្លាមគាត់បានចាប់ផ្ដើមបង្ហាញពីបទបង្ហាញមួយចំនួន ។

នៅក្នុងបទបង្ហាញរបស់គាត់ដែលមានរូបភាពរបស់ព្រះអង្គសង្គ្រោះ ទិដ្ឋភាពបុណ្យគ្រីស្ទម៉ាស់ និង ពាក្យដែលបានរចនាដោយយកចិត្តទុកដាក់ លោកប៉ាបង្ហាញសេចក្ដីស្រឡាញ់របស់គាត់ដល់យើង ។ បទបង្ហាញរបស់គាត់ក៏រំឭកយើងពីអត្ថន័យដ៏ពិតនៃបុណ្យគ្រីស្ទម៉ាស់ និង សុភមង្គលព្រមទាំងអំណរគុណដែលយើងគួរមានចំពោះការប្រសូតរបស់ព្រះអង្គសង្គ្រោះដែរ ។ រូបភាពមួយនៃបទបង្ហាញគឺជាដើមឈើគ្រីស្ទម៉ាស់ដែលមានចម្រុះពណ៌ក៏មាននូវពាក្យថា « បុណ្យគ្រីស្ទម៉ាស់នេះជា សេចក្ដីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទនឹងនាំជីវិតថ្មីមកឲ្យខ្ញុំ » ដែរ ។

បន្ទាប់មកទៀត ផ្នែកដ៏សំខាន់បំផុតនៃបទបង្ហាញរបស់លោកប៉ា គឺគាត់បានប្រើបទបង្ហាញស្ដីពីរូបគំនូរនៃព្រះអង្គសង្គ្រោះដើម្បីប្រាប់ដំណឹងមួយចំនួនដល់យើង ។ វាមិនដូចជាដំណឹងនានានោះទេ ប៉ុន្តែវាជាដំណឹងដ៏អស្ចារ្យបំផុតដែលមិនធ្លាប់ឮ ។ នៅខាងលើរូបព្រះអង្គសង្គ្រោះមានដាក់ពាក្យថា « ខ្ញុំបានសម្រេចចិត្តដើម្បីជ្រមុជទឹកនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » ។

នៅទីបំផុតលោកប៉ាយើងបានសម្រេចចិត្តចូលក្នុងសាសនាចក្រ ! ការសម្រេចចិត្តមួយបែបនេះអាចជារឿងមួយងាយស្រួលសម្រាប់មនុស្សមួយចំនួន ប៉ុន្តែវាជារឿងដ៏ពិបាកសម្រាប់លោកប៉ាយើង ។ គាត់បានសិក្សាដំណឹងល្អ ហើយរៀនពីសាសនាចក្រអស់រយៈពេល 25 ឆ្នាំ ។ ថ្វីបើយើងខិតខំធ្វើអស់ពីលទ្ធភាព និងមានការពិភាក្សារបស់អ្នកផ្សព្វផ្សាយសាសនាជាច្រើនក្ដី ក៏គាត់នៅតែមិនព្រមទទួលពិធីបុណ្យជ្រមុជទឹកដែរ ។ យើងមិនបានដឹងពីហេតុផលទេ ប៉ុន្តែយើងបានដឹងថា គាត់មិនទាន់រៀបចំខ្លួននៅឡើយ ។

ខ្ញុំសារភាពថា មានពេលខ្លះខ្ញុំមានអារម្មណ៍ថា ឪពុកខ្ញុំនឹងមិនទទួលយកពិធីបុណ្យជ្រមុជទឹកឡើយ ។ ប៉ុន្តែនៅក្នុងចិត្ត ខ្ញុំមិនដែលអស់សង្ឃឹមឡើយ ហើយយើងទាំងអស់គ្នាបានបន្តអធិស្ឋានសម្រាប់គាត់ ។ នៅល្ងាចមុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ ព្រះអម្ចាស់បានឆ្លើយតបនឹងការអធិស្ឋានរបស់យើង ។

កាលលោកប៉ាបានធ្វើសេចក្ដីប្រកាសរបស់គាត់ដំបូងឡើយយើងបានស្រក់ទឹកភ្នែកដោយសេចក្ដីអំណរ ។ យើងមានអារម្មណ៍ច្រើនលាយលំគ្នា—រំភើបភ្ញាក់ផ្អើល ហើយលើសពីនោះទៅទៀត គឺជាអារម្មណ៍ដ៏មានសុភមង្គលបំផុតដែលមិនអាចរៀបរាប់បាន ។

ការប្រកាសរបស់លោកប៉ាមិនគ្រាន់តែបានផ្លាស់ប្ដូរល្ងាចមុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ប៉ុណ្ណោះទេ—វាក៏បានផ្លាស់ប្ដូរដល់ជីវិតគ្រួសារយើងទាំងមូលផងដែរ ។ ក្នុងនាមជាបុគ្គលម្នាក់ៗ និង ជាគ្រួសារយើងនៅតែអាចមានការរីកចម្រើនបាន ប៉ុន្តែខ្ញុំដឹងថាអនាគតមានភាពល្អប្រសើរនៅពេលនេះដោយសារយើងបានរួមរស់ជាមួយនឹងគ្នាក្នុងសាសនាចក្រ ។

ខ្ញុំមានអំណរគុណជាខ្លាំងចំពោះព្រះអម្ចាស់សម្រាប់ពរជ័យនេះ ។ នៅប៉ុន្មានខែទៀតនេះ យើងនឹងត្រូវបានផ្សារភ្ជាប់ជាគ្រួសារនៅក្នុងព្រះវិហារបរិសុទ្ធ ។ ការប្រកាសរបស់លោកប៉ាគឺពិតជាអំណោយថ្ងៃបុណ្យគ្រីស្ទម៉ាស់ដ៏ល្អបំផុតដែលពុំធ្លាប់មាន ។ ■

អាន់ទ្រីយ៉ាណា ណាវ៉ា ណាវ៉ារ៉ូ ប្រទេសបូលីវី

**បន្ទាប់មកទៀត ផ្នែកដ៏សំខាន់បំផុតនៃបទបង្ហាញរបស់លោកប៉ា គឺកាលដែលគាត់បានប្រើបទបង្ហាញមួយស្ដីពីរូបគំនូររបស់ព្រះអង្គសង្គ្រោះដើម្បីប្រាប់ដំណឹងមួយចំនួនដល់យើង ។**



# បុណ្យគ្រីស្ទម៉ាស់នៅក្រោមដំបូលស័ង្កសី

កាលខ្ញុំរស់នៅក្នុងទីក្រុងម៉ានីល ប្រទេសហ្វីលីពីន កាលសង្គ្រាមលោកលើកទី 2 ជារឿយៗខ្ញុំតែងជួបនឹងក្រុមតូចមួយនៃពួកអិ ល.ឌី.អែស. ផ្សេងទៀតដើម្បីធ្វើការប្រជុំសាក្រាម៉ង់ ។ នៅក្នុងការប្រជុំមួយ ខ្ញុំបានសង្កេតឃើញស្ត្រីហ្វីលីពីនម្នាក់ នៅខាងក្រោយអគារដែលត្រូវបានបំផ្លាញដោយគ្រាប់ផ្លោង កំពុងមើលមកយើងតាមច្រកទ្វារដែលធ្លាប់មានទ្វារកាលពីមុននោះ ។ ខ្ញុំបានគិតថាប្រហែលជាការច្រៀងរបស់យើងបានទាក់ទាញដល់ចិត្តគាត់ ។ កាលយើងបិទភ្នែកសម្រាប់ការអធិស្ឋានបិទ គាត់បានដើរចេញទៅដោយស្ងៀមស្ងាត់ ។

កាលគាត់បានមកលើកក្រោយ យើងបានអញ្ជើញគាត់ឲ្យចូលរួមនឹងយើង ។ គាត់មានឈ្មោះថា អានីសេតា ហ្វាចារឌូ ហើយគាត់បានព្រមទទួលយើងធ្វើជាមិត្ត ។ កាលគាត់បន្តចូលរួមក្នុងការប្រជុំរបស់យើង គាត់បានរៀនអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ។

លុះបុណ្យគ្រីស្ទម៉ាស់ខិតជិតចូលមកដល់ យើងបានសម្រេចចិត្តរៀបចំអំណោយមួយចំនួនឲ្យអានីសេតា និង គ្រួសារគាត់សម្រាប់បុណ្យគ្រីស្ទម៉ាស់ ។ យើងប្រមូលទឹកដោះគោកំប៉ុង សាច់ និង បន្លែ ភួយពីរបី និងថ្នាំពេទ្យមួយកញ្ចប់ រួមមាន ប៉េនីសេលីន ផងដែរ ដើម្បីជួយដល់ចៅប្រុសរបស់ អានីសេតា ដែលមានជំងឺ ។

នៅល្ងាចមុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ យើងបានរៀបចំអំណោយទាំងនោះ ហើយចេញទៅផ្ទះរបស់អានីសេតា ។ គាត់រស់នៅជាមួយនឹងកូនស្រីគាត់ និង ចៅប្រុសគាត់នៅក្រោមដំបូលដែលប្រើបន្ទះស័ង្កសីដាក់ផ្អែកនឹងជញ្ជាំងថ្មី—ជាសំណល់នៃអគារដែលបានបាក់បែក ។ យើងបានងឿងឆ្ងល់ថាតើពួកគេអាចរស់នៅបែបនេះយ៉ាងម៉េចបានក្នុងរដូវភ្លៀងដ៏ខ្លាំងបែបនេះ ។

មានបុរសរបស់យើងម្នាក់បានកាច់មែកស្វាយមួយមក ហើយដោតវាទៅនឹងដី ។ យើងបានរកកូនឈើបន្តិចបន្តួចដើម្បីយកមកតុបតែងមែកឈើនោះ ។

អានីសេតា និង គ្រួសារគាត់បានមើលដោយក្ដីអំណរ ហើយស្ញើចសរសើរអស្ចារ្យ ។ នៅពេលពួកគេបានឃើញអំណោយដែលយើងបានយកទៅ ក្ដីអំណររបស់ពួកគេបានក្លាយទៅជាទឹកភ្នែកនៃសុភមង្គល និងការដឹងគុណ ។ ពួកគេហាក់ដូចជាគ្មានអាហារហូបគ្រប់គ្រាន់ជាយូរមកហើយ ហើយពួកគេបានយំយ៉ាងខ្លាំងរហូតដល់ពួកគេមិនអាចនិយាយចេញមួយសន្ទុះ ។

ដោយសារវាជាល្ងាចមុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ គំនិតរបស់យើងបាននឹកដល់គ្រួសារ និងញាតិមិត្តជាទីស្រឡាញ់ ។ ខ្ញុំបានគិតពីទូរលេខដែលខ្ញុំបានទទួលកាលពីពីរថ្ងៃមុន ដោយប្រាប់ខ្ញុំថា ខ្ញុំបានក្លាយជាឪពុកគេហើយ ។ យើងបានចែកចាយអារម្មណ៍របស់យើង ហើយបានបញ្ចប់ដោយទីបន្ទាល់របស់យើងអំពីព្រះអង្គសង្គ្រោះ និង ដំណឹងល្អដែលបានស្ដារឡើងវិញ ។

យើងបានប្រាប់ដល់គ្រួសារដ៏ល្អនេះពីសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះចំពោះពួកគេ ។ ពួកគេទទួលបានការលួងលោមដោយពាក្យសម្ដីរបស់យើង និងអារម្មណ៍នៃក្ដីសុខសាន្តដ៏កក់ក្ដៅនាយប់ដ៏ត្រជាក់ ។ រួចយើងបានលាមិត្តជាទីស្រឡាញ់របស់យើង ហើយជូនពរដល់ពួកគេសម្រាប់ថ្ងៃបុណ្យគ្រីស្ទម៉ាស់ ។

ក្រោយមកមិនយូរប៉ុន្មាន ខ្ញុំត្រូវបានផ្លាស់ទៅតំបន់ថ្មី ហើយខ្ញុំមិនជួបនឹងអានីសេតា ឬគ្រួសារគាត់ម្ដងទៀតឡើយ ។ ប៉ុន្តែច្រើនឆ្នាំក្រោយមក ខ្ញុំបានបើក*សៀវភៅកំណត់ហេតុរបស់សាសនាចក្រ* ត្រង់ផ្នែកប្រទេសហ្វីលីពីន ហើយបានដឹងថា អានីសេតា ប៉ាប៊ីឡូណា ហ្វាចារឌូ គឺជាជនជាតិហ្វីលីពីនដំបូងគេដែលបានចូលរួមក្នុងសាសនាចក្រនៅលើកោះនោះ ។[1] វាជាពរជ័យមួយដ៏អស្ចារ្យណាស់ ដោយគិតពីគ្រាប់ពូជដែលបានដាំនៅក្នុងគ្រាថ្ងៃបុណ្យគ្រីស្ទម៉ាស់ក្នុង 1945 នោះ ។ ■

អើរវីន អ៊ី វើរខាស់ រដ្ឋយូថាហ៍ ស.រ.អា.

**កំណត់ចំណាំ**

1. សូមមើល « Philippines » *Deseret News 1991–1992 Church Almanac*, ទំព័រ 157, recent issues of the *Church Almanac*, spell Sister Fajardo's first name Aneleta ។

មានពួកយើងម្នាក់បានកាច់មែកស្វាយមួយមក ហើយដោតវាទៅនឹងដី ។ អានីសេតា និង គ្រួសារគាត់បានមើលដោយក្ដីអំណរ ហើយស្ញើចសរសើរ ។



# ចម្លើយ ចំពោះ សំណួរពិបាកៗ



# កាលជួបនឹងសំណួរពិបាកៗ មានតែរឿងមួយប៉ុណ្ណោះដែលសំខាន់បំផុត ។

ដោយ អ័រ ក៏ល ធនសុន
ទស្សនាវដ្ដីសាសនាចក្រ

សំណួរដែលយើងជួបក្នុងជីវិត វាពុំមែនជាសំណួរដែលងាយនឹងឆ្លើយជានិច្ចនោះទេ ។ ឧបសគ្គផ្ទាល់ខ្លួនមួយចំនួនដែលយើងមាន—ឧទាហរណ៍ដូចជាការស្លាប់កូនម្នាក់ ការក្បត់ចិត្តរបស់មិត្ត ឬបញ្ហាអកុសលផ្នែកហិរញ្ញវត្ថុ—ជារឿងៗវាមិនងាយដើម្បីដោះស្រាយនោះទេ ហើយយើងត្រូវការការគាំទ្រដោយសេចក្ដីមេត្តាករុណាពីមនុស្សដែលនៅជុំវិញយើង ។ ពេលខ្លះ អ្វីដែលជាឧបសគ្គដ៏លំបាកបំផុតនៅក្នុងស្ថានភាពទាំងនេះគឺដើម្បីដឹងថាព្រះវរបិតាសួគ៌ស្រឡាញ់យើង ហើយថាទ្រង់មិនមែនកំពុងតែដាក់ទណ្ឌកម្មដល់យើងនោះទេ ថ្វីបើវាជាមូលហេតុសម្រាប់ការសាកល្បងក្ដី បើទោះបីវាមានមូលហេតុណាមួយ ក៏យើងមិនអាចយល់បានឡើយនៅពេលនេះ ។

សំណួរដ៏ពិបាកបំផុតមួយចំនួនកើតឡើងនៅពេលអ្វីដែលយើងជឿត្រូវបានសាកល្បងដោយការផ្លាស់ប្ដូរទំនោរខាងវប្បធម៌ ឬដោយព័ត៌មានថ្មី ពេលខ្លះ ជាព័ត៌មានខុសដែលអ្នករិះគន់នៃសាសនាចក្រយកមកតទល់នឹងយើង ។ ក្នុងពេលបែបនោះ វាហាក់ដូចជាគ្រឹះខាងគោលលទ្ធិ ឬខាងប្រវត្តិសាស្ត្ររបស់យើងគ្មានភាពរឹងមាំដូចដែលយើងបានគិត ។ យើងប្រហែលជាត្រូវបានល្បួងឲ្យសង្ស័យពីសេចក្ដីពិតដែលយើងមិនសូវបានឲ្យតម្លៃ និង បទពិសោធន៍ខាងវិញ្ញាណដែលបានបង្កើតសេចក្ដីជំនឿរបស់យើង ។

តើយើងគួរធ្វើអ្វីខ្លះនៅពេលដែលភាពសង្ស័យជ្រាតជ្រែកចូលទៅក្នុងដួងចិត្តរបស់យើង ? តើពិតជាមានចម្លើយចំពោះសំណួរដ៏ពិបាកៗទាំងនោះមែនឬ ?

មែនហើយ វាពិតជាមាន ។ ពិតណាស់ ចម្លើយទាំងអស់—ចម្លើយដ៏ត្រឹមត្រូវទាំងអស់—ផ្អែកទៅលើចម្លើយសម្រាប់សំណួរតែមួយគត់ ៖ តើខ្ញុំទុកចិត្តព្រះលើសពីមនុស្សដទៃទៀតដែរឬទេ ?

### សាមញ្ញ ប៉ុន្តែមិនងាយស្រួល

តើរបៀបដោះស្រាយនោះវាសាមញ្ញពេកឬ? ហើយងាយបែបហ្នឹងមែនឬ ?

ប្រហែលជាអញ្ចឹង ។ តាមពិតទៅវាពុំមែនជានិច្ចនោះទេ ជាពិសេសពេលដែលវាត្រូវប្រកួតប្រជែងនឹងការផ្លាស់ប្ដូរដែលបានបង្ហាញតាមរបៀបដែលទាក់ទាញនោះ ។ ជារឿយៗ យើងយល់ពីសេចក្ដីពិតនោះតែមួយផ្នែកប៉ុណ្ណោះ កាលដែលទិដ្ឋភាពទាំងមូលមិនទាន់បានស្វែងយល់នៅឡើយ ។ ហើយនៅក្នុងការស្វែងយល់នោះ យើងប្រឈមមុខនឹងទិដ្ឋភាពយ៉ាងសោប់សល់នៃការចាកចេញពីភាពមិនល្អឥតខ្ចោះ ហើយទៅរកការយល់ដឹងដែលបានផ្ដល់នូវការល្បួងលោមរហូតមកដល់ពេលនេះ ។ ប៉ុន្តែការទុកចិត្តថាព្រះមាននូវរាល់ចម្លើយ ថាទ្រង់ស្រឡាញ់យើង ហើយថាទ្រង់នឹងឆ្លើយនូវរាល់សំណួររបស់យើង—តាមរបៀបរបស់ទ្រង់ តាមកាលវេលារបស់ទ្រង់—អាចធ្វើឲ្យការស្វែងរករបស់យើងមានភាពងាយស្រួល ។ វាមិនមែនងាយស្រួលជានិច្ចនោះទេ ប៉ុន្តែការទុកចិត្តលើដំបូន្មានរបស់ព្រះអាចជួយយើងឲ្យយកឈ្នះអារម្មណ៍នៃការច្របូកច្របល់ដោយសុវត្ថិភាព ។

ក្នុងសន្និសីទទូទៅរបស់សាសនាចក្រខែ តុលា ឆ្នាំ 2013 ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ជាទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ បានផ្ដល់នូវគំនិតដ៏មានខ្លឹមសារនេះថា ៖

« ការមានសំណួរទាំងនេះ គឺជារឿងធម្មតាទេ—គ្រាប់ពូជនៃសំណួរស្មោះត្រង់តែងលេចចេញជាពន្លកឡើង និងលូតលាស់ជាដើមឈើនៃការយល់ដឹងមួយដ៏ធំ ។ មានសមាជិកតិចណាស់ដែលពុំធ្លាប់ប្រឈមមុខនឹងសំណួរដ៏លំបាកហើយពិបាកដោះស្រាយទាំងនេះនៅក្នុងជីវិតរបស់ខ្លួននៅឡើយ។ គោលបំណងនៃសាសនាចក្រគឺបីបាច់ និងបណ្ដុះគ្រាប់ពូជនៃសេចក្ដីជំនឿ—សូម្បីពេលខ្លះជាដីខ្សាច់នៃមន្ទិល និងភាពមិនប្រាកដក្ដី ។ សេចក្ដីជំនឿគឺត្រូវសង្ឃឹមលើការណ៍ដែលមើលពុំឃើញតែពិត ។

« ដូច្នេះ បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ—ជាមិត្តជាទីស្រឡាញ់ខ្ញុំអើយ—សូមសង្ស័យមន្ទិលពីខ្លួនអ្នកពីមុនសង្ស័យសេចក្ដីជំនឿអ្នក ។ យើងពុំត្រូវអនុញ្ញាតឲ្យមន្ទិលចាប់យើងជាអ្នកទោស ហើយបញ្ចៀសយើងពីសេចក្ដីស្រឡាញ់ព្រះ ភាពសុខសាន្ត និងអំណោយទាន ដែលបានមកពីសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទជាដាច់ខាត » ។[1]

### គោលការណ៍ដ៏មានអត្ថប្រយោជន៍មួយចំនួន

ដូច្នេះតើយើងអាចលុបបំបាត់ភាពសង្ស័យរបស់យើងតាមរបៀបណាបាន ? តើយើងអាចពង្រឹងសេចក្ដីជំនឿរបស់យើងនៅលើសិលាដ៏រឹងមាំនៃវិវរណៈ ហើយមិនមែននៅលើដីខ្សាច់នៃការយល់ដឹងរបស់មនុស្សបានដោយរបៀបណា ? សូមចងចាំថា គោលការណ៍ខាងក្រោមនេះអាចជួយយើងបាន ។

គោលការណ៍ទី 1៖ **ព្រះជ្រាបបានវែងឆ្ងាយជាងយើង ។** កាលយើងប្រឈមមុខនឹងសំណួរនានា—មិនថាជាសំណួរផ្ទាល់ខ្លួនទាក់ទងនឹងសង្គម ឬគោលលទ្ធិនោះទេ—យើងអាចពឹងផ្អែកទៅលើការពិតដែលថា ព្រះដ៏បង្កបង្កើតនៃសកលលោកជ្រាបយល់អ្វីៗវែងឆ្ងាយជាងយើង ។ ប្រសិនបើទ្រង់បានលើកប្រធានបទមួយមកប្រឹក្សា (ហើយពេលខ្លះទ្រង់មិនបានធ្វើ

ដូច្នេះទេ) យើងអាចទុកចិត្តថា ព្រះតំរិះរបស់ទ្រង់គឺមានភាពច្បាស់លាស់ជាងយើង ។

« ពីព្រោះព្រះយេហូវ៉ាទ្រង់មានបន្ទូលថា គំនិតយើងមិនមែនដូចជាគំនិតរបស់អ្នករាល់គ្នាទេ ឯផ្លូវរបស់អ្នករាល់គ្នាក៏មិនមែនជាផ្លូវរបស់យើងដែរ ។

« ត្បិតដែលផ្ទៃមេឃខ្ពស់ជាងផែនដីយ៉ាងណា នោះអស់ទាំងផ្លូវរបស់អញ ខ្ពស់ជាងផ្លូវរបស់ឯងហើយគំនិតរបស់អញ ក៏ខ្ពស់ជាងគំនិតរបស់ឯងរាល់គ្នាយ៉ាងនោះដែរ » (អេសាយ 55:8–9) ។



**ភាពក្លាហានដើម្បីឈរការពារគោលការណ៍**

« វាមានការពិបាកខ្លាំងណាស់ដើម្បីឈរឲ្យរឹងមាំ កាលបុគ្គលម្នាក់ចាក់ឫសរបស់ខ្លួននៅក្នុងទីដែលគ្មានស្ថេរភាពនៃទស្សនៈ និងការអនុមតិដ៏ពេញនិយម ។ . . . យើងនឹងជួបការភ័យខ្លាច ការចំអក និង ឧបសគ្គ ។ ចូរយើង—យើងទាំងអស់គ្នា—មានចិត្តក្លាហានតតាំងនឹងមតិនិយមទូទៅ ហើយការពារគោលការណ៍របស់យើង » ។

**ប្រធាន ថូម៉ាស អេស ម៉នសុន « Be Strong and of a Good Courage, » *Liahona,* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 66–69 ។**

**ស្វែងរកចម្លើយនានា**

ដើម្បីពង្រីកការសិក្សារបស់អ្នកស្ដីពីសំណួរពិបាក។ សូមចូលទៅ lds.org/topics និង history.lds.org ក្នុងចំណោមធនធានជំនួយតាមអ៊ិនធើរណែតផ្សេងទៀត ។

គោលការណ៍ទី 2៖ **ព្រះចែករំលែកចំណេះដឹងមួយចំនួនរបស់ទ្រង់ ។** លទ្ធផលនៃគោលការណ៍ទី 1 គឺថាព្រះចែករំលែកជាមួយនឹងយើងនូវអ្វីដែលទ្រង់ជ្រាបយល់ កាលណាយើងបានរៀបចំខ្លួនដើម្បីទទួល ហើយទ្រង់បានត្រៀមដើម្បីប្រទានមកដល់យើង ។ អ្វីដែលយើងត្រូវធ្វើ គ្រាន់ តែត្រូវរៀបខ្លួនទទួលរួចស្វែងរកវាប៉ុណ្ណោះ ។ ព្រះគម្ពីរឆ្លើយតបនឹងសំណួរជាច្រើន ។ ក្ដីរីករាយដ៏អស្ចារ្យមួយនៅក្នុងជីវិតនេះគឺការត្រូវបានបង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធ នៅពេលទ្រង់បានប្រើបទគម្ពីរដើម្បីបើកសម្ដែង « មួយបន្ទាត់ម្ដងៗ មួយសិក្ខាបទម្ដងៗ ឯណេះបន្តិច ឯណោះបន្តិច » (នីហ្វៃទី 2 28:30) ដើម្បីឆ្លើយតបចំពោះការសិក្សាដ៏ឧស្សាហ៍ព្យាយាមរបស់យើង ។

សំណួរមួយចំនួន ជាពិសេសស្ដីពីប្រវត្តិសាស្ត្រ មាននូវការពន្យល់ដ៏សមហេតុផល ហើយកាលណាព័ត៌មានដែលបណ្ឌិតដ៏ស្មោះត្រង់បានបើកសម្ដែងកាន់តែច្រើន នោះទស្សនៈរបស់យើងក៏បានឃើញកាន់តែច្បាស់ដែរ ។

យើងក៏បានពរផងដែរ ដោយមានពួកព្យាការី និង ពួកសាវកដែលនៅរស់ដើម្បីបង្រៀនយើងក្រោមការបំផុសគំនិតពីស្ថានសួគ៌ ។ យើងមិនត្រូវធ្វើជា « កូនតូចទៀត ទាំងត្រូវគ្រប់អស់ទាំងខ្យល់នៃសេចក្ដីបង្រៀនបោកហើយផាត់យើងចុះឡើង » នោះទេ ។ យើងអាចទុកចិត្តថា ការដឹកនាំរួម



របស់ពួកលោកនឹងជួយយើង « រាល់គ្នាបានរួបរួមខាងឯសេចក្ដីជំនឿរួចជាស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះ » ។ (សូមមើល អេភេសូរ 4:11–15) ។

គោលការណ៍ទី 3៖ **យើងអាចទុកចិត្តលើសេចក្ដីស្រឡាញ់របស់ព្រះ ។** ព្រះស្រឡាញ់យើងច្រើនជាងយើងអាចនឹកគិតដល់ទៅទៀត ។ យើងគឺជាកូនចៅរបស់ទ្រង់ ហើយសព្វព្រះទ័យឲ្យយើងត្រឡប់ទៅវត្តមានទ្រង់វិញជាមនុស្សរុងរឿង ហើយចាស់ទុំ ជាបុគ្គលដ៏រុងរឿងដែលមានលទ្ធភាពប្រែក្លាយដូចជាទ្រង់ (សូមមើល ម៉ូសេ 1:39) ។ រាល់ការទូន្មានដែលទ្រង់ប្រទានដល់យើង គឺធ្វើឡើងដោយសេចក្ដីស្រឡាញ់យ៉ាងជ្រាលជ្រៅបំផុត ដើម្បីប្រទានពរមកយើងអស់កល្បជានិច្ច ។ យើងអាចទុកចិត្តលើសេចក្ដីស្រឡាញ់នោះទាំងស្រុង ។

« ឱព្រះអង្គអើយ សេចក្ដីសប្បុរសនៃទ្រង់ថ្លៃវិសេសយ៉ាណាហ្ន៎ ! ពួកមនុស្សលោកក៏ជ្រកនៅម្លប់នៃស្លាបទ្រង់ » (ទំនុកដំកើង 36:7) ។

គោលការណ៍ទី 4៖ **យើងត្រូវស្វែងរកការបញ្ជាក់ខាងវិញ្ញាណ ។** ប្រសិនបើប្រាជ្ញារបស់លោកិយយ៉ាងច្រើន ហាក់ដូចជាផ្ទុយពីប្រាជ្ញារបស់ព្រះ យើងមិនគួរភ្ញាក់ផ្អើលឡើយ ។ នៅទីបំផុតស្របតាម

ការរៀបចំរបស់ព្រះ យើងរស់នៅក្នុងពិភពលោកមួយដែលធ្លាក់ ជាកន្លែងដែលយើងត្រូវកាត់ចេញពីវត្តមាន និង ព្រះទ័យរបស់ទ្រង់ ។ ស្ថានភាពមួយបែបនេះអាចធ្វើឲ្យការយល់ដឹងពីរឿងនៃព្រះមានការលំបាក « ត្បិតបើមិនមែនជាវិញ្ញាណដែលនៅក្នុងខ្លួនមនុស្សទេ នោះតើមានអ្វីនឹងស្គាល់សណ្ឋានមនុស្សនោះបាន ? ហើយបើមិនមែនជាព្រះវិញ្ញាណនៃព្រះនោះក៏គ្មានអ្នកណាស្គាល់សណ្ឋានព្រះបានដែរ ។

« មនុស្សខាងសាច់ឈាម គេមិនទទួលសេចក្តីខាងឯវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ត្បិតត្រង់ឯសេចក្តីទាំងនោះត្រូវពិចារណាយល់ខាងវិញ្ញាណវិញ » (កូរិនថូសទី 1 2:11, 14) ។

ប្រសិនបើយើងត្រូវយល់ដឹងពីរឿងរបស់ព្រះ យើងមិនអាចពឹងផ្អែកលើប្រាជ្ញារបស់មនុស្សតែមួយគត់ដើម្បីធ្វើកិច្ចការនេះបានឡើយ ។ យើងត្រូវស្វែងរកព្រះវិញ្ញាណនៃព្រះ « ដើម្បីឲ្យបានស្គាល់អស់ទាំងព្រះគុណដែលព្រះបានផ្តល់មកយើង ។ . . . ដែលព្រះវិញ្ញាណវិញ ព្រមទាំងផ្ទឹមពន្យល់សេចក្តីខាងឯវិញ្ញាណ ដោយសារសេចក្តីខាងឯវិញ្ញាណផង » (កូរិនថូសទី 1 2:12–13) ។

កាលយើងទទួលបុណ្យជ្រមុជទឹក ហើយបញ្ជាក់ជាសមាជិកនៃសាសនាចក្ររបស់ព្រះគ្រីស្ទ យើងត្រូវបានប្រទានឲ្យនូវអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ។ ជាមួយនឹងអំណោយទាននោះ យើងអាចរៀនពីព្រះវិញ្ញាណ ហើយទទួលការបញ្ជាក់របស់ទ្រង់ពីសេចក្តីពិត ។ ការទទួលបានការបញ្ជាក់ខាងវិញ្ញាណនេះបានបណ្តេញនូវភាពសង្ស័យយ៉ាងប្រាកដ លើសពីហេតុផលដ៏គួរឲ្យទុកចិត្តបំផុតទៅទៀត ហើយវាមានសម្រាប់អស់អ្នកដែលស្វែងរកសេចក្តីពិតតាមរយៈការអធិស្ឋានដោយចិត្តស្មោះ ការសិក្សាដោយឧស្សាហ៍ព្យាយាម និងការគោរពប្រតិបត្តិដល់ព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ។

« ចូរសូម នោះតែងនឹងឲ្យមកអ្នក ចូររក នោះតែងនឹងឃើញ ចូរគោះ នោះតែងនឹងបើកឲ្យអ្នក ៖ (ម៉ាថាយ 7:7) ។

គោលការណ៍ទី 5៖ **យើងត្រូវរង់ចាំមើលព្រះអម្ចាស់ ។** ពេលខ្លះ យើងរវើរវាយកាលយើងពិបាកនឹងយល់ពីការសាកល្បងនានា និង សំណួរដែលយើងមាន ។ ថ្វីបើយើងខិតខំអស់ពីលទ្ធភាពក្តី ក៏យើងនៅតែមិនអាចយល់បានដែរ ។ ស្ថានសួគ៌ហាក់ដូចជាបិទទ្វារ ។ នោះគឺជាពេលដែលការទុកចិត្តរបស់យើងទៅលើ ព្រះអាចជួយឲ្យយើងមានការអត់ធ្មត់ដើម្បីរង់ចាំមើលទ្រង់ ។ មិនមែនគ្រប់អស់ទាំងសំណួរនឹងនឹងត្រូវបានចម្លើយតបភ្លាមៗ ឬ សូម្បីតែនៅក្នុងជីវិតនេះនោះទេ ។ មិនមែនគ្រប់អស់ទាំងឧបសគ្គទាំងអស់នឹងក្លាយមកជាងាយស្រួលមុននឹងរូបកាយ និងវិញ្ញាណបែកចេញពីគ្នានោះទេ ។ ប៉ុន្តែប្រសិនបើយើងស្រឡាញ់ព្រះលើសពីអ្វីៗទាំងអស់ ប្រសិនបើយើងទុកចិត្តលើសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើង យើងនឹងអាចស៊ូទ្រាំដោយសេចក្តីជំនឿរហូតដល់ថ្ងៃនោះនឹងមកដល់ ជាពេលដែលវាំងននត្រូវបានលើកឡើង ហើយអ្វីៗទាំងអស់ត្រូវបានបើកបង្ហាញ ។

« ចូរទុកដាក់ផ្លូវអ្នកនឹងព្រះយេហូវ៉ាចុះ ថែមទាំងទុកចិត្តដល់ទ្រង់ផង ។

« ទ្រង់នឹងឲ្យសេចក្តីសុចរិតរបស់អ្នកបានផ្សាយចេញដូចជាពន្លឺ ហើយសេចក្តីយុត្តិធម៌របស់អ្នកដូចជាវេលាថ្ងៃត្រង់ផង ។

« ចូរស្ងៀមនៅចំពោះព្រះយេហូវ៉ា ហើយរង់ចាំទ្រង់ចុះ » (ទំនុកដំកើង 37:5–7) ។ ■

**កំណត់ចំណាំ**

1. ឌៀថើរ អេស្វ អុជដូហ្វ « Come, Join with Us, » *Liahona*, ខែ វិច្ឆិកា ឆ្នាំ 2013 ទំព័រ 23 ។





ដោយ ដេវីឌ អិល បេ៊ក
ប្រធានយុវជនទូទៅ

# ព្រះអង្គសង្គ្រោះ និង ពិធីសាក្រាម៉ង់



### បទពិសោធន៍របស់ខ្ញុំក្នុងពិធីសាក្រាម៉ង់

តាមដែលខ្ញុំអាចចាំបាន គឺខ្ញុំត្រូវបានប្រាប់ឲ្យគិតពីព្រះយេស៊ូវគ្រីស្ទនៅក្នុងពិធីសាក្រាម៉ង់ ។ នៅពេលខ្ញុំចែកសាក្រាម៉ង់ជាលើកដំបូងនៅខែធ្នូឆ្នាំមុន ខ្ញុំត្រូវបានគ្របដណ្ដប់ដោយអារម្មណ៍សុខសាន្ត ហើយបរិសុទ្ធ ។ ខ្ញុំមានអារម្មណ៍ថាព្រះវិញ្ញាណប្រាប់ខ្ញុំថា ខ្ញុំកំពុងជួយដល់អ្នកដទៃឲ្យមករកព្រះគ្រីស្ទ ។ ខ្ញុំមានអំណរគុណដែលព្រះវរបិតាសួគ៌បានទុកព្រះទ័យលើខ្ញុំ រហូតដល់ទ្រង់អនុញ្ញាតឲ្យខ្ញុំបម្រើទ្រង់ ហើយជួយដល់អ្នកដទៃ ។

**ជេកុប អ័រ អាយុ 12 ឆ្នាំ រដ្ឋអៃដាហូ ស.រ.អា.**

*នៅពេលអ្នកទទួលទានសាក្រាម៉ង់ អ្នករំឭកពីសេចក្ដីសញ្ញារបស់អ្នកដើម្បីចងចាំដល់ព្រះអង្គសង្គ្រោះជានិច្ច ។*

តើអ្នកគិតពីអ្វីខ្លះ នៅពេលអ្នកទទួលទាននំបុ័ង និងទឹកនៃពិធីសាក្រាម៉ង់ ឬពេលអ្នករៀបចំខ្លួនប្រសិទ្ធពរ ឬចែកសាក្រាម៉ង់ ? យើងភាគច្រើនគិតពីសេចក្ដីសញ្ញារបស់យើង និងរបៀបដែលយើងកំពុងរស់នៅ ។ យើងគិតពីអំពើបាបយើង ហើយអធិស្ឋានសូមការអត់ទោស ហើយតាំងចិត្តធ្វើឲ្យប្រសើរឡើង ។

ទាំងនេះជាកត្តាដ៏សំខាន់នៃពិធីបរិសុទ្ធនៃពិធីសាក្រាម៉ង់ ។ លើសពីនេះទៀត មានអ្វីមួយផ្សេងទៀតដើម្បីសញ្ជឹងគិត—ជាអ្វីមួយដ៏ជ្រាលជ្រៅ ហើយជាក់លាក់បំផុត ដែលវាជាផ្នែកមួយនៃការអធិស្ឋានសាក្រាម៉ង់ ។ វាគឺជាការរំឭកចាំពីព្រះយេស៊ូវគ្រីស្ទ ព្រះរាជបុត្រានៃព្រះ ជាព្រះអង្គសង្គ្រោះនៃពិភពលោក ។ ជនដែលទទួលទាននំបុ័ងសន្យាថានឹង« ទទួលទានដោយនូវការចងចាំដល់ព្រះកាយនៃព្រះរាជបុត្រា » ហើយ « ចងចាំទ្រង់ជានិច្ច » (គ. និង ស. 20:77) ។ ស្រដៀងគ្នានេះដែរ ជនដែលទទួលទានទឹកសន្យាថាទទួលទាន « ដោយនូវការចងចាំដល់ព្រះលោហិតនៃព្រះរាជបុត្រា » ហើយ « ថាពួកគេនឹងចងចាំទ្រង់ជានិច្ច » (គ. និង ស. 20:79) ។

ជម្រើសដើម្បីចងចាំដល់ព្រះអង្គសង្គ្រោះព្រមទាំងដង្វាយធួន និង ការ ពលិកម្មរបស់ទ្រង់គឺជារឿងដ៏សំខាន់នៃពិធីបរិសុទ្ធនេះ ។ ដូចជាអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « នៅក្នុងភាសាដ៏សាមញ្ញ និងដ៏មានអត្ថន័យនៃការអធិស្ឋានសាក្រាម៉ង់ . . . ពាក្យដ៏សំខាន់ដែលយើងឮហាក់ដូចជាពាក្យថា*ចងចាំ* ។ . . . អ្វីដែល*បាន*សង្កត់ធ្ងន់នៅក្នុងការអធិស្ឋានទាំងពីរនេះគឺថាកិច្ចការនេះត្រូវបានធ្វើឡើងដោយចងចាំដល់ព្រះគ្រីស្ទ ។ នៅក្នុងការចូលរួមបែបនេះ យើងធ្វើជាសាក្សីថា យើងនឹងចងចាំទ្រង់ជានិច្ច ដើម្បីឲ្យយើងអាចបានព្រះវិញ្ញាណរបស់ទ្រង់គង់ជាមួយយើង » ។[1]

ព្រះអង្គសង្គ្រោះបានលើកឡើងពីចំណុចដដែលនេះ កាលទ្រង់ចាប់ផ្ដើមធ្វើពិធីសាក្រាម៉ង់ជាមួយនឹងពួកសាវកទ្រង់នៅបុណ្យរំលង ក្នុងទីក្រុងយេរូសាឡឹមនាយប់ចុងក្រោយនៃការបម្រើរបស់ទ្រង់នៅលើផែនដី—ជាយប់ដែលទ្រង់បានរងទុក្ខសម្រាប់យើង ក្នុងសួនច្បារច្បារគែតសេម៉ានីពីមុនការរងទុក្ខម្ដង ទៀតនៅលើឈើឆ្កាង ។ ឧទាហរណ៍ បន្ទាប់ពីហ៊ុចនំបុ័ងឲ្យពួកគេបរិភោគមក ទ្រង់បានមានបន្ទូលថា « នេះហើយជារូបកាយខ្ញុំដែលបានប្រទានសម្រាប់អ្នករាល់គ្នា ចូរធ្វើបុណ្យនេះដើម្បីរំឭកពីខ្ញុំចុះ » (លូកា 22:19–20 សូមមើលផងដែរ ម៉ាថាយ 26:26–28) ។

នៅថ្ងៃដំបូងរបស់ព្រះអង្គសង្គ្រោះនៅក្នុងចំណោមសាសន៍នីហ្វៃនៅទ្វីបអាមេរិក ទ្រង់ក៏បានបង្រៀនពួកគេពីពិធីបរិសុទ្ធនៃពិធីសាក្រាម៉ង់នេះផងដែរ ។ ជាថ្មីម្ដងទៀត ទ្រង់បានណែនាំពួកគេឲ្យទទួលទានដោយចងចាំដល់ព្រះកាយ និង ព្រះលោហិតរបស់ទ្រង់ ហើយមានបន្ទូលប្រាប់ពួកគេថា កាលពួកគេធ្វើដូច្នេះ « ការណ៍នេះនឹងទៅជាទីបន្ទាល់ដល់ព្រះវរបិតាថា អ្នករាល់គ្នាចងចាំដល់យើងជានិច្ច » (នីហ្វៃទី 3 18:7) ។ រួចទ្រង់បានសន្យានឹងពួកគេថា « បើសិនជាអ្នករាល់គ្នាចងចាំដល់យើងជានិច្ច នោះអ្នករាល់គ្នានឹងមានព្រះវិញ្ញាណរបស់យើងនៅជាមួយនឹងអ្នក » (នីហ្វៃទី 3 18:7, 11) ។

ឱជាពរជ័យដ៏មហិមាម្ល៉េះហ្ន៎! នៅក្នុងពិភពលោកមួយដែលពោរពេញដោយឧបសគ្គភាពជ្រួលច្របល់ និង ការល្បួងដែលខំព្យាយាមដឹកនាំយើងឲ្យវង្វេងនោះ តើមានអំណោយទានឯណាទៀតទៅ ដែលសំខាន់ដែលយើងអាចមាន ? ដោយមានព្រះវិញ្ញាណគង់ជាមួយនឹងយើង យើងអាច « ស្គាល់សេចក្ដីពិតនៃគ្រប់ការណ៍ទាំងអស់ » (ម៉ូរ៉ូណៃ 10:5) ។ ការណ៍នោះនឹងផ្ដល់អំណាច និង ប្រាជ្ញាដល់យើងដើម្បីរស់នៅតាមរបៀបដែលព្រះអម្ចាស់សព្វព្រះទ័យ ដើម្បីធ្វើការជ្រើសរើសត្រូវ ដើម្បីបម្រើដោយស្មោះត្រង់ និងដើម្បីប្រែក្លាយដូចជាទ្រង់ ។

កាលអ្នកចូលរួមនៅក្នុងពិធីសាក្រាម៉ង់រៀងរាល់សប្ដាហ៍ តើអ្នកអាចធ្វើអ្វីខ្លះដើម្បីចងចាំដល់ទ្រង់ ? តើអ្នកអាចធ្វើអ្វីខ្លះដើម្បីចងចាំដល់ទ្រង់*ជានិច្ច*—ពេញមួយសប្ដាហ៍ និង ពេញមួយជីវិតរបស់អ្នក?

ខ្ញុំសូមអញ្ជើញអ្នកឲ្យគិតនូវសំណួរទាំងនោះ ហើយធ្វើការតាំងចិត្តមួយដើម្បីចងចាំដល់ព្រះអង្គសង្គ្រោះជានិច្ច ។ អ្នកនឹងភ្ញាក់ផ្អើលពីរបៀបដែលការណ៍នេះនឹងផ្លាស់ប្ដូរជីវិតអ្នក ។ ■



**ការចងចាំដល់ព្រះអង្គសង្គ្រោះ**

ដើម្បីជួយអ្នក និង គ្រួសារអ្នកឲ្យចងចាំដល់ព្រះអង្គសង្គ្រោះ សូមពិចារណាអំពីការសិក្សាក្នុងសៀវភៅ *Come, Follow Me* (ចូរមកតាមខ្ញុំ) នៅមេរៀនដែលមានចំណងជើងថា « How can I help others have a meaningful experience with the sacrament ? (តើខ្ញុំអាចជួយអ្នកដទៃឲ្យមានបទពិសោធន៍ដ៏មានតម្លៃ នៅក្នុងពិធីសាក្រាម៉ង់បានដោយរបៀបណា ?) » នៅ lds.org/go/491214 ។ វីដេអូនៅលើទំព័រនោះដែលមានចំណងជើងថា « Always Remember Him, (ចងចាំទ្រង់ជានិច្ច) » អាចប្រើជាធនធានដ៏មានតម្លៃមួយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។



កំណត់ចំណាំ

1. Jeffery R. Holland, « This Do in Remembrance of Me, » *Ensign*, ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 68 ។

ដោយ យូស្វេ ផេ ភីខី
ទស្សនាវដ្ដីសាសនាចក្រ

មេរៀនទាំងឡាយនៅថ្ងៃអាទិត្យ

ប្រធានបទសម្រាប់ខែនេះ ៖
ការស្ដាប់បង្គាប់

# តើការធ្វើជាការប្រែចិត្តជឿថ្មីសុទ្ធសាធមានអារម្មណ៍បែបណាដែរ ?

*អ្នកអាចជួយសមាជិកតាមរយៈការរៀនយល់ដឹងពីអ្វីដែលពួកគេកំពុងជួបប្រទះ ។*

ប្រសិនបើអ្នកធំឡើងនៅក្នុងសាសនាចក្រ កិច្ចការទាំងឡាយនៅក្នុងព្រះវិហារគឺជារឿងធម្មតា ។ អ្នកយល់ស្គាល់ពីភាពទៀងទាត់នៃការប្រជុំនានា អគារដែលអ្នកចូលរួម ប្រភេទសំលៀកបំពាក់ដែលមនុស្សទូទៅស្លៀកពាក់ទៅព្រះវិហារ ។ រឿងដូចជាការឡើងនិយាយក្នុងការប្រជុំសាក្រាម៉ង់ ការបង់ដង្វាយមួយភាគក្នុងដប់ និង ដង្វាយតមអាហារ ព្រមទាំងការតមអាហារមួយខែម្ដងគឺជាផ្នែកមួយនៃជីវិត ។ ការរស់នៅតាមច្បាប់នៃពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ការទទួលយកការហៅបម្រើ និង ការរស់នៅតាមច្បាប់ព្រហ្មចារីភាពគឺជាអ្វីដែលអ្នករៀនធ្វើ ។

ប៉ុន្តែសម្រាប់ពួកអ្នកប្រែចិត្តជឿ វាអាចជាការសម្របខ្លួនមួយដ៏ធំដើម្បីទទួលយកកិច្ចការទាំងនោះ ។ ពិតណាស់ ការទទួលបានទីបន្ទាល់មួយពីសេចក្ដីពិតនៃដំណឹងល្អគឺជាជំហានដំបូងដើម្បីក្លាយជាសមាជិកក្នុងសាសនាចក្ររបស់ព្រះគ្រីស្ទ ។ ប៉ុន្តែការមានទីបន្ទាល់មួយពុំមែនមានន័យថាដំណើរផ្លាស់ប្ដូរដើម្បីរស់នៅក្នុងជីវិតជាសមាជិកសាសនាចក្រមានភាពងាយស្រួលនោះទេ ។

## សាសនាចក្រអាចទំនងជាអ្វីមួយខុសប្លែកពីគេ ។

ឧទាហរណ៍ដូចជារូបខ្ញុំ ៖ ខ្ញុំមានមិត្តជាពួកបរិសុទ្ធថ្ងៃចុងក្រោយចាប់តាំងពីខ្ញុំមានអាយុ 13 ឆ្នាំ ហើយនៅទីបំផុតខ្ញុំបានចូលក្នុងសាសនាចក្រកាលខ្ញុំមានអាយុ 19 ឆ្នាំ ។ ប៉ុន្តែទោះជាបានរៀនច្រើនអំពីវប្បធម៌សាសនាចក្រអស់រយៈពេលជាច្រើនឆ្នាំក្ដី ក៏ខ្ញុំនៅតែមានការផ្លាស់ប្ដូរដ៏លំបាកដែរ ។ ចំពោះខ្ញុំ វប្បធម៌ និង ការអនុវត្តរបស់សាសនាចក្រមានភាពខុសគ្នាយ៉ាងខ្លាំងដែលវាហាក់ដូចជារឿងដ៏ចម្លែក ។

ខ្ញុំបានធំឡើងនៅក្នុងព្រះវិហារមួយដែលមានភាពខុសគ្នាយ៉ាងខ្លាំងជាមួយនឹងព្រះវិហារដែលអ្នកស្គាល់ ឬនឹងស្គាល់ ។ នៅឯព្រះវិហារពួកគ្រូគង្វាល និង ក្រុមចម្រៀងស្លៀករ៉ូបស្រដៀងនឹងរ៉ូបសម្រាប់ការបញ្ចប់ការសិក្សានៅវិទ្យាល័យ ។ ក្នុងកម្មវិធីថ្វាយបង្គំ—ជាការប្រជុំសាក្រាម៉ង់របស់ពួកគេ—ពួកគ្រូគង្វាលបានឡើងបង្រៀនដល់ក្រុមជំនុំទាំងមូល ។ រៀងរាល់ថ្ងៃអាទិត្យយើងបានសូត្រពាក្យអធិស្ឋានរបស់ព្រះអម្ចាស់រួមគ្នា ហើយតែងច្រៀងទំនុកតម្កើងបទ « Praise God from Whom All Blessings Flow (សរសើរដល់ព្រះដែលជាអង្គប្រទាននូវពរជ័យទាំងពួង) » ។ ទារកត្រូវបានគេជ្រមុជទឹកឲ្យ



ដោយការប្រោះទឹកនៅលើក្បាលរបស់ពួកគេ ប៉ុន្តែពិធីបញ្ជាក់បានកើតឡើងនៅពេលមានអាយុប្រហែល 14 ឆ្នាំ ។

យើងទទួលទានទឹកទំពាំងបាយជូជំនួសឲ្យទឹកសម្រាប់ពិធីសាក្រាម៉ង់ ហើយក្មេងៗនៅអនុវិទ្យាល័យចូលរួមសាលាថ្ងៃអាទិត្យជាមួយនឹងពួកមនុស្សពេញវ័យក្នុងថ្នាក់មួយដែលនិយាយពីរឿងរ៉ាវបច្ចុប្បន្នក្នុងសង្គម ។

សូម្បីតែអគាររបស់យើងក៏ខុសប្លែកពីអគារពួកបរិសុទ្ធថ្ងៃចុងក្រោយដែលខ្ញុំធ្លាប់ទៅដែរ ។ យើងមានរោងថ្វាយបង្គំធំមួយរៀបចំឡើងតាមព្រះវិហារពួកគ្រីស្ទាននៅប៉ែកអឺរ៉ុប ដោយមានដំបូលស្រួចខ្ពស់ និង បង្អួចកញ្ចក់រូបភាពខ្ពស់ៗ ។ មានឈើឆ្កាងនៅលើវេទិការបស់ក្រុមចម្រៀង ។ មានប៉ម ជួងដ៏ខ្ពស់យ៉ាងស្រស់ស្អាតនៅពីមុខអគារ ។ ខ្ញុំចូលចិត្តវាយជួងនោះក្រោយពីកម្មវិធីព្រះវិហារ ។ វាមានទម្ងន់ធ្ងន់ល្មមអាចលើកក្មេងតូចម្នាក់ផុតពីដី កាលខ្សែរ៉ូបនោះត្រូវបានទាញឡើងចុះ ។

ទំនៀមទម្លាប់ និង ជំនឿខាងសង្គមរបស់យើងក៏ខុសគ្នាដែរ ។ យើងត្រូវបានបង្រៀនថា ការហូបស្រា ឬបារីគឺគ្មានបញ្ហាអ្វីទេ ។ ការមានមិត្តប្រុស ឬមិត្តស្រីក្នុងវ័យជំទង់គឺគ្មានបញ្ហាអ្វីនោះទេ ។ យើងក៏ត្រូវបានបង្រៀនថា អ្នកអាចមានទំនាក់ទំនងខាងផ្លូវភេទពីមុនអាពាហ៍ពិពាហ៍បានដែរ ដរាបណាអ្នកជឿថាអ្នកស្រឡាញ់គ្នា ។ យើងមិនដែលនិយាយគ្នាពីការមានទីបន្ទាល់ឡើយ ។ គ្រាដំបូងដែលខ្ញុំបានឃើញការប្រជុំតមអាហារ និង ទីបន្ទាល់—ខ្ញុំមានការភ្ញាក់ផ្អើល! ខ្ញុំមិនជឿថា វាចម្លែកបែបនេះទេ ។ គ្មាននរណាម្នាក់ក្រោកឈរឡើងចែកចាយជំនឿរបស់ពួកគេដូចជានៅក្នុងព្រះវិហារខ្ញុំឡើយ ។

ការមកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

វាពិបាកខ្លាំងនៅប្រាំមួយខែដំបូង
បន្ទាប់ពីខ្ញុំបានជ្រមុជទឹក ។ ខ្ញុំស្ទើរតែមិនអាចទ្រាំទ្របាន ។
**អ្វីៗគ្រប់យ៉ាងមានភាពខុសប្លែកគ្នាខ្លាំងណាស់ . . . ។**

ពុំមែនគ្រាន់តែរៀនគោលលទ្ធិថ្មី ដូចជាជីវិតមុនឆាកជីវិតនេះ និង បុណ្យជ្រមុជទឹកសម្រាប់មនុស្សស្លាប់ប៉ុណ្ណោះទេ វាជាការផ្លាស់ប្តូរមួយខាងវប្បធម៌ រចនាបទជីវិត និង ការរំពឹងទុក ។ ការដោះស្រាយភាពខុសគ្នាទាំងនោះគឺជាផ្លូវមួយដែលពិបាកដើរ ។

ប្រាំមួយខែដំបូងបន្ទាប់ពីខ្ញុំជ្រមុជទឹកគឺពិតជាលំបាកមែន ។ ខ្ញុំស្ទើរតែសម្របខ្លួនតាមមិនបាន ។ អ្វីទាំងអស់មានភាពខុសប្លែកគ្នាខ្លាំងណាស់ ជាពិសេសដោយសារខ្ញុំចូលរួមព្រះវិហារដោយគ្មានគ្រួសារខ្ញុំ ។ ខ្ញុំនៅតែមានការលំបាកនឹងចំណុចគោលលទ្ធិជាក់លាក់ ក៏ដូចជាអារម្មណ៍នៃការឃ្លាតឆ្ងាយពីអតីតកាលរបស់ខ្ញុំ ។

ជាសំណាងល្អ មិត្តខ្ញុំក្នុងសាសនាចក្រមានចិត្តអត់ធ្មត់ ចិត្តល្អ ហើយហ្មឹងធឹងជានិច្ច។ ពួកគេបាននាំខ្ញុំចូលរួមសកម្មភាពផ្សេងៗ អញ្ជើញខ្ញុំទៅផ្ទះពួកគេសម្រាប់អាហារពេលល្ងាច និង រាត្រីជួបជុំក្រុមគ្រួសារ ហើយបានអធិស្ឋានជាមួយខ្ញុំ ។ ការណ៍នោះបានធ្វើឲ្យមានភាពខុសប្លែកយ៉ាងខ្លាំង មិនគ្រាន់តែនៅក្នុងការចូលរួមរបស់ខ្ញុំនឹងសាសនាចក្រប៉ុណ្ណោះទេ ប៉ុន្តែចំពោះការបន្តសកម្ម

របស់ខ្ញុំ ហើយរកឃើញកម្លាំងក្នុងពេលដែលទីបន្ទាល់របស់ខ្ញុំបានរេរា ។ ខ្ញុំជំពាក់គុណពួកគេច្រើនណាស់សម្រាប់ការជួយខ្ញុំឲ្យយកឈ្នះនូវរឿងទាំងនេះ ។

ក្នុងដំណើររឿងបន្ទាប់ទៀត មានសមាជិកវ័យក្មេងពីររូបបានចែកចាយបទពិសោធន៍ផ្ទាល់របស់ពួកគេស្ដី ពីការចូលរួមក្នុងសាសនាចក្រ និង ពីរបៀបដែលពួកគេបានរកឃើញកម្លាំងដើម្បីសម្របខ្លួនពួកគេ ។ នៅពេលអ្នកអានពីបទពិសោធន៍របស់ពួកគេ សូមគិតពីអ្វីដែលអ្នកអាចធ្វើដើម្បីជួយដល់អ្នកប្រែចិត្តជឿថ្មីម្នាក់ ឬនរណាម្នាក់ដែលត្រឡប់មកសកម្មវិញ ការរកឃើញកម្លាំងដើម្បីសម្របខ្លួនខាងសង្គម និង ខាងវប្បធម៌ ហើយរីកចម្រើនខាងវិញ្ញាណ ។

## ការរង់ចាំអស់ជាច្រើនឆ្នាំដើម្បីទទួលបុណ្យជ្រមុជទឹក

កាលខ្ញុំរៀននៅអនុវិទ្យាល័យ ខ្ញុំបានសម្រេចចិត្តចូលរួមនឹងសាសនាចក្រ បន្ទាប់ពីការជួបពួកអ្នកផ្សព្វផ្សាយសាសនានៅក្នុងថ្នាក់ភាសាអង់គ្លេស ហើយសិក្សាជាមួយនឹងពួកគេ ។ ឪពុកម្ដាយខ្ញុំបានប្រតិកម្មយ៉ាងខ្លាំង កាលខ្ញុំបានប្រាប់ដល់ពួកគាត់ថាខ្ញុំចង់ទទួលបុណ្យជ្រមុជទឹក ។ ពួកគាត់មិនបានដឹងច្រើនពីសាសនាចក្រនោះទេ ហើយពួកគាត់បានភ័យខ្លាចថា ខ្ញុំត្រូវបានទាក់ទាញទៅរកអ្វីមួយដែលគ្រោះថ្នាក់ ។ ពួកគាត់បានគិតថា សាសនាចក្ររាំងដល់ការអប់រំរបស់ខ្ញុំ ហើយថាដោយសារច្បាប់ទាំងអស់ ខ្ញុំនឹងគ្មានភាពរីករាយក្នុងជីវិត ។ ពួកគាត់មិនអនុញ្ញាតឲ្យខ្ញុំជ្រមុជទឹកអស់រយៈពេលពីរឆ្នាំកន្លះ ។

## អ្វីដែលពួកអ្នកប្រែចិត្តជឿប្រឈមមុខ

នេះជាឧបសគ្គមួយចំនួនដែលអ្នកប្រែចិត្តជឿថ្មីជួបប្រទះ ។ តើមិត្តភាពរបស់អ្នកអាចជួយពួកគេប្រឈមនឹងឧបសគ្គរបស់ពួកគេបានដោយរបៀបណា ?

1. ការពិបាកយល់នូវគោលលទ្ធិថ្មី ។
2. ការជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយ តន្ត្រី ខ្សែភាពយន្ត និង សៀវភៅខុសគ្នា ។
3. ការយល់ដឹងពីភាសាក្នុងបទគម្ពីរ ។
4. ការប្រឈមមុខនឹងការខ្វះភាពទទួលយកពីគ្រួសារ និង មិត្តដែលពុំមែនជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ។
5. ការស្លៀកពាក់សំលៀកបំពាក់ខុសគ្នា ។
6. ការលះបង់ពេលវេលាដើម្បីទៅព្រះវិហារ និង ថ្នាក់សិក្ខាសាលា ។
7. ការរៀនពីការអនុវត្ត និង ប្រពៃណីថ្មីក្នុងកម្មវិធីថ្វាយបង្គំ ។
8. ការត្រូវផ្លាស់ប្ដូរទម្លាប់ ភាសា និង ការគិត ។
9. ការសម្របខ្លួនទៅនឹងវប្បធម៌ខាងសង្គមរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ។
10. ការរៀននូវពាក្យជាក់លាក់របស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ដូចជា*ដំណឹងល្អ* *ការក្បត់សាសនា*និង*ការស្ដារឡើងវិញ* ។



ខ្ញុំត្រូវតែ**ស្ដាបនាសេចក្ដីជំនឿ និង ទីបន្ទាល់របស់ខ្ញុំ**ដោយការអធិស្ឋាន ការអានព្រះគម្ពីរ និង ពាក្យពេចន៍នៃពួកព្យាការីសម័យទំនើប **—ដោយខ្លួនឯង** ។

ខ្ញុំត្រូវបានសាកល្បងតាំងពីដំបូងមក ។ ពីមុនខ្ញុំអាចទទួលបុណ្យជ្រមុជទឹក ខ្ញុំបានអធិស្ឋានអស់រយៈពេលជាច្រើនឆ្នាំម្ដងហើយម្ដងទៀតទូលសូមកម្លាំង និង សេចក្ដីជំនឿដ៏ចាំបាច់ដើម្បីរក្សាការជឿនេះ ។ ខ្ញុំមិនអាចទៅព្រះវិហារ ឬសេពគប់នឹងសមាជិក ឬពួកអ្នកផ្សព្វផ្សាយសាសនាបានទេ ។ ខ្ញុំត្រូវស្ដាបនាសេចក្ដីជំនឿ និង ទីបន្ទាល់របស់ខ្ញុំដោយការអធិស្ឋាន ការអានព្រះគម្ពីរ និង ប្រសាសន៍នៃពួកព្យាការីសម័យទំនើប—ដោយខ្លួនឯង ។ ខ្ញុំបានខកខានចូលរួមកម្មវិធីល្អៗ និងកម្មវិធីកម្សាន្តសប្បាយជាច្រើន ។

នៅពេលខ្ញុំផ្លាស់ទៅទីក្រុងរ៉ូមទៅរៀននៅមហាវិទ្យាល័យ ប៊ីស្សពរបស់ខ្ញុំបានក្លាយទៅជាមិត្តពិតម្នាក់ដែលបានឈរក្បែរខ្ញុំ កាលឪពុកម្ដាយខ្ញុំមានកំហឹងជាខ្លាំង ។ គាត់បានបង្រៀនខ្ញុំថា ការស្រឡាញ់ឪពុកម្ដាយខ្ញុំដោយឥតលក្ខខណ្ឌគឺជារឿងដ៏ចាំបាច់ ។

នៅទីបំផុតកាលខ្ញុំបានទទួលបុណ្យជ្រមុជទឹក មានសមាជិកវួដជាច្រើនបានមក ហើយជួយគាំទ្រដល់ខ្ញុំ ។ ខ្ញុំបានចូលរួមនឹងក្រុមចម្រៀង ហើយមានមិត្តជាច្រើននៅទីនោះ ។ មិត្តភាព និង សេចក្ដីសប្បុរសរបស់ពួកគេបានធ្វើឲ្យខ្ញុំមានអារម្មណ៍ដូចជាគ្រួសារ ។

នៅពេលយើងស្មោះត្រង់ចំពោះការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយធ្វើតាមគំរូរបស់ទ្រង់ដោយមានចិត្តស្រឡាញ់ ហើយមើលថែដល់អ្នកដទៃ នោះ

ពួកអ្នកប្រែចិត្តជឿថ្មី និង ពួកអ្នករៀននឹងឃើញ ថា យើងមិនត្រឹមតែនិយាយនឹងបបូរមាត់ទ្បើង តែយើងពិតជាអនុវត្តទៀតផង ។

*អូតាវីយ៉ូ ការូសូ មកពីប្រទេសអ៊ីតាលី ហើយបច្ចុប្បន្ននេះកំពុងបម្រើបេសកកម្មពេញម៉ោង ។*

## ការចូលចំណោមគេមិនចុះ

ខ្ញុំបានចូលរួមនឹងសាសនាចក្រកាលខ្ញុំមានអាយុ 13 ឆ្នាំ ។ ខ្ញុំមានទីបន្ទាល់ពីដំណឹងល្អ ប៉ុន្តែខ្ញុំមានអារម្មណ៍តានតឹងថា ខ្ញុំចូលចំណោមមិនចុះក្នុងសាសនាចក្រឡើយ ។ មនុស្សផ្សេងទៀតបានស្គាល់ពីចម្រៀង និង ដំណើររឿងបទគម្ពីរលើកលែងតែខ្ញុំម្នាក់ឯងគត់ ។ មនុស្សផ្សេងទៀតមានអនុស្សាវរីយ៍នៃសកម្មភាពថ្នាក់កុមារ ឬ មេរៀនរាត្រីជួបជុំក្រុមគ្រួសារ ដោយលែកតែខ្ញុំពុំធ្លាប់មានរឿងទាំងនោះឡើយ ។

ប៉ុន្តែលើសពីនោះទៀត មនុស្សគ្រប់គ្នាហាក់ដូចជាមានចំណាប់អារម្មណ៍ ឬទស្សនៈដូចគ្នា—ពេលខ្លះ ជាទស្សនៈដែលផ្ទុយយ៉ាងខ្លាំងពីទស្សនៈរបស់ខ្ញុំ—ស្ដីពីអ្វីៗគ្រប់យ៉ាងតាំងពីខ្សែភាពយន្ត និង នយោបាយងាកទៅរកការបកស្រាយពីបទគម្ពីរនានាណាមួយ ។ ខ្ញុំបានសម្លឹងមើលជុំវិញនូវការងក់ក្បាលទាំងអស់ ហើយគិតថា « អ្នកទាំងអស់គ្នាជាមនុស្សល្អ ហើយខ្ញុំក៏ជាមនុស្សល្អ ។ ប៉ុន្តែយើងមានគំនិតខុសគ្នា ។ ខ្ញុំមិនសមនៅទីនេះសោះ » ។

អ្នកទាំងអស់គ្នាជាមនុស្សល្អ
ហើយខ្ញុំក៏ជាមនុស្សល្អ ។
**ប៉ុន្តែយើងមានលក្ខណៈខុសគ្នាឆ្ងាយណាស់ ។**
ខ្ញុំមិនសមនៅទីនេះសោះ ។

ខ្ញុំមានអារម្មណ៍បែបនោះអស់រយៈពេលពីរទៅបីឆ្នាំ។ រួចខ្ញុំបានចាំ ហើយបានអានឡើងវិញនូវដំណើររឿងក្នុង លូកា 19 ស្ដីពី សាខេ ។ ដោយសារគាត់ជាពួកអ្នកយកពន្ធ គាត់គ្មានភាពល្បីល្បាញ ហើយត្រូវបានចាត់ទុកថាជាអ្នកមានបាប ។ ប៉ុន្តែកាលព្រះយេស៊ូវបានយាងកាត់ទីក្រុងនោះ សាខេ បានឡើងដើមឈើដើម្បីមើលឃើញទ្រង់ ។ គាត់មិនបានខ្វល់ពីអ្វីដែលអ្នកដទៃគិតពីគាត់នោះទេ ។ ការឡើងដើមឈើនេះ—ការញែកខ្លួនគាត់ចេញពីបណ្ដាជន—បានជួយគាត់ឲ្យមានបទពិសោធន៍ផ្ទាល់ខ្លួនដ៏មានតម្លៃបំផុតជាមួយនឹងព្រះអង្គសង្គ្រោះ ។ កាលខ្ញុំអាន ខ្ញុំបានដឹងថា អារម្មណ៍ដែលថាខ្ញុំដូចជាជនចំឡែកម្នាក់នោះគឺមិនមែនមកពីព្រះគ្រីស្ទនោះទេ ។ ព្រះយេស៊ូវមាននូវការរាប់បញ្ចូល និងការអភ័យទោស ។ ទ្រង់តែងតែស្វែងរកជនដែលត្រូវបានគេថ្កោលទោស ហើយបណ្ដេញចេញ—ជាជនទាំងឡាយដែលមើលទៅហាក់ដូចជាខុសពីគេ ។

ខ្ញុំមិនអាចនិយាយថា ខ្ញុំមិនធ្លាប់មានអារម្មណ៍ឃ្លាតឆ្ងាយម្ដងទៀតឡើយ ។ ខ្ញុំមាន ។ ប៉ុន្តែខ្ញុំបានរៀនថា អ្វីដែលធ្វើឲ្យខ្ញុំខុសប្លែក—ទស្សនៈរបស់ខ្ញុំ របៀបដែលអ្នកដទៃមើលមកខ្ញុំ អ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍ ទស្សនៈរបស់ខ្ញុំអំពីពិភពលោកនេះ—ទាំងនេះពុំមែនជាហេតុផលដើម្បីបែរចិត្តចេញនោះឡើយ ។ មានហេតុផលជាច្រើនដែលសាសនាចក្រត្រូវការយើងរាល់គ្នា ទាំងជាមួយនឹងទេពកោសល្យ កម្លាំង និង ទស្សនៈផ្សេងៗគ្នារបស់យើង ។ ■

*អេឡេន វីយើរស៍ រស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*



*ZACCHAEUS, MAKE HASTE, COME DOWN* ដោយ ឡូរ៉ា អិល ខាយ

*សាខេបានឡើងដើមឈើដើម្បីមើលឃើញទ្រង់ កាលព្រះគ្រីស្ទយាងដើរកាត់ទីក្រុងរបស់គាត់ ។*

### ចូលរួមក្នុងការសន្ទនា

#### រឿងគួរពិចារណា

- តើការផ្លាស់ប្ដូរបែបណាខ្លះដែលធ្វើឲ្យមានបទពិសោធន៍លំបាកសម្រាប់មនុស្សមួយចំនួនក្នុងការចូលរួមក្នុងសាសនាចក្រ ?
- តើមិត្តភាពរបស់អ្នកអាចជួយមនុស្សម្នាក់ឲ្យត្រឡប់មក ឬមានភាពរឹងមាំនៅក្នុងសាសនាចក្របានដោយរបៀបណា ?

#### រឿងទាំងឡាយដែលអ្នកអាចធ្វើ

- សូមសរសេរពីឧបសគ្គនានាដែលពួកអ្នកប្រែចិត្តជារឿយៗត្រូវជំនះលើ ហើយដាក់គោលដៅដើម្បីរកវិធីដែលអ្នកជួយដល់ពួកគេបាន ។
- អញ្ជើញអ្នកប្រែចិត្តជឿថ្មីម្នាក់ ឬមិត្តម្នាក់ដែលមិនសូវសកម្មឲ្យជួយអ្នកធ្វើសកម្មភាពសម្រាប់ថ្នាក់ ឬកូរ៉ុមរបស់អ្នក ។
- ចែកចាយបទពិសោធន៍របស់អ្នកនៅឯព្រះវិហារ នៅផ្ទះ ឬតាមអ៊ិនធើរណែត ។

# « តើខ្ញុំគួរធ្វើអ្វីនៅពេលខ្ញុំត្រូវបានគេចំអកឲ្យនៅឯសាលាដោយសារធ្វើតាមបទដ្ឋានសាសនាចក្រនោះ ? »

ប្រសិនបើអ្នកត្រូវបានគេសើចចំអកដោយសារការធ្វើតាមបទដ្ឋានសាសនាចក្រ អ្នកអាចចាប់យកឱកាសនោះដើម្បីធ្វើជាតំណាងឲ្យព្រះយេស៊ូវគ្រីស្ទ ។ ចូរមានការគោរព និង សេចក្ដីសប្បុរស ។ ប្រសិនបើត្រូវបានបំផុសគំនិត អ្នកអាចពន្យល់ពីហេតុផលដែលអ្នករស់នៅតាមរបៀបដែលអ្នកធ្វើ ។ សូមពិចារណាពីការប្រើសៀវភៅ*ដើម្បីកម្លាំងនៃយុវជន*ដើម្បីជួយអ្នកពិភាក្សាពីបទដ្ឋានរបស់អ្នក ។ សូមអញ្ជើញព្រះវិញ្ញាណចូលក្នុងជីវិតអ្នក ដើម្បីឲ្យទ្រង់អាចប៉ះដល់ដួងចិត្តរបស់មិត្តអ្នក ។ ព្រះវិញ្ញាណអាចជួយអ្នកឲ្យដឹងពីអ្វីដែលត្រូវនិយាយ ។

អ្នកក៏អាចសុំពាក្យទូន្មានពីឪពុកម្ដាយរបស់អ្នក ថ្នាក់ដឹកនាំសាសនាចក្រ ឬពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងផងដែរ ។ សូមសួរពួកគាត់ពីរបៀបដែលពួកគាត់តបតចំពោះស្ថានភាពស្រដៀងគ្នានេះ ។

ពេលខ្លះអ្នកប្រហែលជាត្រូវបានល្បួងឲ្យឈ្លោះប្រកែកនឹងអ្នកដទៃអំពីជំនឿរបស់អ្នក ។ ប៉ុន្តែសូមចងចាំថា « អស់អ្នកណាដែលមានវិញ្ញាណនៃការទាស់ទែងគ្នាគឺពុំមែនជារបស់ផងព្រះគ្រីស្ទទេ » (នីហ្វៃទី 3 11:29) ។

នៅពេលខ្លះទៀត អ្នកអាចមានសម្ពាធឲ្យចុះចាញ់ ហើយឈប់ធ្វើតាមបទដ្ឋានសាសនាចក្រ ។ ចូររឹងមាំ ។ ការឈរដ៏រឹងមាំនឹងមិនគ្រាន់តែប្រទានពរដល់ជីវិតអ្នកនូវសេចក្ដីសុខសាន្តប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចប្រទានពរដល់ជីវិតរបស់មិត្តភក្តិអ្នកផងដែរ ។ គំរូរបស់អ្នកអាចលើកទឹកចិត្តពួកគេឲ្យធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវ ។

សូមមើលទៅគំរូរបស់ព្រះអង្គសង្គ្រោះសម្រាប់ជាកម្លាំង ។ ព្រះអង្គសង្គ្រោះត្រូវបានគេចំអកដោយសារការទ្រង់ការពារសេចក្ដីពិត (សូមមើល អេសាយ 53) ។ ទ្រង់ជ្រាបយ៉ាងច្បាស់ពីអារម្មណ៍របស់អ្នក ។ ទ្រង់បានធ្វើដង្វាយធួនសម្រាប់អ្នកហើយជួបពិសោធន៍នឹងការសាកល្បងដូចអ្នកដែរ ។ ទ្រង់គង់នៅជាមួយនឹងអ្នក ។ សូមសិក្សាពីជីវិតទ្រង់ឲ្យបានច្រើនដើម្បីឲ្យអ្នកអាចប្រែក្លាយដូចជាទ្រង់នៅក្នុងស្ថានភាពទាំងនេះ ។



### កាន់ខ្ជាប់នឹងដំបងដែក

កាលមនុស្សទូទៅសើចចំអកឲ្យខ្ញុំនៅឯសាលារៀន ខ្ញុំគិតពីការនិមិត្តដែលលីហៃមានស្ដីពីអគារដ៏ធំ ហើយទូលាយ៖ « អគារនោះពេញទៅដោយមនុស្សទាំងចាស់ទាំងក្មេង ទាំងប្រុសទាំងស្រី ហើយរបៀបស្លៀកពាក់របស់ពួកគេសុទ្ធតែល្អប្រសើរ ហើយពួកគេកំពុងតែនៅក្នុងអាកប្បកិរិយាចំអកឡកឡឺយ ហើយចង្អុលដៃខ្លួនទៅរកពួកអ្នកដែលបានទៅដល់ ហើយកំពុងតែទទួលទានផ្លែឈើនោះ » (នីហ្វៃទី 1 8:27) ។ ខ្ញុំនឹងធ្វើដូចជាលីហៃ ។ ខ្ញុំនឹងមិនលែងដៃចេញពីដំបងដែកនេះទេរហូតដល់វាបានដឹកនាំខ្ញុំទៅដល់ជីវិតដ៏នៅអស់កល្បជានិច្ច ។

*ភា អេស អាយុ 18 ឆ្នាំ ប្រទេសហៃទី*



### ចែកចាយដំណឹងល្អ

ក្នុងនាមជាមិត្តម្នាក់ ហើយខ្ញុំបានបញ្ចប់ផ្នែកគម្រោងតម្លៃគុណធម៌សម្រាប់ការអភិវឌ្ឍន៍ខ្លួនរបស់ក្រុមយុវនារី យើងបានអានព្រះគម្ពីរមរមននៅសាលាក្នុងម៉ោងសម្រាក ។ គ្រូ និង មិត្តរួមថ្នាក់យើងបានចាប់ផ្ដើមសើចចំអកយើង ។ ពេលខ្លះ ខ្ញុំចង់ឈប់អាន ប៉ុន្តែខ្ញុំមិនអាចទុកព្រះគម្ពីរខ្ញុំនៅផ្ទះបានទេ ។ យើងបានបន្តអាននៅសាលារៀន ហើយទីបំផុតយើងមិនត្រូវបានគេសើចចំអកទៀតឡើយ ។ មានមិត្តយើងម្នាក់បានមានចំណាប់អារម្មណ៍នឹងដំណឹងល្អ និងការអភិវឌ្ឍន៍ខ្លួនរបស់ក្រុមយុវនារី ។ យើងបានឲ្យកូនសៀវភៅនោះ និង បណ្ដាំព្រះគម្ពីរទៅនាង ហើយចាប់ពីពេលនោះមកយើងបានបន្តប្រាប់នាងអំពីដំណឹងល្អ ។ បងប្រុសនាងក៏មានចំណាប់អារម្មណ៍នឹងដំណឹងល្អដែរ ។ ពួកគេទាំងពីរកំពុងអានព្រះគម្ពីរមរមន ។

*យ៉ែមបើលី អេ អាយុ 16 ឆ្នាំ ប្រទេសប្រេស៊ីល*

*ចម្លើយទាំងឡាយគឺមានបំណងទុកជាជំនួយ និង ជាទស្សនវិស័យ មិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*



**ធ្វើជាគំរូ**

នៅសាលារៀនខ្ញុំ សិស្សភាគច្រើនមិនស្គាល់ដំណឹងល្អឡើយ ។ ខ្ញុំគិតថា រឿងដ៏ល្អបំផុតដែលអ្នកធ្វើគឺ បង្ហាញដល់មនុស្សទូទៅពីរបៀបដែលការរស់នៅតាមដំណឹងល្អបានជះឥទ្ធិពលវិជ្ជមានមកលើអ្នក ។ តាមរយៈការមានចិត្តល្អ ហើយគោរព មិនថាពួកគេនិយាយអ្វីមកកាន់អ្នកនោះទេ អ្នកត្រូវធ្វើជាគំរូល្អ ហើយពួកគេនឹងមានការគោរពច្រើនឡើងចំពោះអ្នក និង ជំនឿរបស់អ្នក ។ ការចងចាំពីគំរូរបស់អ្នក មនុស្សដដែលនោះអាចនឹងបើកដួងចិត្តចំពោះការរៀនបន្ថែមទៀតពីដំណឹងល្អនៅពេលក្រោយ !

*ខេលស៊ី ភី អាយុ 14 ឆ្នាំ រដ្ឋផ្លរីដា ស.រ.អា.*

**ចែកចាយទីបន្ទាល់របស់អ្នក**

នៅពេលអ្នកស្គាល់ពីពរជ័យដែលកើតមានតាមរយៈការរស់នៅតាមបទដ្ឋានទាំងឡាយ អ្នកនឹងគ្មានអារម្មណ៍ខ្មាស់អៀន នៅពេលគេសើចចំអកឲ្យនោះឡើយ ។ អ្នកអាចបង្រៀនបទដ្ឋានទាំងនោះ ហើយចែកចាយទីបន្ទាល់មួយនៃការរស់នៅតាមបទដ្ឋានទាំងនោះ ។ មិត្តរបស់អ្នកអាចរៀន ហើយពោរពេញដោយព្រះវិញ្ញាណ ចាប់តាំងពីអ្នកបានចែកចាយទីបន្ទាល់ពីដំណឹងល្អ ។

*អេម៉ាញូអែល អេ អាយុ 16 ឆ្នាំ ប្រទេសហ្គាណា*



**ចងចាំថាអ្នកជានរណា**

សម្រាប់កម្មវិធីនៅសាលារៀន មិត្តរួមថ្នាក់ខ្ញុំ ឬសូម្បីតែមិត្តខ្ញុំបានប្រាប់ខ្ញុំឲ្យស្លៀកពាក់សំលៀកបំពាក់ដែលមិនសមរម្យចំពោះព្រះនេត្ររបស់ព្រះ ។ ពួកគេនិយាយថា « ឯងត្រូវតែស្អាត ។ ឯងត្រូវតែមើលទៅឲ្យខុសពីគេ » ។ ពេលខ្លះ ពួកគេនិយាយថា ខ្ញុំត្រូវបំភ្លេចពីជំនឿរបស់ខ្ញុំដើម្បីសម្របខ្លួនទៅនឹងពិភពលោកនេះ ។ ប៉ុន្តែខ្ញុំតែងឆ្លើយបដិសេធជានិច្ច ។ ខ្ញុំដឹងថា ដើម្បីធ្វើជាខ្លួនខ្ញុំពិត ខ្ញុំត្រូវតែមានចរិកលក្ខណៈខុសពីពិភពលោកនេះ ។ វាមិនជាអ្វីទេ ប្រសិនបើពួកគេមិនចូលចិត្តខ្ញុំដោយព្រោះតែលក្ខណៈសម្បត្តិរបសខ្ញុំនោះ ។ វាមិនសំខាន់ថាអ្នកដទៃនិយាយអ្វីនោះទេ តែអ្វីដែលសំខាន់គឺការធ្វើតាមមាគ៌ារបស់ព្រះវរបិតាសួគ៌ ។

*ជេស៊ី ស៊ី អាយុ 19 ឆ្នាំ ប្រទេសហ្វីលីពីន*



**ធ្វើជាអ្នកផ្សព្វផ្សាយសាសនា**

ខ្ញុំមានបទពិសោធន៍ជាច្រើនទាក់ទងនឹងការរស់នៅតាមបទដ្ឋាននៃដំណឹងល្អនៅសាលារៀន ។ ខ្ញុំបានរៀនថា នេះគឺជាពេលមួយដ៏ល្អបំផុតសម្រាប់យើងដើម្បីពង្រឹងទីបន្ទាល់របស់យើង ហើយចូលរួមក្នុងកិច្ចការផ្សព្វផ្សាយសាសនា ។ នៅពេលណាខ្ញុំដឹងថាខ្លួនខ្ញុំស្ថិតនៅក្នុងស្ថានភាពមួយដូចនេះ ហើយបានបន្តលើកកម្ពស់ដល់បទដ្ឋានរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍រីករាយក្នុងខ្លួនដោយបានធ្វើដូចដែលព្រះសព្វព្រះទ័យឲ្យខ្ញុំធ្វើ ។ សូមកុំឲ្យមានចិត្តសង្ស័យថាតើអ្នកជានរណា និងអ្វីដែលអ្នកជឿឲ្យសោះ ។

*ហាយរ៉ាម ឌី អាយុ 18 ប្រទេសប្រេស៊ីល*



**ចិញ្ចឹមបីបាច់ទីបន្ទាល់អ្នក**

« សូមមានចិត្តក្លាហានដើម្បីឈរឲ្យរឹងមាំ ការពារសេចក្ដីពិត និង សេចក្ដីសុចរិត ។ ដោយសារតែនិន្នាការនៅក្នុងសង្គមសព្វថ្ងៃនេះងាកឆ្ងាយពីតម្លៃ និងគោលការណ៍ដែលព្រះអម្ចាស់បានប្រទានដល់យើង អ្នកនឹងត្រូវបានហៅឲ្យការពារនូវអ្វីដែលអ្នកជឿ ។ លើកលែងតែឫសគល់នៃទីបន្ទាល់របស់អ្នកមានភាពរឹងមាំ បើមិនដូច្នោះទេ អ្នកនឹងមានការលំបាកដើម្បីស៊ូទ្រាំនឹងការចំអកឡកឡឺយពីសំណាក់ជនដែលចង់សាកល្បងនូវសេចក្ដីជំនឿអ្នក ។ . . . ទីបន្ទាល់របស់អ្នកត្រូវបានចិញ្ចឹមបីបាច់ជាទៀតទាត់ វានឹងរក្សាអ្នកឲ្យមានសុវត្ថិភាព » ។

ប្រធាន ថូម៉ាស អេស ម៉នសុន « May You Have Courage, » *Liahona,* ខែ ឧសភា ឆ្នាំ 2009 ទំព័រ 126 ។

## សំណួរចេញលើកក្រោយ

« ខ្ញុំមានអារម្មណ៍ភ័យខ្លាចដើម្បីធ្វើជាប្រធានថ្នាក់ម៉េម៉េត ។ តើខ្ញុំអាចក្លាយជាអ្នកដឹកនាំដ៏ល្អប្រសើរម្នាក់បានដោយរបៀបណា ? »

ប្រសិនបើអ្នកមានបំណង សូមផ្ញើចម្លើយរបស់អ្នក និង រូបថតច្បាស់មួយសន្លឹកមកត្រឹមថ្ងៃទី 15 ខែ មករា ឆ្នាំ 2015 នៅ liahona.lds.org (សូមចុច « Submit Your Work,) » តាមអ៊ីម៉ែលទៅ liahona@ldschurch.org ឬផ្ញើសំបុត្រ (សូមមើលអាសយដ្ឋាននៅទំព័រទី 3) ។

ព័ត៌មាន និង ការអនុញ្ញាតខាងក្រោម ត្រូវតែបញ្ចូលនៅក្នុងអ៊ីម៉ែល ឬ សំបុត្ររបស់អ្នក ៖ (1) ឈ្មោះពេញ (2) ថ្ងៃខែឆ្នាំកំណើត (3) វួដ ឬ សាខា (4) ស្តេក ឬ មណ្ឌល (5) សំបុត្រអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក ហើយបើសិនអ្នកមានអាយុក្រោម 18 ឆ្នាំ នោះត្រូវមានសំបុត្រអនុញ្ញាតពីឪពុកម្ដាយរបស់អ្នកជាលាយលក្ខណ៍អក្សរ (អ៊ីម៉ែលអាចទទួលយកបាន) ដើម្បីធ្វើការបោះពុម្ពចម្លើយ និង រូបថតរបស់អ្នក ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ បើវាវែងពេក ឬមិនសូវច្បាស់លាស់ ។

# មិនត្រូវការពួកទេវតាឡើយ

*នៅព្រឹកថ្ងៃបុណ្យគ្រីស្ទម៉ាស់ក្នុងមន្ទីរពេទ្យមួយនៅប្រទេសក្វាតេម៉ាឡា យើងមិនអាចអំពាវនាវឲ្យពួកទេវតាមកច្រៀងបានឡើយ ។ ប៉ុន្តែយើងបានធ្វើវាដោយខ្លួនឯង ។*

**ដោយ ជេនៀន ជេនសិន នៀលសិន**

ភ្លើងកាំជ្រួច ទិដ្ឋភាពដ៏ស្រស់បំព្រងនៃការប្រសូតិដ៏ចម្រុះពណ៌ និងអាហារឈ្មោះថាតាម៉ាឡេស—នោះគឺជាបុណ្យគ្រីស្ទម៉ាស់ក្នុងប្រទេសក្វាតេម៉ាឡា ។ ក្នុងនាមជាអ្នកផ្សាយសាសនាពេញម៉ោងម្នាក់ ខ្ញុំរកឃើញថាទំនៀមទម្លាប់នេះខុសប្លែកគ្នាយ៉ាងខ្លាំង ពីទំនៀមទម្លាប់របស់ខ្ញុំនៅសហរដ្ឋអាមេរិក ។ ខ្ញុំបាននឹកផ្ទះ ហើយបានគិតថាបុណ្យគ្រីស្ទម៉ាស់របស់ខ្ញុំធ្វើឲ្យខ្ញុំតប់ប្រមល់ក្នុងចិត្តណាស់ ។

ដៃគូរបស់ខ្ញុំ ស៊ិស្ទើរ អាណាយ៉ា បាននិយាយថា យើងនឹងរកឃើញក្តីអំណរក្នុងបុណ្យគ្រីស្ទម៉ាស់តាមរយៈការបម្រើដល់អ្នកដទៃ ។ នាងបានឲ្យយោបល់ថា យើងចំណាយពេលពេញមួយព្រឹកនៅមន្ទីរពេទ្យដើម្បីច្រៀងចម្រៀង ហើយយើងអញ្ជើញអ្នកផ្សាយសាសនាផ្សេងទៀតឲ្យចូលរួមនឹងយើង។

កាលយើងជិតទៅដល់ក្លោងទ្វារចូល ខ្ញុំបានមើលមនុស្សដែលកំពុងឈរតម្រង់ជួរដើម្បីជួបនឹងមនុស្សដែលខ្លួនស្រឡាញ់ ។ ផ្ទៃមុខពួកគេសោកសៅ ជើងពាក់ស្បែកជើងផ្ទាត់ប្រឡាក់សុទ្ធតែដី ហើយពាក់ខោអាវចាស់ៗ ។ យើងបានរង់ចាំជាមួយនឹងពួកគេ ។ នៅទីបំផុត កាលយើងត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងអគារនោះ យើងបានដើរតាមច្រកដើរតូចៗដោយមានជញ្ជាំងលាបថ្នាំពណ៌ខៀវរបកអស់ និង កម្រាលស៊ីម៉ង់ ។ ក្លិនថ្នាំពេទ្យ និង ជំងឺបានធ្វើឲ្យខ្ញុំរន្ធត់ក្នុងចិត្ត ។

ក្នុងបន្ទប់ដ៏ធំមួយដែលមានភ្លើងភ្លឺព្រឹមៗ ខ្ញុំអាចមើលឃើញអ្នកជំងឺដេកនៅលើគ្រែដែលមានខ្យល់ចេញចូល ឬភាពឯកជនតិចតួចបំផុត ។ ពួកគេបានដេកសម្រាកនៅទីនោះ ខ្លះមានបិទបង់រុំរបួស ខ្លះមានព្យួរស៊ីរ៉ូម ខ្លះដាក់ម៉ាស៊ីនបញ្ចូលអុកស៊ីសែន ។ ខ្លះបានយំថ្ងូរតិចៗ ។ ឯខ្លះទៀតកំពុងសំរាន ។ ខ្ញុំងឿងឆ្ងល់ថាហេតុអ្វីបានជាយើងមកទីនេះ ។ ក្រុមដ៏តូចនៃពួកផ្សាយសាសនារបស់យើង ភាគច្រើនបានឈរនៅមាត់ទ្វារ ដោយមិនដឹងថាត្រូវធ្វើអ្វីនោះទេ ។

ប៉ុន្តែមិនមែនជាស៊ិស្ទើរ អាណាយ៉ា ឡើយ ។ នាងបានដើរទៅគ្រែអ្នកជំងឺនីមួយៗ សួរសុខទុក្ខដល់ពួកគេ សួរថាតើពួកគេមានអារម្មណ៍យ៉ាងណាដែរ ហើយនិយាយពាក្យសួស្តីបុណ្យគ្រីស្ទម៉ាស់ទៅដល់ពួកគេ ។ ភាពក្លាហានរបស់នាងបានរំឭកដល់យើងទាំងអស់គ្នាពីហេតុផលដែលយើងមក ហើយបានចាប់ផ្តើមច្រៀងបទគ្រីស្ទម៉ាស់ ដំបូងឡើងដោយសំឡេងតិចៗ ប៉ុន្តែក្រោយមកទៀតយើងបានបន្តច្រៀងដោយចិត្តក្លាហាន ។ មានអ្នកជំងឺខ្លះបានញញឹម ខ្លះដេកដោយមិនអើរពើរ ហើយខ្លះទៀតបានគ្រហឹមតាម ។

ស៊ិស្ទើរ អាណាយ៉ា បានដើរសំដៅទៅស្ត្រីម្នាក់ដែលមានបិទបង់រុំរបួស ដោយច្រៀង ហើយកាន់សៀវភៅទំនុកតម្កើងក្នុងដៃនាង ។ ស្ត្រីនោះបានចាប់ផ្តើមយំដោយស្ងៀមស្ងាត់ ហើយដៃគូខ្ញុំបានអង្អែលសក់នាងថ្នមៗ ។ ស្ត្រីនោះបានពោលទាំងទឹកភ្នែកថា « អ្នកគឺជាពួកទេវតា ។ អ្នកគឺជាពួកទេវតា » ។

ខ្ញុំមិនអាចភ្លេចពីចម្លើយរបស់ស៊ិស្ទើរ អាណាយ៉ា បានឡើយ ។ នាងបានតបថា « មិនមែនទេ អ្នកមិនមែនកំពុងស្តាប់ឮពួកទេវតានោះទេ » ។ « អ្នកកំពុងស្តាប់ឮពីពួកបរិសុទ្ធថ្ងៃចុងក្រោយ » ។

កាលព្រះយេស៊ូវគ្រីស្ទបានប្រសូតមក មានទេវតាមួយអង្គបានប្រកាសពីការប្រសូតរបស់ទ្រង់ ហើយពលស្ថានសួគ៌បានច្រៀងសរសើរដល់ព្រះ (សូមមើល លូកា 2:8–14) ។ ខ្ញុំគិតពីពួកទេវតាទាំងនោះរាល់បុណ្យគ្រីស្ទម៉ាស់ ។

ប៉ុន្តែខ្ញុំក៏គិតដល់ស៊ិស្ទើរ អាណាយ៉ា ដែរ ។ ខ្ញុំនៅចាំ នាងបានលើកទឹកចិត្តយើងដើម្បីច្រៀងនៅឯមន្ទីរពេទ្យនោះ និងពីអារម្មណ៍នៃក្តីអំណរដែលយើងមានតាមរយៈការចែកចាយក្តីអំណរ ។ ខ្ញុំនៅចាំពីកាលដែលនាងបានអង្អែលសក់ស្ត្រីដែលមានជំងឺម្នាក់នោះ ។ ហើយខ្ញុំនៅចាំថា ខ្ញុំមិនចាំបាច់ក្លាយជាទេវតាដើម្បីបម្រើដល់មនុស្សដទៃនោះទេ ។ ខ្ញុំអាចបម្រើពួកគេក្នុងនាមជាពួកបរិសុទ្ធថ្ងៃចុងក្រោយម្នាក់ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*





# រៀបចំកន្លែងមួយ

« យើងម្នាក់ៗគឺជាម្ចាស់ផ្ទះសំណាក់ដែលសម្រេចចិត្តថាតើនឹងមានបន្ទប់មួយសម្រាប់ព្រះយេស៊ូវដែរឬអត់ ! »

អែលឌើរ នែល អេ ម៉ាក់ស្វែល (1926–2004) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Settle This in Your Hearts, » *Ensign*, ខែ វិច្ឆិកា ឆ្នាំ 1992 ទំព័រ 66 ។

រចនារូបថត ដោយដេវីដ ស្តូឃើ *ព្រះប្រសូតិកម្ម* ដោយ ដេវីឌ លីនស្លី



**ដោយ អែលឌើរ**
**មើរវីន ប៊ី អាណុល**
នៃពួកចិតសិបនាក់

# តើខ្ញុំនៅទីណា?

## របៀបដើម្បីស្វែងរក ហើយអភិវឌ្ឍអំណោយទានខាងវិញ្ញាណ និង ទេពកោសល្យនានារបស់អ្នក

*ព្រះវរបិតាសួគ៌បានប្រទានឲ្យអ្នកនូវអំណោយទានខាងវិញ្ញាណ និង ទេពកោសល្យនានាដើម្បីជួយអ្នកឲ្យប្រែក្លាយទៅជាមនុស្សដែលទ្រង់សព្វព្រះទ័យឲ្យប្រែក្លាយ ។*

**នៅ**ក្នុងព្រះគម្ពីរយើងរកឃើញនូវសំណួរជាច្រើនដែលធ្វើឲ្យយើងគិតពីជីវិតរបស់យើង ។ សំណួរដំបូងទីមួយនៅក្នុងព្រះគម្ពីរប៊ីបដែលចោទសួរទៅអ័ដាមបន្ទាប់ពីលោកបានទទួលទានផ្លែដែលហាមឃាត់ ។ ខ្ញុំសូមអញ្ជើញអ្នកឲ្យសញ្ជឹងគិតពីរបៀបដែលសំណួរនេះអាចអនុវត្តចំពោះជីវិតរបស់អ្នក ៖

« អ័ដាម និងប្រពន្ធគាត់ក៏ពួននឹងព្រះយេហូវ៉ាដ៏ជាព្រះនៅកណ្ដាលដើមឈើក្នុងសួនច្បារ ។

« ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ហៅរកអ័ដាមដោយបន្ទូលថា *អ្នកនៅឯណា* ? »(លោកុប្បត្តិ 3:8–9 ការគូសបញ្ជាក់បានបន្ថែម) ។

ព្រះអម្ចាស់ទ្រង់ជ្រាបរាល់កិច្ចការទាំងអស់ ដូច្នេះយើងអាចជឿជាក់ថា ទ្រង់បានជ្រាបពីទីកន្លែងដែលអ័ដាម និង នាងអេវ៉ាលាក់ខ្លួន ។ ប្រសិនបើទ្រង់បានជ្រាបពីទីកន្លែងដែលពួកគាត់នៅ ដូច្នេះតើព្រះអម្ចាស់ចង់សួរពីអ្វីទៅ ?

សំណួរនេះហាក់ដូចជាបានបំផុសដល់អ័ដាម និង អេវ៉ាឲ្យគិតពីអ្វីដែលកំពុងតែកើតឡើងនៅក្នុងជីវិតរបស់ខ្លួន ។ យើងអាចសួរខ្លួនឯងនូវសំណួរស្រដៀងគ្នានេះ ។ ឧទាហរណ៍ ៖ តើយើងស្ថិតនៅត្រង់ណាក្នុងដំណើរនៅលើផ្លូវនៃសេចក្ដីសញ្ញាឆ្ពោះទៅរកជីវិតដ៏នៅអស់កល្បជានិច្ចនោះ ? តើអំណោយទាន និង ទេពកោសល្យនានាអ្វីខ្លះដែលព្រះវរបិតាសួគ៌បានប្រទានដល់យើងនៅក្នុងជីវិតមុនឆាកជីវិតនេះ ដើម្បីជួយយើងឲ្យដើរលើផ្លូវនេះ ? តើអំណោយទាន និង ទេពកោសល្យនានាអ្វីខ្លះទៀតដែលយើងត្រូវមានកាលដែលយើងខិតខំប្រែក្លាយទៅជាមនុស្សដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យយើងប្រែក្លាយនោះ ?

ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ (1838–1918) បានថ្លែងថា « ក្នុងនាមជាវិញ្ញាណមួយ មនុស្សត្រូវបានព្រះមាតាបិតាសួគ៌បង្កើត ហើយឲ្យកំណើត ព្រមទាំងត្រូវបានចិញ្ចឹមបីបាច់ រហូតដល់ពេញវ័យនៅក្នុងវិមានដ៏អស់កល្បជានិច្ចរបស់ព្រះវរបិតាពីមុនការមកកាន់ផែនដីនៅក្នុងរូបកាយ [ខាងសាច់ឈាម] បណ្ដោះអាសន្នមួយ » ។[1] សៀវភៅសិក្សា*គោលការណ៍ទាំងឡាយនៃដំណឹងល្អ*បង្រៀនយើងថា « ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ជ្រាបថាយើងជានរណា ហើយយើងបានធ្វើអ្វីខ្លះពីមុនយើងមកកាន់ទីនេះ ។ ទ្រង់បានជ្រើសរើសពេលវេលា និងទីកន្លែងសម្រាប់យើងម្នាក់ៗ ដើម្បីឲ្យចាប់កំណើត ដើម្បីឲ្យយើងអាចរៀនមេរៀនដែលចាំបាច់សម្រាប់យើងផ្ទាល់ខ្លួន ហើយ*ធ្វើសេចក្ដីល្អឲ្យច្រើនបំផុតជាមួយនឹងទេពកោសល្យ និង បុគ្គលិកលក្ខណៈផ្ទាល់ខ្លួនរបស់យើង* ។ »[2]

ព្រះវរបិតាសួគ៌បានដាក់អ្នកនៅទីកន្លែងដ៏ល្អបំផុតដើម្បីប្រើប្រាស់អំណោយទានវិញ្ញាណរបស់អ្នក ហើយពង្រីកទេពកោសល្យរបស់អ្នក ។ មិនថាអ្នករស់នៅទីណា ឬអ្នកមានស្ថានភាពបែបណានៅក្នុងជីវិតនេះនោះទេ អ្នកអាចធ្វើការជ្រើសរើសដើម្បីទទួលបានជោគជ័យ មិនថាឧបសគ្គរបស់អ្នកគឺជាអ្វីនោះទេ ។ កុំរាថយ ។ ចូរបន្តធ្វើវា ។ កុំចុះចាញ់ ។ សូមចងចាំថា អ្វីដែលអ្នកបានធ្វើជាមួយនឹងអ្វីដែលអ្នកមានវាបង្ហាញពីអត្តសញ្ញាណពិតរបស់ អ្នក ។

គំរូរបស់អ័ដាម និង នាងអេវ៉ាអាចផ្ដល់សេចក្ដីសង្ឃឹមដល់យើងយ៉ាងច្រើន ។ បន្ទាប់ពីពួកគាត់បានរំលងព្រះបញ្ញត្តិមិនឲ្យទទួលទានផ្លែដែលហាមឃាត់មក ពួកគាត់ត្រូវបានបណ្ដេញចេញពីសួនច្បារដ៏ស្រស់ស្អាតមួយ ដីត្រូវបានដាក់បណ្ដាសារ បន្លា និង អញ្ចាញបានដុះឡើង ហើយពួកគាត់ត្រូវធ្វើរកស៊ីពីដីដោយនឿយហត់ដើម្បីផ្គត់ផ្គង់ដល់ខ្លួនឯង ។ ពួកគាត់មិនបានចុះចាញ់ឡើយ ។ ពួកគាត់បានចេញទៅធ្វើការ ដូចដែលព្រះអម្ចាស់បានបង្គាប់ដល់ពួកគាត់ (សូមមើល ម៉ូសេ 5:1) ។ កូនប្រុសពួកគាត់ កាអ៊ីន បានធ្វើការជ្រើសរើសមួយដ៏អាក្រក់បំផុត ប៉ុន្តែពួកគេបាន



**តើអ្វីទៅជាអំណោយទានរបស់អ្នក ?**

នេះ ជាវិធីមួយចំនួនដែលអ្នកអាចកំណត់ពីអំណោយទានដែលអ្នកមាន ៖

- ទូលសួរដល់ព្រះវរបិតាសួគ៌ថាវាមានអ្វីខ្លះ ហើយទូលសូមទ្រង់ឲ្យប្រទានពរដល់អ្នកជាមួយនឹងអំណោយទានផ្សេងទៀតផងដែរ ។
- សួរមនុស្សដែលស្គាល់អ្នកច្បាស់ ។ ពេលខ្លះ អ្នកដទៃអាចមើលឃើញពីអំណោយទានរបស់អ្នកច្បាស់ជាងអ្នកទៅទៀត ។
- ចូលរួមនឹងសកម្មភាពថ្មី ឬរៀនជំនាញថ្មីដើម្បីស្វែងរកទេពកោសល្យ និង អំណោយទានវិញ្ញាណរបស់អ្នក ។
- ប្រសិនបើអ្នកមានពររបស់លោកអយ្យកោ សូមសិក្សាវាដើម្បីដឹងពីអំណោយទានអ្វីខ្លះដែលបានលើកឡើង ឬសក្ដានុពលអ្វីខ្លះដែលអ្នកមានក្នុងផ្នែកជាក់លាក់នានា ។

បន្តរស់នៅដោយសុចរិត ហើយបន្តបង្រៀនដល់កូនចៅខ្លួន ។

## ការរកឃើញរបស់ពូបិន

ខ្ញុំមានពូម្នាក់ដែលបានបន្តខិតខំកែលម្អ ហើយបង្កើនអំណោយទាន និង ទេពកោសល្យដែលគាត់បានទទួលពីព្រះវរបិតាសួគ៌ ។ ខ្ញុំសូមចែកចាយនូវដំណើររឿងមួយពីជីវិតគាត់ដែលវាបានជួយខ្ញុំឲ្យមើលឃើញពីរបៀបដែលអំណោយទានវិញ្ញាណ និង ទេពកោសល្យត្រូវបានអភិវឌ្ឍ ហើយលើកតម្កើង ។

នៅថ្ងៃមួយ កាលពូបិនកំពុងធ្វើការនៅអណ្ដូងរ៉ែមួយ គាត់បានសង្កេតឃើញដុំលោហៈកោងដ៏ចំណាស់មួយនៅក្បែរផ្លូវរថភ្លើង ។ គាត់បានសួរចៅហ្វាយរបស់គាត់ថា គាត់អាចយកវាបានទេ ។ ចៅហ្វាយគាត់បានតបថា « បិន ដុំលោហៈចាស់នោះគ្មានតម្លៃទេ ។ ឯងកុំចំណាយពេលឯងទៅរើស វាអី » ។

ពូបិនបានញញឹម រួចតបថា « ខ្ញុំឃើញវាមានតម្លៃលើសពីដុំលោហៈចាស់មួយដុំទៅទៀត » ។

ដោយមានការអនុញ្ញាតពីចៅហ្វាយគាត់ គាត់បានយកវាទៅផ្ទះ ។ នៅក្នុងរោងជាងរបស់គាត់ គាត់ដុតលោហៈនោះរហូតដល់វាឡើងក្ដៅពណ៌ក្រហម ។ រួចដោយចំណាយពេលយ៉ាងច្រើន គាត់អាចធ្វើពុម្ព ហើយពត់វារហូតដល់វាត្រង់ ។

ពេលវាត្រជាក់ គាត់បានគូររូបកាំបិតដ៏ធំមួយនៅលើវា ។ ដោយមានប្រដាប់ផ្សា គាត់បានកាត់លោហៈនោះចេញជារាងកាំបិត ។ រួចពូបិនបានចាប់ផ្ដើមវាយជម្រុសដំណែមគ្រើមៗចេញ ដោយចំណាយពេលជាច្រើនម៉ោងកាត់ សំលៀង ខាត់ ហើយបន្សុទ្ធដុំលោហៈចាស់នោះ ។

គាត់បានចំណាយពេលជាច្រើនថ្ងៃធ្វើការជាមួយនឹងអ្វីដែលចៅហ្វាយគាត់ហៅថា ជាដុំលោហៈគ្មានតម្លៃនោះ ។ បន្តិចម្ដងៗ ផ្លែកាំបិតនោះបានចាប់ផ្ដើមចេញជារូបរាង ហើយក្លាយជាកាំបិតមួយដ៏ស្អាត ហើយភ្លឺ ។

ឥឡូវនេះអ្វីដែលចាំបាច់បានធ្វើរួចហើយ ។ ពូបិនបានចូលទៅក្នុងព្រៃរកបាន

ស្នែងសត្វប្រើសមួយ ។ កាលត្រឡប់មកដល់រោងជាងរបស់គាត់វិញ គាត់បានលាងសម្អាត កាត់ ហើយខាត់ស្នែងនោះ ។ កាលគាត់ធ្វើរួចរាល់ហើយ វាមានភាពរលោង ហើយស្អាត ។ គាត់បានភ្ជាប់ដងកាំបិតទៅនឹងផ្លែកាំបិតដោយប្រុងប្រយ័ត្ន ។ ឥឡូវនេះវត្ថុមួយដែលកាលពីមុនជាដុំលោហៈចាស់ មានច្រេះស៊ី ហើយកោង បានក្លាយទៅជាកាំបិតមួយដ៏ស្រស់ស្អាតដែលបានឈ្នះពានរង្វាន់ជាច្រើន ។

អ្នក និង ខ្ញុំប្រៀបដូចជាដុំលោហៈចាស់នោះដែរ ។ យើងក៏ត្រូវការនូវការបត់បែន ការបន្សុទ្ធ និង ការដុសខាត់ដើម្បីឈានទៅដល់សក្ដានុពលពេញលេញរបស់យើងផងដែរ។ ផ្នែកនៃដំណើរការនោះគឺការស្វែងរក ការពង្រឹង និង ការធ្វើឲ្យចម្រើនឡើងនូវទេពកោសល្យ និង អំណោយទានរបស់យើង ។

ពូបិនបានយល់ថា សក្ដានុពលរបស់យើងភាគច្រើនគឺមិនអាចមើលឃើញឡើយ ហើយវាត្រូវតែមានការស្វែងរកហើយអភិវឌ្ឍ ។ ព្រះអម្ចាស់បង្រៀនយើងឲ្យ « ស្វែងរកអំណោយទាននានាដែលវិសេសបំផុត » (គ. និង ស. 46:8) និង « ឲ្យមនុស្សគ្រប់រូបអាច



**តើអ្នកមានអំណោយទានមួយក្នុងចំណោមអំណោយទានទាំងនេះដែរឬទេ ?**

« ខ្ញុំសូមលើកឡើងនូវអំណោយទានមួយចំនួនដែលគ្មានភាពច្បាស់លាស់ ឬគ្មានការកត់សម្គាល់ជានិច្ច ប៉ុន្តែជារឿងដ៏សំខាន់បំផុត ។ ក្នុងចំណោមអំណោយទានទាំងនេះ ប្រហែលជាមានអំណោយទានរបស់អ្នក—អំណោយទានដែលមិនច្បាស់លាស់ក្នុងពេលនេះ ប៉ុន្តែវាពិតហើយមានតម្លៃ ។

« ចូរយើងពិនិត្យឡើងវិញនូវអំណោយទានមួយចំនួនដែលគេមិនសូវមើលឃើញ ៖ អំណោយទាននៃការសួរ អំណោយទាននៃការស្ដាប់ អំណោយទាននៃការស្ដាប់ឮ និង ការប្រើសំឡេងតូចរហៀង អំណោយទាននៃការដែលអាចយំ អំណោយទាននៃការជៀសវាងពីជម្លោះ អំណោយទាននៃការយល់ព្រម អំណោយទាននៃការជៀសវាងពីការធ្វើរឿងដដែលឥតប្រយោជន៍ អំណោយទាននៃការស្វែងរកអ្វីដែលសុចរិត អំណោយទាននៃការមិនរហ័សវិនិច្ឆ័យ អំណោយទាននៃការទូលសូមការដឹកនាំពីព្រះ អំណោយទាននៃការធ្វើជាសិស្សម្នាក់ អំណោយទាននៃការមើលថែអ្នកដទៃ អំណោយទាននៃការចេះសញ្ជឹងគិត អំណោយទាននៃការធ្វើការអធិស្ឋាន អំណោយទាននៃការថ្លែងទីបន្ទាល់មួយដ៏អស្ចារ្យ និង អំណោយទាននៃការទទួលបានព្រះវិញ្ញាណបរិសុទ្ធ » ។

អែលឌើរ ម៉ាវីន ជេ អាស្តុន (1915–94) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « There Are Many Gifts, » *Ensign,* ខែ វិច្ឆិកា ឆ្នាំ 1987 ទំព័រ 20 ។



បានប្រសើរឡើងចំពោះការប៉ិនប្រសប់របស់ខ្លួន ប្រយោជន៍ឲ្យមនុស្សគ្រប់រូបអាចបានការប៉ិនប្រសប់ផ្សេងៗទៀត មែនហើយ គឺរាប់រយ » (គ. និង ស. 46:8) ។ ហេតុអ្វីយើងត្រូវធ្វើបែបនេះ ? យើងអាចប្រើទេពកោសល្យ និង អំណោយទានរបស់យើងដើម្បីបម្រើដល់អ្នកដទៃ ដូចដែលខគម្ពីរបន្ទាប់បានពន្យល់ថា ៖ « មនុស្សគ្រប់រូបស្វែងរកចំណូលចិត្តនៃអ្នកជិតខាងរបស់ខ្លួន ហើយប្រព្រឹត្តនូវគ្រប់ការណ៍ទាំងអស់ដោយមានភ្នែកស្មោះស្ម័គ្រទាំងស្រុងចំពោះសិរីល្អនៃព្រះ » (គ. និង ស. 82:19) ។ ការផ្ដល់ការបម្រើរៀបចំយើងឲ្យរស់នៅក្នុងជីវិតមួយកាន់តែដូចជាព្រះគ្រីស្ទ ។

## ការស្វែងរកទេពកោសល្យរបស់យើង

អែលឌើរ រីឆាដ ជី ស្កុត ក្នុងកូរ៉ុមនៃពួកសាវក ដប់ពីរនាក់បានបង្រៀនពីរបៀបដែលការសាកល្បងនានាបានពង្រឹងដល់យើងថា ៖ « កាលអ្វីទាំងអស់ហាក់ដូចជាមានភាពត្រឹមត្រូវ ជារឿយៗឧបសគ្គជាច្រើនបានកើតឡើងក្នុងពេលតែមួយ ។ ពេលការសាកល្បងទាំងនោះពុំមែនជាលទ្ធផលនៃការមិនគោរពប្រតិបត្តិរបស់អ្នក នោះវាគឺជាភស្ដុតាងថា ព្រះអម្ចាស់ទ្រង់សព្វព្រះទ័យចង់ឲ្យអ្នករីកចម្រើនបន្ថែមទៀត (សូមមើល សុភាសិត 3:11–12) ។ ដូច្នេះទ្រង់ប្រទានបទពិសោធន៍នានាដល់អ្នកដែលទាក់ទាញឲ្យមានការរីកចម្រើន *ទាំងការយល់ដឹង និងសេចក្ដីមេត្តាករុណា* [អំណោយទានពីរដ៏សំខាន់បំផុត] ដែល*ដុសខាត់អ្នកសម្រាប់ប្រយោជន៍ដ៏អស់កល្បជានិច្ចរបស់អ្នក* ។ ដើម្បីយកអ្នកពីកន្លែងដែលអ្នកស្ថិតនៅទៅកាន់កន្លែងដែលទ្រង់ចង់អ្នកប្រែក្លាយ វាតម្រូវឲ្យមានការកែតំរង់ជាច្រើន ហើយជាទូទៅវាតម្រូវឲ្យមានការលំបាក និងការឈឺចាប់ » ។[3]

## ការធ្វើឲ្យទេពកោសល្យយើងបានប្រសើរឡើង

ការបង្កើនទេពកោសល្យយើងតម្រូវឲ្យមានការខិតខំ ។ ថ្មីៗនេះ អែលឌើរ ស្កុត បានប្រាប់ភរិយាខ្ញុំថា « ខឿនណា អ្នកគួររៀនគូររូប » ។

ស៊ិស្ទើរ អាណុល មិនធ្លាប់គូររូបពីមុនមកឡើយ ។ គាត់ត្រូវខិតខំយ៉ាងខ្លាំង ។ គាត់បានចូលរៀនថ្នាក់មួយចំនួន គូររូបរាល់ថ្ងៃ ហើយក្រោយមកដោយការចំណាយពេល និង ការខិតខំយ៉ាងច្រើនដើម្បីរៀនគូររូបឲ្យបានស្រស់ស្អាត ។ ខ្ញុំមានគំនូរមួយផ្ទាំងដ៏ស្រស់ស្អាតរបស់គាត់ស្ដីពីទិដ្ឋភាពនៃមាត់ទន្លេមួយដាក់ព្យួរនៅលើជញ្ជាំងក្នុងការិយាល័យខ្ញុំ ។

ពិតណាស់ ការទទួលបានទេពកោសល្យតម្រូវឲ្យមានការខិតខំ ប៉ុន្ដែថាតើយើងនឹងមានក្ដីអំណរបែបណាទៅ កាលយើងបានស្ដាប់ឮព្រះអម្ចាស់មានបន្ទូលប្រាប់យើងថា « ប្រពៃហើយ អំណោយទាន និង ទេពកោសល្យរបស់អ្នកនឹងបានចម្រើនឡើងដោយសារភាពឧស្សាហ៍ព្យាយាមរបស់អ្នក » (សូមមើល ម៉ាថាយ 25:14–30) ។

## អំណោយទានខាងវិញ្ញាណរបស់អ្នក

ភរិយាខ្ញុំបានរកឃើញទេពកោសល្យនៃការគូររូប ។ តើអ្វីទៅជាអំណោយទាន និង ទេពកោសល្យរបស់អ្នក ? ខ្ញុំដឹងថា ព្រះវរបិតាសួគ៌យើងបានប្រទាននូវទេពកោសល្យ និង អំណោយទានមួយចំនួនដល់អ្នក ។ តើខ្ញុំដឹងបានដោយរបៀបណា? « មានអំណោយទានជាច្រើន ហើយមនុស្សរាល់គ្នាត្រូវបានប្រទានអំណោយទានមួយ ដោយព្រះវិញ្ញាណនៃព្រះ » (គ. និង ស. 46:11) ។ អំណោយទាន និង ព្រះចេស្ដារបស់ព្រះមានសម្រាប់យើងរាល់គ្នា ។ វាជាសិទ្ធិ និង ទំនួលខុសត្រូវរបស់យើងដើម្បីទទួលយកអំណោយទានវិញ្ញាណរបស់យើង ធ្វើឲ្យទេពកោសល្យយើងរីកចម្រើន ហើយចែកចាយវា ។

ព្រះគម្ពីរបានរៀបរាប់ពីអំណោយទានមួយចំនួនដែលយើងអាចស្វែងរកបាន (ឧទាហរណ៍ សូមមើល គ. និង ស. 46) ប៉ុន្ដែនៅមានអំណោយទាន និង ទេពកោសល្យរាប់រយទៀត ។ ជាពិសេសសូមស្រាវជ្រាវក្នុងព្រះគម្ពីរមរមន នីហ្វៃទី 3 11–26 អ្នកនឹងរកឃើញនូវអំណោយទាន និង ទេពកោសល្យជាច្រើនដែលមានសម្រាប់យើងម្នាក់ៗ ។ ឧទាហរណ៍ នៅក្នុង នីហ្វៃទី 3 11 យើងអានពីប្រជាជនស្ដាប់ឮសំឡេងរបស់ព្រះវរបិតាសួគ៌ ប៉ុន្ដែដំបូងឡើយមិនបានយល់នោះទេ ៖

« ពួកគេបានឮសំឡេងនោះជាលើកទីបីទៀត ហើយបានផ្ទៀងត្រចៀកស្ដាប់ ហើយភ្នែកគេសម្លឹងឆ្ពោះទៅសំឡេងនោះ . . .

« ហើយហេតុការណ៍បានកើតឡើងថា នៅពេលប្រជាជនយល់នូវពាក្យទាំងនោះហើយ នោះពួកគេបានសម្លឹងមើលទៅលើឆ្ពោះទៅលើមេឃទៀត ហើយមើលចុះ គេបានឃើញបុរសម្នាក់ [ព្រះយេស៊ូវគ្រីស្ទ] យាងចុះមកពីលើមេឃ » (ខ 5, 8) ។

ដើម្បីស្ដាប់ឮ ហើយមើលឃើញឲ្យច្បាស់គឺគ្រាន់តែជាឧទាហរណ៍ពីរនៃអំណោយទានវិញ្ញាណ និង ទេពកោសល្យដែលអ្នកទទួលបាន ហើយធ្វើឲ្យរីកចម្រើន ប្រសិនបើអ្នកព្រម*ស្វែងរក ហើយខិតខំ*ទៅរកវា ។

ខ្ញុំសូមអញ្ជើញយើងម្នាក់ៗឲ្យធ្វើដូចជាពូបិនបានធ្វើ ៖ សូមមើលឃើញនូវភាពល្អបំផុតនៅគ្រប់អ្វីទាំងអស់ កាលយើងស្វែងរកអំណោយទានវិញ្ញាណ និង ទេពកោសល្យ ហើយប្រើវាដើម្បីប្រទានពរដល់មនុស្សនៅជុំវិញយើង ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌យើងមានអំណោយទាន និង ទេពកោសល្យជាច្រើនដែលទ្រង់សព្វព្រះទ័យប្រទានដល់យើង ប៉ុន្ដែវា « មានលក្ខខណ្ឌ ដោយយើងត្រូវទូលសុំវា ។ ពរជ័យទាំងឡាយតម្រូវឲ្យមានការលះបង់ ឬការខិតខិតមួយចំនួនរបស់យើង » (Bible Dictionary « Prayer ») ។ សូមឲ្យយើងស្វែងរក ខិតខំ ហើយធ្វើឲ្យអំណោយទាន និង ទេពកោសល្យដែលព្រះប្រទានឲ្យពីកំណើតបានចម្រើនឡើង ហើយសូមឲ្យយើងទូលសូមនូវអំណោយទានផ្សេងទៀត នេះជាការអធិស្ឋានដ៏រាបសាររបស់ខ្ញុំ ។ ■

**កំណត់ចំណាំ**

1. *Teachings of Presidents of the Church: Joseph F. Smith,* (ឆ្នាំ 1998) ទំព័រ 335 ។
2. *គោលការណ៍ទាំងឡាយនៃដំណឹងល្អ* (ឆ្នាំ 2009) ទំព័រ 10 ការគូសបញ្ជាក់បានបន្ថែម ។
3. អែលឌើរ រីឆាដ ជី ស្កុត « Trust in the Lord » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 16–17 ការគូសបញ្ជាក់បន្ថែម ។



ដោយ អែលឌើរ
ដាល្លិន អេច អូក
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# របៀបរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ

« ជីវិតនេះគឺជាពេលវេលាសម្រាប់ឲ្យមនុស្សប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ » (អាលម៉ា 34:32) ។ តើយើងកំពុងប្រុងប្រៀបខ្លួនដែរឬទេ ?

ចុះបើថ្ងៃនៃការយាងមករបស់ទ្រង់គឺជាថ្ងៃស្អែក ? បើយើងដឹងថា យើងនឹងជួបព្រះអម្ចាស់នៅថ្ងៃស្អែក—តាមការស្លាប់ដែលមិនបានប្រុងទុក ឬ តាមដែលទ្រង់យាងមកដោយមិនបានរំពឹងទុក—តើយើងនឹងធ្វើអ្វីនៅថ្ងៃនេះ ? តើការសារភាពអ្វីខ្លះដែលយើងនឹងសារភាព ? តើការអនុវត្តន៍អ្វីខ្លះ ដែលយើងនឹងមិនបន្តធ្វើទៀត ? តើបញ្ហាអ្វីខ្លះដែលយើងនឹងដោះស្រាយ ? តើការអត់ទោសណាខ្លះដែលយើងនឹងអត់ទោស ? តើទីបន្ទាល់អ្វីខ្លះដែលយើងត្រូវថ្លែង ?

ចុះបើយើងនឹងត្រូវធ្វើការណ៍ទាំងនោះនៅពេលនោះ ហេតុអ្វីយើងមិនធ្វើឥឡូវនេះ ? ហេតុអ្វីមិនស្វែងរកសេចក្ដីសុខសាន្ដ ពេលដែលសេចក្ដីសុខសាន្ដអាចរកបាន ? »

អំពើអាក្រក់ដែលធ្លាប់តែស្ថិតនៅមួយកន្លែង ហើយលាក់ខ្លួនដូចជាបួសទ្រនិច ឥឡូវនេះបែរជាមានច្បាប់អនុញ្ញាតពេញលេញទៅវិញ ។ ឫសគល់ និង ការការពារដ៏សំខាន់បំផុត (ជញ្ជាំងការពារ) នៃអារ្យធម៌ត្រូវចោទសួរ ឬរងការវាយប្រហារ ។ ប្រទេសនានាបានបដិសេធកេរមតកសាសនារបស់ខ្លួន ។ អាពាហ៍ពិពាហ៍ និង ទំនួលខុសត្រូវក្នុងគ្រួសារត្រូវបានបដិសេធដោយសារតែបញ្ហាមិនអើពើរបស់ខ្លួន ។ ខ្សែភាពយន្ដ និងទស្សនាវដ្ដី និងទូរទស្សន៍ដែលពង្រឹងដល់ឥរិយាបថរបស់យើងមានពេញទៅដោយរឿង ឬរូបភាពដែលបង្ហាញកូនចៅនៃព្រះថាជាសត្វ ឬនិយាយឲ្យល្អស្ដាប់ទៅ ថាជាមនុស្សឥតបានការដែលតាមរកភាពរីករាយបន្ថែមទៀតសម្រាប់ខ្លួនឯង ។ ហើយមានពួកយើងជាច្រើននាក់ដែរ ដែលទទួលវាជាការកម្សាន្ដ ។

សេចក្ដីល្អ ភក្ដីភាព និង ភាពស្រស់ស្អាតត្រូវបានជំនួសដោយសេចក្ដីអាក្រក់ ជា « អ្វីក៏ដោយ » និងចំណីដ៏គ្មានតម្លៃនៃចិត្តផ្ទាល់ខ្លួន ។ ពិតណាស់មានមនុស្សជាច្រើនត្រូវបានជាប់ជុំពាក់ក្នុងរូបអាសគ្រាម ការផ្ដេកផ្ដួលទៅលើតម្រេកនៃតណ្ហាការបម្រើតែភាពរីករាយផ្ទាល់ខ្លួន ឥរិយាបថមិនស្មោះត្រង់ សំលៀកបំពាក់ខ្លីៗ ភាសាឆ្កួតលីលា និងការបង្អាប់បន្ថោកដល់ការយល់ដឹងខាងផ្លូវភេទ ។

រឿងទាំងអស់នេះគឺជារឿងដ៏ធ្ងន់ធ្ងរចំពោះព្រះនេត្ររបស់ព្រះវរបិតាសួគ៌យើង ដែលទ្រង់ស្រឡាញ់កូនចៅទ្រង់ទាំងអស់ ហើយហាមដល់រាល់សកម្មភាពដែលរាងរាំងពួកគេមិនឲ្យត្រឡប់មកវត្តមានរបស់ទ្រង់វិញ ។

តើអ្វីទៅជាស្ថានភាពនៃការរៀបចំផ្ទាល់ខ្លួនរបស់យើងសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ? រាស្ដ្រនៃព្រះតែងជាប្រជាជននៃសេចក្ដីសញ្ញា រួមបញ្ចូលទាំងការសន្យាពិសិដ្ឋដែលយើងបានធ្វើនៅក្នុងទឹកនៃពិធីបុណ្យជ្រមុជទឹក ក្នុងការទទួលបព្វជិតភាពបរិសុទ្ធ និងក្នុងព្រះវិហារបរិសុទ្ធនៃព្រះ ។ តើយើងគឺជាមនុស្សសន្យាតែមាត់ និងជាពួកអ្នកជឿតែមិនធ្វើតាមមែនទេ ?

តើយើងកំពុងធ្វើតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដែលថា « ចូរអ្នករាល់គ្នាឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយចូរកុំរើឡើយ រហូតដល់ថ្ងៃនៃព្រះអម្ចាស់មកដល់ ត្បិតមើលចុះ ថ្ងៃនោះនឹងមកដល់យ៉ាងឆាប់រហ័ស » មែនទេ ? គ. និង ស. 87:8 ។

យើងត្រូវបានហ៊ុមព័ទ្ធដោយឧបសគ្គជាច្រើននៅគ្រប់ទិសទី (សូមមើល កូរិនថូសទី 2 4:8–9) ។ ប៉ុន្តែដោយមានសេចក្ដីជំនឿលើព្រះ យើងទុកចិត្តលើពរជ័យដែលព្រះបានសន្យាដល់ជនដែលគោរពព្រះបញ្ញត្តិរបស់ទ្រង់ ។ យើងមានសេចក្ដីជំនឿលើអនាគត ហើយយើងនឹងរៀបចំខ្លួនសម្រាប់អនាគតនោះ ។

ព្រះអង្គសង្គ្រោះមានបន្ទូលប្រាប់យើងថា « ហេតុដូច្នោះហើយ ចូរមានចិត្តស្មោះត្រង់ ដោយអធិស្ឋានជានិច្ច ដោយមានចង្កៀងបង្កាត់ ហើយឆេះ ហើយមានប្រេងនៅជាមួយអ្នកផង ដើម្បីឲ្យអ្នកអាចបានប្រុងប្រៀបជាស្រេចក្នុងកាលការយាងមកនៃប្ដីថ្មោងថ្មី—

« ត្បិតមើលចុះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា យើងមកយ៉ាងឆាប់រហ័ស » (គ. និង ស. 33:17–18) ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៅក្នុងសន្និសីទទូទៅ ខែ មេសា ឆ្នាំ 2004 ។*



ពីផ្ទាំងគំនូរដែលមានចំណងជើង *ការយាងមកជាលើកទីពីរ* ដោយ ហារី អាន់ឌើសិន

# អំណោយបុណ្យគ្រីស្ទម៉ាស់របស់ខ្ញុំ

## តើខ្ញុំនឹងថ្វាយអ្វីដល់ព្រះអង្គសង្គ្រោះនៅឆ្នាំនេះ ?

**ដោយជាស្ទីន រូជ**

កន្លែងដែលខ្ញុំអង្គុយក្នុងថ្នាក់សិក្ខាសាលាកាលរៀននៅថ្នាក់ទីប្រាំបួនគឺនៅជួរខាងក្រោយ ជាកន្លែងដែលខ្ញុំអាចនិយាយលេងសើចជាមួយនឹងមិត្តខ្ញុំ ។ ខ្ញុំបានចុះឈ្មោះចូលរៀនថ្នាក់សិក្ខាសាលា ដោយសារខ្ញុំមានពេលទំនេរក្នុងកាលវិភាគរបស់ខ្ញុំតែប៉ុណ្ណោះ ។ នៅទីកន្លែងដែលខ្ញុំរស់នៅ ថ្នាក់សិក្ខាសាលាមាននៅម៉ោងរៀនធម្មតា ហើយអ្នកប្រឹក្សានៅសាលាបានណែនាំឲ្យខ្ញុំចូលរៀនថ្នាក់នោះ ដោយសារខ្ញុំជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ខ្ញុំបានស្គាល់ឈ្មោះគ្រូបង្រៀន ប៉ុន្តែអ្វីៗទាំងនោះគ្រាន់តែជាអ្វីដែលខ្ញុំបានរៀនពីថ្នាក់នោះប៉ុណ្ណោះ ។

លុះថ្ងៃមួយមិត្តខ្ញុំបានអវត្តមាន ដូច្នេះខ្ញុំបានជួបនឹងបញ្ហា ៖ ខ្ញុំគ្មានមនុស្សនិយាយលេងជាមួយសោះ ។ តើខ្ញុំអាចឆ្លងផុតពេលវេលានោះបានដោយរបៀបណា ? ដោយការភ័យខ្លាច ខ្ញុំមានជម្រើសតែមួយគត់គឺ—ខ្ញុំត្រូវស្តាប់គ្រូ ។ វាជាលើកដំបូងដែលខ្ញុំបានយកចិត្តទុកដាក់ស្តាប់គ្រូបង្រៀន ។

កាលខ្ញុំគិតឡើងវិញ ខ្ញុំមិនបានចាំពីអ្វីដែលគាត់បាននិយាយនៅថ្ងៃនោះទេ ប៉ុន្តែខ្ញុំបានចាំពីការទាក់ទាញអារម្មណ៍ ។ លុះស្អែកឡើង មិត្តខ្ញុំបានត្រឡប់មកវិញ ប៉ុន្តែជាជាងការនិយាយលេងសើច ខ្ញុំបានស្តាប់ ហើយបានដក់ចិត្តជាថ្មីម្តងទៀត ។

នៅទីបំផុត ខ្ញុំបានផ្លាស់ពីជួរខាងក្រោយមកអង្គុយនៅជួរខាងមុខ ជាកន្លែងដែលខ្ញុំអាចយកចិត្តទុកដាក់ស្តាប់កាន់តែប្រសើរជាងមុន ។ គ្មានពេលណាមួយដែលខ្ញុំពុំមានអារម្មណ៍ចាប់ចិត្តយ៉ាងខ្លាំងទៅលើមេរៀន ឬទៅលើពួកសិស្សដែលបានចែកចាយទីបន្ទាល់របស់ពួកគេឡើយ ។

ខ្ញុំចូលចិត្តថ្នាក់សិក្ខាសាលាខ្លាំងណាស់រហូតដល់ខ្ញុំបានចុះឈ្មោះម្តងទៀតនៅឆ្នាំក្រោយ ។ ខ្ញុំបានជ្រមុជទឹកនៅអាយុប្រាំបីឆ្នាំ ប៉ុន្តែខ្ញុំមិនបានទៅព្រះវិហារនោះទេ ។ ប៉ុន្តែមានអ្វីមួយបានផ្លាស់ប្តូរនៅថ្ងៃមួយក្នុងខែធ្នូ ចំពេលវិស្សមកាលបុណ្យគ្រីស្ទម៉ាស់ជិតចូលមកដល់ ។ គ្រូបង្រៀនបានអញ្ជើញយើងឲ្យមកឈរនៅមុខក្តារខៀន ហើយនិយាយពីអំណោយដែលយើងនឹងថ្វាយដល់ព្រះគ្រីស្ទនៅឆ្នាំនោះ ។

ខ្ញុំបានគិតថា « គ្មាននរណាម្នាក់នឹងធ្វើរឿងនេះទេ » ។ ប៉ុន្តែ ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង សិស្សទាំងអស់បានដើរមកខាងមុខម្តងម្នាក់ៗ ។ អ្នកខ្លះបានសម្រក់ទឹកភ្នែក ខ្លះទៀតបានចែកចាយពីគោលដៅដែលពួកគេបានដាក់ ហើយខ្លះបានប្រាប់ពីដំណើររឿងនានា ។ ខ្ញុំមិនចង់ជឿឡើយ ។

ពេលវេលាចេះតែរំកិលទៅមុខ ។ ខ្ញុំជាមនុស្សតែម្នាក់គត់ដែលមិនទាន់បានឡើងទៅ ។ ពីមុនខ្ញុំបានដឹងរឿងនេះ ខ្ញុំរកឃើញថាខ្លួនឯងក្រោកឈរ ។ ខ្ញុំមិនដឹងថាត្រូវនិយាយពីអ្វីនោះទេ ។ រួចខ្ញុំបាននិយាយទាំងភ័យថា « ឆ្នាំនេះសម្រាប់ខួបនៃការប្រសូតរបស់ព្រះគ្រីស្ទ ខ្ញុំនឹងចាប់ផ្តើមទៅព្រះវិហារ » ។

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំបានចាប់ផ្តើមទៅព្រះវិហារទុកជាអំណោយមួយថ្វាយដល់ព្រះអង្គសង្គ្រោះ ។ លទ្ធផលដ៏ចម្លែកគឺថា ខ្ញុំគឺជាអ្នកដែលបានទទួលអំណោយនោះ ។ ការត្រឡប់ទៅព្រះវិហារវិញបានផ្លាស់ប្តូរជីវិតខ្ញុំ ហើយវាបានចាប់ផ្តើមនៅថ្ងៃដែលខ្ញុំបានឈប់ជជែកគ្នា ហើយបានស្តាប់ ហើយអនុញ្ញាតឲ្យព្រះវិញ្ញាណប៉ះដួងចិត្តខ្ញុំ ។

ព្រះវិញ្ញាណនៅតែមានបន្ទូលមកកាន់ខ្ញុំ ។ អ្វីដែលខ្ញុំត្រូវធ្វើគឺឈប់ដើម្បីស្តាប់—រួចធ្វើតាម ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*



រូបភាព ដោយ បេន ស៊ីម៉ុនសិន

# ត្រៀមរួចជាស្រេចដើម្បី
# ឆ្ពោះទៅមុខ


ណូដូកា ធី


ជេស ដបបុយូ


ក្រេស អេស


ប្រាយអឹន អរ


អ៊ូទ្បា និងអ៊ីវាលីន វី


ចន ស៊ី

*ឡើងពីថ្នាក់បឋមសិក្សាទៅថ្នាក់យុវជន ឬ ថ្នាក់យុវនារី ? សូមគិតអំពីគំនិតទាំងនេះ ដែលចេញមកពីក្មេងអាយុ 12 ឆ្នាំ ទាំងប្រាំពីរនាក់ដែលកំពុងតែធ្វើការផ្លាស់ប្តូរ ។*

**ដោយរីឆាត អឹម រ៉មនី ទស្សនាវដ្តីរបស់សាសនាចក្រ**
**និង ម៉ាក់ឃី សាយមុមីយ៉ា ទីក្រុងតូក្យូ ប្រទេសជប៉ុន**

អ្នកជិតដល់អាយុ 12 ឆ្នាំហើយ ។ ជីវិត គឺពោរពេញដោយការផ្លាស់ប្តូរ ។ នៅក្នុងសាសនាចក្រ អ្នកនឹងឡើងពីថ្នាក់បឋមសិក្សាទៅថ្នាក់យុវជន ឬ យុវនារី ។ នោះមានន័យថា ជាការដាក់គោលដៅ ការផ្តល់ការបម្រើ ការរៀបចំខ្លួនទៅព្រះវិហារបរិសុទ្ធ ការរៀនបន្ថែមអំពីដំណឹងល្អ ។ ប៉ុន្តែ សូមកុំភ័យខ្លាចឡើយ ! អ្នកផ្សេងទៀតដែលកំពុងឆ្លងកាត់រឿងដូចគ្នានេះ និយាយថា វាអស្ចារ្យណាស់ ។

## ពីររួមគ្នា

អ៊័រូឡា វី ប្រទេសបារាំង ក្នុងថ្នាក់បីហាយ មានអាយុ 12 ឆ្នាំ ។ ចំណែកបងស្រីនាង អ៊ីវ៉ាលីន នឹងមានអាយុ 13 ឆ្នាំនៅខែក្រោយនេះ ។ អ៊័រូឡានិយាយថា « ខ្ញុំសប្បាយរីករាយណាស់ដែលបងស្រីខ្ញុំនៅទីនេះ ដើម្បីជួយខ្ញុំឡើងពីថ្នាក់បឋមសិក្សា ទៅថ្នាក់យុវនារី » ។

រឿងមួយដែលពួកគេចូលចិត្ត គឺសៀវភៅ ការពង្រីកខ្លួនរបស់យុវនារី ប៉ុន្តែនៅពេលពួកគេអានអំពីគោលដៅមួយ នោះពួកគេបានសើច ។ ក្នុងសៀវភៅនេះសរសេរថា « ចូររៀនលេងឧបករណ៍តន្ត្រីមួយ » ។

អ៊ីវ៉ូលីននិយាយថា « យើងលេងវាអស់រយៈពេលច្រើនឆ្នាំហើយ » ។ ប៉ុន្តែបន្ទាប់មកពួកគេបាននិយាយជាមួយម្ដាយពួកគេ ។ គាត់បានជួយពួកគេឲ្យមើលឃើញថា ពួកគេអាចប្រើតន្ត្រីដើម្បីបំពេញគោលដៅផ្សេងមួយទៀត ៖ ការបម្រើ ។

អ៊័រូឡា និង អ៊ីវ៉ាលីន ឥឡូវកំពុងរៀបចំខ្លួនដើម្បីសម្ដែងនៅក្នុងការប្រជុំសាក្រាម៉ង់ និងរាត្រីនៃការបង្ហាញទេពកោសល្យ ដែលផ្ដល់ជាការប្រគុំដូរតន្ត្រីសម្រាប់កុមារ និងសមាជិកទាំងអស់ និងចូលរួមច្រៀងជាមួយពួកអ្នកផ្សព្វផ្សាយសាសនា ។

អ៊ីវ៉ាលីននិយាយថា « ការពង្រីកខ្លួនរបស់យុវនារី គឺល្អណាស់ » ។ « វាឲ្យអ្នកធ្វើអ្វីដែលអ្នកស្រឡាញ់ ហើយធ្វើអ្វីដែលថ្មីផងដែរ » ។

## សួរសំណួរ

ប្រាយអឹន អាយុដប់ពីរឆ្នាំ ពីរដ្ឋ អារីសូណា សហរដ្ឋអាមេរិក កំពុងតែរៀបចំចែកនំប៉័ង និងទឹកជាលើកដំបូង ។ គាត់ពុំចង់ឲ្យមានកំហុសឡើយ ដូច្នេះគាត់បានសួរដល់អ្នកកាន់បព្វជិតភាពអើរ៉ុនផ្សេងទៀតក្នុងវួដរបស់គាត់ឲ្យពន្យល់ពីរបៀបទាំងឡាយដល់គាត់ ។

គាត់និយាយថា « ពួកគេអស្ចារ្យណាស់ » ។ « ពួកគេបានប្រាប់ខ្ញុំពីកន្លែងដែលត្រូវឈរ កន្លែងដែលត្រូវទៅ និងពីរបៀបដើម្បីចែក » ។

ប៉ុន្តែសំខាន់ជាងនេះទៅទៀត ពួកគេបានរំលឹកគាត់ឲ្យមានគារវភាព ។ ប្រាយអឹននិយាយថា « យើងត្រូវនឹកចាំពីព្រះអង្គសង្គ្រោះពេលយើងចែកនំប៉័ង និងទឹក » ។ « បើយើងមានគារវភាព វាជួយអ្នកដទៃឲ្យនឹកចាំពីទ្រង់ផងដែរ » ។

ប្រាយអឹនបានរៀនថា អ្នកដទៃរីករាយដើម្បីជួយគាត់ឲ្យយល់ពីតួនាទីរបស់គាត់ ហើយឲ្យរៀនធ្វើវាឲ្យបានល្អ ។ គាត់និយាយថា « គ្រាន់តែសួរប៉ុណ្ណោះ » ។ « ការឡើពីថ្នាក់បឋមសិក្សាទៅថ្នាក់យុវជនវាស្រួលជាងអ្វីដែលអ្នកគិត » ។

## បង្កើតមិត្តភក្ដិថ្មី

ណូដូកា ធី ពីទីក្រុង អូគីណាវ៉ា ប្រទេសជប៉ុន រៀបរាប់ថា « ខ្ញុំភ័យខ្លាចពេលទីប្រឹក្សាបានសុំខ្ញុំឲ្យចូលរួមការបោះជំរំយុវនារីស្តេកជាលើកទីដំបូង » ។ « ខ្ញុំបានសម្រេចចិត្តអធិស្ឋាន ។ បន្ទាប់ពីអធិស្ឋានរួច ខ្ញុំមានអារម្មណ៍កក់ក្ដៅ ដូច្នេះខ្ញុំបានសម្រេចចិត្តទៅ ។

« តាំងពីថ្ងៃទីមួយ ខ្ញុំអាចបង្កើតមិត្តភក្ដិថ្មីបាន ។ ពួកយុវនារីគួរឲ្យស្រឡាញ់ និងចិត្តល្អចំពោះខ្ញុំ មិនយូរប៉ុន្មានភាពភ័យខ្លាចរបស់ខ្ញុំក៏រសាត់បាត់ទៅ ។ ហើយខ្ញុំបានរៀនចេះពីវិធីបន្សុទ្ធទឹក ចងខ្សែ ធ្វើបង់រុំរបួស របៀបជួយសង្គ្រោះឲ្យមានដង្ហើមវិញ និងស្គាល់រុក្ខជាតិណាដែលអាចបរិភោគបាន ! »

## ទទួលអារម្មណ៍ស្វាគមន៍

ហ្វ្រេស អេស ពីរដ្ឋអារីសូណា សហរដ្ឋអាមេរិករៀបរាប់ថា « ថ្ងៃដំបូងរបស់ខ្ញុំក្នុងថ្នាក់យុវនារី គឺជាថ្ងៃខួបកំណើតរបស់ខ្ញុំ » ។ « ពួកគេបានធ្វើដូចជាមិនខ្វល់ ។ ប៉ុន្តែបន្ទាប់មកពួកគេបានចាប់ធ្វើល្អដាក់ខ្ញុំ ។ ពួកគេបានធ្វើការតិចតួចដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ថាស្វាគមន៍ » ។

អ្នកប្រឹក្សារបស់នាងក៏ស្វាគមន៍ចំពោះនាងផងដែរ ។ ហ្វ្រេស និយាយថា « គាត់ប្រាប់យើងអំពីអ្វីដែលគាត់បានធ្វើ នៅពេលគាត់នៅក្នុងថ្នាក់យុវនារី » ។ « ហើយគាត់អានកូនសៀវភៅ ការពង្រីកខ្លួនរបស់យុវនារី ជាមួយយើងម្នាក់ៗ ដើម្បីធ្វើឲ្យប្រាកដថា ពួកយើងយល់ » ។





រូបថត នៃរីឆាត អឹម រ៉ម រ៉នដល អរ រ៉េយប្លីងហ្គ្រ និង ម៉ាក់ឃី សាយមុមីយា

## រៀន បង្រៀន ហើយចែកចាយ

ក្នុងនាមជាឌីកុនថ្មីម្នាក់ ចស៍ ដបបុយូ រស់នៅរដ្ឋយូថាហ៍ ស.រ.អា. ត្រូវបានសុំឲ្យបង្រៀនមេរៀនមួយអំពីការក្លាយជាសិស្សម្នាក់របស់ព្រះគ្រីស្ទ ។ « ខ្ញុំបានរកឃើញខគម្ពីរដែលនិយាយអំពី ពេត្រុស និងអ្នកផ្សេងទៀតកំពុងនេសាទត្រី ។ ចស៍ និយាយថា ពួកលោកបានព្យាយាមនៅមួយចំហៀងទូក ហើយនេសាទពុំបានអ្វីសោះ » ។ « បន្ទាប់មកព្រះអង្គសង្គ្រោះបានប្រាប់ពួកលោកឲ្យនេសាទទៅម្ខាងទៀត ហើយពួកលោកនេសាទបានត្រីយ៉ាងច្រើន (សូមមើល លូកា 5:5–11 និង យ៉ូហាន 21:6–11) ។ ដូច្នោះនៅក្នុងមេរៀនរបស់ខ្ញុំ យើងបានអានពីរឿងនោះ ។ បន្ទាប់មកយើងបាននិយាយអំពីថា តើវាមានន័យបែបណាចំពោះយើងវិញ ។ នៅពេលយើងធ្វើអ្វីដោយខ្លួនឯង នោះយើងអាចជួបឧបសគ្គ ។ ប៉ុន្តែនៅពេលយើងស្ដាប់តាមព្រះអម្ចាស់ នោះទ្រង់ជួយយើង » ។

ចស៍ និយាយថា ការរៀនសូត្រ ការបង្រៀន និងការចែកចាយ គឺសំខាន់ណាស់នៅក្នុងថ្នាក់យុវជន ។ គាត់និយាយថា « នៅក្នុងបឋមសិក្សា យើងបានរៀនច្រើន និងមានសកម្មភាពជាច្រើន » ។ « ឥឡូវយើងកំពុងរៀនច្រើន *និង* ការចែកចាយ ។ មានន័យថា *ធ្វើ* ច្រើនជាមួយអ្វីដែលយើងរៀន » ។ ឧទាហរណ៍ បន្ទាប់ពីមេរៀនបព្វជិតភាពរួច ចស៍ បានទៅសួរសុខទុក្ខមិត្តម្នាក់ដែលពុំបានមកព្រះវិហារជាយូរមកហើយ ។ « ឪពុកម្ដាយរបស់គាត់ធ្វើការនៅថ្ងៃអាទិត្យ ដូច្នេះពួកគេមិនមកព្រះវិហារទេ ។ ប៉ុន្តែខ្ញុំបានប្រាប់គាត់ថា គាត់អាចមកជាមួយខ្ញុំបាន » ។

ចស៍ កំពុងរៀនអំពីគោលបំណងនៃថ្នាក់យុវជន និង ថ្នាក់យុវនារី ។ គាត់និយាយថា « វាគឺបង្ហាញយើងពីរបៀបដើម្បីប្រែក្លាយឲ្យកាន់តែដូចព្រះអង្គសង្គ្រោះ » ។ គាត់ដឹងថាការអញ្ជើញឲ្យ « មកឯព្រះគ្រីស្ទ » មានន័យថាការដើរលើផ្លូវមួយដែលចាប់ផ្ដើមជាមួយពិធីជ្រមុជទឹក និង ពិធីបញ្ជាក់ បន្តឆ្ពោះទៅព្រះវិហារបរិសុទ្ធ និងនាំទៅដល់ជីវិតដ៏អស់កល្បជានិច្ច ។

គាត់ពោលថា « ខ្ញុំត្រៀមខ្លួនជាស្រេចដើម្បីឆ្ពោះទៅមុខ » ■





### ការធ្វើការរួមគ្នាដើម្បីបំពេញកាតព្វកិច្ចចំពោះព្រះ

ប៊ិន ស៊ី អាយុដប់ពីរឆ្នាំ និង ឪពុករបស់គាត់តែងរៀបគម្រោងធ្វើការជាមួយគ្នា ។ ឧទាហរណ៍ ពួកគេបានប៉ាក់ក្ជួយ ដែលពួកគេនឹងប្រើនៅពេលគេទៅបោះជុំរំ ។ រូបប៉ាក់ទាំងឡាយ គឺបានមកពីការបោះជំរំ និង សកម្មភាពផ្សេងៗ ដែលពួកគេបានចូលរួម នៅខេត្ត ប្រ៊ីតធីស កូឡុំប៊ី ប្រទេសកាណាដា ជាកន្លែងដែលពួកគេរស់នៅ ។

ចន និយាយថា « ប៉ា ជាអ្នកជួយដ៏ល្អ » ។ « ខ្ញុំមិនអាចស្រមៃឃើញពីការធ្វើគម្រោងរបស់សាសនាចក្រដោយគ្មានគាត់បានឡើយ » ។

នៅពេលចនអាយុ 12 ឆ្នាំ ពួកគេបានរំលឹកពីកូនសៀវភៅ កាតព្វកិច្ចចំពោះព្រះរួមគ្នា ។ មិនយូរប៉ុន្មានពួកគេបាន « យល់គោលលទ្ធិ » នៅក្នុងមេរៀនឌីកុន ។ ចន និយាយថា « ប៉ាបានពន្យល់ខ្ញុំអំពីកូនសោបព្វជិកភាព និងសិទ្ធអំណាច » ។ ហើយនោះបានជួយ ចន ឲ្យបំពេញតម្រូវការមួយនៃតម្រូវការទាំងឡាយ ។

ចន និយាយថា « នៅពេលអ្នកកំពុងធ្វើកាតព្វកិច្ចចំពោះព្រះ សូមឲ្យឪពុកអ្នកចូលរួមចំណែកផង » ។ ប៉ា ខ្ញុំបានជួយខ្ញុំច្រើនហើយ » ។

សាក្សីពិសេស



# តើព្រះយេស៊ូវពិតជាបានសុគត ហើយមានព្រះជន្ម ឡើងវិញម្ដងទៀត មែនទេ ?


**ដោយអែលឌើរ**
**ឌី ថត គ្រីស្ដូហ្វឺសិន**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*សមាជិកនៃកូរ៉ុមនៃពួកដប់ពីរនាក់ គឺជាសាក្សីពិសេសរបស់ព្រះយេស៊ូវគ្រីស្ទ ។*




## មែនហើយ ។

ខ្ញុំឈរជាសាក្សីម្នាក់ថា ព្រះយេស៊ូវនៃណាសារ៉ែតគឺជាព្រះដ៏ប្រោសលោះ ដែលបានរស់ឡើងវិញ ។



ទ្រង់គឺជាព្រះដ៏បង្កបង្កើត នៃផែនដីនេះ ។



អព្ភូតហេតុរបស់ទ្រង់មានពិត ។



ទ្រង់នឹងយាងមកម្ដងទៀត ។



ព្រះគុណរបស់ទ្រង់មានពិត ដោយអនុញ្ញាតឲ្យមនុស្សទាំងអស់បានប្រែចិត្ត ហើយបានស្អាតស្អំ ។



មានការរស់ឡើងវិញមួយ សម្រាប់មនុស្សគ្រប់រូប ។

*ដកស្រង់ចេញពី « The Resurrection of Jesus Christ, »* Liahona, *ខែ ឧសភា ឆ្នាំ* 2014 *ទំព័រ* 111–14 ។

ព័ត៌មានលម្អិតដកស្រង់ពី*ទ្រង់មានព្រះជន្មរស់ឡើងវិញ* ដោយ ឌេល ផាសិន ព័ត៌មានលម្អិតដកស្រង់ពី *ព្រះយេស៊ូវកំពុងព្យាបាលមនុស្សខ្វាក់ភ្នែក* ដោយ ខាល ហេនរីច ប្លុក, *ការយាងឡើងទៅស្ថានសួគ៌* ហារី អាន់ឌើរសិន, ព័ត៌មានលម្អិតដកស្រង់ពី *ស្ត្រីធ្វើអំពើកំផិត* ដោយ ហារី អាន់ឌើរសិន រូបថតដោយ ISAILORR/ISTOCK/THINKSTOCK

# យើងចងចាំ ហើយថ្វាយបង្គំដល់ព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ

ដោយ មេរ៉ែន សាន់ឌើរសុន និង ជីន ប៊ីងហាំ

ជាយូរយារមកហើយ ព្រះវរបិតាសួគ៌មានបន្ទូលប្រាប់ដល់ពួកព្យាការីរបស់ទ្រង់អំពីអំណោយមួយដ៏អស្ចារ្យដែលទ្រង់នឹងបញ្ជូនទៅកាន់ពិភពលោកទាំងមូល ។ អំណោយនោះគឺជាព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ដែលនឹងយាងមកកាន់ផែនដីធ្វើជាព្រះអង្គសង្គ្រោះរបស់យើង ។ ព្រះយេស៊ូវនឹងបង្ហាញយើងពីរបៀបរស់នៅដើម្បីយើងអាចត្រឡប់ទៅរកព្រះវរបិតាសួគ៌វិញ ។ ពួកព្យាការីបានទន្ទឹងរង់ចាំដោយសេចក្ដីអំណរជាខ្លាំងដល់គ្រាដែលព្រះយេស៊ូវនឹងប្រសូតមក ។

កាលពួកទេវតាបានប្រាប់ដល់ពួកគង្វាលនៅក្បែរភូមិបេថ្លេហិមថា ព្រះឱរសដ៏ពិសេសមួយអង្គដែលជាព្រះរាជបុត្រានៃព្រះបានប្រសូតមក នោះពួកគេមានសេចក្ដីអំណរយ៉ាងអស្ចារ្យ ។ ពួកគេបានប្រញាប់ប្រញាល់ទៅមើល ហើយថ្វាយបង្គំទ្រង់ ។

នៅទ្វីបអាមេរិក សាសន៍នីហ្វៃបានដឹងថាទ្រង់បានប្រសូតកាលផ្ទៃមេឃមានពន្លឺពេញមួយថ្ងៃ ទោះជាព្រះអាទិត្យបានអស្ដង្គតក្ដី ។ ពួកគេក៏មានសេចក្ដីអំណរដ៏អស្ចារ្យផងដែរ ហើយបានថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌សម្រាប់អំណោយនៃព្រះរាជបុត្រាទ្រង់ ។

នៅជំនាន់យើង យើងចងចាំ ហើយអបអរដល់ការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទនៅបុណ្យគ្រីស្ទម៉ាស់ ។ យើងបង្ហាញសេចក្ដីអំណរ និង អំណរគុណរបស់យើងសម្រាប់អំណោយនៃព្រះអង្គសង្គ្រោះយើងដោយការធ្វើតាមគំរូរបស់ទ្រង់ដោយការផ្ដល់សេចក្ដីស្រឡាញ់ដល់អ្នកដទៃតាមដែលយើងអាចធ្វើបាន ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*



**ព្រះគម្ពីរ**
- យ៉ូហាន 14:6

### គំនិតយោបល់សម្រាប់ការនិយាយក្នុងគ្រួសារ

ពិភាក្សាពីរបៀបជាច្រើនដែលព្រះយេស៊ូវគ្រីស្ទបានបង្ហាញសេចក្ដីស្រឡាញ់ ។ សូមជ្រើសរបៀបមួយចំនួនជាគ្រួសារដើម្បីបង្ហាញសេចក្ដីស្រឡាញ់ដល់អ្នកដទៃក្នុងខែធ្នូ ជារបៀបមួយដើម្បីចងចាំ ហើយធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ។

ខាងឆ្វេង ៖ គូរដោយ ចល មេន

# អំណោយនៃសេចក្ដីស្រឡាញ់

សូមកាត់ប្រអប់អំណោយតាមបន្ទាត់ជិត ។ សរសេរសកម្មភាពអំណោយរបស់អ្នកនៅកន្លែងទទេរ ។ បត់ត្រង់បន្ទាត់ដាច់ៗ រួចបិទគម្របចុះ ។ ចុះរន្ធនៅផ្នែកខាងលើនៃអំណោយនីមួយៗ ហើយចងខ្សែ ។ ព្យួរអំណោយទាំងនោះនៅកន្លែងដែលអ្នកអាចមើលឃើញ ។ រៀងរាល់ពីរបីថ្ងៃម្ដង សូមបើក « អំណោយ » មួយ ហើយធ្វើសកម្មភាពនៅក្នុងនោះ ។ ចងចាំថា អ្នកអាចផ្ដល់អំណោយទាំងនេះពេញមួយឆ្នាំ !




*អ្នកអាចបោះពុម្ពសកម្មភាពនេះជាច្រើនច្បាប់នៅ liahona.lds.org ។*



# យ៉េនសុី

ដោយអែលឌើរ ប្រេន អេជ នៀលសុន
នៃពួកចិតសិបនាក់

*« ហើយឥឡូវនេះ ខ្ញុំចង់ឲ្យអ្នករាល់គ្នាបន្ទាបខ្លួន ហើយចុះចូល ហើយសុភាពទន់ភ្លន់ »* *(អាលម៉ា 7:23)* ។

បងប្អូនជីដូនមួយខ្ញុំ និង ខ្ញុំតែងចង់បានសត្វសេះមួយក្បាល ។ កាលខ្ញុំមានអាយុប្រហែលជា 9 ឬ 10 ឆ្នាំ ឪពុកខ្ញុំបានទិញសេះញីពណ៌ខ្មៅមួយក្បាលដ៏ស្រស់ស្អាត ។ យើងបានដាក់ឈ្មោះឲ្យវាថា យ៉េនសុី ។ យើងរីករាយយ៉ាងខ្លាំងដោយមានសេះនេះ ប៉ុន្តែវាមិនបានត្រូវបានគេបង្ហាត់ឲ្យមានអ្នកជិះពីលើខ្នងវាឡើយ ។ យើងនៅក្មេងពេកដើម្បីធ្វើកិច្ចការដ៏លំបាកទាំងអស់នេះក្នុងការបង្ហាត់បង្រៀនដល់សេះ ដូច្នេះឪពុកខ្ញុំបានសុំមិត្តម្នាក់ដែលដឹងច្រើនពីសត្វសេះជួយបង្ហាត់ដល់យ៉េនសុី ។

ជារឿយៗ យើងបានទៅវាលស្មៅដើម្បីមើលយ៉េនសុី ។ យើងទន្ទឹងយ៉ាងអន្ទះសារនូវថ្ងៃដែលយើងអាចជិះលើខ្នងរបស់វា ។ ប៉ុន្តែមិនថាមនុស្សគ្រប់គ្នាខំព្យាយាមយ៉ាងណាទេ គ្មាននរណាម្នាក់អាចបង្ហាត់ដល់យ៉េនសុីបានឡើយ ។ វាមានភាពរឹងរូសខ្លាំងណាស់ ។ យើងមិនដែលជិះវាបានឡើយ ។

ថ្ងៃមួយ មិត្តរបស់ឪពុកខ្ញុំបានព្យាយាមជិះវាក្នុងក្បួនដង្ហែរមួយ ។ កាលមិត្តរបស់ឪពុកខ្ញុំបានជិះ យ៉េនសុី ចុះទៅថ្នល់ យ៉េនសុីកញ្ជ្រោលគាត់ធ្លាក់ពីលើខ្នងវា ហើយបានចាប់ផ្តើមបោលកាត់ពេញទីក្រុង ។ យ៉េនសុី បានបោលយ៉ាងលឿនរហូតដល់ជើងវាមានរបួសដោយសារប៉ះនឹងក្បាលម៉ាសុីនទឹកលត់ភ្លើង ។ ខ្ញុំបានរត់តាម យ៉េនសុី ហើយរកឃើញវាដេកនៅលើថ្នល់ទាំងឈឺចាប់ ។

ខ្ញុំមានចិត្តសោកសៅ ។ យើងស្រឡាញ់យ៉េនសុី ។ ប្រសិនបើវាស្តាប់បង្គាប់អ្នកបង្ហាត់ វាអាចក្លាយជាសេះមួយក្បាលដែលមានជីវិតរីករាយដ៏អស្ចារ្យ ។ ប៉ុន្តែ យ៉េនសុី មិនបានស្តាប់ហើយធ្វើតាមម្ចាស់វាឡើយ ។ ឥឡូវនេះវាមានរបួស ហើយដេកនៅកណ្តាលថ្នល់ ។

ដំណើររឿងរបស់ យ៉េនសុី បានបង្រៀនខ្ញុំពីពរជ័យដែលកើតមាន កាលយើងធ្វើតាមលោកចៅហ្វាយ ជាព្រះអង្គសង្គ្រោះរបស់យើងព្រះយេស៊ូវគ្រីស្ទ ។ កាលយើងមានចិត្តសប្បុរសទន់ភ្លន់ ហើយរាបសា យើងអាចរីករាយកាលយើងអនុញ្ញាតឲ្យព្រះអង្គសង្គ្រោះដឹងនាំយើង ។ ■

រូបគំនូរដោយ ដាន បឺ

# ទំព័ររបស់យើង



*កាលពីឆ្នាំមុន គ្រួសារខ្ញុំ និង ខ្ញុំបានទៅព្រះវិហារបរិសុទ្ធក្នុងប្រទេសស្វីសរយៈពេលប្អូនថ្ងៃជាមួយនឹងសមាជិកវួដយើង ។ នៅព្រឹកថ្ងៃសៅរ៍ ពីមុនយើងត្រឡប់មកប្រទេសអ៊ីតាលីវិញ មានឥន្ទធនូមួយបានលេចឡើង ។*

សារីយ៉ា សឺ អាយុ 10 ឆ្នាំ ប្រទេសអ៊ីតាលី



*យើងធ្វើបញ្ជីគ្រួសារសម្រាប់សកម្មភាពថ្នាក់កុមារ ។*

វួដឡាសហោវ៉ាស ប្រទេសអាហ្សង់ទីន




*នេះគឺជាព្រះគម្ពីរមរមនដំបូងរបស់ខ្ញុំ ។ ឥឡូវនេះដោយសារខ្ញុំអាចអានពាក្យបានខ្លះ។ ខ្ញុំអាចអានព្រះគម្ពីរ ។*

អាន់ណា អិល អាយុ 5 ឆ្នាំ ប្រទេសប្រេស៊ីល



*កាលពីឆ្នាំមុន យើងមានបទបង្ហាញក្នុងការប្រជុំសាក្រាម៉ង់របស់យើងសម្រាប់ថ្នាក់កុមារជាលើកដំបូង ។ ភ្លើងបានដាច់មួយសប្ដាហ៍ពីមុនអំឡុងពេលយើងហាត់ ប៉ុន្តែយើងនៅតែបន្តច្រៀង ហើយឡើងនិយាយផ្នែករបស់យើងដដែល ។*

សាខាវៀងចន្ទន៍ ប្រទេសឡាវ

# ហាទ្យូ វ៉េនណែរ !*

# ខ្ញុំឈ្មោះមីនណា មកពីប្រទេសស៊ុយអែត

* « សួស្ដី មិត្តភក្ដិទាំងឡាយ ! » ជាភាសាស៊ុយអែត

**ដកស្រង់ពីការសម្ភាសមួយ ដោយអាមី ជេន លីវិត**

តើអ្នកចូលចិត្តរស់នៅក្នុងផ្ទះដែលជាសាលារៀនបែបណាដែរ ? មីនណា និង គ្រួសារនាងរស់នៅតំបន់ជនបទនៃភាគខាងត្បូងប្រទេសស៊ុយអែត ។ ផ្ទះរបស់ពួកគេធ្លាប់ជាសាលារៀនជាយូរយារណាស់មកហើយ ។ នាងប្រាប់ថា ផ្នែកដ៏ល្អបំផុតគឺថា ផ្ទះនោះមានបន្ទប់ធំមួយល្មមអាចដាក់មនុស្សច្រើននាក់បាន ។ នៅខែធ្នូ គ្រួសាររបស់ មីនណា បានអញ្ជើញពួកអ្នកជិតខាង មិត្តភក្ដិ និង គ្រួសារមកលេងផ្ទះសម្រាប់ « កម្មវិធីច្រៀង » ដ៏ពិសេសមួយ ។ មានមនុស្សប្រមាណជា 80 នាក់បានមកច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់រួមគ្នា ។ រួចពួកគេបានរីករាយនឹងម្ហូបអាហារពីមុនមនុស្សគ្រប់គ្នាបានត្រឡប់ទៅវិញក្នុងអាកាសធាតុខែរងារដ៏ត្រជាក់ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*



***នេះជាផ្លែនោងដែលខ្ញុំ បេះមកពីចម្ការយើង ។***



រូបថតនៃស្លឹកខុល ដោយ MARK OLEKSIY/HEMERA/THINKSTOCK រចនារូបភាពដោយ ប្រាដ ធា



នៅសាលាខ្ញុំជាសមាជិកសាសនាចក្រតែម្នាក់គត់ ដូច្នេះខ្ញុំព្យាយាមចែកចាយដំណឹងល្អដល់មិត្តភក្តិខ្ញុំ ។ ជារឿយៗ ខ្ញុំនាំមិត្តភក្តិខ្ញុំនៅសាលារៀនមកសកម្មភាពថ្នាក់កុមាររបស់ខ្ញុំ ។ នោះមានន័យថា ឥឡូវនេះខ្ញុំកំពុងធ្វើជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ដូចជាពួកបងស្រីរបស់ខ្ញុំដែរ ។

ខ្ញុំចូលចិត្តលេងលោតត្រេមប៉ូលីន ។ ខ្ញុំក៏ចូលចិត្តលេងព្យាណូ និងផ្លុំខ្លុយផងដែរ ។

ខ្ញុំមានអាយុ 10 ឆ្នាំ ហើយជាកូនពៅក្នុងចំណោមកូនទាំង 9 នាក់ក្នុងគ្រួសារខ្ញុំ ។ បងស្រីខ្ញុំពីរនាក់កំពុងបម្រើបេសកកម្ម— ម្នាក់នៅប្រទេសបារាំង ហើយម្នាក់ទៀតនៅវិសាលដ្ឋាននៃព្រះវិហារបរិសុទ្ធក្នុងរដ្ឋយូថាហ៍ ។









## ខ្ញុំចូលចិត្តមើលព្រះវិហារបរិសុទ្ធ

ព្រះវិហារបរិសុទ្ធស្តុកខុលស៊ុយអែតនៅក្បែរផ្ទះរបស់លោកតាលោកយាយខ្ញុំ ។ ព្រះវិហារបរិសុទ្ធនេះជាកន្លែងមួយដ៏សំខាន់នៅក្នុងចិត្តខ្ញុំ ។ មានគ្រាមួយ ឪពុកខ្ញុំ និង ខ្ញុំបានដើរនៅជុំវិញបរិវេណនោះ ។ យើងបាននិយាយពីព្រះវិហារបរិសុទ្ធ និងពីរបៀបដែលខ្ញុំអាចចូលទៅខាងក្នុងនៅថ្ងៃណាមួយ ។

រឿងមួយដែលខ្ញុំចូលចិត្តធ្វើជាមួយនឹងគ្រួសារខ្ញុំ គឺជិះឡានទៅភាគជើងទៅកាន់រាជធានីរបស់ប្រទេសស៊ុយអែតដែលមានឈ្មោះថា ស្តុកខុល ។ ខ្ញុំចូលចិត្តទៅលេងលោកតាលោកយាយខ្ញុំ និងសាច់ញាតិផ្សេងទៀតដែលរស់នៅទីនោះ ។

គ្រួសារខ្ញុំចូលចិត្តហែលទឹករួមគ្នា ។ នារដូវក្តៅយើងទៅបឹងមួយនៅក្បែរផ្ទះយើង ។ នារដូវរងារយើងទៅកន្លែងមួយដែលមានអាងហែលទឹក និងកន្លែងលេងទឹកជាច្រើននៅខាងក្នុង ។





## ត្រៀមខ្លួនហើយឬនៅ!

កាបូបរបស់មីនណាត្រូវបានដាក់ទៅដោយរបស់របរមួយចំនួនដែលនាងចូលចិត្ត ។ តើរបស់ណាខ្លះ អ្នកចង់ដាក់ក្នុងកាបូបរបស់អ្នក ?

# បុណ្យគ្រីស្ទម៉ាស់ដំបូង

ដោយ ជេន វិលកស៍

*អ្នកអាចធ្វើការសម្តែងនេះ ជាមួយគ្រួសារ មិត្តភក្តិ ឬថ្នាក់កុមាររបស់អ្នក ។ សូមអាន លូកា 2:1–16 ដើម្បីជួយអ្នកឲ្យរៀបចំខ្លួន ។*



**តួ ៖**

ម៉ារា

យ៉ូសែប

ម្ចាស់ផ្ទះសំណាក់

អ្នកគង្វាលទី 1

អ្នកគង្វាលទី 2

ទេវតា



**សំលៀកបំពាក់ ៖**

សូម ធ្វើសំលៀកពាក់សាមញ្ញ ៖ រ៉ូបសម្រាប់យ៉ូសែប កន្សែងបង់-កសម្រាប់ម៉ារា និង ដំបងសម្រាប់ពួកអ្នកគង្វាល ។



រចនារូបភាពដោយជូលី យ៉ាំង

**ឆាក ៖**

ដាក់ភួយមួយនៅលើកៅអីពីរធ្វើជាក្រោល

ខ្នើយតូចៗធ្វើជាកូនចៀម

កូនតុក្កតា ឬ ភួយដែលរមូរធ្វើ ជាព្រះឱរសយេស៊ូវ



ចម្រៀង ៖ « When Joseph Went to Bethlehem (កាលយ៉ូសែបទៅភូមិបេថ្លេហិម) » វគ្គទីមួយ (*Children's Songbook* ទំព័រ 38) ។

**គំនិត ៖** សូមឲ្យអ្នកទស្សនាច្រៀងចម្រៀងជាមួយនឹងពួកអ្នកសម្ដែង ។

ម៉ារា ៖ ខ្ញុំសង្ឃឹមថា យើងអាចរកកន្លែងសម្រាកបានឆាប់ៗនេះ ។ យើងបានធ្វើដំណើរយូរហើយ ។

យ៉ូសែប ៖ មានផ្ទះសំណាក់មួយនៅខាងមុខ ។ ចាំនៅទីនេះហើយ កាលបងទៅរកមើលថាតើមានបន្ទប់សល់សម្រាប់យើងដែរឬអត់ ។

*[យ៉ូសែបជួយម៉ារាឲ្យអង្គុយចុះ រួចគោះ « ទ្វារ » ។ ម្ចាស់ផ្ទះសំណាក់បានបើកទ្វារ]* ។

ម្ចាស់ផ្ទះសំណាក់ ៖ តើអ្នកមានការអ្វីដែរ ?

យ៉ូសែប ៖ ខ្ញុំកំពុងរកបន្ទប់សម្រាក ។ ភរិយាខ្ញុំ និង ខ្ញុំបានធ្វើដំណើរយ៉ាងវែងឆ្ងាយ ហើយ យើងត្រូវការកន្លែងសម្រាក ។

ម្ចាស់ផ្ទះសំណាក់ ៖ ឲ្យខ្ញុំសុំទោស បន្ទប់ពេញអស់ហើយ ។

យ៉ូសែប ៖ សូមមេត្តាផង តើលោកមិនអាចធ្វើអ្វីមួយដើម្បីជួយយើងបានទេឬ ? ភរិយាខ្ញុំនឹងសម្រាលកូនក្នុងពេលឆាប់ៗនេះ ។

ម្ចាស់ផ្ទះសំណាក់ ៖ ខ្ញុំគិតថា អ្នកអាចសម្រាកនៅក្នុងក្រោល ។ វានៅទំនេរ ។

យ៉ូសែប ៖ សូមអរគុណ ។ នោះជាសន្ដានចិត្តដ៏ប្រពៃណាស់ ។

*[យ៉ូសែបបានទៅរកម៉ារា ហើយជួយនាងឲ្យក្រោយឡើង ។]*

យ៉ូសែប ៖ ផ្ទះសំណាក់ពេញអស់ហើយ ប៉ុន្តែម្ចាស់ផ្ទះសំណាក់ប្រាប់ថា យើងអាចសម្រាកក្នុងក្រោលបាន ។

ម៉ារា ៖ អ៊ូ អូនត្រេកអរណាស់ដែលយើងរកកន្លែងបានសម្រាកនៅយប់នេះ ។

*[ពួកគេបានដើរទៅក្រោលនោះ ។ ម៉ារា និង យ៉ូសែប បានអង្គុយចុះ ហើយឈុតឆាកនេះបានបញ្ចប់]* ។

ចម្រៀង ៖ « When Joseph Went to Bethlehem (កាលយ៉ូសែបទៅភូមិបេថ្លេហិម) » វគ្គទីពីរ និង ទីបី (*Children's Songbook* ទំព័រ 38) ។

*[ពួកអ្នកគង្វាលកំពុងចាំយាមចៀមរបស់ខ្លួន ។ [ទេវតាបានយាងមក ហើយពួកអ្នកគង្វាលបានលុតជង្គង់ទៅនឹងដី]* ។

អ្នកគង្វាលទី 1 ៖ តើអ្នកជានរណា ?

អ្នកគង្វាលទី 2 ៖ សូមកុំធ្វើបាបយើងអី ។

ទេវតា ៖ កុំខ្លាចអី ។ ខ្ញុំមកប្រាប់ពីដំណឹងដ៏រីករាយទេតើ ! នៅយប់នេះ ព្រះរាជបុត្រានៃព្រះបានប្រសូតនៅភូមិបេថ្លេហិម ។ អ្នកនឹងឃើញព្រះឱរសផ្ដេកក្នុងស្នូក ។

អ្នកគង្វាលទី 1 ៖ តោះចូរយើងទៅមើលព្រះឱរសនោះ ។

ទេវតា ៖ សួស្ដីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្ដីសុខសាន្តនៅផែនដីនៅកណ្ដាលមនុស្ស ។

ចម្រៀង ៖ « Stars Were Gleaming » (*Children's Songbook* ទំព័រ 37) ។

*[ពួកអ្នកគង្វាលទៅផ្ទះសំណាក់នោះ ហើយបានគោះ « ទ្វារ » ។ ម្ចាស់ផ្ទះសំណាក់បានបើកទ្វារ]* ។

អ្នកគង្វាលទី 2 ៖ យើងមកមើលព្រះឱរសព្រះគ្រីស្ទ ។

អ្នកគង្វាលទី 1 ៖ មានទេវតាមកប្រាប់យើងថា ទ្រង់នឹងដាក់នៅក្នុងស្នូក ។

អ្នកគង្វាលទី 2 ៖ តើលោកដឹងថាទ្រង់នៅទីណាទេ ?

ម្ចាស់ផ្ទះសំណាក់ ៖ ព្រះឱរសនោះបានប្រសូតនៅក្នុងក្រោលខ្ញុំកាលពីយប់មិញ ។ ខ្ញុំនឹងនាំផ្លូវអ្នកទាំងពីរ ។

*[ពួកអ្នកគង្វាលបានដើរតាមម្ចាស់ផ្ទះសំណាក់នោះទៅក្រោល ជាកន្លែងដែលយ៉ូសែប និង ម៉ារីអង្គុយនៅក្បែរស្នូកមួយដែលមានព្រះឱរសយេស៊ូវនៅក្នុងនោះ]* ។

**គំនិត ៖** សូមបិទផ្កាយក្រដាសធំមួយលើដំបងមួយ ហើយដាក់វាចំពីលើក្រោលនោះ ។

អ្នកគង្វាលទី 1 ៖ វាជាការពិតមែន ! ពិតជាមានព្រះឱសមួយអង្គនៅក្នុងស្នូក ដូចដែលទេវតាបានប្រាប់មែន ។

អ្នកគង្វាលទី 2 ៖ នេះពិតជាព្រះអង្គសង្គ្រោះ ព្រះគ្រីស្ទជាព្រះអម្ចាស់មែន ។

*[ពួកអ្នកគង្វាល និង ម្ចាស់ផ្ទះសំណាក់បានលុតជង្គង់នៅជុំវិញស្នូកនោះ]* ។

ចម្រៀង ៖ « យប់ដ៏សុខសាន្ត » (*ទំនុកដំកើងព្រះ និង ចំរៀងកុមារាកុមារី* ទំព័រ 53) ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា.* ។

# សូមមើលទៅខាងក្នុង !



ដោយ សូហ្វៀ ស៊ី អាយុ 9 ឆ្នាំ ប្រទេសប្រេស៊ីល

ពីមុនបុណ្យគ្រីស្ទម៉ាស់ ឪពុកម្ដាយខ្ញុំបានទិញព្រះគម្ពីរមរមនមួយប្រអប់ធំ ដើម្បីឲ្យទៅមនុស្សដទៃទៀត ។ នៅពេលនោះខ្ញុំមានគំនិតមួយដើម្បីយកព្រះគម្ពីរនោះខ្លះទៅសាលា ហើយឲ្យជាអំណោយដល់គ្រូបង្រៀនរបស់ខ្ញុំបីនាក់ ។

កាលខ្ញុំចូលរៀនថ្នាក់តន្ត្រី ខ្ញុំបានឃើញគ្រូតន្ត្រីរបស់ខ្ញុំ ហើយបានគិតថា « យកទៅឲ្យ សូហ្វៀ ។ ឲ្យព្រះគម្ពីរមួយក្បាលដល់គាត់ទៅ ! » ខ្ញុំបានដើរទៅរកអ្នកគ្រូខ្ញុំយឺតៗ ។ ប៉ុន្តែខ្ញុំគ្មានភាពក្លាហានឲ្យព្រះគម្ពីរនោះដល់គាត់ឡើយ ។

ខ្ញុំបានទៅជ្រុងម្ខាងនៃបន្ទប់នោះ ហើយបានអធិស្ឋានយ៉ាងស្ងៀមស្ងាត់ ។ « ព្រះវរបិតាសួគ៌ កូនសូមដល់ទ្រង់ដើម្បីជួយកូនឲ្យផ្ដល់ព្រះគម្ពីរនេះទៅដល់អ្នកគ្រូរបស់កូន » ។ កាលខ្ញុំបញ្ចប់ការអធិស្ឋានខ្ញុំហើយ ខ្ញុំបានទទួលការបំផុសគំនិតយ៉ាងខ្លាំងថា ខ្ញុំគួរឲ្យព្រះគម្ពីរនោះទៅគាត់ ។ រំពេចនោះខ្ញុំមានសេចក្ដីក្លាហាន ។

ខ្ញុំបានដើរទៅរកគាត់ ។ គាត់បានមើលមុខខ្ញុំ ហើយខ្ញុំបានឲ្យព្រះគម្ពីរមរមនដល់គាត់ ហើយពោលថា « អ្នកគ្រូ ខ្ញុំស្រឡាញ់អ្នកគ្រូអស់ពីចិត្តខ្ញុំ ហើយខ្ញុំចង់ឲ្យព្រះគម្ពីរមរមនមួយក្បាលនេះដល់អ្នកគ្រូ ! »

គាត់បានយកវា ហើយមើលគម្រប ។ « សូមមើលទៅខាងក្នុង ! » ខ្ញុំបានពោល ។ គាត់បានឃើញថា ខ្ញុំបានសរសេរនូវពាក្យពេចន៍មួយចំនួន ។

គាត់បានឱបខ្ញុំ ហើយពោលថា « អ៊ូ សូហ្វៀ អរគុណដែលកូនឲ្យសៀវភៅនេះមកអ្នកគ្រូ ! »

បន្ទាប់ពីខ្ញុំបានអង្គុយចុះ គាត់បានថ្លែងទៅកាន់សិស្សក្នុងថ្នាក់ថា « មើលនែ៎ តើ សូហ្វៀ បានឲ្យអ្វីដល់អ្នកគ្រូ ។ អ្នកគ្រូនឹងអានសៀវភៅនេះក្នុងអំឡុងពេលបុណ្យឈប់សម្រាកនេះ ! »

កាលខ្ញុំទៅដល់ផ្ទះខ្ញុំបានរត់ទៅរកម្ដាយខ្ញុំ ហើយប្រាប់ថា « តើម៉ាក់ដឹងទេ ! កូនបានឲ្យព្រះគម្ពីរមរមនមួយក្បាលដល់អ្នកគ្រូកូន » ។

គាត់បានញញឹម ហើយតបថា « ប្រពៃខ្លាំងណាស់ ! សូហ្វៀ កូនបានធ្វើគំរូមួយដ៏ល្អសម្រាប់ម៉ាក់ » ។

យើងបានសម្រេចចិត្តអធិស្ឋានដើម្បីថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌ចំពោះការផ្ដល់ភាពក្លាហានដល់ខ្ញុំ ក្នុងការឲ្យព្រះគម្ពីរមរមនដល់អ្នកគ្រូខ្ញុំ ។ ■

គំនូរគូរដោយ ម៉ាក់ ប្រ៊ីនសុន

# ដាវីឌ និង កូលីយ៉ាត

សាំយ៉ូអែលទី 1 17

សូមបិទទំព័រនេះនឹងក្រដាសរឹង ឬក្រដាសការតុង រួចកាត់រូបនោះចេញ ហើយបិទវាទៅនឹងឈើ ឬថង់ក្រដាស ។ អ្នកអាចប្រើវា ដើម្បីជួយសម្ដែងដំណើររឿងដែលអ្នកចូលចិត្តក្នុងព្រះគម្ពីរសញ្ញាចាស់ ។ ■



កូលីយ៉ាត





ដាវីឌ



ដាវីឌ

រចនារូបភាពដោយ ប៊េថ វីតធើរ

សម្រាប់កុមារតូចៗ

# បុណ្យគ្រីស្ទម៉ាស់បន្តិចម្ដងៗ

**ដោយ ខេត ស្រួងអ៊ីន**

ផ្អែកទៅលើដំណើររឿងពិតមួយ

« *Have a very merry Christmas! Scatter gladness ev'rywhere!* » (Children's Songbook, *ទំព័រ 51*) ។

បុណ្យគ្រីស្ទម៉ាស់ជិតមកដល់ហើយ ។ អាម៉ាលី មានចិត្តរីករាយជាខ្លាំង ។ មិនយូរប៉ុន្មាន នាងអាចបើកអំណោយនៅក្រោមដើមគ្រីស្ទម៉ាសនោះ !

នៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ត្រូវដល់វេណរបស់ម៉ាក់ជាអ្នកបង្រៀនមេរៀន ។

« ហេតុអ្វីយើងផ្ដល់អំណោយក្នុងពេលបុណ្យគ្រីស្ទម៉ាស់ ? » ម្ដាយបានសួរ ។

« ដោយសារវាជាថ្ងៃប្រសូតរបស់ព្រះយេស៊ូវ ! » អាម៉ាលី បានឆ្លើយ ។

« អញ្ចឹងតើយើងគួរថ្វាយអំណោយដល់ទ្រង់ដែរឬទេ ? » ម្ដាយបានសួរ។

ឪពុកបានជួយប្អូនប្រុស អាម៉ាលី ឈ្មោះ ណូអេ ឲ្យអានខគម្ពីរមួយ ។ ខគម្ពីរនោះចែងថា កាលណាយើងបម្រើដល់អ្នកដទៃ នោះយើងកំពុងបម្រើដល់ព្រះ (សូមមើល ម៉ូសាយ 2:17) ។

« តើការបម្រើដល់អ្នកដទៃជាការថ្វាយអំណោយមួយដល់ព្រះយេស៊ូវមែនទេ ? » ម្ដាយបានសួរ ។

ណូអេ បានងក់ក្បាល ។

« មានអ្វីទៀតទេ ? »

« ការគោរពព្រះបញ្ញត្តិ » អាម៉ាលី បានតប ។

« ការធ្វើល្អដល់គេ » ណូអេ បានឆ្លើយ ។

« គំនិតល្អណាស់ ! » ម្ដាយបានតប ។ « ឥឡូវនេះ យើងនឹងលេងល្បែងមួយ ។ ម៉ាក់នឹងនិយាយពីអំណោយមួយដែលមនុស្សម្នាក់បានថ្វាយដល់ព្រះយេស៊ូវ ។ សូមប្រាប់ម៉ាក់ បើកូនដឹងថាមនុស្សម្នាក់នោះជានរណា ។ សូមត្រងត្រាប់ស្ដាប់ ។ មនុស្សម្នាក់នេះចែកប័ណ្ណបុណ្យគ្រីស្ទម៉ាស់នៅមជ្ឈមណ្ឌលថែទាំជំងឺ » ។

ណូអេ បានលើកដៃឡើង ។ « អាម៉ាលី បានធ្វើវា ! »

« មនុស្សម្នាក់នេះបានទៅធ្វើការបង្រៀនតាមផ្ទះ » ។




រូបគំនូរដោយ ឌីលីន ម៉ាស

# ជារៀងរាល់ថ្ងៃ

*រាល់អំណោយទាំងអស់ត្រូវបានរុំ ហើយ ដាក់នៅក្រោមដើមគ្រីស្ទម៉ាស់ ។ តើមែនទេ ?*

អាម៉ាលី បានឆ្លើយថា « គឺលោកប៉ា » ។

មិនយូរប៉ុន្មាន ពួកគេបានឲ្យឈ្មោះអំណោយជាច្រើនដែលពួកគេបានថ្វាយដល់ព្រះអង្គសង្គ្រោះ ។

ម្ដាយបានពោលថា « យើងអាចឲ្យអំណោយនេះជារៀងរាល់ថ្ងៃ » ។

ព្រឹកស្អែកគឺជាពេលបោសសម្អាតផ្ទះ ។ អាម៉ាលី បានត្អូញត្អែរថា « ទៀតហើយ » ។ ប៉ុន្តែក្រោយមកនាងបាននឹកឃើញ ។ ការបម្រើដល់អ្នកដទៃគឺជាអំណោយមួយ ! ប្រសិនបើនាងជួយម្ដាយនាង គឺវាដូចគ្នានឹងការជួយដល់ព្រះយេស៊ូវដែរ ។ នាងបានរកឃើញក្រណាត់មួយ ហើយបានជូតតុរហូតដល់វាបានរលោងស្អាត ។

លុះស្អែកឡើង អាម៉ាលី បានទទួលប្រាក់មួយចំនួន ។

ម្ដាយបានពោលថា « ដង្វាយមួយភាគក្នុងដប់កូនគឺប្រាំបីសេន » ។

អាម៉ាលី បាននឹកឃើញម្ដងទៀត ។ ដង្វាយមួយភាគក្នុងដប់គឺជាបទបញ្ញត្តិមួយ ដូច្នេះការបង់វាគឺជាអំណោយមួយ ។ នាងបានដាក់ប្រាក់ប្រាំបីសេនក្នុងក្រឡដង្វាយមួយភាគក្នុងដប់របស់នាង ។

ក្រោយមកទៀតនៅសប្ដាហ៍ដដែលនោះ អាម៉ាលី បានជួយរៀបចំខ្នើយ ។ ប្អូនប្រុសតូចនាងបានបោះខ្នើយចេញពីសាឡុង ។ នាងបានពោលថា « អំណោយមួយទៀតសម្រាប់ព្រះយេស៊ូវ » ។

នៅល្ងាចមុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ ឪពុក និង ម្ដាយ បានប្រាប់ អាម៉ាលី ថាពួកគាត់កោតសរសើរដល់នាងខ្លាំងណាស់ ។ ឪពុកបានពោលថា « ពេញមួយសប្ដាហ៍នេះ កូនបានថ្វាយអំណោយជាច្រើនដល់ព្រះយេស៊ូវ » ។ « ការណ៍នោះប្រៀបដូចជាការមានបុណ្យគ្រីស្ទម៉ាស់បន្តិចម្ដងៗជារៀងរាល់ថ្ងៃដែរ » ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*





ដោយអែលឌើរ មេលវិន ជេ បាឡឺដ
(1873–1939)
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# ខ្ញុំដឹងថា ទ្រង់មានព្រះជន្មរស់

*ខ្ញុំនឹងឲ្យអ្វីៗទាំងអស់ដែលខ្ញុំមាន អ្វីទាំងអស់ដែលខ្ញុំសង្ឃឹមថានឹងមាន ដើម្បីមានអារម្មណ៍ដែលខ្ញុំធ្លាប់មាននៅពេលនោះ !*

ខ្ញុំចូលចិត្តគិតថាតើព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌បានចំណាយអ្វីខ្លះ ដើម្បីប្រទានអំណោយនៃបុត្រាដ៏ជាទីស្រលាញ់របស់ទ្រង់ដល់យើង ដែលជាបុត្រាដ៏បរិសុទ្ធនៃព្រះវរបិតាយើងជាអង្គដែលស្រឡាញ់ពិភពលោកនេះជាខ្លាំងរហូតទ្រង់បានលះបង់ព្រះជន្មទ្រង់ដើម្បីប្រោសលោះដល់ពិភពលោកនេះ ដើម្បីសង្គ្រោះយើង ហើយចិញ្ចឹមបីបាច់យើងខាងវិញ្ញាណកាលយើងដើរនៅក្នុងជីវិតនេះ ហើយរៀបចំយើងទៅរស់នៅជាមួយនឹងទ្រង់ក្នុងពិភពអស់កល្បជានិច្ច ។ . . .

ខ្ញុំនឹកចាំពីបទពិសោធន៍មួយដែលខ្ញុំធ្លាប់មាន . . . ដោយថ្លែងជាសាក្សីដល់ព្រលឹងខ្ញុំពីធាតុពិតនៃការសុគត [របស់ព្រះអង្គសង្គ្រោះ] ពីការឆ្កាងរបស់ទ្រង់ និង ការរស់ឡើងវិញរបស់ទ្រង់ដែលខ្ញុំមិនអាចបំភ្លេចបានឡើយ ។ . . .

. . . នៅល្ងាចមួយខ្ញុំបានសុបិនឃើញថាខ្លួនឯងស្ថិតនៅក្នុងអគារដ៏ពិសិដ្ឋនោះ ជាព្រះវិហារបរិសុទ្ធ នៅពេលយប់ ។ បន្ទាប់ពីការអធិស្ឋាន និង ភាពរីករាយ ខ្ញុំត្រូវបានគេប្រាប់ថា ខ្ញុំគួរមានអភ័យឯកសិទ្ធិដើម្បីចូលទៅក្នុងបន្ទប់មួយដើម្បីជួបនឹងតួអង្គមួយអង្គដ៏រុងរឿង ហើយកាលខ្ញុំចូលតាមទ្វារនោះ ខ្ញុំបានឃើញតួអង្គមួយដ៏រុងរឿងបំផុតដែលខ្ញុំពុំធ្លាប់ឃើញពីមុនមក ឬ ដែលខ្ញុំពុំដែលគិតថាមាននៅក្នុងពិភពអស់កល្បជានិច្ច កំពុងគង់នៅលើបល្ល័ង្ក



កាលខ្ញុំដើរទៅណែនាំខ្លួន ទ្រង់បានក្រោក ហើយយាងមករកខ្ញុំដោយព្រះហស្តលាតសន្ធឹង ហើយទ្រង់បានញញឹម កាលទ្រង់ហៅឈ្មោះខ្ញុំដោយស្រទន់ ។ ប្រសិនបើខ្ញុំអាចរស់នៅបានអាយុមួយលានឆ្នាំ ខ្ញុំនឹងមិនអាចបំភ្លេចពីស្នាមញញឹមនោះបានឡើយ ។ ទ្រង់បានឱបខ្ញុំ យ៉ាងណែនហើយថើបខ្ញុំ ហើយបានប្រទានពរខ្ញុំរហូតដល់ខួរឆ្អឹងរបស់ខ្ញុំស្ទើរតែទន់អស់ ! កាលទ្រង់បានបញ្ចប់ ខ្ញុំបានលុតជង្គង់ចុះនៅឯព្រះបាទទ្រង់ ហើយកាលខ្ញុំបានលាងព្រះបាទទ្រង់ទាំងពីរដោយទឹកភ្នែក និង ការថើបរបស់ខ្ញុំ ខ្ញុំបានឃើញស្នាមដែកគោលនៅត្រង់ព្រះបាទានៃព្រះដ៏ប្រោសលោះនៃពិភពលោកនេះ ។ អារម្មណ៍ដែលខ្ញុំមាននៅក្នុងវត្តមានរបស់ទ្រង់ ដែលជាអង្គមាននូវអ្វីៗទាំងអស់នៅក្នុងព្រះហស្តទ្រង់ ដើម្បីទទួលបានសេចក្តីស្រឡាញ់របស់ទ្រង់ ការយកព្រះទ័យទុកដាក់ពីទ្រង់ និង ការប្រសិទ្ធពររបស់ទ្រង់ដូចដែលខ្ញុំធ្លាប់មានពីមុនបែបនេះ ខ្ញុំនឹងថ្វាយអ្វីៗទាំងអស់ដែលខ្ញុំមាន អ្វីទាំងអស់ដែលខ្ញុំសង្ឃឹមថាមាន ដើម្បីមានអារម្មណ៍ដែលខ្ញុំធ្លាប់មាន !

. . . ឥឡូវនេះខ្ញុំឃើញព្រះយេស៊ូវមិនបាននៅលើឈើឆ្កាង ។ ខ្ញុំមិនបានឃើញព្រះកេសទ្រង់បានមុតនឹងបន្លា ឬព្រះហស្តទ្រង់បានជាប់នឹងដែកគោលនោះទេ ប៉ុន្តែខ្ញុំបានឃើញទ្រង់ញញឹម ដោយលាតសន្ធឹងព្រះហស្តទ្រង់ ហើយមានបន្ទូលមកកាន់យើងទាំងអស់គ្នាថា ៖ « ចូរមកតាមខ្ញុំ ! » ■

*ការរៀបចំជាអក្សរធំត្រូវបានធ្វើតាមបទដ្ឋាន ។*

*ដកស្រង់ពី ប្រាយអិន អេស ហ៊ិងគ្លី* Sermons and Missionary Services of Melvin Joseph Ballard *(ឆ្នាំ 1949) ទំព័រ 147–57 បានបោះពុម្ពឡើងវិញក្នុង « Classic Discourses from the General Authorities: The Sacramental Covenant, »* New Era, *ខែ មករា ឆ្នាំ 1976 ទំព័រ 7–11 ។*

រូបភាពរបស់ព្រះគ្រីស្ទដោយ ហែនរិច ហូហ្វមែន ទទួលបានសិទ្ធិអនុញ្ញាតពីក្រុមហ៊ុន C. HARRISON CONROY CO.

# ការយល់ដឹង



**តើព្រះយេស៊ូវគ្រីស្ទគឺជាពន្លឺនៃលោកិយតាមរបៀបណាខ្លះ ?**

« [ព្រះយេស៊ូវគ្រីស្ទ]គឺជាពន្លឺនៃភូមិបេថ្លេហិម ជាអង្គដែលបានប្រសូតមកពីម៉ារា ជាមាតាទ្រង់ក្នុងជីវិតរមែងស្លាប់ និងព្រះវរបិតាទ្រង់ ដែលជាព្រះដ៏មានមហិទ្ធិឫទ្ធិ ។ … ទ្រង់គឺជាពន្លឺនៃដង្វាយធួនដែលបានបំពេញនៅក្នុងសួនច្បារគេតសាម៉ានី និង គាល់កូថា ជាអង្គដែលលើកដាក់មកលើអង្គទ្រង់នូវអំពើបាបនៃលោកិយ ដើម្បីឲ្យមនុស្សលោកទាំងអស់អាចទទួលបានសេចក្តីសង្គ្រោះនៅអស់កល្បជានិច្ច ។ ទ្រង់គឺជាពន្លឺនៃផ្នូរទទេរ ជាព្រះអម្ចាស់ដែលបានរស់ឡើងវិញដោយមានរូបកាយជាសាច់ និង ឆ្អឹងដ៏រុងរឿង ជាអង្គដែលបានផ្តាច់ចំណងនៃសេចក្តីស្លាប់ ហើយទទួលបានជោគជ័យដ៏អស់កល្បលើផ្នូរ ។ … ទ្រង់គឺជាពន្លឺខ្ញុំ ជាព្រះប្រោសលោះខ្ញុំ ជាព្រះអង្គសង្គ្រោះខ្ញុំ—និងជារបស់អ្នកផងដែរ » ។

**អែលឌើរ រ៉ូបឺត ឌី ហែល** ក្នុងក្បួនខ្សែពួកសាវកដប់ពីរនាក់ « Out of Darkness into His Marvelous Light » *Liahona* ខែ កក្កដា ឆ្នាំ 2002 ទំព័រ 79, 80 ។

# កំមាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់មជ្ឈិមវ័យវ័យក្មេង

# ចម្លើយ
## ចំពោះសំណួរពិបាកៗ

ប្រធាន អុជដូហ្វ បានប្រឹក្សាយើងឲ្យសង្ស័យពីការសង្ស័យរបស់យើងពីមុនសង្ស័យទៅលើសេចក្ដីជំនឿរបស់យើង ។ ដូច្នេះតើអ្នកអាចសួរពីភាពសង្ស័យរបស់អ្នក ហើយឆ្ពោះទៅមុខដោយសេចក្ដីជំនឿបានដោយរបៀបណា ?



ទំព័រ 44

## សម្រាប់យុវវ័យ



ទំព័រ 48

# ព្រះអង្គសង្គ្រោះ និង ពិធីសាក្រាម៉ង់

តើអ្នកកំពុងគិតអ្វី កាលកំពុងរៀបចំខ្លួន ធ្វើការប្រសិទ្ធិពរ ចែក ឬទទួលទានសាក្រាម៉ង់នោះ ?

## សម្រាប់កុមារ

# បុណ្យគ្រីស្ទម៉ាស់ដំបូង

សូមធ្វើឲ្យដំណើររឿងបុណ្យគ្រីស្ទម៉ាស់មានជីវិតរស់រវើកដោយធ្វើការសម្ដែងពីព្រះប្រសូតិកម្មនេះ !



ទំព័រ 74

CAMBODIAN

4 02109 92258 8

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ